
ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
ស្វែងរកការពិត
នៅពេលដែលសង្គ្រាម
When the War Was Over
រលត់ទៅ
លេខ ៨៤ ខែធ្នូ ឆ្នាំ២០០៦

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ៧២ ខែធ្នូ ឆ្នាំ២០០៥

## មាតិកា


◆ សំបុត្រ ៈ កន្ទុះខាតថវិកាមិនត្រូវក្លាយជាឧបសគ្គ..........................១

**ផ្នែកឯកសារ**

◆ ជា ប៉ុនចេង យុវជនមន្ទីរក-១៥ ......................................៤

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ............៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ.........................................១០

◆ នៅពេលដែលសង្គ្រាមរលត់ទៅ.........................................២១

**ផ្នែកច្បាប់**

◆ ដីកាចាប់ខ្លួនដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ..................៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ភាសាខ្មែរក្រហមនិងការលំបាករបស់អ្នកបកប្រែ....................៤៩

◆ សមាជិកាសភាអាមេរិករំឭកដល់ជនរងគ្រោះ........................៥១

◆ ស្ពានឆ្ពោះទៅរកយុត្តិធម៌...................................................៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ គ្មានថ្ងៃបំភ្លេច..............................................................៥៧




ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិបាន សម្រេចយកបញ្ជាការដ្ឋានកងទ័ពជើងគោកដែលទើបនឹងសាងសង់ថ្មីនៅ ឯជាយក្រុងភ្នំពេញធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** យិន នាន, ប៉ាង ពីវ៉ន, ស៊ុំ សាវីណា, សួ ប៊ុនស៊ូ, ឈុន ឡៃហេង, អេលីហ្សាប៊ែត ប៊េកខ័រ, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា, **អ្នកបកប្រែៈ** ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ីម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** រ័ត្ន តារាពិដោរ

*សំបុត្រៈ*

# កង្វះខាតថវិកាមិនត្រូវក្លាយជាឧបសគ្គក្នុងការស្វែងរកយុត្តិធម៌ទេ

## តើរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិអាចជួយដោះស្រាយឧបសគ្គ របស់អង្គជំនុំជម្រះវិសាមញ្ញតាមរបៀបណា?

អង្គការសហប្រជាជាតិនឹងចាប់ផ្តើមបើកការិយាល័យរបស់ខ្លួននៅទីក្រុងភ្នំពេញនៅខែកុម្ភៈ ឆ្នាំ២០០៦ ខាងមុខនេះ ដើម្បីរៀបចំបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលមានរយៈពេលបីឆ្នាំ សម្រាប់ជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ។ ស្ថាប័នតុលាការពិសេសមួយ (អង្គជំនុំជម្រះវិសាមញ្ញ) នឹងលេចរូបរាងឡើងយ៉ាងពិតប្រាកដក្នុងពេលឆាប់ៗខាងមុខនេះដើម្បីចាប់ផ្តើមដំណើរការស៊ើបអង្កេតនិងជំនុំជម្រះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយអតីតសមាជិកនៃរបបនេះ ។

ប្រជាជនកម្ពុជាបានទន្ទឹងរង់ចាំមើលការស្វែងរកយុត្តិធម៌សម្រាប់ខ្លួនអស់រយៈកាលជាង២៥ឆ្នាំមកហើយ ។ នៅក្រោមការគ្រប់គ្រងអំណាចរបស់របបខ្មែរក្រហម ប្រទេសកម្ពុជាបានបាត់បង់ប្រជាជនមិនតិចជាង២៥ភាគរយនៃចំនួនប្រជាជនសរុបឡើយ ។ បើគិតជាភាគរយ វាគឺជាអត្រាមរណៈខ្ពស់បំផុតបើធៀបទៅនឹងការប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រទំនើបនេះ ។ ចាប់ពីឆ្នាំ១៩៧៩មក មិនទាន់មានសវនាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមណាមួយដែលអាចជឿទុកចិត្តបាននៅឡើយទេ ។

មេដឹកនាំខ្មែរក្រហមមួយចំនួនបានស្លាប់ទៅហើយ ។ ប៉ុល ពត បានបាត់បង់ជីវិតនៅក្នុងព្រៃនៅឆ្នាំ១៩៩៨ ។ សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស កែ ពក ក៏បានស្លាប់នៅក្នុងដំណេកកាលពីឆ្នាំ២០០២ ។ មានតែអតីតកម្មាភិបាលពីរនាក់ប៉ុណ្ណោះដែលកំពុងជាប់នៅក្នុងមន្ទីរឃុំឃាំង ។ ម្នាក់ក្នុងចំណោមនេះគឺ ឌុច (អាយុ៥៩ឆ្នាំ) អតីតប្រធានមន្ទីរទួលស្លែង(ស-២១) ដែលបានធ្វើឲ្យបាត់បង់ជីវិតមនុស្សប្រមាណ១ម៉ឺន៤ពាន់នាក់ ដែលរបបនេះចាត់ទុកថាជាសត្រូវ ។ មានអ្នកទោសប្រហែលជា១២នាក់ប៉ុណ្ណោះដែលបានរួចជីវិតពីមន្ទីរឃុំឃាំងនេះ ។ អតីតកម្មាភិបាលមួយរូបទៀតគឺ តាម៉ុក (អាយុ៧៨ឆ្នាំ) អតីតមេបញ្ជាការភូមិភាគនិរតីនិងសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ដែលត្រូវចាប់ខ្លួនកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលគាត់បដិសេធមិនព្រមចុះចូលជាមួយរាជរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ជនទាំងពីររូបនេះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មេដឹកនាំដទៃទៀតមានជីវិតរស់នៅងាយស្រួលជាងអ្នកដែលជាប់ឃុំឃាំងខាងលើ ប៉ុន្តែមេដឹកនាំទាំងនោះមានអាយុកាន់តែច្រើនណាស់ទៅហើយ ។

មានចម្ងល់ជាច្រើនទាក់ទងនឹងរឿងថាតើប្រជាជនកម្ពុជាត្រូវតែបន្តរង់ចាំមើលដំណើរស្វែងរកយុត្តិធម៌នេះតទៅទៀត ដោយសារតែរាជរដ្ឋាភិបាលកម្ពុជាមិនអាចឬនឹងនៅតែមិនអាចស្វែងរកថវិកាបំពេញចំណែកដែលខ្លួនខ្វះខាតសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ប្រសិនបើរាជរដ្ឋាភិបាលនៅតែមិនអាចបំពេញចំណែកនេះបាន តើអង្គការសហប្រជាជាតិត្រូវព្យាយាមដើម្បីបំពេញចំណែកថវិកាដែលខ្វះខាត ឬក៏ត្រូវដកខ្លួនចេញពីដំណើរការនេះឬយ៉ាងណា? វាហាក់បីដូចជាឆាប់រហ័សពេកក្នុងការទទួលបានចម្លើយនេះ ប៉ុន្តែមុនពេលប្រកាសថារាជរដ្ឋាភិបាលមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបំពេញចំណែកដែលខ្លួនខ្វះខាត យើងអាចរកបាននូវដំណោះស្រាយមួយចំនួន ។

នៅក្នុងឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានព្រមព្រៀងបែងចែកការទទួលខុសត្រូវខាងផ្នែកច្បាប់និងហិរញ្ញវត្ថុសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ សហគមន៍អន្តរជាតិប្រមូលបានថវិកាគ្រប់គ្រាន់សម្រាប់បំពេញចំណែកទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ ដែលយ៉ាងហោច

ណាស់ទឹកប្រាក់នេះគ្រប់គ្រាន់សម្រាប់ដំណើរការឆ្នាំទីមួយរបស់អង្គជំនុំជម្រះ ។ ប្រទេសដែលបានចូលរួមវិភាគទានថវិកានៅក្នុងដំណើរការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មាន ប្រទេសអូស្ត្រាលី អូទ្រីស បែលហ្សិក កាណាដា ដាណឺម៉ាក សហគមន៍អឺរ៉ុប បារាំង អាល្លឺម៉ង់ ឥណ្ឌា ជប៉ុន លុចហ្សំបួរ ហូល្លង់ ន័រវេ សាធារណរដ្ឋកូរ៉េ ស៊ុយអែដ និងចក្រភពអង់គ្លេស ។ រាជរដ្ឋាភិបាលកម្ពុជាយល់ព្រមផ្តល់ថវិកាចំនួន១៣លានដុល្លារសហរដ្ឋអាមេរិកនិងសេវាកម្មផ្សេងៗទៀតសម្រាប់ជួយសម្រួលដល់ដំណើរការអង្គជំនុំជម្រះនេះ ។

រាជរដ្ឋាភិបាលកម្ពុជាមិនធ្លាប់បង្ហាញថា បញ្ហាថវិកាជាបញ្ហាចោទនោះឡើយ ទើបតែកាលពីរដូវក្តៅឆ្នាំកន្លងទៅនេះ អ្នកតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជាបានចេញមុខមកនិយាយថា រាជរដ្ឋាភិបាលមានលទ្ធភាពបរិច្ចាគត្រឹមតែ១,៥លានដុល្លារប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលបានបន្ថែមទៀតថា ខ្លួននឹងខំស្វែងរកវិភាគទានពីប្រទេសម្ចាស់ជំនួយ ដើម្បីបំពេញ ចំណែកថវិកាដែលខ្លួនបានសន្យា ។ ការឆ្លើយតបរបស់សហគមន៍អន្តរជាតិគឺមិនគួរឲ្យសប្បាយចិត្តទាល់តែសោះ ដោយសារកន្លងមកមានតែប្រទេសឥណ្ឌាមួយគត់ ដែលបានជួយវិភាគទានថវិកាចំនួន១លានដុល្លារមកឲ្យរាជរដ្ឋាភិបាលកាលពីខែតុលាឆ្នាំ២០០៥ ។



ឯកឧត្តម ស៊ាន វិសុទ្ធ
ប្រធានការិយាល័យរដ្ឋបាល
នៃអង្គជំនុំជម្រះវិសាមញ្ញ

កាលថ្ងៃទី៩ ខែធ្នូ ថ្មីៗនេះ អង្គការសហប្រជាជាតិបានអំពាវនាវឲ្យប្រទេសម្ចាស់ជំនួយ នៅជុំវិញពិភពលោកនិងជាពិសេសប្រទេសជប៉ុន ជួយបំពេញចំណែកថវិកាដែលខ្វះខាតរបស់រដ្ឋាភិបាលកម្ពុជា ។ រដ្ឋាភិបាលកម្ពុជាក៏បានបញ្ជាក់ដែរថា ខ្លួននឹងទទួលយកវិភាគទានថវិកាពីបុគ្គលដែលមានទ្រព្យសម្បត្តិនិងពីវិស័យឯកជន មិនថានៅក្នុងស្រុកឬក្រៅស្រុកឡើយ ។ សេចក្តីថ្លែងការណ៍ទាំងនេះបានបង្កើតជាសំណួរច្រើនជាងការផ្តល់ចម្លើយ ។ តើការប្រមូលថវិកានឹងត្រូវធ្វើឡើងតាមរបៀបណា? តើដំណើរការប្រមូលថវិកានេះមានតម្លាភាពដែរឬទេ? តើរាជរដ្ឋាភិបាលខ្លួនឯងគួរតែចំណាយថវិកាឲ្យច្រើនជាង១,៥លានដុល្លារនេះឬទេ? តើរាជរដ្ឋាភិបាលកម្ពុជាគួរតែងាកទៅស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុជាផ្លូវការពីប្រទេសជិតខាងនៅក្នុងសមាគមអាស៊ានដែរឬទេ?

**រាជរដ្ឋាភិបាលកម្ពុជាអាចចាត់វិធានការដូចខាងក្រោមនេះ÷**

រហូតមកដល់សព្វថ្ងៃនេះ រាជរដ្ឋាភិបាលបានបដិសេធសំណើរបស់ប្រទេសជប៉ុនក្នុងការជួយបំពេញចំណែកថវិកាដែលខ្វះខាតនេះ ។ បើទោះបីជាមិនមានហេតុផលផ្លូវការណាមួយបញ្ជាក់ពីជំហរបដិសេធនេះក៏ដោយរាជរដ្ឋាភិបាលកម្ពុជាប្រហែលជាបារម្ភថាប្រទេសជប៉ុននឹងព្យាយាមប្រើឥទ្ធិពលរបស់ខ្លួនជ្រុលហួសហេតុ ឬក៏អាចនឹងផ្តាច់មុខលើដំណើរការតុលាការនេះតែម្នាក់ឯង ។ ការណ៍នេះគឺជាការលំបាកនិងអាចកើតឡើងព្រោះសហគមន៍អន្តរជាតិ ដែលតំណាងដោយអង្គការសហប្រជាជាតិនេះអាចមើលរំលងបញ្ហានេះ ។ ប្រទេសជប៉ុនមានឆន្ទៈចង់ជួយបំពេញកង្វះខាតនេះ ដូច្នេះរដ្ឋាភិបាលគួរតែទទួលយកជំនួយនេះដើម្បីឲ្យកម្ពុជាអាចបន្តដំណើរទៅមុខបាននិងដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមធ្វើកិច្ចការរបស់ខ្លួន ។



លោកស្រី មីសែល លី
ប្រធានការិយាល័យរដ្ឋបាល
នៃអង្គជំនុំជម្រះវិសាមញ្ញ

ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាពិតជាចង់ឲ្យប្រជាពលរដ្ឋខ្លួនចូលរួមវិភាគទានមែននោះ ការអំពាវនាវដែលធ្វើឡើងត្រឹមតែតាមរយៈសារព័ត៌មានគឺមិនគ្រប់គ្រាន់ទេ ។ រាជរដ្ឋាភិបាលគួរតែធ្វើសំណូមពរជាផ្លូវការនិងដោយស្មោះត្រង់ ហើយផ្សព្វផ្សាយឲ្យបានទូលំទូលាយទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស ។ ប្រជាជនក្រីក្រដែលជាជនរងគ្រោះនៃរបបខ្មែរក្រហមចង់ធ្វើការបរិច្ចាគវិភាគទានបន្តិចបន្តួចរបស់ខ្លួន ប៉ុន្តែនៅក្នុងចំណោមប្រជាជនទាំង

នេះ មានតិចតួចណាស់ដែលមានលទ្ធភាពអានឬអាចទទួលបានសារព័ត៌មាននិងមិនដឹងថាតើត្រូវផ្តល់វិភាគទានតាមរបៀបណា ។ ការអនុញ្ញាតឲ្យប្រជាពលរដ្ឋបានជួយទ្រទ្រង់អង្គជំនុំជម្រះវិសាមញ្ញនេះ ទោះតិចក្តីឬច្រើនក្តីក៏ដូចជាអនុញ្ញាតឲ្យអ្នកទាំងនោះបានជួយជ្រោមជ្រែងប្រព័ន្ធតុលាការរបស់ខ្លួនដែរ ។

នៅក្នុងការទទួលយកវិភាគទាននេះ រាជរដ្ឋាភិបាលក៏ត្រូវមានកាតព្វកិច្ចដើម្បីធានាឲ្យបាននូវតម្លាភាព ។ ប្រជាពលរដ្ឋចាំបាច់ត្រូវតែដឹងថា តើថវិការបស់ខ្លួនធ្លាក់ទៅកន្លែងណា? ហើយតើថវិកានេះប្រើសម្រាប់ធ្វើអ្វី? រាជរដ្ឋាភិបាលគួរតែរៀបចំឲ្យមានការធ្វើសវនកម្ម ឬផ្ទៀងផ្ទាត់បញ្ជីចំណាយ ហើយត្រូវចេញផ្សាយរបាយការណ៍សវនកម្មនេះ ។ ការធ្វើរបៀបនេះក៏អាចជួយដល់រាជរដ្ឋាភិបាលដែរ ព្រោះថា ប្រសិនបើប្រជាជនមានឱកាសបំពេញចេតនាល្អរបស់ខ្លួន ប្រជាពលរដ្ឋក៏នឹងមានទំនុកចិត្តលើមន្ត្រីរាជការដែលខ្លួនបានបោះឆ្នោតជ្រើសរើសដែរ ។

រាជរដ្ឋាភិបាលគួរតែខំប្រឹងបង្កើតចេតនាស្មោះត្រង់មួយទៀត ដើម្បីបែងចែកថវិកាពីប្រភពថវិការបស់ខ្លួនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ បើយោងតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចចំណាយថវិកាដែលជាចំណែកទទួលខុសត្រូវរបស់ខ្លួនសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ បើធ្វើមិនបានដូច្នោះទេ រាជរដ្ឋាភិបាលនឹងបំពានលើកិច្ចព្រមព្រៀងរបស់ខ្លួនជាមួយអង្គការសហប្រជាជាតិ ។ នៅក្នុងករណីនេះអង្គការសហប្រជាជាតិមានសិទ្ធិបញ្ឈប់ការផ្តល់ជំនួយបន្តទៀត ។

បន្ទាប់ពីការចរចាអស់រយៈពេលជិត១០ឆ្នាំ រាជរដ្ឋាភិបាលកម្ពុជាមិនអាចអះអាងថាខ្លួនមិនបានដឹងអំពីចំណែកទទួលខុសត្រូវរបស់ខ្លួនជាអ្វីនោះទេ ។ ថវិកាចំនួន១៣លានដុល្លារអាមេរិកគឺមិនមែនជាចំនួនតិចតួចទេសម្រាប់ប្រទេសក្រីក្រដូចកម្ពុជា ប៉ុន្តែវាក៏មិនមែនជាបញ្ហាធំដុំពេកនោះដែរ បើពិនិត្យមើលទៅលើគម្រោងថវិកាចំណាយប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលនិងផលចំណូលវិជ្ជមានពីការបង្កើតតុលាការនេះ ។

អ្នកស្រី មីសែល លី ដែលជាអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិនិងជាអនុប្រធានការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មាននៅទីក្រុងភ្នំពេញកាលពីថ្ងៃទី១៣ ខែធ្នូ កន្លងមកនេះថា អង្គការសហប្រជាជាតិកំពុងតែពិនិត្យមើលថាតើថវិកាប្រមាណ៦,៩លានដុល្លារដែលនៅសល់ក្នុងមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់ចំណាយលើការបោះឆ្នោតកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០អាចយកមកប្រើប្រាស់បង្គ្រប់ចំណែកថវិកាដែលខ្វះខាតនេះបានដែរឬយ៉ាងណា ។ ប៉ុន្តែ អ្នកស្រី លី បានរំឭកថា បណ្តាប្រទេសដែលផ្តល់ថវិកានេះដូចជា ជប៉ុន ដាណឺម៉ាក និងអូស្ត្រាលី ត្រូវតែយល់ព្រមឲ្យប្រើប្រាស់ថវិកានេះ ទើបយើងអាចយកមកប្រើប្រាស់បាន ហើយគ្មានការធានាអះអាងណាមួយថាបណ្តាប្រទេសទាំងនេះនឹងយល់ព្រមឲ្យប្រើប្រាស់នៅឡើយទេ ។

ការប្រើប្រាស់ប្រភពថវិកាផ្ទាល់ខ្លួនកាន់តែច្រើន រាជរដ្ឋាភិបាលកម្ពុជាកាន់តែទទួលបានអត្ថប្រយោជន៍ច្រើន ។ ធ្វើដូច្នេះអាចជួយលុបបំបាត់នូវទស្សនៈដដែលៗ ដែលចោទប្រកាន់ថារាជរដ្ឋាភិបាលកម្ពុជាកំពុងតែព្យាយាមរារាំងដំណើរការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះ ហើយលើសពីនេះទៀត កម្ពុជាអាចបង្ហាញទៅកាន់មនុស្សនៅក្នុងពិភពលោកទាំងមូលថា អង្គជំនុំជម្រះវិសាមញ្ញនេះជារបស់កម្ពុជាយ៉ាងពិតប្រាកដ ។ ការបង្កើនចំណែកថវិកាឧបត្ថម្ភអង្គជំនុំជម្រះវិសាមញ្ញគឺជាការបង្ហាញពីការប្តេជ្ញាយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ហើយការធ្វើដូច្នេះអាចជាកត្តាជំរុញឲ្យបណ្តាប្រទេសដទៃទៀតផ្សេងៗមកជួយឧបត្ថម្ភកម្ពុជាកាន់តែច្រើនឡើង ។

ប្រទេសជាច្រើនបានសម្តែងនូវការព្រួយបារម្ភថា ថវិការបស់ខ្លួនអាចត្រូវចំណាយប្រើប្រាស់ដោយឥតប្រយោជន៍ ព្រោះប្រព័ន្ធតុលាការនៅកម្ពុជាមានភាពខ្សោយ ។ ដើម្បីកាត់បន្ថយការព្រួយបារម្ភបែបនេះ ម្ចាស់ជំនួយអាចពិចារណាជ្រើសរើសយកការផ្តល់វិភាគទានប្រចាំឆ្នាំវិញ ។ នេះមានន័យថា ម្ចាស់ជំនួយមិនចាំបាច់ផ្តល់ថវិកាទាំងស្រុងនៅមុនដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញទេ ហើយថាខ្លួននឹងផ្តល់ថវិកាសម្រាប់ឆ្នាំបន្ទាប់ៗទៀតតែក្នុងករណីដែលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញមានយុត្តិធម៌និងមានតម្លាភាព ។ **ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ជា ប៊ុនចេង: យុវជនមន្ទីរក-១៥

ជា ប៊ុនចេង មានស្រុកកំណើតនៅសង្កាត់លេខ៣ ទឹកល្អក់ ក្រុងភ្នំពេញ ជានិស្សិតម្នាក់ដែលបានទៅសិក្សាមុខវិជ្ជាជំនាញចែកចាយប្រេងនៅប្រទេសបារាំង ។ ប៊ុនចេង បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមការអំពាវនាវរបស់អង្គការបដិវត្តន៍ ។ ពេលមកដល់ប្រទេសកម្ពុជា ប៊ុនចេង ត្រូវអង្គការបញ្ជូនទៅលត់ដំនៅមន្ទីរក-១៥បឹងត្របែក បន្ទាប់មកក៏ត្រូវចាប់ខ្លួននិងសម្លាប់ចោល ។

## ការសិក្សានិងមូលហេតុនាំដល់ការចាប់ខ្លួន

កាលពីកុមារ ប៊ុនចេង រៀននៅសាលាបឋមសិក្សាភ្នំពេញ ។ ក្រោយមកបានផ្លាស់ទៅសិក្សានៅសាលាព្រះជ័យចេស្តានិងបានប្រឡងជាប់ប្រកាសនីយបត្របឋមភូមិឆ្នាំ១៩៥៧ ។

នៅឆ្នាំ១៩៥៨ ប៊ុនចេង បានសិក្សារយៈពេលបួនឆ្នាំនៅវិទ្យាល័យឯកជនមួយឈ្មោះរស្មីវិជ្ជា ហើយបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សានៅឆ្នាំ១៩៦៥ ។ ក្នុងអំឡុងពេលសិក្សា ប៊ុនចេង មានមិត្តភក្តិជិតស្និទ្ធពីរនាក់ឈ្មោះ សរ មាស និង សេក សាមុល ប៉ុន្តែក្រោយពេលប្រឡងចូលរៀននៅមហាវិទ្យាល័យពហុវិជ្ជាជាន់ខ្ពស់ផ្នែកគីមីអនុវត្ត ប៊ុនចេង មិនសូវមានទំនាក់ទំនងជាមួយអ្នកទាំងពីរទៀតទេ ។

ក្នុងឆ្នាំសិក្សា១៩៦៥-៦៦ ប៊ុនចេង បានឮដំណឹងថា អ៊ឹង ក្រពុំផ្កា (ក្រោយរដ្ឋប្រហារឈ្មោះនេះបានទៅធ្វើជាចាងហ្វាងអាកាសស៊ីវិល និងក្រោយមកត្រូវកងទ័ពរំដោះចាប់ខ្លួនក្នុងពេលគាត់រត់ទៅថៃ) ចាងហ្វាងសកលវិទ្យាល័យពហុបច្ចេកទេសមានគម្រោងបើករោងចក្រចម្រាញ់ប្រេងដូងនៅស្រុកទឹកសាប ដូច្នេះ ប៊ុនចេង ក៏បានទៅសុំការងារធ្វើពីគាត់ ក្រពុំផ្កាសន្យាថានឹងឲ្យការងារធ្វើក្រោយពេល ប៊ុនចេង បញ្ចប់ការសិក្សា ប៉ុន្តែគាត់បានសំណូមពរឲ្យ ប៊ុនចេង ខស្សាហ៍ទៅលេងគាត់ផងពេលទំនេរពីការសិក្សា ។ នៅពេលទៅលេងម្តងៗ ក្រពុំផ្កា តែងតែសួរនាំប្រវត្តិរបស់ប៊ុនចេង ហើយថែមទាំងបានលើកសរសើរអំពីរបៀបរបបរស់នៅ ការហូបចុកនិងការសប្បាយហ៊ឺហារបស់សង្គមជាតិនីមួយៗ ជាពិសេសលើកយកភាពរីកចម្រើនរបស់ប្រទេសមូលធនមកប្រៀបធៀបនឹងប្រទេសសង្គមនិយមមួយចំនួនដូចជាសូវៀតនិងចិនជាដើម ។ គ្រប់ពេលដែល ប៊ុនចេង ទៅជួបក្រពុំផ្កា ឬ កិក ប៊ុនប៉ុង (អតីតនិស្សិតគីមី) អ្នកទាំងពីរតែងតែឲ្យលុយចាយនិងនាំទៅហូបបាយនៅភោជនីយដ្ឋាន ។ ប៊ុនចេង ដឹងថាទង្វើល្អរបស់អ្នកទាំងពីរនេះគឺប្រាកដជាចង់បានអ្វីមួយពីគាត់មិនខាន ប៉ុន្តែគាត់គ្រាន់តែឆ្ងល់ថាអ្នកទាំងពីរអប់រំគាត់ដើម្បីអ្វីទៅ?

មានពេលមួយ ក្រពុំផ្កា បានបង្ហើបប្រាប់ ប៊ុនចេង ឲ្យដឹងថា «ប្រជាជនកម្ពុជាម្នាក់ៗរស់នៅសប្បាយរីករាយ មិនដែលនិយាយពីបញ្ហាអត់បាយនិងការលំបាកដូចនៅប្រទេសចិនទេ ហេតុដូចម្តេចបានជាពួកកុម្មុយនិស្តចង់យកស្រុកទេសទៅលក់ឲ្យប្រជាជនក្រធ្វើខ្ញុំគេ» ។ ក្រពុំផ្កា ថែមទាំងអប់រំណែនាំ ប៊ុនចេង ឲ្យប្រឆាំងដាច់ខាតកុំឲ្យរបបកុម្មុយនិស្តតាំងនៅកម្ពុជាយើងបាន ។ កិក ប៊ុនប៉ុង បានសុំឲ្យ ប៊ុនចេង សហការជាមួយខ្លួនចូលរួមកសាងកម្លាំងឲ្យបានទាន់ពេលវេលា ដើម្បីកម្ទេចរបបកុម្មុយនិស្តនៅកម្ពុជា ។

នៅខែកក្កដា ឆ្នាំ១៩៦៦ អ៊ឹង ក្រពុំផ្កា និង កិក ប៊ុនប៉ុង បានបញ្ចូល ប៊ុនចេង និងនិស្សិតពីរនាក់ឈ្មោះ ជ័យ រិត និង សំ ជាសមាជិកសេ.អ៊ី.អានៅក្នុងបន្ទប់ការិយាល័យមួយ ។ បន្ទាប់ពីអ្នកទាំងបីធ្វើសច្ចាប្រណិធានម្នាក់ម្តងៗរួច ក្រពុំផ្កា បានប្រាប់ពីការងារដែលត្រូវធ្វើ គឺកម្ទេចជនកុម្មុយនិស្តឲ្យអស់តាមគ្រប់វិធីទាំងនៅក្នុងនិងក្រៅប្រទេស ។ ប៊ុនប៉ុង បានចាប់ផ្តើមណែនាំ ប៊ុនចេង ឲ្យស្គាល់មនុស្សពីរនាក់ឈ្មោះ ថាច់ អ៊ុង និង ម៉ៃ សូភី ដើម្បីធ្វើការជាមួយគ្នា ។ នៅក្នុងរយៈពេលវិស្សមកាល ប៊ុនចេង អូសទាញបាននិស្សិតគីមីវិទ្យាម្នាក់ឈ្មោះ ជូ ស៊ីថន ។ ប៊ុនចេង, ថាច់ អ៊ុង និង កិក ប៊ុនប៉ុង បានដើរបំផុសសិស្សនិងនិស្សិតនៅតាមសាលាឲ្យធ្វើញត្តិប្រឆាំងនឹងការបិទសមាគមចម្រើន ញត្តិខ្លះ

ក៏ទាមទារឲ្យចាប់សមាជិកនៃសមាគមនេះដោយយកលេសថា ជាកន្លែងអប់រំបម្រើផលប្រយោជន៍ឲ្យចិននិងយួនកុម្មុយនិស្ត ។ នៅក្នុងសមាគមនេះមានការរៀបចំល្អ បម្រើផលប្រយោជន៍សិស្ស-និស្សិតមែន ប៉ុន្តែអប់រំតាមមនោគមវិជ្ជាចិនកុម្មុយនិស្ត ។ ក្រោយមក សមាគមនេះត្រូវបានបិទទ្វារដោយសារតែញត្តិគាំទ្ររបស់ជនមួយក្តាប់តូច ។

នៅពាក់កណ្តាលឆ្នាំសិក្សា ជូ ស៊ីថន បាននាំ ប៊ុនចេង ឲ្យស្គាល់មិត្តម្នាក់ឈ្មោះ ស៊ី កិក (និស្សិតអាកាសចរណ៍ភូមិន្ទស៊ីវិលនៅពោធិចិនតុង) ដើម្បីធ្វើការអប់រំ ។ តាមរយៈ ជូ ស៊ីថន, ប៊ុនចេង ក៏បានធ្វើការងារមួយរយៈជាមួយឈ្មោះ ប៉ែន ភី (និស្សិតសាលាពហុបច្ចេកទេសផ្នែកសំណង់) ដែលជាខ្សែតាមដាននិស្សិតនិងជាអ្នកកាន់តំណែងជំនួស អ៊ីង ក្រពុំផ្កា ។ សកម្មភាពការងាររបស់អ្នកទាំងពីរនៅពេលនោះគឺតាមដាននិស្សិតនៅសាលាពហុបច្ចេកទេសមិត្តភាពខ្មែរសូវៀត ។ ជាលទ្ធផល ប៊ុនចេង រកឃើញនិស្សិតខ្មែរក្រហមពីរនាក់ដែលកំពុងមានទំនាក់ទំនងជិតស្និទ្ធជាមួយសមាគមដែលត្រូវបិទទ្វារ ។ ក្រោយពីនោះ ប៊ុនចេង បានធ្វើសកម្មភាពមួយទៀត គឺញុះញង់ឲ្យមានការដកសាស្ត្រាចារ្យចម្រើនចេញពីសាលាគីមី ។

នៅឆ្នាំបញ្ចប់ការសិក្សា ប៊ុនចេង មិនបានធ្វើការនៅកន្លែងរបស់ អ៊ីង ក្រពុំផ្កា ទេ ព្រោះថារោងចក្រមិនទាន់បានសាងសង់ ។ ក៏ប៉ុន្តែ ក្រពុំផ្កា បានជួយ ប៊ុនចេង ឲ្យបន្តការសិក្សានៅមហាវិទ្យាល័យវិទ្យាសាស្ត្រនៅទីក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៦៨ ប៊ុនចេង បានអប់រំនិស្សិតពីរនាក់ឈ្មោះ ចាន់ មានថន និស្សិតផ្នែកគណិតវិទ្យាឲ្យចូលជាសមាជិកសេ.អ៊ី.អា នៅឆ្នាំ១៩៦៨ និងម្នាក់ទៀតឈ្មោះ ឡាំ ស៊ុនរី និស្សិតមហាវិទ្យាល័យវិទ្យា-សាស្ត្រអគ្គិសនីដែលត្រូវទៅបន្តការសិក្សានៅសហរដ្ឋអាមេរិក ។ ឈ្មោះដែលអប់រំបានទាំងប៉ុន្មាន ប៊ុនប៉ុង បានបញ្ចូលក្នុងខ្សែតែមួយដើម្បីធ្វើការជាមួយគ្នា ។ ប៊ុនចេង និង ចាន់ មានថន ជាអ្នកតាមដានគោលជំហររបស់សាស្ត្រាចារ្យទាំងពីរនាក់ដែលចូលចិត្តនិយាយអំពីគុណសម្បត្តិបដិវត្តន៍នៅក្នុងមហាវិទ្យាល័យ ។ ក្រោយមកក៏លែងឃើញសាស្ត្រាចារ្យទាំងពីរបង្រៀននៅក្នុងសាលានោះ ។

ឆ្នាំ១៩៦៩ ប៊ុនចេង បានមកធ្វើការនៅក្នុងរោងចក្រចម្រាញ់ប្រេងនៅគីឡូម៉ែត្រលេខ៦ភ្នំពេញ ។ មិនយូរប៉ុន្មាន ប៊ុនចេង ត្រូវបានបញ្ជូនឲ្យទៅបំពេញវិជ្ជាឯកទេសខាងបែងចែកប្រេងនៅប្រទេសបារាំងរយៈពេលមួយឆ្នាំ តាមរយៈអាហារូប-ករណ៍របស់រដ្ឋាភិបាលបារាំង ។ មុនចេញដំណើរទៅទីក្រុងប៉ារីស អ៊ីង ក្រពុំផ្កា បានណែនាំឲ្យធ្វើកិច្ចការមួយចំនួនៈ ទីមួយ ប៊ុនចេង ត្រូវចូលជាសមាជិកសហភាពនិស្សិតខ្មែរនៅទីនោះដើម្បីងាយស្រួលស៊ើបរកសមាជិកពេញលក្ខណៈ ហើយបញ្ជូនឈ្មោះមកឲ្យខ្លួន និងទីពីរ យកសំបុត្រមួយច្បាប់ទៅឲ្យឈ្មោះ យី គឹមសួរ (នៅផ្ទះខ្មែរប្រទេសបារាំង) រួចទំនាក់ទំនងជាមួយគាត់ ព្រោះគាត់មានខ្សែសេ.អ៊ី.អា នៅអាមេរិកដែរ ។

ប៊ុនចេង បានធ្វើដំណើរទៅដល់ប្រទេសបារាំងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៦៩ ។ ពេលទៅដល់បានពីរថ្ងៃ ប៊ុនចេង បានយកសំបុត្រទៅឲ្យ យី គឹមសួរ ។ គឹមសួរ បានសុំឲ្យ ប៊ុនចេង ធ្វើការជាមួយគាត់ ប៉ុន្តែ ប៊ុនចេង បានបដិសេធរឿងនេះ ព្រោះខ្លួនត្រូវត្រឡប់ទៅរៀននៅឯទីក្រុងម៉ាកសីប្រទេសបារាំង និងត្រូវទៅធ្វើការជាមួយនឹងសមាគមចម្រើនដើម្បីស៊ើបរកសមាកជិកស្នូលឲ្យបានល្អិតល្អន់ផង ។ ខ្សែទាក់ទងរបស់ ប៊ុនចេង ត្រូវធ្វើការជាមួយ ជូ ស៊ីថន, ចាន់ មានថន និង ថាច់ អ៊ុង ។ អ្នកទាំងអស់នេះ បានធ្វើដំណើរមកប្រទេសបារាំងក្រោយ ប៊ុនចេង ជាងមួយខែប៉ុណ្ណោះ ។ មួយរយៈក្រោយមក ប៊ុនចេង ស៊ើបរកឃើញសមាជិកស្នូលបីនាក់ឈ្មោះ ជួន មុម្ម, ជួន ប្រសិទ្ធ និង ម៉ែន វ៉ាស័យ ។ ប៊ុនចេង ក៏បានរាយការណ៍ឈ្មោះទាំងបីទៅឲ្យ យី គឹមសួរ ។ សមាគមនេះគាំទ្រចលនាតស៊ូរបស់ប្រជាជនមុនគេបង្អស់ គឺនៅពេលមានការតស៊ូដោយអាវុធនៅកម្ពុជា ។ នៅខែមេសា ឆ្នាំ១៩៧០ ប៊ុនចេង បានចូលរួមក្នុងចលនាតស៊ូបដិវត្តន៍ ។

ឆ្នាំ១៩៧០-៧១ ប៊ុនចេង ទៅធ្វើការនៅទីក្រុងនីស និងអប់រំបាននិស្សិតកម្ពុជាម្នាក់ឈ្មោះ កែវ សុខ ។ ឈ្មោះនេះត្រូវបាន ថាច់ អ៊ុង បញ្ចូលជាសមាជិកសេ.អ៊ី.អា នៅសាក់សែលក្នុងឆ្នាំ១៩៧១ ។ ពេលរដ្ឋប្រហារឆ្នាំ១៩៧០ ប៊ុនចេង បានសម្រេចចិត្តស្នាក់នៅប្រទេសបារាំងតទៅទៀត ហើយបានចូលរួមរណសិរ្សតាមរយៈសហភាពនិស្សិតខ្មែរ ។ នៅក្នុងរណសិរ្សប្រចាំ

ក្រុងប៉ារីសមានសមាគមគាំទ្រច្រើន ខាងផ្នែកនិស្សិតមានគណៈកម្មាធិការយុវជនរណសិរ្សរួបរួមជាតិនៅប្រទេសបារាំង ហើយនៅក្នុងគណៈរបស់យុវជនរណសិរ្សមានតំណាងមកពីសមាគមនីមួយៗថែមទៀត ។ ប៉ុនចេង ត្រូវបានសមាគមបញ្ជូនមកធ្វើជាតំណាង និងជាអ្នកទទួលឈ្មោះអ្នកដែលសុំចូលជាសមាជិករណសិរ្ស ។ ការងារទាំងអស់នេះ ប៉ុន ចេង តែងតែរាយការណ៍ទៅឲ្យ យី គឹមសួរ ជានិច្ច ។ មន្ត្រីទូតខ្លះក៏បានមកសុំចូលរណសិរ្សដែរ ដោយយករថយន្ត ផ្ទះរដ្ឋ និងលុយ មកឲ្យប្រជាជនកម្ពុជា ។ ការងារសំខាន់ៗនេះ ប៉ុនចេង បានដឹងតាមរយៈ ខែក វណ្ណឌី ដែលត្រូវជាមិត្តភក្តិប្អូនថ្លៃរបស់ខ្លួន ។

ឆ្នាំ១៩៧០ គឹមសួរ បានត្រឡប់មកភ្នំពេញវិញ ។ អិត សារ៉េត បានឡើងកាន់តំណែងជំនួសម្តង ។ ក្នុងឆ្នាំ១៩៧១ ប៉ុនចេង បានចុះឈ្មោះចូលរៀនមហាវិទ្យាល័យនៅសង្កាត់ទី៨ ទីក្រុងប៉ារីស ។ ពេលកំពុងសិក្សា ប៉ុនចេង និង សឿ សាម៉េត បានទៅបញ្ចុះបញ្ចូលនិស្សិតពីរនាក់ឈ្មោះ វណ្ណ ភំ និង តាន់ គឹមដារា ឲ្យចូលសមាជិកសេ.អុី.អានៅខែកក្កដា ។

ឆ្នាំ១៩៧២ សមាគមនេះត្រូវបានរំសាយចោលដោយទុកឲ្យមានតែនិស្សិតរណសិរ្សតែមួយប៉ុណ្ណោះ ហើយខាងភ្នំពេញក៏បានបញ្ជូនសមាជិកទៅប្រទេសបារាំងឲ្យចូលក្នុងជួររណសិរ្សជាបន្តបន្ទាប់ ក្នុងគោលបំណងកម្ទេចគ្រឹះពីខាងក្នុងមកវិញ ។ រហូតមកដល់ពាក់កណ្តាលឆ្នាំ ប៉ុនចេង បញ្ចុះបញ្ចូលបាននិស្សិតម្នាក់ទៀតឈ្មោះ អុី ណារ៉ា ឲ្យចូលជាសមាជិករបស់ខ្លួននៅក្នុងឆ្នាំ១៩៧២ ។

ឆ្នាំ១៩៧៣ សភាពការណ៍ផ្ទះខ្មែរនៅប្រទេសបារាំងភាគច្រើនត្រូវបានកាន់កាប់ដោយនិស្សិតរណសិរ្សនៅទីក្រុងប៉ារីស ។ ដោយឃើញសភាពរញ៉េរញ៉ៃពេក ចាងហ្វាងផ្ទះខ្មែរបានបណ្តេញនិស្សិតរណសិរ្សចេញពីបន្ទប់ដោយយកហេតុផលថាមានខ្មាំងចូលបង្កប់ខ្លួន ។ រយៈពេល៥ខែក្រោយមក គណៈនិស្សិតរណសិរ្សបានរៀបចំការចាត់តាំងថ្មី ដោយបែងចែកសមាជិកឲ្យទៅតំបន់ផ្សេងៗ ។ ប៉ុនចេង បានមកឈរជើងនៅតំបន់ខាងត្បូងទទួលភារកិច្ចជាអនុប្រធានតំបន់ ដែលមាន ទ្រី ម៉េងហួត ជាប្រធាន ។ នៅក្នុងរយៈពេលនោះការពង្រីកកម្លាំងសេ.អុី.អា មានការលំបាកខ្លាំង ដូច្នេះខាងខ្មែររបស់ ប៉ុនចេង ក្រោមការទទួលខុសត្រូវរបស់ សាំង សុីរ៉ាត ក៏បានពិភាក្សាគ្នារកមធ្យោបាយចរចាធ្វើយ៉ាងណាឲ្យមានសភាពធូរស្រាលឡើងវិញរវាងរណសិរ្សនិងពួកប្រឆាំង ។ ពេលនោះ ប៉ុនចេង បានទៅទាក់ទងនិស្សិតខាងខេត្តស្ត្រាសបួរ ដើម្បីបំភាន់ភ្នែកអ្នកសារព័ត៌មាន ហើយឲ្យជួយផ្សព្វផ្សាយដល់មតិពិភពលោកថា កម្ពុជានឹងចរចាជាមួយអាមេរិក ព្រោះថានិស្សិតរណសិរ្សនៅបរទេសបានចុះចូលជាមួយភ្នំពេញអស់ហើយ ។ ធាតុពិត ភារកិច្ចចម្បងរបស់ ប៉ុនចេង នៅពេលនោះ គឺបង្កប់ខ្លួនក្នុងក្រុមនិស្សិតរណសិរ្ស ដើម្បីអូសទាញនិស្សិតដែលមានគោលជំហរស្ទាក់ស្ទើរឲ្យមកខាងខ្លួន ។ ចុងឆ្នាំ១៩៧៤ សាំង សុីរ៉ាត ត្រូវត្រឡប់មកកម្ពុជាវិញ ដូច្នេះអ្នកទទួលខុសត្រូវជំនួសគឺ ថាច់ អុ៊ុង ។

ដើមឆ្នាំ១៩៧៥ ស្ថានភាពនៅប្រទេសកម្ពុជាមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំង ធ្វើឲ្យខាងសហរដ្ឋអាមេរិកអស់សង្ឃឹម ហើយក៏បានរៀបចំគម្រោងចាញ់សង្គ្រាមមួយដើម្បីយកមកអនុវត្តនៅកម្ពុជា ។ ពេលនោះ ថាច់ អ៊ុង បានបោះបង់តួនាទីរបស់ខ្លួន ហើយបានយកលុយមួយចំនួនរត់បាត់ ។ អុី ចេង មកពីខេត្តស្ត្រាសបួរ ក៏បានទទួលខុសត្រូវជំនួសវិញ ។ ខ្សែរបស់ ប៉ុនចេង នៅពេលនេះមានតែ អុី ឆេង, សឿ សាម៉េត, រង, កែវ, សុខ, វណ្ណភំ, តាន់ គឹមដារ៉ា និង អុី ណារ៉ា ប៉ុណ្ណោះ ហើយអ្នកបង្កប់ខ្លួននៅក្នុងជួរបដិវត្តមាន សឿ សាម៉េត, កែវ សុខ និង អុី ណារ៉ា ។ អុី ឆេង បានរៀបចំឲ្យមានការប្រជុំពិភាក្សាគម្រោងធំមួយជាមួយសមាជិកសេ.អុី.អាទាំងអស់ ដើម្បីពង្រឹងវិន័យឲ្យបានល្អគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ។ ប៉ុនចេង បានទទួលភារកិច្ចថ្មីគឺទៅបង្កប់ខ្លួននៅក្នុងវគ្គរៀនសូត្រឲ្យបានច្រើន ដើម្បីឆក់យកឱកាសពីខាងបដិវត្តន៍ឲ្យខ្លួនបានតំណែងអ្នកទទួលខុសត្រូវក្នុងបដិវត្តនឹងគេ ។

ចុងឆ្នាំ១៩៧៥-៧៦ និស្សិតរណសិរ្សរួបរួមជាតិនៅប្រទេសបារាំងត្រូវបានប្រែឈ្មោះទៅជា «សមាគមអាណិកជនស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យ» និងមានការចាត់តាំងគណៈកម្មាធិការថ្មីទៀតផង ។ ប៉ុនចេង ទទួលតួនាទីជាលេខាកាន់កាប់កិច្ចការផ្ទៃក្នុងនិងទទួលលិខិត ។ ប៉ុនចេង ដើរឃោសនាបំភិតបំភ័យមិនឲ្យអាណិកជនកម្ពុជាដែលស្ទាក់ស្ទើរក្នុងការវិលត្រឡប់

មកកម្ពុជាពន្យារពេល ឬក៏ធ្វើបាត់ពាក្យសុំរបស់អាណិកជនដែលចង់វិលត្រឡប់មកកម្ពុជា ព្រោះថាពាក្យសុំត្រឡប់ចូលប្រទេសវិញត្រូវធ្វើតាមរយៈសមាគមនេះ ។ ចុងឆ្នាំ១៩៧៦ ប៊ុនចេង បានឈប់ធ្វើជាលេខាដោយសារថា អង្គការហៅឲ្យត្រឡប់មកកម្ពុជាវិញ ។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ប៊ុនចេង បានធ្វើដំណើរតាមយន្តហោះដោយឆ្លងកាត់ប្រទេសចិននិងមកដល់កម្ពុជានៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។

មកដល់ភ្នំពេញ ប៊ុនចេង ត្រូវអង្គការបញ្ជូនមករស់នៅមន្ទីរក-១៥បឹងត្របែកអស់រយៈពេលមួយឆ្នាំ ។ ពេលមកដល់ ប៊ុនចេង ចាប់អារម្មណ៍ថាអង្គការមានវិន័យតឹងរ៉ឹងណាស់ក្នុងការទាក់ទងគ្នា ។ សមាជិកនៅក្នុងក្រុមនីមួយៗអាចទាក់ទងគ្នាក្រៅម៉ោងធ្វើការបានតែចាប់ពីម៉ោង១១ទៅម៉ោង១រសៀលប៉ុណ្ណោះ ក្រៅពីនោះអាចទាក់ទងគ្នានៅពេលបាយ ។ នៅមន្ទីរក-១៥ ជាកន្លែងមួយដែលមានសុទ្ធតែបញ្ញាជនមកពីបរទេសនិងនៅក្នុងស្រុកខ្លះៗ ។ ប៊ុនចេង ទទួលភារកិច្ចច្រើនដោយចល័តពីកសិកម្ម ទៅរុះរើសំណង់ និងសម្អាតដីឡូតិ៍ ប៉ុន្តែតួនាទីជារួមគឺធ្វើជាមេក្រុម ។

នៅដើមឆ្នាំ១៩៧៧ ប៊ុនចេង បានធ្វើសកម្មភាពដុតបំផ្លាញសម្បត្តិរួមមាន គុទ្ធ របស់របរប្រើប្រាស់និងបានធ្វើឲ្យខូចខាតគ្រឿងឈើល្អៗក្នុងពេលរុះរើផ្ទះថែមទៀត ។ ក្នុងឆ្នាំដដែលនៅមន្ទីរក-១៥ មានការដូរប្រធានតំណាងអង្គភាពមួយចំនួន ។ ទូន សារិន ហៅ កើត ជាប្រធានមន្ទីរចាស់ត្រូវអង្គការដកចេញពីតំណែង ។ ប៊ុនចេង ក៏ធ្លាប់បានជួប កើត ម្តងម្កាលដែរ ហើយពេលជួបម្តងៗ កើត តែងតែនិយាយពីបញ្ហាក្នុងនៅក្រុមសាមគ្គី ពេលធ្វើការជាមួយប្រធានតំណាងអង្គភាពថ្មី ។ ប៊ុនចេង បានលើកយកចំណុចខ្វះខាតរបស់អ្នកតំណាងថ្មីនេះប្រាប់វិញដែរ កើត បានប្រាប់ថាតំណាងអង្គភាពកំពុងបំបាក់ស្មារតីមិត្តរាល់គ្នាមិនឲ្យងើបតស៊ូវណ្ណៈ ។ លាន សេរីវុធ នៅខាងក្រុមសិប្បកម្មក៏បានរិះគន់អំពីបញ្ហាខ្វះខាតរបស់តំណាងប្រធានអង្គភាពនិងអនុប្រធានមន្ទីរដែរ ហើយបានទាំងប្រាប់ទៀតថា អ្នកមានទំនាស់នឹងមាគ៌ានៅអង្គការថ្នាក់លើក៏ដកអស់ដែរ ដូចជា កុយ ធួន, ហ៊ូ យន់ និង ភោគ ឆាយ ជាដើម ។ នៅខែកក្កដា កើត ត្រូវអង្គការចាប់ខ្លួន ។ ពេលនោះ មានចលនាផុសផុលពីបុរសនារីមួយចំនួនប្រឆាំងនឹងអនុប្រធានមន្ទីរអំពីការរើសប្រធានស្តីទីបណ្តោះអាសន្ន ។ ប៊ុនចេង, ធុន ហៅ ដើម, នុត ប៊ុនស៊ុង និង លាន សេរីវុធ ប្រជុំពិភាក្សាគ្នាដើម្បីធ្វើសកម្មភាពបំផុសចលនាប្រឆាំងនឹងពួកជននៅមានឥទ្ធិពលនាយទុនសក្តិភូមិ ។ ប៊ុនចេង យកតួនាទីជាប្រធានក្រុមចល័តទី២ និងម៉ោងធ្វើការទៅបំផុសសមាជិកក្រុមរបស់ខ្លួនឲ្យប្រឆាំងនឹងការដឹកនាំរបស់ប្រធានអង្គភាពនិងគណៈមន្ទីរ ។ ពេលខ្លះ ប៊ុនចេង ឆ្លៀតពេលបាយថ្ងៃត្រង់ដើរទាក់ទងអ្នកដែលខ្លួនធ្លាប់ស្គាល់ឲ្យឡើងចាប់អារម្មណ៍ឬជួយទះដៃគាំទ្រអ្នកវាយប្រហារបក្សឲ្យបានខ្លាំងៗ ។ នារីវិជ្ជា ដែលជាប្រពន្ធរបស់ កើត ក៏បានចូលរួមចលនាប្រឆាំងជាមួយ ប៊ុនចេង ដែរ ព្រោះនាងខឹងនឹងតំណាងអង្គភាពដែលធ្វើឲ្យប្តីរបស់គាត់ធ្លាក់ពីតំណែង ។ ក្នុងការឃោសនារបស់ ប៊ុនចេង ជារូបភាពគឺបំផុសឲ្យគ្រប់គ្នាតស៊ូវណ្ណៈដើម្បីកម្ទេចវណ្ណៈដែលនៅមានឥទ្ធិពលនាយទុន សក្តិភូមិ ប៉ុន្តែជាទិសដៅ ប៊ុនចេង វាយប្រហារធាតុបក្ស វណ្ណៈកម្មករ កសិករ តាមរយៈការបរិប្រហារតំណាងអង្គភាពថ្មី ។ ពីមួយថ្ងៃទៅមួយថ្ងៃសកម្មភាពប្រឆាំងនឹងបដិវត្តន៍របស់ ប៊ុនចេង កាន់តែលេចធ្លោឡើងនិងស្តែងចេញឲ្យបក្សនិងមហាជនឃើញកាន់តែច្បាស់ ។

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ប៊ុនចេង និងអ្នកដែលទាក់ទងទាំងប៉ុន្មានត្រូវអង្គការបក្សចាប់ខ្លួនទាំងអស់ ក្នុងនោះមាន នារី ផ្លែក វិជ្ជា, លាន សេរីវុធ, ចាន់ គីស៊ុយ និងគ្រួសារ, នុត ប៊ុនស៊ុង និងគ្រួសារ, តាន់ លៀកផេង, កែ ថាវរៈ ហៅ សំ, ជា, គង់និងគ្រួសារ និង អ្នូ សាគម ហៅរឿង ។ ចម្លើយសារភាពដែលមានចំនួន៣០ទំព័រនិងបញ្ជីឈ្មោះអ្នកពាក់ព័ន្ធចំនួន៩សន្លឹក ប៊ុនចេង ត្រូវចំណាយអស់រយៈពេល៦ថ្ងៃនិងត្រួតពិនិត្យការសរសេរដោយក្រុមអ្នកធ្វើឯកសារ ឈ្មោះអ៊ឹម អឿន ។

**លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

◆ លើកតម្កើងស្មារតីនិតៀនដោយសុចរិត តស៊ូយ៉ាងសកម្ម មិនយោគយល់ មិនគិតគូរដល់ឯកជន ឱ្យតែមានផលប្រយោជន៍ដល់សមូហភាព ឱ្យតែការពារអង្គការវិន័យរបស់បក្ស។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៤២៧ | ជា វន ហៅ ភាព | យុទ្ធជន | ដែកំពង់សោម | ១៥-២-៧៧ | ១២-៥-៧៧ |
| ២៤២៨ | ជឹម សេងហ៊ាង ហៅ ឈាង | យុទ្ធជន | ពាណិជ្ជកម្ម | ១៧-២-៧៧ | ១២-៥-៧៧ |
| ២៤២៩ | ធ្លក សួន ហៅ យ៉ន | ប្រធាននេសាទ | ពាណិជ្ជកម្ម | ១៧-២-៧៧ | ១២-៥-៧៧ |
| ២៤៣០ | ប្រុក ធឿន ហៅ ជុំ | អនុប្រធានមន្ទីរ | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៤៣១ | សៀង ស៊ីផាន ហៅ និត | យុទ្ធជន | ព-៩៨ | ១៩-២-៧៧ | ១២-៥-៧៧ |
| ២៤៣២ | ធីវ យឿន | សមាជិកពេទ្យ | តំបន់១០៦ | ២-២-៧៧ | ១២-៥-៧៧ |
| ២៤៣៣ | ម៉ៅ ម៉េត ហៅ វ៉ន | អនុវរសេនាតូច | កងពល៣១០ | ១៩-២-៧៧ | ១២-៥-៧៧ |
| ២៤៣៤ | ចាប ធិន ហៅ សាម | លេខាវរសេនាតូច | កងពល៣១០ | ១៨-២-៧៧ | ១២-៥-៧៧ |
| ២៤៣៥ | សុក ហុន | យុទ្ធជន | កងពល៣១០ | ៨-១-៧៧ | ១២-៥-៧៧ |
| ២៤៣៦ | ឃួន ស៊ុយ ហៅ ស៊ឹម | យោធា | កងពល៣១០ | ២៤-២-៧៧ | ១២-៥-៧៧ |
| ២៤៣៧ | ព្រុំ សៃឡេក | យុទ្ធជន | ពាណិជ្ជកម្ម | ១៦-១-៧៧ | ១២-៥-៧៧ |
| ២៤៣៨ | ម៉ម សូត្រ | អនុនយោបាយ | កងពល៣១០ | ២៩-២-៧៧ | ១២-៥-៧៧ |
| ២៤៣៩ | យឹម រេន ហៅ វ៉ាវ | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ១៦-១-៧៧ | ១២-៥-៧៧ |
| ២៤៤០ | ម៉ក់ សុខុម | កម្មករចាស់ | មន្ទីរស-៨ | ១-២-៧៧ | ១២-៥-៧៧ |
| ២៤៤១ | ហុង សៀក | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ១៥-២-៧៧ | ១២-៥-៧៧ |
| ២៤៤២ | សំ ឈឿន ហៅ ផេង | លេខាវរសេនាធំ | កងពល៣១០ | ១៩-២-៧៧ | ១២-៥-៧៧ |
| ២៤៤៣ | ជា មៀច ហៅ ចិត្ត | សមាជិក | រោងចក្រជ-៣ | ២៣-១-៧៧ | ១២-៥-៧៧ |
| ២៤៤៤ | ម៉ែន នីថូ ហៅ ជន | គណៈសាលា | សាធារណការ | ១-១-៧៧ | ១២-៥-៧៧ |
| ២៤៤៥ | ពេជ ម៉ាច | លេខាវរសេនាតូច | កងពល៣១០ | ២០-១-៧៧ | ១២-៥-៧៧ |
| ២៤៤៦ | ក្រូច រឿន | អនុប្រធានវ.ត | ដែកំពង់សោម | ??-១-៧៧ | ១២-៥-៧៧ |
| ២៤៤៧ | សួ សុខុន | លេខាវរសេនាតូច | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៤៨ | ឈួន ស្រឿន ហៅ សែ | អនុវរសេនាតូច | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៤៩ | ព្រុំ ឆួយ ហៅ ចិត្ត | យោធាវរសេនាតូច | កងពល៣១០ | ១៨-២-៧៧ | ១២-៥-៧៧ |
| ២៤៥០ | ញ៉ែម ថុល ហៅ វ៉ា (ស្រី) | ប្រពន្ធ ម៉េញ សាយ ហៅ កែវ | ពាណិជ្ជកម្មរដ្ឋ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៤៥១ | នូវ សុវណ្ណ ហៅ ម៉ៃ (ស្រី) | យុទ្ធនារី | មន្ទីរក-១៦ | ៤-២-៧៧ | ១២-៥-៧៧ |
| ២៤៥២ | ជុំ ផល | កុមារ | មន្ទីរក-១៥ | ១-២-៧៧ | ១២-៥-៧៧ |
| ២៤៥៣ | សយ គឹមយាត ហៅ ភុំ (ស្រី) | ប្រពន្ធ លួ ន | កាត់ដេររដ្ឋ | ៧-២-៧៥ | ១២-៥-៧៧ |
| ២៤៥៤ | តាន់ សុហួយ ហៅ ជាតិ (ស្រី) | ប្រពន្ធ ឆៃហេង | ការបរទេស | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៥៥ | ចាន់ ធឿន ហៅ ធីម (ស្រី) | អនុកងហា | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៤៥៦ | ជា ឡាំងហ៊ាង (ស្រី) | ប្រពន្ធ កែវ ផាត់ | កងពល៣១០ | ៧-២-៧៧ | ១២-៥-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៤៥៧ | សុក សុខុម (ស្រី) | មេពួក | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៤៥៨ | ឌុច មាញ (ស្រី) | មេក្រុមកាត់ដេរ | សេនាធិការ | ១៣-១-៧៧ | ១២-៥-៧៧ |
| ២៤៥៩ | ចាប ខុំ (ស្រី) | ពេទ្យឃុំញ្ញាយ | ភាគបស្ចិម | ៣-១-៧៧ | ១២-៥-៧៧ |
| ២៤៦០ | ចឹក យន់ ហៅ អែម (ស្រី) | ប្រធាននារីមន្ទីរ | មន្ទីរក-៩ | ៦-២-៧៧ | ១២-៥-៧៧ |
| ២៤៦១ | ឈួន ធត ហៅ រី (ស្រី) | ពេទ្យ | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៤៦២ | អេង គឹមឡេង ហៅ ណាត (ស្រី) | សមាជិកមន្ទីរ | ក្រសួងការបរទេស | ៣-២-៧៧ | ១២-៥-៧៧ |
| ២៤៦៣ | ឈុន លុន | យុទ្ធជន | រោងចក្រអ-៣ | ៣-១-៧៧ | ១២-៥-៧៧ |
| ២៤៦៤ | ឃួន សាន ហៅ រឿន | លេខាកងធំទី៣ | ពាណិជ្ជកម្មរដ្ឋ | ៦-២-៧៧ | ១២-៥-៧៧ |
| ២៤៦៥ | កាន់ សុខា ហៅ ជ្រូក | យុទ្ធជន | រោងចក្រអ-៣ | ២៤-១-៧៧ | ១២-៥-៧៧ |
| ២៤៦៦ | ណែម យុន ហៅ ពាន់ | អនុក្រុម | ពាណិជ្ជកម្មរដ្ឋ | ២៥-១-៧៧ | ១២-៥-៧៧ |
| ២៤៦៧ | ឡុង សុខា ហៅ ប៉ុន | ផ្ញើបញ្ជី | ពាណិជ្ជកម្មរដ្ឋ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៤៦៨ | ឡយ លឿន ហៅ ឡុម | យុទ្ធជន | តំបន់១០៦ | ?-២-៧៧ | ១២-៥-៧៧ |
| ២៤៦៩ | គឹម ប្រាក់ ហៅ ចាន់ | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៧០ | ឈិន ជត | យុទ្ធជន | កសិកម្មរដ្ឋ | ៨-១-៧៧ | ១២-៥-៧៧ |
| ២៤៧១ | ឃើ ម៉ាត់ ហៅ ឆន | សមាជិកកងវរយ | ស-២១ | ២២-២-៧៧ | ១២-៥-៧៧ |
| ២៤៧២ | សុក ដាន់ ហៅ វុធ | និរសារ | តំបន់១០៦ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៧៣ | សំ សៀង | យុទ្ធជន | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៤៧៤ | អ៊ឹម ម៉ាន់ ហៅ សាន | យុទ្ធជន | រោងចក្រមី | ២៥-១-៧៧ | ១២-៥-៧៧ |
| ២៤៧៥ | ភាំង ស៊ីន | កុមារចោរព្រៃ | ពោធិសាត់ | ?-១-៧៧ | ១២-៥-៧៧ |
| ២៤៧៦ | សឹម ស៊ន់ ហៅ សួន | យុទ្ធជន | ផែភ្នំពេញ | ៥-២-៧៧ | ១២-៥-៧៧ |
| ២៤៧៧ | នួន អេត | លេខាវរសេនាតូច | កងពល៣១០ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៤៧៨ | ខ្មៅ រ៉ែន ហៅ រ៉ុម | មេក្រុម | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៤៧៩ | លុន គឹម ហៅ សារឿន | យោធាវរសេនាតូច | កងពល៣១០ | ២៤-២-៧៧ | ១២-៥-៧៧ |
| ២៤៨០ | ពាង វ៉ិរ ហៅ វង់ | មេពួក | កាត់ដេររដ្ឋ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៤៨១ | កាំ ដាន់យ៉ា ហៅ ដាំ | សមាជិករណសិរ្ស | ប៉េកាំង | ២-១-៧៧ | ១២-៥-៧៧ |
| ២៤៨២ | រស់ សូត្រ ហៅ សារ៉ាត | យុទ្ធជន | មន្ទីរពិការ | ១-១-៧៧ | ១២-៥-៧៧ |
| ២៤៨៣ | ញ៉ែម ញាណ | លេខាវរសេនាតូច | កងពល៣១០ | ២៩-២-៧៧ | ១២-៥-៧៧ |
| ២៤៨៤ | នង គឹម ហៅ កាំ | ជាងភ្លើង | រោងចក្រត-៣ | ២៩-១-៧៧ | ១២-៥-៧៧ |
| ២៤៨៥ | រស់ ឆាត ហៅ សៀម | សមាជិកកងធំ | ពាណិជ្ជកម្មរដ្ឋ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៨៦ | ទេព អុល ហៅ ឃឹម | លេខាវរសេនាតូច | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៤៨៧ | ហៃ ស៊ាប ហៅ ដាត | និរសារ | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៤៨៨ | ឃីម យឿន ហៅ ភព | យុទ្ធជន | ក្រសួងការបរទេស | ២៥-១-៧៧ | ១២-៥-៧៧ |
| ២៤៨៩ | សំ រិតវង់ ហៅ ជា | លេខាវរសេនាតូច | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៤៩០ | ព្រំ បួ ហៅ ដាន | លេខាវរសេនាតូច | កងពល៣១០ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៤៩១ | អ៊ឹម ស្រ៊ុន ហៅ ធួន | យុទ្ធជន | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |

(នៅមានត))

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## ព្រាំ ធុច អតីតវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យព្រះកេតុមាលា


ព្រាំ ធុច
នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០

ព្រាំ ធុច ជាអតីតវេជ្ជ-បណ្ឌិតនៅមន្ទីរពេទ្យព្រះកេតុមាលា ។ ឪពុករបស់គាត់ឈ្មោះ ព្រាំ ថៃ ម្តាយឈ្មោះ ពេញ ប៉ិច ។ ប្រពន្ធរបស់ ធុច ឈ្មោះ ហោ វណ្ណា មានស្រុកកំណើតនៅស្រុកមោងឬស្សី ខេត្តបាត់ដំបង ។ ធុច មានកូន៥នាក់ ស្រី២នាក់ ប្រុស៣នាក់ ។ ធុច ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ នៅខេត្តបាត់ដំបង រួចបញ្ជូនមកមន្ទីរស-២១ឃុំឃាំងនៅក្នុងផ្ទះក-០៣ បន្ទប់ធំ៧ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានតម្កល់ប្រវត្តិរូបរបស់ ព្រាំ ធុច ដែលមានបិទរូបថតផង ។ ជា យ៉ុម ត្រូវជាក្មួយសាច់ថ្លៃរបស់ ធុច បានរក្សាទុករូបថតរបស់ ធុច ចំនួនពីរសន្លឹក ។ ជា យ៉ុម បានរៀបរាប់អំពីរឿងរ៉ាវរបស់ ព្រាំ ធុច ថា៖

ពូធុច បានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៥ នៅពេលជម្លៀសចេញពីទីក្រុងភ្នំពេញ ចំណែកប្រពន្ធនិងកូនរបស់គាត់សព្វថ្ងៃកំពុងរស់នៅសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៨៣ ប្រពន្ធរបស់ពូធុច ធ្លាប់បានផ្ញើសំបុត្រមួយច្បាប់មកសុំឲ្យខ្ញុំផ្ញើរូបថត ពូធុច ទៅឲ្យគាត់ ។ គាត់បានប្រាប់ខ្ញុំថា ប្តីរបស់គាត់ស្លាប់ហើយ កូនៗរបស់គាត់មុខដូចឪពុកវាណាស់ ។ ពេលនោះដោយសារតែប្រទេសជាតិមិនទាន់មានសន្តិភាពស្រួលបួល ខ្ញុំក៏មិនបានឆ្លើយតបសំបុត្រទៅប្រពន្ធគាត់វិញទេ ។ ក្រោយមកខ្ញុំបានធ្វើឲ្យបាត់អាសយដ្ឋានប្រពន្ធរបស់គាត់ ។ ខ្ញុំទើបតែបានឃើញប្រវត្តិរូបមួយសន្លឹករបស់ ពូធុច តាមរយៈបុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលចុះទៅស្រាវជ្រាវនៅភូមិរបស់ខ្ញុំ ។

ពូធុច មានបងប្អូន៣នាក់ ស្រី២នាក់និងប្រុសម្នាក់គឺរូបគាត់ ។ ក្រុមគ្រួសាររបស់គាត់ស្លាប់នៅក្នុងរបបខ្មែរក្រហមទាំងអស់ ។ បងប្អូនគាត់ពីរនាក់និងឪពុកម្តាយរបស់គាត់បានស្លាប់ដោយសារខ្វះខាតអាហារនិងឈឺគ្មានថ្នាំព្យាបាល ចំណែក ពូធុច ស្លាប់ដោយអង្គការសម្លាប់ ។

ពូធុច មានស្រុកកំណើតនៅភូមិស្វាយពល ស្រុកពារាំង ខេត្តព្រៃវែង ។ គាត់រៀននៅសាលាស្វាយពល ។ បន្ទាប់មកគាត់ចូលរៀនសាលាពេទ្យនៅទីក្រុងភ្នំពេញ ។ ពេលគាត់រៀនចប់ គាត់ទៅធ្វើការនៅខេត្តស្ទឹងត្រែងមួយរយៈទើបផ្លាស់មកធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលាទីក្រុងភ្នំពេញ ។ ពូធុច ធ្វើការខាងផ្នែកវះកាត់ ។ ប្រពន្ធរបស់គាត់ជាអ្នករស់នៅខេត្តបាត់ដំបង ។ ទាំងពីរនាក់ប្តីប្រពន្ធបានស្គាល់គ្នានៅពេលដែល ពូធុច ទៅដើរលេងនៅទីនោះ ។ ក្រោយពេលរៀបការហើយ ប្តីប្រពន្ធគាត់រស់នៅទីក្រុងភ្នំពេញ ផ្ទះនៅតាមផ្លូវកម្ពុជាក្រោម ។

ពូធុច បានបើកគ្លីនិកមួយនៅផ្ទះរបស់គាត់ដើម្បីរកប្រាក់ចំណូលបន្ថែមទៀត ហើយឲ្យប្រពន្ធគាត់នៅមើលខុសត្រូវគ្លីនិកនោះ ។ ជីវភាពគ្រួសារគាត់ធូរធារ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសារ ពូធុច ចេញពីទីក្រុងភ្នំពេញរួមជាមួយឪពុកម្តាយ បងប្អូន និងប្រពន្ធកូនរបស់គាត់ ។ ពេលដែលធ្វើដំណើរមកតាមផ្លូវជាតិលេខ១១បានពាក់កណ្តាលផ្លូវ ពូធុច ក៏សុំបែកផ្លូវពីឪពុកម្តាយនិងបងប្អូន ។ គាត់មិនចង់ទៅស្រុកកំណើតរបស់គាត់ទេ ពីព្រោះប្រជាជននៅទីនោះភាគច្រើនបានដឹងពីការងាររបស់គាត់ ។ គាត់បានផ្តាំផ្ញើខ្ញុំឲ្យជួយថែរក្សាឪពុកម្តាយរបស់គាត់ផង ។ ចាប់តាំងពីពេលនោះមក ពូធុច ក៏បាត់ដំណឹងរហូត ។ ឪពុកម្តាយនិងបងប្អូនរបស់គាត់បានធ្វើដំណើរទៅដល់ស្រុកកំណើតនៅឯភូមិស្វាយពលស្រុកពារាំង ខេត្តព្រៃវែង ។

នៅស្រុកពារាំង ខ្ញុំបានសុំអនុញ្ញាតពីអង្គការយកឪពុក

ម្តាយរបស់ ពូធុច នៅរស់នៅក្នុងផ្ទះជាមួយខ្ញុំ ។ ប្អូនគាត់២នាក់ទៀតត្រូវអង្គការបែងចែកឲ្យធ្វើការនៅកងចល័តនារី ។

ក្រោយមកឪពុកម្តាយរបស់ ពូធុច បានស្លាប់ជាបន្តបន្ទាប់ ។ ម្តាយ ពូធុច ស្លាប់ដោយសារជំងឺគ្រុនក្តៅ គ្មានថ្នាំសង្កូវព្យាបាល និងគ្មានអាហារហូបគ្រប់គ្រាន់ ។ ៥ខែក្រោយមកឪពុករបស់ ពូធុច ក៏ស្លាប់ដែរ ដោយសារជំងឺស្លាប់មួយចំហៀងខ្លួន ។ បន្ទាប់មកបងស្រីរបស់គាត់ឈ្មោះ ព្រំ ថូ បានស្លាប់ដោយសារជំងឺ ចំណែកឯប្អូនស្រីរបស់គាត់ឈ្មោះ ព្រំ សាប ត្រូវអង្គការហៅឲ្យផ្លាស់ទីលំនៅទៅភូមិថ្មីជាមួយកូន៣នាក់ ហើយបាត់ដំណឹងតាំងពីពេលនោះរហូតមក ។ ខ្ញុំគិតថា ព្រំ សាប ត្រូវអង្គការសម្លាប់ហើយ ពីព្រោះមានអ្នកនៅក្នុងភូមិដែលត្រូវបញ្ជូនទៅដីថ្មីដែរ មិនដែលឃើញត្រឡប់មកវិញសោះ ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានប្តូរទីកន្លែងរស់នៅពីភូមិមួយទៅភូមិមួយ ក្នុងគោលបំណងរកកន្លែងណាដែលមានអាហារហូបចុកគ្រាន់បើបន្តិច ។ បងប្អូនរបស់ខ្ញុំសុទ្ធសឹងជាប្រជាជនមូលដ្ឋាន ។ មានតែគ្រួសារ ពូធុច ទេដែលជាអតីតប្រជាជនថ្មី ។

រូបថតមួយសន្លឹកនេះគឺខ្ញុំជាអ្នករក្សាទុក ។ ខ្ញុំបានរូបថតនេះតាំងពីជំនាន់សម្តេចសីហនុម្ល៉េះ ។ ពូធុច ថតនៅពេលគាត់ចូលធ្វើពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា ។ ខ្ញុំបានវេចខ្ចប់វាយ៉ាងស្អាតហើយលាក់ទុកនៅក្នុងបង្វេចខោអាវរបស់ខ្ញុំ ។ ប្រសិនបើឈ្លបរកឃើញរូបថតនេះ ក្រុមគ្រួសារខ្ញុំពិតជាស្លាប់ ។

រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំគ្មានសង្ឃឹមថា ពូធុច នៅរស់ទេ ។ បើសិនជាគាត់នៅរស់ គាត់ពិតជាវិលទៅរកសាច់ញាតិរបស់គាត់នៅភូមិកំណើតមិនខាន ។ ខ្ញុំសង្ឃឹមថា ថ្ងៃណាមួយខ្ញុំអាចរកឃើញអាសយដ្ឋានប្រពន្ធរបស់ ពូធុច ហើយផ្ញើរូប ពូធុច ទៅឲ្យគាត់វិញ ។ ◆◆◆

## ហុក ឆាយស្រេង អតីតប៉េអឹម និង ឈួន លាងខួច ត្រូវជាប្រពន្ធ អតីតគ្រូបង្រៀន

ហុក ឆាយស្រេង បានបាត់ខ្លួននៅឆ្នាំ១៩៧៥បន្ទាប់ពីត្រូវអង្គការហៅទៅទទួលសម្តេចនៅភ្នំឆិបដេ ។ លាងខួច ដែលជាប្រពន្ធក៏គេចខ្លួនពីការតាមសម្លាប់ ហើយក៏បាត់ដំណឹងដូចគ្នា ។ អ្នកទាំងពីរបន្សល់ទុកនូវកូនប្រុសម្នាក់ឈ្មោះ ស៊ិន គីណាល់ ដែលត្រូវបានពេទ្យម្នាក់ជួយលាក់បំពួននិងចិញ្ចឹម ។ រហូតមកដល់សព្វថ្ងៃ គីណាល់ បានព្យាយាមស្វែងរកឪពុកម្តាយរបស់ខ្លួន ប៉ុន្តែជាង២៥ឆ្នាំទៅហើយ គីណាល់ នៅតែមិនបានទទួលដំណឹងអ្វីសោះ ។ គីណាល់ នៅតែមានសង្ឃឹមថាឪពុកម្តាយរបស់ខ្លួននៅរស់រានមានជីវិត ហើយថ្ងៃណាមួយនឹងត្រឡប់មករកខ្លួនមិនខាន ។ គីណាល់ នៅសល់តែរូបថតរៀបការរបស់ឪពុកម្តាយមួយសន្លឹកដែលអ៊ីម្នាក់រក្សាទុកឲ្យប៉ុណ្ណោះ ។ ស៊ិន គីណាល់ បានរៀបរាប់អំពីប្រវត្តិឪពុកម្តាយគាត់ថា ៖

ប៉ាធ្វើប៉េអឹមនៅទីក្រុងភ្នំពេញ ។ ក្រោយមក ប៉ាខ្ញុំបានទៅរៀនផ្នែកកងទ័ពនៅប្រទេសឥណ្ឌូនេស៊ីរយៈពេល១ឆ្នាំ ។ ពេលត្រឡប់មកវិញ គាត់បានទទួលតំណែងជាប្រធានប៉េអឹមពាក់ស័ក្តិ៤ នៅភូមិគគី ស្រុកកៀនស្វាយ ខេត្តកណ្តាល ចំណែកម៉ាក់របស់ខ្ញុំធ្វើជាគ្រូបង្រៀននៅសាលាស៊ឹងមានជ័យ ។ ប៉ាបានស្គាល់ម៉ាក់តាំងពីមុនពេលគាត់ចេញទៅរៀននៅប្រទេសឥណ្ឌូនេស៊ី ។ ពេលប៉ា ត្រឡប់មកដល់ភ្នំពេញវិញ ប៉ាបានសុំម៉ាក់រៀបការ ហើយគាត់ទាំងពីរនាក់បានមករស់នៅជាមួយសាច់ញាតិដែលមានផ្ទះនៅឃ្លាំងរំសេវ ។

នៅឆ្នាំ១៩៧៤ ប៉ារបស់ខ្ញុំត្រូវផ្លាស់ទៅធ្វើប្រធានប៉េអឹមនៅខេត្តបាត់ដំបង ។ ក្រុមគ្រួសារខ្ញុំផ្លាស់ទៅនៅទីនោះទាំងអស់គ្នា ។ ម៉ាក់របស់ខ្ញុំធ្វើជាគ្រូបង្រៀននៅសាលាវត្តដំរីស (បច្ចុប្បន្នសាលាណេតយ៉ង់) ។

នៅឆ្នាំ១៩៧៥ អង្គការបានតាមដានក្រុមគ្រួសាររបស់ខ្ញុំ ហើយស្រាវជ្រាវរកឃើញថាប៉ាខ្ញុំជាអតីតប៉េអឹម ។ ក្រោយមកអង្គការបានហៅប៉ាឲ្យទៅទទួលសម្តេចនៅភ្នំឆិបដេ ។ អង្គការប្រាប់ថា សម្តេចយាងមកសួរសុខទុក្ខប្រជាជននៅទីនោះ ។ ប៉ាខ្ញុំត្រូវអង្គការដឹកតាមឡានជាមួយអតីតប៉េអឹមនិងទាហាន លន់ នល់ ជាច្រើននាក់ ។ ក្រោយពីរបបខ្មែរក្រហមដួលរលំខ្ញុំបានជួបពូម្នាក់ដែលទៅទទួលសម្តេចឪជាមួយប៉ាខ្ញុំដែរ ។ ពូនោះប្រាប់ខ្ញុំថា អ្នកដែលអង្គការហៅទៅទទួលសម្តេច តាមពិតហៅយកទៅសម្លាប់ចោលសោះ ចំណែកគាត់បានគេចខ្លួនរួច ។ គាត់រៀបរាប់ថា ពេលឡានដឹកទៅដល់ភ្នំ មានគ្រាប់កាំភ្លើងជាច្រើនបាញ់ចេញពីព្រៃជុំវិញនោះ ។ ពេលនោះមានមនុស្សតិចណាស់ដែល

បានរត់រួចពីគ្រាប់កាំភ្លើង ។

ក្រោយពីយកប៉ារបស់ខ្ញុំទៅ អង្គការបានតាមដានម៉ាក់ខ្ញុំទៀត ហើយស៊ើបដឹងថាម៉ាក់របស់ខ្ញុំជាអតីតគ្រូបង្រៀន ។ មិត្តភក្តិរបស់ម៉ាក់ពីរ-បីនាក់ដែលជាអតីតគ្រូបង្រៀនបានស៊ើបដឹងថាខ្លួនគាត់ និងម៉ាក់ក៏មានឈ្មោះនៅក្នុងបញ្ជីដែលអង្គការត្រូវយកទៅសម្លាប់ដែរ ។ មិត្តភក្តិម៉ាក់បានបបួលម៉ាក់រត់គេចខ្លួន ។ ម៉ាក់ខ្ញុំក៏សម្រេចចិត្តទៅជាមួយអ្នកទាំងនោះ ។ ម៉ាក់មិនអាចយកខ្ញុំទៅជាមួយបានទេ ពីព្រោះខ្ញុំនៅតូច ហើយធ្វើដំណើរផ្លូវឆ្ងាយតាមផ្លូវពោរពេញដោយគ្រោះថ្នាក់ ហើយគ្មានអ្នកណាដឹងថាដំណើរទៅនេះស្លាប់ឬក៏រស់ទេ ។ ម៉ាក់បានជួបបងស្រីម្នាក់ឈ្មោះ ស៊ិន ស៊ីយ៉ែម ដែលប្អូនរបស់គាត់គឺជាកូនសិស្សរបស់ម៉ាក់កាលពីមុន ។ ម៉ាក់បានយកខ្ញុំទៅផ្ញើឲ្យ បងយ៉ែម ជួយថែរក្សាខ្ញុំជំនួសគាត់ ។ ម៉ាក់ផ្តាំ ហើយផ្តាំទៀតថាកុំឲ្យប្តូរឈ្មោះខ្ញុំឲ្យសោះ បើគាត់មានសំណាងបាននៅរស់ គាត់នឹងវិលត្រឡប់មករកខ្ញុំវិញ ។ ពេលដែលគាត់ចេញទៅ ខ្ញុំកំពុងតែដេកលក់ ។ បងយ៉ែម និយាយថា មុនពេលម៉ាក់ខ្ញុំចាកចេញ គាត់យំមើលទៅគាត់នៅតែមិនដាច់អាល័យពីខ្ញុំទេ ។ គាត់ដើរចេញទៅបានប៉ុន្មានជំហានគាត់វិលមកមើលមុខខ្ញុំវិញ ។ ម៉ាក់ធ្វើដំណើរទៅដល់ភ្នំចាក់អង្រាម ហើយក៏បាត់ខ្លួនតាំងពីពេលនោះរហូត ។

ក្រោយពីម៉ាក់ខ្ញុំបាត់ខ្លួន អង្គការចោទប្រកាន់ថាខ្ញុំគឺជាកូនខ្មាំង ។ បងយ៉ែម ព្យាយាមលាក់ខ្ញុំ ។ ខ្ញុំមិនអាចចេញដើរដោយសេរីទេ ។ ពេលខ្លះខ្ញុំលាក់ខ្លួននៅក្នុងបន្ទប់បិទជិត ពេលខ្លះទៀតខ្ញុំពួននៅក្រោមគ្រែ ហើយពេលយប់ ខ្ញុំលួចចេញទៅរកបាយដែលនៅជាប់បាតឆ្នាំងយកមកហូបនិងពេលខ្លះទៀតខ្ញុំដើររើសកាកឆ្អឹងប្រហុកមកហូប ។ ការរស់នៅរបស់ខ្ញុំនៅពេលនោះ គឺប្រឈមមុខនឹងការខ្វះខាតអាហារ ។ អង្គការហៅ បងយ៉ែម ទៅកសាង



ឪពុកម្តាយរបស់ ស៊ិន គីណាល់ នៅក្នុងពិធីមង្គលការក្នុងឆ្នាំ១៩៧២

ជាច្រើនដងអំពីការលាក់បំពួនខ្ញុំ ។ បងយ៉ែម ប្តូរទីកន្លែងរស់នៅពីកន្លែងមួយទៅកន្លែងមួយដើម្បីកុំឲ្យអង្គការរកខ្ញុំឃើញ ។ បងយ៉ែម បានមកធ្វើការនៅក្នុងមន្ទីរពេទ្យកំពង់ព្រះ ។ ខ្ញុំមិនដែលបានហូបឆ្អែតទេ ។ ពេលមួយនៅម៉ោងវាយជួង ហូបបបរ ខ្ញុំកាន់ចានមួយដើរទៅយកបបរ ។ ពេលត្រឡប់មកវិញ ខ្ញុំដើរឆ្លងស្ពានឈើមួយ ហើយរអិលជើងធ្លាក់ចានបបរអស់ពីចាន ។ ពេលខ្ញុំឈឺហើម បងយ៉ែម បានសុំស្រូវខ្លះយកមកលីងនិងស្ងោររំងាស់ ហើយលាយស្ករឲ្យខ្ញុំផឹកដើម្បីឲ្យបាត់ហើម ។ មានពេលមួយប្រពន្ធប្រធានសហករណ៍ឈឺពោះឆ្លងទន្លេ ។ ឆ្មប២-៣នាក់ត្រូវបានយកទៅសម្លាប់ដោយសារមិនអាចបង្កើតកូនបាន ។ ប្រធានសហករណ៍នោះបានហៅ បងយ៉ែម ឲ្យជួយបង្កើតកូន និងគំរាមថា ប្រសិនបើបង្កើតកូនមិនបានទេ បងយ៉ែម នឹងត្រូវស្លាប់ ។ បងយ៉ែម បានកាច់មែកសង្កែធ្វើជាធូប រួចអុជបន់ស្រន់ដើម្បីសុំឲ្យគាត់បង្កើតកូនបានសម្រេច ។ គាត់ប្រឹងប្រែងអស់ពីសមត្ថភាព រហូតដល់កូននោះកើតមកដោយសុវត្ថិភាពទាំងម្តាយទាំងកូន ។ ប្រធានសហ-ករណ៍រូបនោះបានអរគុណដល់ បងយ៉ែម ហើយបានឲ្យស្ករដល់គាត់ជារង្វាន់ ។

បងយ៉ែម ចិញ្ចឹមខ្ញុំដោយប្តូរត្រកូលខ្ញុំដាក់តាមត្រកូលរបស់គាត់វិញ ដើម្បីកុំឲ្យអង្គការរកឃើញ ។ ក្នុងឆ្នាំ១៩៧៨ ខ្ញុំបានមករស់នៅវត្តកណ្តាល ហើយបន្តមករស់នៅម្តុំវត្តកំពង់ព្រះ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានរស់នៅជាមួយបងចិញ្ចឹមរបស់ខ្ញុំនៅខេត្តបាត់ដំបង ។ នៅឆ្នាំ១៩៩៣ ខ្ញុំបានជួបអ៊ំពីរនាក់ត្រូវជាបងបង្កើតរបស់ប៉ាខ្ញុំម្នាក់រស់នៅខេត្តពោធិសាត់ និងម្នាក់ទៀតរស់នៅម្តុំព្រែកតាអុង ។ ចំណែកបងប្អូនខាងម្តាយរបស់ខ្ញុំរស់នៅខេត្តសៀមរាប ។ រូបថតមួយនេះគឺជារូបរៀបការ

ប៉ាម៉ាក់របស់ខ្ញុំក្នុងពិធីរៀបមង្គលការនៅទីក្រុងភ្នំពេញ ។ រូបថតនេះគឺអីរបស់ខ្ញុំជាអ្នករក្សាទុកដោយប្រកថង់ហើយកប់ទុកនៅក្នុងដី ។ ក្រោយពេលរបបខ្មែរក្រហមត្រូវបានបញ្ចប់ គាត់ប្រគល់រូបនេះទុកឲ្យខ្ញុំ ។ រហូតមកដល់សព្វថ្ងៃ ខ្ញុំនៅតែទន្ទឹងរង់ចាំមើលផ្លូវឪពុកម្តាយខ្ញុំជានិច្ច ជាពិសេសខ្ញុំរង់ចាំម៉ាក់របស់ខ្ញុំមកទទួលយកខ្ញុំទៅវិញ ។ ខ្ញុំនៅតែមានសង្ឃឹមថា ម៉ាក់ខ្ញុំនៅមានជីវិតនៅឡើយ ។ ◆◆◆

## ភិន រដ្ឋា អតីតសិស្ស

រូបថតខ្មៅពណ៌ក្រហមប្រិញៗពីរសន្លឹកដែល ភិន រដ្ឋា យកមកបង្ហាញក្រុមស្រាវជ្រាវ គឺជារូបថតរបស់ឪពុកម្តាយគាត់ រូបថតគាត់ និងរូបប្អូនស្រីរបស់គាត់ឈ្មោះ ភិន សុខដាណ្ណា ។ រូបថតមួយសន្លឹករបស់ឪពុកម្តាយគាត់ គឺថតនៅក្នុងពេលរៀបការ ដែលកាលណោះឪពុកគាត់មានអាយុ២២ឆ្នាំនិងម្តាយគាត់អាយុ ១៦ឆ្នាំ ។ ចំណែករូបថតមួយសន្លឹកទៀត គឺជារូបថតរបស់ រដ្ឋា និង សុខដាណ្ណា ថតនៅក្នុងឆ្នាំ១៩៧០ ក្នុងពិធីរៀបការសាច់ញាតិ ។ រូបថត២សន្លឹកនេះ គឺយាយខាងម្តាយរបស់ រដ្ឋា ជាអ្នករក្សាទុក ។ យាយរបស់គាត់ឈ្មោះ សៅ ឃឹម លាក់ទុកបានតែ ២សន្លឹកនេះទេ ចំណែករូបថតផ្សេងៗទៀត មានដូចជារូបថតជីតានិងរូបថតប៉ាម៉ាក់របស់គាត់ត្រូវ ឃឹម ដុតចោលជាមួយឯកសារផ្សេងៗ ពីព្រោះមានប្រជាជនមូលដ្ឋានលួចខ្សឹបប្រាប់គាត់ថា កុំទុករបស់ទាំងនេះអី វាអាចនាំគ្រោះថ្នាក់ដល់ជីវិត ។ នៅក្នុងរបបខ្មែរក្រហមមានឈ្លបមកឆែកឆេរផ្ទះរបស់ រដ្ឋា ដែរ ប៉ុន្តែឈ្លបទាំងនោះមិនបានយករូបថតនេះទេ គឺយកតែគ្រឿងអលង្ការដែលមានបន្តិចបន្តួចនៅក្នុងផ្ទះប៉ុណ្ណោះ ។ រដ្ឋា បានរៀបរាប់ពីប្រវត្តិរឿងរ៉ាវគាត់ថា÷

ភ្នែករបស់ខ្ញុំងងឹតដោយសារតែនៅក្នុងរបបខ្មែរក្រហម ឈ្លបយកវិពាត់វាយខ្ញុំ ហើយចុងវិពាត់នោះវាត់ត្រូវភ្នែកខ្ញុំ ។ ខ្ញុំជាអ្នកនៅស្រុកគិរីវង្ស ខេត្តតាកែវ ។ នៅក្នុងរបប លន់ នល់ ក្រុមគ្រួសារខ្ញុំភៀសខ្លួនទៅរស់នៅប្រទេសវៀតណាមដើម្បីគេចពីសង្គ្រាមដែលយាយីភូមិរបស់ខ្ញុំ ។ ក្រោយមក អាជ្ញាធរវៀត-ណាមបានបញ្ជូនយើងត្រឡប់មកវិញ ។ យើងរស់នៅក្នុងអគារមួយក្បែរមាត់ទន្លេក្នុងទីក្រុងភ្នំពេញ ។ នៅក្នុងអគារមានប្រជា-ជនជាច្រើនភៀសខ្លួនមកពីខេត្តព្រៃវែងនិងស្វាយរៀង ។ ការរស់នៅរបស់យើងគឺពឹងផ្អែកទៅលើជំនួយពីអង្គការកាកបាទក្រហម ។ អំណោយទាំងនោះមាន អង្ករ ត្រីងៀត ប៊ីចេង សាប៊ូ ស្ករស ទឹកដោះគោ គ្រែដេក មុង ភួយ កន្ទេល ជាដើម ។ ម៉ាក់របស់ខ្ញុំឆ្លាតណាស់ ។ គាត់អាច និយាយភាសាបារាំងបានល្អ ។ ពេលដែលក្រុមការងារកាកបាទក្រហមមកម្តងៗ ម៉ាក់របស់ខ្ញុំ



ឪពុកម្តាយរបស់ ភិន រដ្ឋា ថតក្នុងទសវត្សរ៍ឆ្នាំ១៩៦០

និយាយភាសាបារាំងជាមួយជនជាតិបរទេសទាំងនោះ ។

ប៉ារបស់ខ្ញុំគឺជាប៉ូលិស ។ បន្ទាយរបស់គាត់នៅឃុំកំបូល ។ នៅឆ្នាំ១៩៧៤ ដោយគាត់ឃើញសភាពការណ៍កាន់តែជ្រួលច្របល់ គាត់ធ្វើពុតជាជាឆ្កួតដើម្បីគេចវេះពីប៉ូលិស ហើយបានមកនៅផ្ទះជួបជុំជាមួយពួកខ្ញុំវិញ ។ ចាប់តាំងពីគាត់ធ្វើជាឆ្កួត ប្រធានរបស់គាត់ បានអនុញ្ញាតឲ្យគាត់ឈប់ពីការងារប៉ូលិស ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឮគ្រាប់កាំភ្លើងផ្ទាំងចេញពីម៉ុំអរិយក្សត្រ ។ ពេលនោះ កងទ័ពខ្មែរក្រហមបានចូលដល់អគារដែលយើងរស់នៅ ហើយស្រែកប្រកាសថា «សូមបងប្អូនចាកចេញពីទីក្រុងភ្នំពេញរយៈពេល៣ថ្ងៃសិនពីព្រោះ

អង្គការមានបំណងរៀបចំទីក្រុងភ្នំពេញឲ្យបានស្អាតសូមបងប្អូនកុំភ័យបារម្ភអ្វីឲ្យសោះ» ។ ពេលនោះក្រុមគ្រួសារខ្ញុំបានរៀបចំរបស់របរបន្តិចបន្តួចដើម្បីធ្វើដំណើរចាកចេញពីទីក្រុង ។ នៅតាមផ្លូវមានមនុស្សកកកុញធ្វើដំណើរប្រជ្រៀតគ្នា ។ ខ្ញុំនិងបងស្រីខ្ញុំចងដៃជាប់គ្នា ព្រោះខ្លាចបែកគ្នា ។ ខ្ញុំឃើញសាកសពទាហាននិងប្រជាជនដេកពាសពេញផ្លូវ ។ យើងបានធ្វើដំណើរទៅដល់វត្តនិរោធ ។ គ្រួសារខ្ញុំស្នាក់នៅវត្តនិរោធរយៈពេល៣ថ្ងៃរង់ចាំអង្គការហៅឲ្យវិលចូលទីក្រុងភ្នំពេញវិញ ។ នៅយប់ថ្ងៃទី៣ ខ្ញុំឮស្នូរកាំភ្លើងនៅក្បែរកន្លែងដែលយើងដេក ។ ព្រឹកព្រលឹមឡើង ខ្ញុំឃើញក្រុមគ្រួសារមួយស្លាប់នៅក្បែររបងវត្ត ។ មើលទៅគ្រួសារនោះទំនងជាមានទ្រព្យសម្បត្តិច្រើន ។ ឃើញសភាពការណ៍បែបនេះ យើងធ្វើដំណើរចាកចេញពីវត្ត ហើយបន្តដំណើរទៅដល់ភូមិអន្សារខេត្តតាកែវ ។ គ្រួសារខ្ញុំជម្លៀសទៅជាច្រើនកន្លែង ប៉ុន្តែមិនបានទៅដល់ស្រុកកំណើតខ្ញុំទេ ។ ខ្ញុំបន្តដំណើរទៅដល់ភូមិតាម៉េងស្រុកគិរីវង្ស ។ នៅទីនោះ អង្គការបែកផ្ទះមួយខ្នងក្នុងមួយគ្រួសារ ។ ផ្ទះនោះធ្វើពីដីឥដ្ឋលាយជាមួយចំបើង ។ ក្រុមគ្រួសារខ្ញុំរស់នៅដោយពឹងលើអង្ករបន្តិចបន្តួចដែលយកមកតាមខ្លួននិងដើររកក្តាម-ខ្យងធ្វើជាម្ហូប ។ អង្គប្រជុំនិយាយអំពីគុណបំណាច់របស់អង្គការបដិវត្តន៍ដែលបានរំដោះប្រជាជនឲ្យមានសេរីភាពពីវណ្ណៈសក្តិភូមិ ។ បន្ទាប់ពីប្រជុំចប់ប្រធានភូមិបានប្រកាសប្រាប់ថា «ខោអាវពណ៌ទាំងអស់ត្រូវជ្រលក់ភក់ឲ្យទៅជាពណ៌ខ្មៅ» ។ ពេលនោះមានអ្នកមូលដ្ឋានម្នាក់បានខ្សឹបប្រាប់ជីតាខ្ញុំថា បើជាអង្គការឲ្យធ្វើអ្វីត្រូវតែធ្វើតាមកុំប្រកែកឲ្យសោះ ។

នៅពេលអង្គការចាត់តាំងឲ្យហូបរួម ខ្ញុំមិនអាចរកក្តាម-ខ្យងបានទៀតទេ ។ អាហារទាំងអស់គឺជារបស់អង្គការ ។ ក្នុងមួយពេលខ្ញុំទទួលបានតែបបរមួយវែកប៉ុណ្ណោះ ។ ពេលខ្លះហូបបាយលាយជាមួយពោតនិងដំឡូង ។ នៅរដូវប្រមូលផលស្រូវទើបយើងបានហូបបាយរយៈពេលមួយខែ ។ អង្គការតែងតែហៅប្រជុំទិតៀនអំពីការហូបចុក ។ អង្គការទិតៀនថា បើអ្នកណាហ៊ានរកក្តាមខ្យង ឬលួចបេះបន្លែហូប អង្គការនឹងធ្វើទារុណកម្ម ។ ដោយសារខ្ញុំឃ្លានពេក ខ្ញុំខស្សរាហ៍លួចបេះបន្លែហូបណាស់ ។ ខ្ញុំលួចជាច្រើនដង ។ ខ្ញុំលួចជីកមើមត្រាវបានទាំងថ្នក់ៗ ។ បន្លែទាំងនោះដាំនៅក្នុងដីផ្ទះដែលក្រុមគ្រួសារខ្ញុំរស់នៅ ប៉ុន្តែខ្ញុំគ្មានសិទ្ធិហូបផលដែលដាំបានទេ ។

ឪពុកម្តាយខ្ញុំជាន់ដីឥដ្ឋធ្វើក្បឿង ចំណែកខ្ញុំទៅធ្វើការនៅកងចល័តកុមារដែលស្ថិតនៅឆ្ងាយពីភូមិ ។ រយៈពេលពី៣-៤ខែទើបអង្គការអនុញ្ញាតឲ្យខ្ញុំមកលេងផ្ទះម្តង ។ ការងាររបស់ខ្ញុំគឺសែងកណ្តាប់នៅក្នុងស្រែ ។ កុមារដែលមានមាឌធំជាងខ្ញុំតែងតែធ្វើបាបខ្ញុំជារឿយៗ ។ ពេលខ្លះ ខ្ញុំកំពុងដើរនៅលើភ្លឺស្រែ គេច្រានខ្ញុំទម្លាក់ទឹកស្រែឲ្យឈ្លើងទាម ខ្ញុំខ្លាចណាស់គ្មានអ្នកណាជួយខ្ញុំទេ ។ ពេលខ្លះខ្ញុំមិនចង់ចុះធ្វើការងារក្នុងស្រែទេ ពីព្រោះខ្ញុំខ្លាចឈ្លើងទាម ។ ប្រធានកងនៅទីនោះតែងតែវាយធ្វើបាបខ្ញុំ ។ ខ្ញុំបានរត់ទៅផ្ទះជាច្រើនដងដើម្បីឲ្យឪពុកម្តាយខ្ញុំជួយ ប៉ុន្តែគ្មានអ្នកណាអាចជួយខ្ញុំបានទេ ។ រាល់លើកឈ្លបមកតាមយកខ្ញុំត្រឡប់ទៅវិញ ហើយវាយធ្វើបាបខ្ញុំ ។ បន្ទាប់មក ខ្ញុំបានរត់ទៅពួននៅក្នុងព្រៃអស់រយៈពេល៦ខែ ។ នៅក្នុងព្រៃខ្ញុំរស់នៅដោយយកដើមឈើធ្វើជាជម្រករបស់ខ្ញុំ ហើយខ្ញុំបេះស្លឹកនិងផ្លែឈើព្រៃធ្វើជាអាហារ ។ នៅពេលយប់ខ្ញុំចេញពីព្រៃមកលួចយកភ្លើងដែលអ្នកភូមិរំងាស់ស្ករទៅដុតបំភ្លឺនិងដុតកូនក្អាត់ហូប ។ ការរស់នៅក្នុងព្រៃលំបាក



(ពីឆ្វេងទៅស្តាំ) ភិន សុខជាណ្ណា និង ភិន វណ្ណា ថតក្នុងឆ្នាំ១៩៧០

វេទនាណាស់ ម្យ៉ាងទៀតខ្ញុំមានតែម្នាក់ឯងគ្មានសម្លៀកបំពាក់ផ្លាស់ប្តូរគ្មានញាតិមិត្តបងប្អូន ។ ដោយមិនអាចទ្រាំបានខ្ញុំរត់មកនៅផ្ទះខ្ញុំវិញ ។ ឪពុកម្តាយនិងជីតារបស់ខ្ញុំបានបញ្ជូនខ្ញុំឲ្យត្រឡប់ទៅកងចល័តវិញ ពីព្រោះបើខ្ញុំនៅជាមួយគាត់ យើងពិតជាមានគ្រោះថ្នាក់ទាំងអស់គ្នា ។ ពេលទៅដល់កងវិញ ប្រធានកងបានធ្វើទារុណកម្មនិងព្រមានខ្ញុំកុំឲ្យរត់ទៀត ។

មានពេលមួយ ខ្ញុំរែកទឹកស្រោចបន្លែស្ពៃហត់ពេក ខ្ញុំអង្គុយសម្រាក ហើយសម្លឹងមើលទៅផ្លែក្រូចឆ្មារដែលនៅលើដើម ។ ពេលនោះកូនប្រជាជនមូលដ្ឋានម្នាក់បានប្រាប់ខ្ញុំថា បើខ្ញុំឃ្លានបេះក្រូចឆ្មារមួយហូបទៅ ។ ខ្ញុំបេះមួយយកមកហូប ហើយជូតមាត់យ៉ាងស្អាតនិងយកសំបកកប់ដីដើម្បីបំបាត់ភ័ស្តុតាង ។ មួយសន្ទុះក្រោយមក គណៈកងឈ្មោះ តាកេះ ចោទប្រកាន់ខ្ញុំថា ខ្ញុំលួចពងមាន់គាត់កាលពីយប់មិញ ហើយបញ្ជាឲ្យឈ្លបយកក្រមារឹតកខ្ញុំលៀនអណ្តាតស្ទើរតែដាច់ដង្ហើមស្លាប់ ។ កូនប្រជាជនមូលដ្ឋាននោះជួយអង្វរគណៈកងកុំឲ្យធ្វើបាបខ្ញុំ ។ តាកេះ ក៏ដោះលែងខ្ញុំ ។

ក្រោយមក អង្គការចាត់តាំងឲ្យខ្ញុំរែកអាចម៍ជ្រូក ដោយមានប្រធានកងដើរតាមពីខាងក្រោយ ។ ដោយអស់កម្លាំងពេក ខ្ញុំទន់ជង្គង់ដួល បណ្តាលឲ្យកំពប់អាចម៍ជ្រូកចេញពីអម្រែក ។ ប្រធានកងយករំពាត់ខ្សែគោមកវាយខ្ញុំ ហើយរំពាត់នោះវាត់ត្រូវភ្នែករបស់ខ្ញុំ ។ ចាប់ពីពេលនោះមក ខ្ញុំចេះតែហៀរទឹកភ្នែក ហើយភ្នែកខ្ញុំឡើងក្រហមពីមួយថ្ងៃទៅមួយថ្ងៃ ។ គ្មានពេទ្យសម្រាប់ព្យាបាលភ្នែកទេ ។ ចំណែកឪពុកម្តាយខ្ញុំមិនអាចមើលថែរក្សាខ្ញុំបានទេ ពីព្រោះកងរបស់ខ្ញុំនៅឆ្ងាយពីគាត់ ។ ខ្ញុំបានសុំប្រធានកងដើម្បីទៅជួបតាខ្ញុំនៅផ្ទះ ។ តាខ្ញុំប្រាប់ឲ្យខ្ញុំយកក្រមាជ្ជុំ ហើយដាក់ស្អំនៅត្រង់កន្ទែងឈើ ប៉ុន្តែកាលនោះដោយសារខ្ញុំនៅក្មេង ហើយមិនបានយកចិត្តទុកដាក់ស្អំភ្នែកឲ្យបានជាប់លាប់ទើបភ្នែករបស់ខ្ញុំមានសភាពកាន់តែធ្ងន់ធ្ងរឡើងៗ រហូតដល់មើលអ្វីលែងច្បាស់ ។

ប្រជាជនមូលដ្ឋាន តែងតែមកសួរខ្ញុំអំពីប្រវត្តិរូបក្រុមគ្រួសារខ្ញុំ ប៉ុន្តែខ្ញុំលាក់មិនប្រាប់តាមត្រង់ទេ ។ ខ្ញុំប្រាប់ថា ជីតារបស់ខ្ញុំជាអ្នកស្រែ ឪពុកខ្ញុំជាអ្នកធាក់ស៊ីក្លូ ម្តាយខ្ញុំជាអ្នកលក់ត្រកួន ។ មនុស្សបាត់ពីភូមិជារៀងរាល់យប់ ។ ពេលខ្លះខ្ញុំ ឃើញសត្វឆ្កែពាំជើងមនុស្សយកទៅស៊ី ។ អង្គការសួរថា «តើមានអ្នកណាចង់ត្រឡប់ទៅស្រុកកំណើតវិញទេ?» មានអ្នកជិតខាងខ្ញុំមួយគ្រួសារបានឆ្លើយព្រមគ្នាថា ចង់ត្រឡប់ទៅវិញ ។ ក្រោយមក គ្រួសារនោះក៏បាត់ខ្លួនរហូត ។ មានអ្នកភូមិខ្សឹបខ្សៀវគ្នាថាអ្នកទាំងនោះត្រូវអង្គការយកទៅសម្លាប់អស់ហើយ ។

នៅមុនបែកឆ្នាំ១៩៧៩ ខ្ញុំឮស្នូរកាំភ្លើងបាញ់គ្នាចេញពីទីរួមខេត្តតាកែវ ។ កម្មាភិបាលនៅទីនោះខ្សឹបខ្សៀវគ្នា ខ្ញុំគិតថាប្រហែលជាមានសង្គ្រាមកើតឡើងម្តងទៀតហើយ ។ ព្រលឹមឡើង កុមារទាំងអស់ចេញទៅប្រូតស្រូវដូចធម្មតា ។ ពេលនោះខ្ញុំមិនបានចេញទៅធ្វើការទេ ។ ខ្ញុំបានរត់សំដៅមកផ្ទះមករកឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំ ។ នៅវេលាម៉ោង១១យប់ ខ្ញុំឃើញមានរថក្រោះព្រោងព្រាតនៅតាមផ្លូវ ។ ពេលនោះ ក្រុមគ្រួសារខ្ញុំត្រូវបានខ្មែរក្រហមកៀរទៅដល់ភ្នំក្រឡើតនៅជិតព្រំដែនកម្ពុជា-ថៃ ។ ពួកខ្ញុំរស់នៅទីនោះដោយគ្មានអាហារបរិភោគនិងទឹកផឹក ។ ក្រុមគ្រួសារខ្ញុំព្យាយាមរត់គេចចេញពីខ្មែរក្រហមមកជួបកងទ័ពវៀតណាម ហើយបានវិលមកស្រុកកំណើតវិញ ។

រហូតមកដល់សព្វថ្ងៃ ខ្ញុំនៅតែមិនអាចបំភ្លេចបាននូវរឿងរ៉ាវដែលខ្ញុំបានឆ្លងកាត់របបខ្មែរក្រហម ជាពិសេសរបបនោះបានធ្វើឲ្យភ្នែករបស់ខ្ញុំមើលមិនច្បាស់រហូតដល់សព្វថ្ងៃ ។ ខ្ញុំសូមសំណូមពរឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ៗ ពីព្រោះខ្ញុំចង់ឲ្យតុលាការរកខុសរកត្រូវឲ្យប្រជាជនដែលរងទុក្ខលំបាកនៅក្នុងសម័យនោះ ។ ◆◆◆

## ស៊ីវ សុខគា អតីតអ្នកលក់ដូរ

រូបថត៣សន្លឹកដែលសល់ពីរបបខ្មែរក្រហម គឺជារូបថតរបស់ ស៊ីវ សុខគា និងប្រពន្ធដែលថតក្នុងពេលរៀបការ ។ នៅពេលជម្លៀសឆ្នាំ១៩៧៥ ប្រពន្ធរបស់គាត់យករូបថតមួយសន្លឹកនេះតាមខ្លួនដោយដាក់នៅក្នុងកន្ត្រកខោអាវទើបអាចរក្សារហូតដល់សព្វថ្ងៃ ។ ចំណែករូបថតពីរសន្លឹកទៀត គឺជារូបថតដែលថតនៅក្រោយពេលរៀបការហើយ ។ ក្រោយពីរបបខ្មែរក្រហមត្រូវបានបញ្ចប់ សុខគា បានព្យាយាមស្វែងរករូបថតរបស់គាត់ពីសាច់ញាតិមកវិញ ដើម្បីទុកជាចំណងដៃនៃការរៀបការរបស់គាត់ កាលពីទសវត្សរ៍ឆ្នាំ១៩៦០ ។ រូបថតនោះគាត់ផ្តិតចែក

បងប្អូនទុកជាអនុស្សាវរីយ៍ ។ ពាក់ព័ន្ធនឹងបញ្ហារូបថត ស៊ីវ សុខគា បានរៀបរាប់ពីប្រវត្តិរបស់គាត់ថា÷

ខ្ញុំនិងប្រពន្ធរបស់ខ្ញុំគឺជាកូនខ្មែរកាត់ចិន ប៉ុន្តែយើងទាំងពីរនាក់មិនចេះនិយាយភាសាចិនទេ ។ នៅក្នុងរបបខ្មែរក្រហមប្រជាជនមូលដ្ឋានហៅខ្ញុំថាអាចិនៗ ពីព្រោះអ្នកទាំងនោះឃើញខ្ញុំសម្បុរស ។

នៅមុនពេលរៀបការយើងទាំងពីរនាក់មិនបានស្គាល់គ្នាពីមុនមកទេ ប៉ុន្តែយើងត្រូវជាបងប្អូនជីទួតមួយនឹងគ្នាយើងទើបតែស្គាល់គ្នានៅថ្ងៃរៀបការប៉ុណ្ណោះ ។ ការរៀបការពេលនោះ


ស៊ីវ សុខគា និង ភរិយា ថតក្នុងពេលរៀបការ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០

គឺត្រូវស្តាប់តាមបង្គាប់ឪពុកម្តាយទាំងសងខាង ។ ខ្ញុំជាកូនមិនអាចប្រកែកបុតវ៉ាអ៊ីបានឡើយ ។ ពិធីរៀបការរបស់ខ្ញុំគឺធ្វើតាមប្រពៃណីចិនផងនិងខ្មែរផងនៅផ្ទះប្រពន្ធរបស់ខ្ញុំនៅភូមិញ្ញេ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ បន្ទាប់មកទើបមកធ្វើពិធីកាត់ចំណងដៃនៅផ្ទះរបស់ខ្ញុំនៅព្រែកលៀប ។

នៅពេលខ្ញុំរៀបការគ្មានសម្លៀកបំពាក់ល្អនិងទាន់សម័យសម្រាប់ស្លៀកពាក់ក្នុងពិធីទេ ។ ម្យ៉ាងវិញទៀតឪពុកម្តាយរបស់ខ្ញុំគឺជាមនុស្សបូរាណ ដូច្នេះខ្ញុំត្រូវស្លៀកពាក់តាមរបៀបបុរាណ ។ នៅថ្ងៃនោះខ្ញុំស្លៀកពាក់តែខោអាវមួយកំប្លេហូតដល់ចប់ពិធី ចំណែកប្រពន្ធរបស់ខ្ញុំស្លៀកខោអាវ២កំប្លេ ។ ខោអាវដែលប្រពន្ធខ្ញុំស្លៀកហៅថា «ឈិនហ៊ូ» ជាសម្លៀកបំពាក់តាមបែបប្រពៃណីចិន ដែលប្រើសម្រាប់តែក្នុងពិធីរៀបការនិងពិធីបុណ្យទានធំៗប៉ុណ្ណោះ ។ ឈុតនេះមានពណ៌ក្រហមនិងពណ៌ផ្កាឈូក ។ ខោដែលប្រពន្ធខ្ញុំស្លៀកគឺជាខោដាក់កៅស៊ូ ។ ពេលខ្លះកូនក្រមុំសៀតផ្កាមួយទងនៅត្រចៀកនិងពេលខ្លះពាក់កម្រងផ្កានៅលើក្បាល ។ កន្សែងដៃដែលប្រពន្ធខ្ញុំកាន់គឺសម្រាប់ខ្ចប់លុយ ។ នៅសម័យនោះប្រជាជនខ្មែរមិននិយមប្រើកាបូបដាក់លុយទេ គឺប្រើតែកន្សែងដៃ ចំណែករោងការមានតែក្រណាត់តង់សម្រាប់ប្រក់និងចងលំអរដោយធាងដូងនៅក្លោងទ្វារ ។

កន្សែងដៃនោះ គឺប្រពន្ធខ្ញុំចាក់ដោយខ្លួនឯង ។ ប្រពន្ធខ្ញុំចូលចិត្តចាក់និងប៉ាក់ផ្កាណាស់ ។ គាត់ចេះចាក់ក្បាច់ជាច្រើន ។ គាត់ចេះចាក់ស្រោមខ្នើយទៀតផង ។ ប្តីប្រពន្ធខ្ញុំស្រឡាញ់គ្នាណាស់ ។ ក្រោយពេលរៀបការហើយ ជីវភាពគ្រួសារខ្ញុំមានធូរធារណាស់ ។ ប្រពន្ធខ្ញុំនៅផ្ទះមើលថែរក្សាកូន ។ ចំណែកខ្ញុំប្រកបរបរទិញ-លក់ស្ករពាង ។ ក្នុង១ឆ្នាំៗខ្ញុំលក់ស្ករបានរាប់រយពាងនិងបានប្រាក់កម្រៃច្រើន ។

នៅមុនពេលរៀបការ ខ្ញុំរៀនបានត្រឹមថ្នាក់ឌីប្លូម ។ ក្រោយពីប្រឡងធ្លាក់ ខ្ញុំឈប់រៀនហើយមកជួយធ្វើការនៅហាងកាត់ដេរបងរបស់ខ្ញុំ ។ ខ្ញុំធ្វើការនៅទីនោះបណ្តើរ ខ្ញុំហាត់រៀនកាត់ដេរសម្លៀកបំពាក់បណ្តើរ ។ បន្ទាប់មកខ្ញុំអាចកាត់ដេរសម្លៀកបំពាក់មនុស្សប្រុសបាន ហើយមកជួយការងារឪពុកម្តាយលក់ដូរចាប់ហួយនិងដឹកជញ្ជូនស្រូវយកទៅលក់នៅតាមភូមិ ។

ខ្ញុំប្តូរផ្ទះជាច្រើនដង ។ ដំបូងខ្ញុំរស់នៅផ្ទះខាងប្រពន្ធរបស់ខ្ញុំនៅខេត្តកំពង់ស្ពឺ ។ បន្ទាប់មក ខ្ញុំមករស់នៅទីក្រុងភ្នំពេញម្តុំពេទ្យលោកសង្ឃ និងចុងក្រោយខ្ញុំមករស់នៅព្រែកលៀប ។ ពេលខ្ញុំប្តូរផ្ទះមករស់នៅម្តុំពេទ្យលោកសង្ឃ ខ្ញុំសន្សំលុយបានច្រើនហើយទិញបានរថយន្តមួយសម្រាប់រត់តាក់ស៊ីដឹកអ្នកដំណើរភ្នំពេញ-បាត់ដំបង ។

ពេលប្រទេសជាតិកាន់តែមានភាពជ្រួលច្របល់ខ្លាំងខ្ញុំបើកឡានទៅដល់ត្រឹមសាលាលេខ៥ ខ្ញុំក៏ឈប់ឡាន

ចាំឲ្យឡានផ្សេងទៀតដើម្បីធ្វើដំណើររួមគ្នា ហើយមានឡានទាហានបើកឡាននាំមុខទៀតផង ដើម្បីការពារសុវត្ថិភាព ពីព្រោះពេលនោះខ្មែរក្រហមវាយឆ្មក់នៅតាមផ្លូវជាហូរហែ ។ អ្នកដំណើរភាគច្រើនគឺជាអ្នករត់ពន្ធទំនិញ ។ ក្រោយមក ដោយសារប្រថុយគ្រោះថ្នាក់ខ្លាំងពេក និងដោយសារខ្មែរក្រហមវាយផ្តាច់ផ្លូវ ខ្ញុំបើកឡានតាក់ស៊ីពីភ្នំពេញទៅត្រឹមសាលាលេខ៥ ។ ដោយគ្រោះថ្នាក់កាន់តែខ្លាំងឡើងៗ ខ្ញុំក៏សម្រេចចិត្តឈប់រត់តាក់ស៊ី ហើយទិញរថយន្តឡាំប្រេតាមួយសម្រាប់ដឹកជញ្ជូនអ្នកដំណើរនៅក្នុងទីក្រុងភ្នំពេញ ។ ខ្ញុំបើកឡាំប្រេតាពីផ្សារអូរឫស្សី ផ្សារថ្មី ទៅដល់ចោមចៅនិងជម្ពូវ័ន ។


ស៊ីវ សុខគា និងភរិយា ថតក្រោយពេលរៀបការក្នុងទសវត្សរ៍ឆ្នាំ១៩៦០

មានពេលមួយ ទាហានលន់នល់ចាប់ក្រុមគ្រួសារខ្ញុំដាក់ឃុំឃាំងនៅមន្ទីរក្បែរពោធិចិនតុងអស់រយៈពេលមួយយប់ ។ មូលហេតុដែលធ្វើឲ្យកើតរឿងនេះដោយសារប្អូនជីដូនមួយរបស់ខ្ញុំដែលជួលផ្ទះ នៅក្បែរផ្ទះខ្ញុំម្តុំពេទ្យលោកសង្ឃ ។ ពេលនោះនៅក្នុងផ្ទះវាអុជចង្កៀងប្រេងកាត ស្របពេលជាមួយនោះ វាចាក់ប្រេងសាំងដាក់ឡានដែរ ។ ដោយសារពេលនោះមានខ្យល់ខ្លាំងធ្វើឲ្យឆាបឆេះសាំង ហើយរាលដាលធ្វើឲ្យឆេះភ្លើងចង្កៀងផ្ទះវា និងផ្ទះអ្នកជិតខាងរួមទាំងផ្ទះរបស់ខ្ញុំផង ទាំងអស់ឆេះអស់១៧ខ្នង ។ ពេលមានភ្លើងឆេះ ផ្ទះរបស់ខ្ញុំត្រូវឆេះខ្ទេចខ្ទីអស់រួមទាំងទ្រព្យសម្បត្តិរបស់ខ្ញុំ ។ ខ្ញុំនៅសល់តែឡាំប្រេតានិងរបស់របរបន្តិចបន្តួចប៉ុណ្ណោះ ហើយនៅសល់លុយដែលនៅជាប់នឹងហោប៉ៅប៉ុណ្ណោះ ខ្ញុំបានយកលុយនោះមកទិញស្បែកជើងពាក់ ពីព្រោះពួកខ្ញុំរត់ចេញមកអត់បានពាក់ស្បែកជើងទេ ។ ប្អូនខ្ញុំស្លាប់អស់កូនម្នាក់ ។ ទាហានលន់នល់មានការសង្ស័យ ហើយចាប់ខ្ញុំព្រមទាំងប្រពន្ធនិងកូនរបស់ខ្ញុំទៅដាក់ឃុំឃាំងជាបណ្ដោះអាសន្ន ។ មួយយប់ក្រោយមក បងប្អូនរបស់ខ្ញុំបានទៅជួយដោះលែងក្រុមគ្រួសារខ្ញុំឲ្យចេញពីការឃុំឃាំងវិញ ។ បន្ទាប់មកមានកាសែតមួយបានចុះផ្សាយថា «ខ្ញុំឈ្មោះ ឡៅ សុខគា ជាជនជាតិចិន បានធ្វើវិច្ឆេទកម្មដុតផ្ទះដើម្បីឲ្យខ្ញុំងចូល» ។

ក្រោយពីមានរឿងនេះកើតឡើង ក្រុមគ្រួសារខ្ញុំបានផ្លាស់មកនៅផ្ទះខ្ញុំនៅព្រែកលៀប ហើយខ្ញុំប្រកបរបររត់ឡាំប្រេតាដដែល ។ ពេលនោះស្រុកកំណើតខាងប្រពន្ធរបស់ខ្ញុំត្រូវបានកាន់កាប់ដោយកងទ័ពរំដោះ ។ ខ្ញុំមានបំណងចូលទៅយករបស់របរខ្លះ និងហៅឪពុកម្ដាយក្មេកខ្ញុំមករស់នៅជាមួយខ្ញុំ ប៉ុន្តែគាត់មិនព្រមមកតាមខ្ញុំទេ ពីព្រោះពួកគាត់នៅស្ដាយដីធ្លីនិងទ្រព្យសម្បត្តិជាច្រើន ។ គាត់សុខចិត្តនៅចាំទីនោះរហូតដល់របបខ្មែរក្រហមដួលរលំ ។

នៅមុនរំដោះឆ្នាំ១៩៧៥ មានគ្រាប់ផ្លោងជាច្រើនធ្លាក់មកក្បែរៗផ្ទះរបស់ខ្ញុំ ។ ប្រជាជនមិនអាចធ្វើដំណើរទៅមកបាន ហើយពេលនោះខ្ញុំក៏ផ្អាកការរត់រ៉ឺម៉កដែរ ។ ខ្ញុំបានយកសម្លៀកបំពាក់រៀបការរបស់ខ្ញុំទៅផ្ញើទុកនៅបងជីដូនមួយរបស់ខ្ញុំនៅភ្នំពេញ ។ ក្រោយពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញបានកន្លះខែ ក្រុមគ្រួសារខ្ញុំត្រូវបានជម្លៀសចេញពីព្រែកលៀប ។ ខ្ញុំបានជួលទូកមួយដើម្បីឆ្លងទៅស្រុកកំណើតខាងប្រពន្ធរបស់ខ្ញុំ ប៉ុន្តែទៅមិនរួចដោយកងទ័ពខ្មែរក្រហមបានឃាត់ក្រុមគ្រួសារខ្ញុំហើយបញ្ជាឲ្យធ្វើដំណើរទៅខាងស្រុកកៀនស្វាយវិញ ។ ប្រពន្ធរបស់ខ្ញុំប្រមូលយកខោអាវបាន១កន្ត្រកនិងអង្ករបន្តិចបន្តួចសម្រាប់ហូប ។

**ក្រុមគ្រួសារខ្ញុំបានទៅរស់នៅភូមិវត្តក្រៅ ស្រុកកៀនស្វាយ**

ខេត្តកណ្តាល ។ ដំបូងឡើយខ្ញុំអាចស្លៀកសម្លៀកបំពាក់ចម្រុះពណ៌បាន ប៉ុន្តែក្រោយមកអង្គការតម្រូវឲ្យក្រុមគ្រួសារខ្ញុំស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅទាំងអស់ ។ អង្គការបានបំបែកសមាជិកគ្រួសារខ្ញុំរស់នៅដាច់ដោយឡែកពីគ្នា ។ ខ្ញុំចេះកាត់សក់និងចេះជួសជុលគ្រឿងម៉ាស៊ីន ដូច្នេះអង្គការបានចាត់តាំងឲ្យខ្ញុំកាត់សក់ឲ្យយុវជននៅក្នុងភូមិនិងជួសជុលឡាននិងម៉ាស៊ីនកាណូត ។ ខ្ញុំថែមទាំងបានជួយបង្រៀនដល់មនុស្សចាស់នៅក្នុងភូមិឲ្យចេះកាត់សក់ទៀតផង ។ ពេលខ្លះអង្គការចាត់តាំងឲ្យខ្ញុំវាស់ដីដើម្បីលើកភ្លឺស្រែ ។ ខ្ញុំវាស់ភ្លឺស្រែបានត្រង់ណាស់ ។ ប្រពន្ធរបស់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យជម្រះស្មៅនិងធ្វើស្រែ ។ ទៅដល់ទីនោះដំបូងមិនទាន់ហូបរួមនៅឡើយទេ ។ ក្រុមគ្រួសារខ្ញុំបានយកអង្ករទៅបានតែ៣តៅ ។ ប្រពន្ធខ្ញុំបានយកអង្ករខ្លះទៅដូរយកមាសមួយដុំប៉ុនមេដៃ ហើយយកមាសនោះទៅដូរបានអង្ករយ៉ាងច្រើនមកវិញ ។ ប្រពន្ធខ្ញុំដោះដូរចុះឡើងៗបានមាសផងនិងអង្ករផង ។ ខ្ញុំខឹងនឹងប្រពន្ធខ្ញុំណាស់ដែលយកអង្ករទៅដូរយកមាស ពីព្រោះខ្ញុំខ្លាចយកមាសមកហើយមិនអាចដូរយកជាអង្ករឬរបស់របរហូបចុកផ្សេងទៀតបាន ។ យើងហូបយ៉ាងសន្សំសំចៃជាទីបំផុត ។ នៅពេលហូបរួមក្នុងសហករណ៍ខ្ញុំហូបអត់ឆ្អែតទេ ។ ពេលខ្លះហូបបបរ ពេលខ្លះទៀតហូបបាយមានតែសម្លមានតែបន្លែ គ្មានសាច់ ទឹកសម្លខ្មៅគ្មានរសជាតិ ។ មានពេលមួយដោយសារកូនប្រុសរបស់ខ្ញុំមិនព្រមទៅធ្វើការនៅការដ្ឋាន ឈ្លបចាប់វាយកទៅជ្រមុជទឹក ហើយអុចបារីពីលើខ្លួនវា ព្រមទាំងដាក់សត្វអង្ក្រងឲ្យខាំវាថែមទៀត ។ ខ្ញុំបានលួងលោមឲ្យវាទៅធ្វើការវិញ ដើម្បីកុំឲ្យអង្គការធ្វើទារុណកម្ម ។

ការរស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋានគ្រួសាររបស់ខ្ញុំជួបនឹងបញ្ហាជាច្រើន ។ អ្នកនៅជិតខាងហៅខ្ញុំថា«អាចិនៗ» ពីព្រោះស្បែកនិងមុខមាត់របស់ខ្ញុំដូចកូនចៅចិន ។ ពាក្យនេះបានលេចឮដល់អង្គការ ហើយបានឲ្យខ្ញុំទៅគាស់គល់រាំងក្នុង១ថ្ងៃឲ្យបានពី២០-២៥គល់ ។ ប្រសិនបើខ្ញុំធ្វើមិនបានខ្ញុំនឹងត្រូវស្លាប់ហើយ ។ កន្លែងនោះស្ថិតនៅឆ្ងាយពីភូមិខ្ញុំកម្របានជួបមុខប្រពន្ធនិងកូនរបស់ខ្ញុំណាស់ ។ កន្លែងធ្វើការរបស់យើងនៅឆ្ងាយពីគ្នា ។ ខ្ញុំធ្វើការគ្មានពេលសម្រាករយៈពេល៣-៤ខែ ទើបខ្ញុំបានជួបមុខប្រពន្ធកូនម្តង ។ មានអ្នកភូមិលួចខ្សឹបប្រាប់ខ្ញុំថា មានប្រជាជនមូលដ្ឋាន២នាក់បានរាយការណ៍អំពីខ្ញុំ ។ ២នាក់នោះធ្លាប់បានរាយការណ៍ទៅអង្គការឲ្យយកប្រជាជននៅក្នុងភូមិទៅសម្លាប់ជាច្រើននាក់ ។

ពេលប្រពន្ធរបស់ខ្ញុំមានផ្ទៃពោះ គាត់ចាញ់កូនយ៉ាងខ្លាំង អង្គការនៅតែចាត់តាំងឲ្យគាត់ទៅកាប់ពោតនិងបកពោតដដែល ។

នៅមុនបែកឆ្នាំ១៩៧៩ អង្គការបានហៅប្រពន្ធរបស់ខ្ញុំនិងអ្នកភូមិផ្សេងទៀតដែលមានទាំងយុវជន និងយុវនារីទៅប្រជុំនៅក្នុងព្រៃនៅវេលាម៉ោង៣-៤ទៀបភ្លឺ ហើយផ្ញើទុកកូនឲ្យយាយៗមើល ។ ចំណែកខ្ញុំធ្វើការនៅការដ្ឋាន ។ ដំបូងឡើយប្រពន្ធខ្ញុំស្មានតែហៅទៅប្រជុំធម្មតា ។ លុះគាត់ឃើញឈ្លបជាច្រើនដើរខ្វាត់ខ្វែង ទើបគាត់សង្ស័យច្បាស់ជាមានរឿងមិនល្អកើតឡើង ។ ពេលអង្គុយប្រជុំ ប្រពន្ធខ្ញុំចេះតែឮស្នូរកាំភ្លើងបាញ់គ្នាកាន់តែជិតមកៗ ប៉ុន្តែឈ្លបប្រាប់ថា «កុំព្រួយបារម្ភអី គេបាញ់គ្នានៅទល់ដែនទេ» ។ បន្ទាប់មកក៏មានភាពជ្រួលច្របល់ខ្លាំង ហើយអ្នកដែលចូលរួមប្រជុំរត់បែកខ្ញែកគ្នាចេញពីអង្គប្រជុំ ។ ប្រពន្ធខ្ញុំបានរត់ទៅរកកូនខ្ញុំទម្រាំតែឃើញ ហើយពររត់កាត់គ្រាប់កាំភ្លើងស្ទើរស្លាប់ស្ទើររស់ទម្រាំតែបានជួបខ្ញុំ ។

នៅថ្ងៃបែកឆ្នាំ១៩៧៩ ខ្ញុំបានឃើញនៅលើឯកសាររបស់កម្មាភិបាលកត់ត្រាមានឈ្មោះរបស់ខ្ញុំដែរ ។ នៅលើឯកសារនោះមានសរសេរថា «ខ្ញុំគឺជាអតីតទាហាន ហើយប្រពន្ធរបស់ខ្ញុំខ្ជិលធ្វើការងារ» ។ អ្នកដែលរាយការណ៍ទៅថ្នាក់លើត្រូវបានអ្នកភូមិព្រួតគ្នាវាយសម្លាប់ចោល ហើយយកទៅកប់នៅក្រោមដើមល្មុត ។ អ្នកទាំងនោះគឺជាប្រជាជនមូលដ្ឋាន ។ ខ្ញុំមិនដែលរករឿងឈ្លោះប្រកែកជាមួយអ្នកណាទេ ប៉ុន្តែខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាមានអ្នកចង់ធ្វើបាបខ្ញុំ ។

រូបថតនេះខ្ញុំថតក្នុងពិធីមង្គលការនៅផ្ទះរបស់ខ្ញុំនៅព្រែកលៀប ។ កាលនោះគ្មានជាងថតរូបទេ គឺជាងថតយកមកពីភ្នំពេញ និងគ្មានរូបថតពណ៌ទេ មានតែរូបថតស-ខ្មៅ ។ កាលណោះខ្ញុំថតរូបបានប្រមាណជា២០-៣០សន្លឹក ។ ពេលរៀបការហើយញាតិមិត្តទាំងសងខាងបានសុំរូបថតទាំងនោះទុកជាអនុស្សាវរីយ៍ ។ រូបថតនេះខ្ញុំបានមកពីបងប្អូនខាងប្រពន្ធខ្ញុំជាអ្នករក្សាទុក ។

ក្រោយឆ្នាំ១៩៧៩ គាត់បានយកមកប្រគល់ឲ្យខ្ញុំវិញ ។ ចំណែករូបថត២សន្លឹកនេះ ពួកខ្ញុំថតនៅហាងមួយនៅក្នុងទីក្រុងភ្នំពេញ ពេលដែលខ្ញុំមានកូន២នាក់ ។ កាលនោះ ប្រពន្ធរបស់ខ្ញុំស្លៀកពាក់របៀបខ្មែរបូរាណ ។ ខោអាវដែលខ្ញុំស្លៀកថតនេះគឺជាខោអាវដែលខ្ញុំធ្លាប់ស្លៀកពាក់នៅពេលដែលខ្ញុំរៀបការ ។ ខ្ញុំស្រឡាញ់វាណាស់ ។ វាគឺជារបស់អនុស្សាវរីយ៍របស់ខ្ញុំ ហើយម្យ៉ាងទៀត បងរបស់ខ្ញុំជាអ្នកកាត់ខោអាវនេះឲ្យ ។ បងប្អូនរបស់ខ្ញុំទាំងអស់ គឺជាជាងកាត់ដេរខោអាវ ។ រូបថត២សន្លឹកនេះប្រពន្ធរបស់ខ្ញុំខ្ចប់ទុកនៅក្នុងកន្ត្រកខោអាវនៅពេលជម្លៀសឆ្នាំ១៩៧៥ ។ ជារឿយៗ មានឈ្លបមកឆែកឆេរកន្ត្រក និងផ្ទះរបស់ខ្ញុំនៅពេលដែលពួកខ្ញុំចេញទៅការដ្ឋានបាត់ៗ ប៉ុន្តែខ្ញុំអត់មានបាត់បង់រូបថតទេ គឺបាត់បង់តែនាឡិកាដៃនិងរបស់របរបន្តិចបន្តួចប៉ុណ្ណោះ ចំណែកឯរូបថតនិងមាសប្រពន្ធខ្ញុំលាក់ទុកយ៉ាងជិត ។

ពេលដែលខ្ញុំឃើញរូបថតទាំងនេះឡើងវិញ ធ្វើឲ្យខ្ញុំនឹកឃើញអនុស្សាវរីយ៍ពីមុនមកជាមួយប្រពន្ធរបស់ខ្ញុំ ជាពិសេសរូបថត២សន្លឹកដែលខ្ញុំថតក្នុងហាងនៅទីក្រុងភ្នំពេញ ដែលពេលនោះគឺជាពេលវេលាដែលក្រុមគ្រួសារខ្ញុំរកចំណូលបានយ៉ាងច្រើន ។ ឥឡូវខ្ញុំមានកូនច្រើន ខ្ញុំត្រូវចំណាយប្រាក់ជាច្រើនទៅលើការរៀនសូត្រនិងការរស់នៅរបស់កូនៗ ។ ខ្ញុំស្តាយសម្លៀកបំពាក់រៀបការរបស់ខ្ញុំណាស់ ។ ក្រោយរបបខ្មែរក្រហម បងរបស់ខ្ញុំប្រាប់ថា គាត់បានយកសម្លៀកបំពាក់ទាំងនោះទៅដូរយកអង្ករហូបអស់ហើយ ។ គាត់ថែមទាំងអរគុណដល់ខ្ញុំទៀតផង បើកុំតែបានសម្លៀកបំពាក់របស់ខ្ញុំម្ល៉េះគាត់ស្លាប់ដោយអត់បាយហើយ ។ ខ្ញុំធ្លាប់ឮអំពីរឿងរ៉ាវស្តីពីការបង្កើតឲ្យមានតុលាការដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែរ ប៉ុន្តែយូរឆ្នាំហើយមិនទាន់ឃើញតុលាការនោះកើតឡើងសោះ ។ ខ្ញុំមិនសង្ឃឹមថា តុលាការនេះអាចកើតឡើងទេ ពីព្រោះកន្លងទៅយូរឆ្នាំហើយ មិនឃើញបង្កើតសោះ ។ ខ្ញុំចង់បានយុត្តិធម៌មួយសម្រាប់ក្រុមគ្រួសាររបស់ខ្ញុំ ក៏ដូចជាជនរងគ្រោះដទៃទៀតដែលធ្លាប់បានឆ្លងកាត់សម័យនោះ ។ ខ្ញុំសង្ឃឹមថា តុលាការអាចទប់ស្កាត់កុំឲ្យរបបនោះកើតឡើងម្តងទៀត ។ ខ្ញុំតែងតែនិយាយរឿងរ៉ាវដែលខ្ញុំធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមប្រាប់ដល់កូនចៅខ្ញុំ ដើម្បីឲ្យពួកវាបានដឹងឮពីរបបនោះ ហើយខ្ញុំចង់កត់ត្រាទុកដើម្បីជាការចងចាំទៅថ្ងៃក្រោយទៀត ។

រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែស្អប់ពាក្យថា «សមមិត្ត» ខ្លាំងណាស់ ។ ពាក្យនេះខ្ញុំតែងតែឮនៅពេលមានប្រជុំម្តងៗក្នុងរបបខ្មែរក្រហម ។ ពេលខ្លះខ្ញុំមើលទូរទស្សន៍ ហើយឮពាក្យនេះខ្ញុំបិទទូរទស្សន៍ឈប់មើល ។ ខ្ញុំមិនចង់ឮពាក្យទាំងនេះទៀតទេ ។ ពាក្យនេះធ្វើឲ្យខ្ញុំនឹកឃើញដល់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ។ អ្នកជិតខាងរបស់ខ្ញុំនៅតែហៅខ្ញុំថា «អាចិន» ជាពិសេសនៅពេលមានជម្លោះ ។

**ប៉ាង ពីច័ន និង ស៊ុំ សាទីណា**

# ពន្យល់ពាក្យខ្មែរក្រហម

◆ ***យោធាបដិវត្តល្អ:*** *យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុង ក៏គ្មានលក្ខខណ្ឌ ។ (កំណត់ហេតុលេខ១០៨)*

◆ ***ធាតុពិតជាប់ជិតស្និទ្ធនឹងមហាជន:*** *មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយនៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយមិនខ្លាំងទេ ។ នៅជាមួយក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយ ចាត់តាំងនៅជាមួយ ។*

*(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)*

◆ ***ឧបាយកល:*** *បន្ទំសុំចរចាដើម្បីដកខ្លួនរៀបចំកម្លាំងមួយសាទៀត ទស្សនៈសភាពការណ៍បដិវត្តកម្ពុជាបច្ចុប្បន្ន និងភារកិច្ចរបស់យើង ។*

◆ ***សកម្មនឹងស្ទុះស្ទាញ:*** *ប្រយុទ្ធនឹងវាយសម្រុក ដោយឈរលើសន្ទុះឈ្នះ ឈរលើជំហរមានប្រៀបដាច់ខាតលើខ្មាំងនឹងលើសុទ្ធិនិយម បដិវត្តឥតងាករេ ។ តែធំបំផុតសកម្មនឹងស្ទុះស្ទាញត្រូវឲ្យចំទិស ។*

*(ដកស្រង់ចេញពីសៀវភៅការងារពង្រីងនិងកែលម្អគោលជំហរនិងអាកប្បកិរិយាដឹកនាំនិងធ្វើការងាររបស់បក្ស)*




## អេលីហ្សាបែត ប៊ែកខ័រ

អេលីហ្សាបែត ប៊ែកខ័រ គឺជាអ្នកឆ្លើយឆ្លងសារព័ត៌មាន របស់សារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ដែលក្រោយមក បាន ទទួលតំណែងជានិពន្ធនាយកបរទេសជាន់ខ្ពស់ របស់វិទ្យុជាតិ ហើយថ្មីៗនេះ ជាជំនួយការនិពន្ធនាយករបស់សារព័ត៌មានញ៉ូវយ៉កថែមស៍ ទទួលបន្ទុកសារព័ត៌មានបរទេស និងសារព័ត៌មានហិរញ្ញវត្ថុ ។ គាត់បានរាយការណ៍ និង សរសេរព័ត៌មានពីប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧៣ ឲ្យទៅញ៉ូវយ៉កថែមស៍, *The London Review of Books*, ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា និង *Die Tageszeitung* ។ សៀវភៅ នៅពេលដែលសង្គ្រាមរលត់ទៅ ទទួលបាន រង្វាន់សៀវភៅរបស់ Robert F. Kennedy និងត្រូវបាន ប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការថតខ្សែភាពយន្តឯកសាររបស់ រិទ្ធី ប៉ាន់ ដែលមានចំណងជើងថា បុប្ផាណា ។ គាត់ក៏ជាអ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រ សង្គ្រាមវៀតណាមរបស់សហរដ្ឋអាមេរិក ។ គាត់ទទួលបានសញ្ញាប័ត្រផ្នែកការសិក្សាពីអាស៊ីខាងត្បូង ពីសាកលវិទ្យាល័យទីក្រុងវ៉ាស៊ីនតោន ហើយសព្វថ្ងៃកំពុងរស់នៅជាមួយកូនពីរនាក់របស់គាត់នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី ។ សៀវភៅនេះមានទំហំ១៨០មមx២៦០មម កម្រាស់៧២៨ទំព័រ ។ ប្រែសម្រួលជាភាសាខ្មែរដោយ ទេព ម៉េងឃាន និង សុក្ខា អ៊ីរ៉ែន ។ ពិនិត្យនិងកែសម្រួលដោយ ឆាំង យុ ។

## សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយស្ថានទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជាបោះពុម្ពផ្សាយសៀវភៅមួយដែលមានចំណងជើងថា «នៅពេលដែលសង្គ្រាមរលត់ទៅ» ដែលបកប្រែចេញពីសៀវភៅដើមរបស់អ្នកស្រី អេលីហ្សាបែត ប៊ែកឃ័រ ។ នៅក្នុងសៀវភៅនេះ អ្នកស្រី អេលីហ្សាបែត រៀបរាប់អំពីរឿងរ៉ាវរបស់ខ្មែរក្រហមសាកល្បងបំភ្លឺថា អ្នកណាខ្លះជាខ្មែរក្រហមមូលហេតុអ្វីបានជាក្រុមនេះដាក់បង្កំឲ្យមានរបបមួយដែលបង្ខិតបង្ខោចនៅប្រទេសកម្ពុជានិងមូលហេតុដែលនាំឲ្យមានសង្គ្រាមជាមួយប្រទេសវៀតណាម ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចែកផ្សាយសៀវភៅនេះដោយឥតគិតថ្លៃដល់ប្រជាជនកម្ពុជាដែលចង់ទទួលបានគំនិតនិងចំណេះដឹងបន្ថែមអំពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាកាលពីបីទសវត្សរ៍មុន ។ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ ១១១០ ឬអាសយដ្ឋានផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬតាមអ៊ីមែលៈ dccam@online.com.kh ។ សូមអរគុណ ។

# នៅពេលដែលសង្គ្រាមរលត់ទៅ

*(មជ្ឈមណ្ឌលឯកសារកម្ពុជាដកស្រង់តែជំពូកទី៧នៃសៀវភៅនេះមកចុះផ្សាយ)*

## ជំពូកទី៧
## «បក្សជាទីគោរពនិងជាទីស្នេហា!...»

*«ចំណុចកំពូលរបស់អំពើភេរវកម្មដែលឡើងដល់កម្រិតខ្ពស់បំផុត គឺនៅពេលណាដែលប៉ូលិសរបស់រដ្ឋចាប់ផ្ដើមសម្លាប់ប្រជាជនរួមជាតិឯងនិងនៅពេលដែលពេជ្ឈឃាតពីមុនវិលក្លាយទៅជាអ្នករងគ្រោះនៅថ្ងៃនេះ» ។ ហាន់ណាស់ អារេនត៍*

*បក្សជាទីគោរពនិងជាទីស្នេហា និងបងៗជាមេដឹកនាំបក្សជាទីគោរពនិងជាទីស្នេហា ខ្ញុំសូមឲ្យបក្សនិងបណ្ដាសមមិត្តជាទីគោរពនិងជាទីស្នេហាអាណិតអាសូរខ្ញុំផង ។ គ្មានពេលណាមួយដែលខ្ញុំមានបំណងក្បត់បក្សបន្តិចសោះឡើយ.... ។*

*ដោយយល់ពីគំនិតផ្សេងៗរបស់បក្សដែលខ្ញុំធ្លាប់ដឹង ខ្ញុំអាចត្រឹមតែបញ្ជាក់ប្រាប់បក្សដោយស្មោះត្រង់ថា ខ្ញុំខ្លាចប្រភេទនៃសេចក្ដីស្លាប់បែបនោះខ្លាំងណាស់... ។*

*សមមិត្ត ផាត់ សរសេរនៅមន្ទីរឃុំឃាំងរបស់ផ្នែកសន្តិសុខ*
*ក្រុងភ្នំពេញ ខែមករា ឆ្នាំ១៩៧៨*

យើងអាចស្វែងយល់ពីរបបមួយដោយសិក្សាស្រាវជ្រាវពីស្ថាប័នផ្សេងៗដែលរបបនេះបង្កើតឡើង ។ មន្ទីរឃុំឃាំងទួលស្លែងល្មមធ្វើឲ្យអ្នកទស្សនានឹកឃើញដល់កម្ពុជាប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ។ មណ្ឌលសម្រាប់សួរចម្លើយធ្វើទារុណកម្មនិងសម្លាប់មនុស្សនេះ បានត្រូវរៀបចំឡើងក្នុងកន្លែងមួយដែលពីមុន ជាសាលាបឋមសិក្សានិងជាវិទ្យាល័យមួយនៅទីក្រុងភ្នំពេញ (ជាអតីតសាលាទួលស្វាយព្រៃនិងវិទ្យាល័យពញាយ៉ាត) ។ ខ្មែរក្រហមបានបណ្ដេញនិស្សិតទាំងអស់ចេញពីរដ្ឋធានី ហើយបញ្ជូនទៅដាក់តាមជំរំពលកម្មជាច្រើន មុនពេលដែលអ្នកទាំងនោះត្រូវសម្លាប់ ។ ខ្មែរក្រហមបានបិទសាលាទូទាំងប្រទេស ដោយឡែកសាលាទួលស្វាយព្រៃត្រូវបានបក្សប្រគល់ទៅឲ្យផ្នែកសន្តិសុខកាន់កាប់ដោយ ឌុច ជាអតីតគ្រូបង្រៀនក្រោមឈ្មោះថា កាំងហ្គិចអៀវ ធ្វើជាប្រធាន ។ ដោយបំបាត់កុមារភាពនិងការអប់រំការសម្លាប់អ្នកចេះដឹងនិងអ្នកគ្មានទោសពៃរ៍ គឺជាចំណែកមួយនៃអ្វីដែលមន្ទីរឃុំឃាំងទួលស្លែងជាតំណាង ។

នេះជាការចំអកបញ្ឈឺចិត្តដ៏អាក្រក់ ទួលស្លែងមានន័យថា «ទួលដែលមានដុះដើមឈើពុល» (ស្លែងជាដើមឈើមួយប្រភេទដែលផ្លែរបស់វាមានជាតិពុលនិងត្រូវបានប្រើប្រាស់សម្រាប់ត្រាំស្រាធ្វើជាថ្នាំផឹក ប៉ុន្តែបើផឹកច្រើនអាចពុលស្លាប់) ។

អគារទាំងបួនរបស់អតីតសាលានេះត្រូវបានបែងចែកជាផ្នែកដាច់ដោយឡែកពីគ្នា សម្រាប់ធ្វើជាកន្លែងនិងធ្វើទារុណកម្មអ្នកទោស កន្លែងសម្រាប់អ្នកយាមស្នាក់នៅ កន្លែងតម្កល់ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ។ សន្តិបាលបានរក្សាទុកសំណុំឯកសារជាច្រើននៅក្នុងនោះ ដែលភាគច្រើនជារបស់អ្នកទោសពីរម៉ឺននាក់ដែលខ្មែរក្រហមនាំយកមកដាក់គុកនៅមណ្ឌលនេះ ។ កន្លែងនេះក៏មានប្រមូលផ្ដុំចម្លើយសារភាពរាប់រយពាន់ទំព័ររូបថតជនរងគ្រោះរាប់ពាន់សន្លឹក និងសេចក្ដីណែនាំឲ្យធ្វើទារុណកម្មអ្នកទោស ។ ឯកសារទាំងគំនរនេះ រួមផ្សំបានជាប្រវត្តិសាស្ត្រដ៏កម្រមួយរបស់បក្សកុម្មុយនិស្តកម្ពុជា ថ្វីបើវាប្រែប្រួលមិនទៀងក៏ដោយ ។

បន្ទប់រៀនជាច្រើនត្រូវខ្មែរក្រហមខណ្ឌចែកជាបន្ទប់តូចៗដោយរៀបឥដ្ឋជាជញ្ជាំងឡើងរហូតដល់កម្ពស់ពាក់កណ្ដាលបន្ទប់រៀន ។ សាលប្រជុំធំៗសម្រាប់ការប្រជុំកាលពីដើមត្រូវខ្មែរក្រហមបំពាក់ដោយគ្រឿងសម្ភារសម្រាប់ការធ្វើទារុណកម្មដូចជា ខ្សែពួរច្រវាក់ ដែកថ្ពក់ស្រួចៗ គ្រែដែក ជាច្រើនដែលនៅលើនោះអ្នកទោសត្រូវចងសន្ធឹងដាក់ច្រវាក់ដៃជើង ។ ក្នុងទីធ្លាសាលាខ្មែរក្រហមរៀបដាក់ពាងទឹកធំៗ សម្រាប់ជ្រមុជក្បាលអ្នកទោសឲ្យថប់ដង្ហើម ។ សៀវភៅសរសេរចាស់ៗរបស់សាលាត្រូវខ្មែរក្រហមយកមកប្រើប្រាស់សម្រាប់កត់ត្រាឯកសារក្ដារខៀនសម្រាប់បិទបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌលដែលបញ្ជាដាច់ខាតមិនឲ្យអ្នកទោស

ស្រែកក្នុងពេលធ្វើទារុណកម្ម ត្រូវឆ្លើយឲ្យចំៗនឹងសំណួរផ្សេងៗ មិនចាំបាច់គិតវែងឆ្ងាយ ហើយត្រូវធ្វើតាមវិន័យដែលពិបាកទ្រាំជាច្រើនទៀតមុននឹងត្រូវយកទៅប្រហារជីវិត ។

ឌុច បានដឹកនាំជំរំមរណៈមួយដែលមានការរៀបចំយ៉ាងល្អឥតខ្ចោះ ។ សន្តិបាលបានថតរូបអ្នកទោស នៅពេលដែលនាំមកដល់ បន្ទាប់មកថតរូបក្នុងពេលដែលអ្នកទោសជិតស្លាប់ឬមុនស្លាប់បន្តិច ដែលសុទ្ធតែមានបំពង់-ករយះដោយអារខ្នងប្រាណ ត្រូវកាត់អវយវៈចេញ ឬត្រូវធ្វើឲ្យចុះស្គមកំព្រឹងដោយការធ្វើទារុណកម្មនិងការស្រេកឃ្លាន ដែលពុំអាចមើលស្គាល់ជានរណា ។ រូបថតទាំងនេះជាផ្នែកមួយនៃសំណុំលិខិតផ្សេងៗ ដែលបានចងក្រងឡើងជាភស្តុតាងដើម្បីបង្ហាញឲ្យឃើញថា សត្រូវរបស់រដ្ឋត្រូវបានសម្លាប់រួចពិតប្រាកដមែន ។ ឌុច ក៏បានកំណត់ជ្រើសរើសថ្ងៃដោយឡែកតាមពួកសម្រាប់អ្នកទោស ដូចជា ថ្ងៃមួយសម្រាប់សម្លាប់អ្នកទោសភេទស្ត្រីថ្ងៃមួយទៀតសម្លាប់កុមារ ថ្ងៃមួយផ្សេងទៀត សម្លាប់កម្មកររោងចក្រជាដើម ។


ឌុច ប្រធានគុកទួលស្លែង(ស-២១)

កន្លល់ដ៏ល្អិតល្អន់បែបនោះបានក្លាយទៅជានិមិត្តរូបពិសេសរបស់ ឌុច ក្នុងរយៈពេលនៃការឈានឡើងឋានានុក្រមបក្សរបស់គាត់ជាអតីតគ្រូបង្រៀននៅខេត្តកំពង់ចាមដែលក្លាយទៅជាភូមិភាគបូព៌ា ឌុច ធ្វើការនៅភូមិភាគនិរតីនៅពេលដែលគាត់សម្រេចទៅរួបរួមក្នុងជួរបដិវត្តន៍ ហើយនៅទីបំផុតក៏បានបំពេញមុខងារខាងផ្នែកសន្តិសុខរបស់ភូមិភាគនេះ ។ ក្នុងអំឡុងឆ្នាំដំបូងៗនៃសង្គ្រាម ឌុច មានឈ្មោះល្បីថាជាអ្នកធ្វើឲ្យរបៀបគ្រប់គ្រងការបោសសម្អាតផ្សេងៗរបស់ខ្មែរក្រហមកាន់តែវិសេសជាងមុន និងស្ទាត់កំបាំងគួរឲ្យកត់សម្គាល់ក្នុងពេលដែលគាត់ដឹកនាំផ្នែកសន្តិសុខរបស់ភូមិភាគនិរតីនេះ ។

នៅឆ្នាំ១៩៧២ គាត់ត្រូវអង្គការផ្ទេរឲ្យមកធ្វើការនៅភូមិភាគពិសេសដែលនៅជុំវិញទីក្រុងភ្នំពេញ ក្នុងគោលបំណងឲ្យគាត់រៀបចំសន្តិសុខនៅភូមិភាគពិសេសដែលជាភូមិភាគមួយងាយរងការប៉ះទង្គិចនិងទន់ខ្សោយបំផុតក្នុងចំណោមភូមិភាគនានាពេញរយៈពេលនៃសង្គ្រាម ។ នៅពេលដែលគណៈកម្មាធិការមជ្ឈិមទទួលកាន់កាប់កងទ័ពនិងអំណាចផ្នែករដ្ឋបាលជំនួសភូមិភាគពិសេសនៅឆ្នាំ១៩៧៥ ឌុច បានក្លាយទៅជប្រធានសន្តិសុខសម្រាប់ប្រទេសយ៉ាងងាយអាស្រ័យដោយសិទ្ធិអំណាចរបស់គាត់ពីមុនមក ។ ប៉ុន្តែផ្នែកសន្តិសុខនេះជាអង្គភាពមួយរបស់បក្សពុំមែនស្ថិតនៅក្រោមអំណាចរបស់រដ្ឋាភិបាលទេ ហើយ ឌុច ត្រូវធ្វើរបាយការណ៍ផ្សេងៗទៅឲ្យ ប៉ុល ពត ផ្ទាល់ និងសមាជិកគណៈលេខាមជ្ឈិមបក្សពីរបីនាក់ប៉ុណ្ណោះ ។ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារប្រទេសផងនិងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធផង គឺជាមេកោយផ្ទាល់ឬជាគូប្រជែងរបស់ ឌុច ។ ក្នុងប្រទេសមួយដែលដឹកនាំដោយអំពើភេរវកម្មមនុស្សដែល «វែកមុខ» និងសម្លាប់ខ្មាំងសត្រូវរបស់បដិវត្តន៍បានក្លាយទៅជាមនុស្សកាន់តែមានអំណាចខ្លាំងឡើងក្នុងលំដាប់ដែលការភ័យបារម្ភរបស់ពួកមេដឹកនាំបក្ស ការគិតមមៃពីសត្រូវផ្ទៃក្នុងនិងក្រៅប្រទេសចេះតែរីកធំឡើងៗ ។

ដូច្នេះ ឌុច បានចូលក្នុងក្រុមមេដឹកនាំសំខាន់ៗរបស់ប្រទេសដែលមានគ្នាតែប្រាំឬប្រាំមួយនាក់ប៉ុណ្ណោះ នៅពេលដែលទួលស្លែងក្លាយទៅជាមជ្ឈមណ្ឌល«ខួរក្បាល»នៃប្រព័ន្ធចាត់ចែងអំពើភេរវកម្ម ។ នៅពេលដែលមន្ទីរឃុំឃាំងទួលស្លែងទើបចាប់ផ្តើមដំណើរការនៅឆ្នាំ១៩៧៦ ការព្រមព្រៀងគ្នាដែលមានមួយរយៈក្នុងជួរគណៈកម្មាធិការមជ្ឈិមបក្សបានប្រេះស្រាំ ហើយ ប៉ុល ពត បានចាត់តាំងឲ្យ ឌុច តាមដានរកសត្រូវក្នុងផ្ទៃបក្សក៏

ដូចក្នុងជួរប្រជាជនដែរ ។ មិនត្រឹមតែប៉ុណ្ណោះ ឌុច បានចាប់និងឃុំខ្លួនជនសង្ស័យជាច្រើននាក់ទៀតតាមការចង្អុលប្រាប់របស់ ប៉ុល ពត ហើយ ឌុច ក៏ជាអ្នកជួយប្រឌិតភ័ស្តុតាងផ្សេងៗប្រឆាំងនឹងអ្នកទាំងនោះថែមទៀត ។ ដោយមានអំណាចចាត់ការទៅលើចម្លើយសារភាពផ្សេងៗរបស់ជនរងគ្រោះដែលជា«ភ័ស្តុតាង» នៃបទឧក្រិដ្ឋនានា ឌុច បានសម្រេចគោលដៅ «បន្ទិល» មេដឹកនាំបក្សតាមចំណង់របស់គាត់និងជ្រើសរើសទុកជាមុននូវ«ខ្មាំងសត្រូវ» ដែលបក្សពុំសង្ស័យថែមទៀត ។

ឌុច និងក្រុមសន្តិបាលរបស់គាត់ បានទទួលសិទ្ធិអំណាចជាចៅក្រមផង ជាទីប្រឹក្សាតុលាការផង និងជាពេជ្ឈឃាតផង ។ នៅទីបំផុត ទួលស្លែងក៏ក្លាយទៅជាកន្លែងដ៏គួរឲ្យស្បើមមួយដែលរួចផុតពីការត្រួតពិនិត្យទាំងអស់ ។

គណៈដឹកនាំបក្សបានចាប់ផ្តើមមន្ទិលសង្ស័យកម្មាភិបាលនិងអ្នកទទួលខុសត្រូវជាន់ខ្ពស់មួយចំនួនតូច នៅពេលដែលខ្លួនបានទទួលព័ត៌មានអំពីការធ្វើមិនបានសម្រេចលទ្ធផលតាមផែនការនៅតាមជនបទនានាក្នុងអំឡុងឆមាសទីមួយឆ្នាំ១៩៧៦ ។ សេចក្តីរាយការណ៍របស់ អៀង ធីរិទ្ធ អំពីភូមិភាគពាយ័ព្យ គឺជារបាយការណ៍មួយក្នុងចំណោមរបាយរាយការណ៍ទាំងឡាយដែលធ្វើឲ្យមជ្ឈិមអំពល់គំនិតយ៉ាងខ្លាំង ។ មជ្ឈិមបានបកស្រាយបរាជ័យទាំងនេះថា ជាសក្ខីភាពនៃការមិនចុះសម្រុងគ្នាក្នុងជួររបស់ពួកកុម្មុយនិស្តហើយ ។ ប៉ុន្តែ បើកុំមានកម្មាភិបាលមួយចំនួនតូចមិនប្រតិបត្តិតាមបទបញ្ជាខ្លះៗនោះ ក៏ប្រហែលជាមជ្ឈិមគ្មានដឹងថាខ្លួនត្រូវគំរាមកំហែងដោយមនុស្សរបស់ខ្លួនដែរ ។

ភ័ស្តុតាងជាច្រើនដែលប្រមូលបានបង្ហាញឲ្យឃើញផ្ទុយទៅវិញ ។ ប្រធានភូមិភាគទាំងឡាយបានរួមសហការយ៉ាងពេញលេញក្នុងការជម្លៀសប្រជាជនចេញពីរដ្ឋធានី ធ្វើតាមបទបញ្ជាផ្សេងៗដោយកែប្រែអ្នកទីក្រុងឲ្យក្លាយទៅជាកសិករតែក្នុងរយៈមួយថ្ងៃ លុបបំបាត់សិទ្ធិជាបុគ្គលទាំងអស់ រឹបអូសទ្រព្យសម្បត្តិទាំងអស់ក្នុងនាមរដ្ឋ កាប់សម្លាប់ជនជាតិភាគតិចនិងប្រើអំពើភេរវកម្មដើម្បីឲ្យមានការផ្លាស់ប្តូរទាំងនេះ ។ វាក៏មានការព្រមព្រៀងគ្នាស្តីពីការកំណត់ទិសដៅជាមូលដ្ឋាននិងគោលការណ៍ផ្សេងៗរបស់បដិវត្តន៍ដែរ ជាការព្រមព្រៀងគ្នាដើម្បីរៀបចំដំណើរ «មហាលោតផ្លោះ» មួយពីលើខ្នងប្រជាជនសម្រាប់ជំនាន់ក្រោយ ។

ប៉ុន្តែ វាក៏កើតមានបញ្ហាផ្សេងៗពីរឿងអំណាចដែរ ។ មានការវាយប្រយុទ្ធគ្នាតូចតាចរវាងកងទ័ពភូមិភាគបូព៌ានិងកងទ័ពភូមិភាគឧត្តរកើតឡើងនៅតាមផ្លូវថ្នល់ក្នុងទីក្រុងភ្នំពេញដើម្បីបោសម្អាតអ្នកមិនល្អចេញ ។ ការរង់ចាំដ៏អន្ទះសារអំពីលទ្ធផលដ៏អស្ចារ្យខាងវិស័យសេដ្ឋកិច្ចក្នុងចំណោមពួកមេដឹកនាំជាន់ខ្ពស់បានប្រែក្លាយទៅជាការរកស្វែងរកខ្មាំងសត្រូវដែលជាអ្នកដណ្តើមជោគជ័យរបស់ខ្លួនទៅវិញ ។ នៅឆ្នាំ១៩៧៦ បន្ទាប់ពីការប្រជុំជាបន្តបន្ទាប់មួយដើម្បីវាយតម្លៃស្ថានការណ៍ក្នុងប្រទេស គណៈដឹកនាំបក្សបានសម្រេចចិត្តដាក់ចេញនូវផែនការសេដ្ឋកិច្ចបួនឆ្នាំកម្ចាត់បណ្តាសមាជិកបក្សដែលក្លាយទៅជាមនុស្សគួរឲ្យសង្ស័យ ដោយអនុលោមទៅតាមប្រព័ន្ធស៊ើបអង្កេតថ្មីមួយហៅថា «ការស្រាវជ្រាវខ្សែបណ្តាញ» បន្ធូរល្បឿនបដិវត្តសង្គមនិយម និងបញ្ចប់រឿងទាំងនោះជាមួយនឹងការសម្របសម្រួលជាប្រវត្តិសាស្ត្រស្តីពីបញ្ហាដើមកំណើតបក្សដែលលំបាកគម្រូវចិត្តនិងទំនាក់ទំនងផ្សេងៗរបស់ខ្លួនជាមួយប្រទេសវៀតណាម ។

ក្នុងភាសារបស់បក្ស ខ្មែរក្រហមលែងនិយាយពាក្យកម្ចាត់ឬកែប្រែចរិតវណ្ណៈគហបតីទៀតហើយ ប៉ុន្តែអាចនិយាយថាកម្ចាត់និន្នាការគហបតីក្នុងផ្ទៃបក្សផ្ទាល់ ។ តាមការពិត គណៈដឹកនាំបក្សបានត្រូវធ្វើឲ្យផ្លាស់ប្តូរជំហរដោយសេចក្តីបារម្ភពីអំពើក្បត់មួយរបស់បណ្តាយុទ្ធមិត្តរបស់ខ្លួន ដែលចាក់ឫសយ៉ាងជ្រៅតាំងពីមុនមក ។ ដើមដំបូងនៃបដិវត្តន៍ ក្រុមកុម្មុយនិស្តខ្មែរបានទទួលរងការឈឺចាប់បន្តិចបន្តួច ព្រោះតែបណ្តាសត្រូវក៏ដូចសម្ព័ន្ធមិត្តរបស់ខ្លួនៈ ពួកវៀតណាមដែលចង់ត្រួតត្រាប្រទេស មេដឹកនាំខ្លួនខ្លះបានក្លាយទៅជាអ្នកឲ្យការណ៍ទៅសម្តេច ព្រះនរោត្តម សីហនុ ចិនបានគាំទ្រសម្តេចដោយធ្វើឲ្យខូចប្រយោជន៍ដល់កុម្មុយនិស្តខ្មែរនិងពួកវៀតណាមជាថ្មីក្នុងជម្លោះដែនដីដំបូងៗបន្ទាប់ពីសម័យសង្គ្រាម ។

ខ្មែរក្រហមបានការពារខ្លួននឹងអំពើក្បត់ថ្មីៗដោយមធ្យោបាយការពារពីរដូចគ្នាៈ បានចងសម្ព័ន្ធភាពដោយឥតអៀនខ្មាសជាមួយនឹងសត្រូវរបស់ខ្លួនទោះជាដឹងថាសត្រូវទាំងនោះនឹងបំផ្លាញ

សម្ព័ន្ធភាពនេះនៅថ្ងៃណាមួយ និងប្រកាន់យកយុទ្ធសាស្ត្រមួយសំដៅ«កម្ចាត់» សត្រូវដែលមិនទាន់ចេញជាក់ស្តែងឲ្យអស់មុនពេលដែលសត្រូវទាំងនោះមានឱកាសក្បត់បក្ស ។ សម្ព័ន្ធភាពជាបណ្តោះអាសន្នក្នុងសម័យសង្គ្រាមដែលមានទម្រង់ជា«រណសិរ្សរួបរួមជាតិ» បានទទួលជោគជ័យលើសពីការសង្ឃឹមទុកទៅទៀត ដោយហេតុតែរណសិរ្សនេះបានបង្រួបបង្រួមប្រជាជនកម្ពុជាទាំងអស់តាំងពីសម្តេចព្រះ នរោត្តម សីហនុ រហូតដល់ព្រះសង្ឃប្រជាកសិករនិងបញ្ញវន្ត ។

ប៉ុន្តែនៅទីបំផុត អ្វីដែលធ្វើឲ្យរបបនេះវិនាសអន្តរាយគឺជំងឺមិនទុកចិត្តគ្នាឯង ពុំមែនវិនាសដោយសារសត្រូវនោះទេ ។ កាលបើវិនិច្ឆ័យគួរដល់កាលវេលាហើយ បក្សបានកាត់ផ្តាច់សម្ព័ន្ធភាព ភ្លាមដោយរបៀបយ៉ាងឃោរឃៅ ។ នៅពេលដែលបក្សហាមមិនឲ្យមានសាសនា បក្សមិនត្រឹមតែបិទវត្តអារាមមិនឲ្យប្រជាជនធ្វើបុណ្យទានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្លាប់ព្រះសង្ឃនិងប្រែក្លាយវត្តទាំងនោះទៅជាជង្រុកស្រូវថែមទៀត ។ នៅពេលលែងត្រូវការសម្តេចព្រះ នរោត្តម សីហនុ ខ្មែរក្រហមមិនបានផ្តល់មុខតំណែងដែលគ្រាន់តែជាកិត្តិយសណាមួយថ្វាយព្រះអង្គឡើយផ្ទុយទៅវិញបានកម្រិតឲ្យព្រះអង្គស្ថិតនៅក្នុងតែព្រះរាជដំណាក់នាព្រះបរមរាជវាំងដោយចាត់ទុកព្រះអង្គជាអ្នកទោស ។ បន្ទាប់ពីបានប្រើប្រាស់ខ្មែរដែលត្រឡប់មកពីទីក្រុងហាណូយឲ្យជួយបណ្តុះបណ្តាលកងទ័ពរួចមក ខ្មែរក្រហមបានសម្លាប់អ្នកទាំងនោះចោលស្ទើរតែទាំងអស់ ។

ដោយត្រូវប្រឈមមុខនឹងភ័ស្តុតាងផ្សេងៗដែលមិនអាចបដិសេធបានចំពោះបរាជ័យដំបូងៗរបស់ការបដិវត្តន៍ មជ្ឈិមបានទម្លាក់ការទទួលខុសត្រូវទៅលើ កុយ ធួន និងភូមិភាគឧត្តរដែលជាសញ្ញាផ្តើមធ្វើការបោសសម្អាតថ្នាក់ភូមិភាគជាលើកដំបូង ។ មជ្ឈិមបានបញ្ជាឲ្យកងទ័ពរបស់ភូមិភាគបូព៌ានិងភូមិភាគកណ្តាលដែលទើបនឹងបង្កើតថ្មី ទៅកម្ទេចកម្មាភិបាលនៅអតីតភូមិភាគឧត្តរនៅឆ្នាំ១៩៧៦ ។ កងទ័ពខ្មែរក្រហមបានចាប់ខ្លួននិងសម្លាប់កម្មាភិបាលប្រមាណដប់នាក់ ហើយដាក់ជំនួសដោយមេដឹកនាំ «ស្មោះត្រង់» តាមការណែនាំរបស់មជ្ឈិម ។ វិធីសាស្ត្រនេះពោរពេញទៅដោយភាពប៉ិនប្រសប់ ពីព្រោះវារួមបញ្ចូលមេដឹកនាំភូមិភាគបូព៌ានិងភូមិភាគកណ្តាលជាមួយគ្នានឹងមេដឹកនាំទីក្រុងភ្នំពេញដែរ ។ វិធីសាស្ត្រនេះបានជំរុញឲ្យមានការសង្ស័យក្នុងផ្ទៃបក្សថែមទៀត ។ រឿងនេះប្រហែលបកស្រាយឲ្យដឹងពីដើមហេតុដែលលេខាបក្សភូមិភាគបូព៌ាបានព្រមព្រៀងរៀបចំអាពាហ៍ពិពាហ៍មួយរវាងកូនស្រីគាត់និងកូនប្រុសរបស់លេខាបក្សភូមិភាគពាយ័ព្យ -នេះជាការជួយគាំពារគ្នាទៅវិញទៅមកក្នុងករណីដែលភូមិភាគណាមួយក្នុងចំណោមភូមិភាគទាំងពីរធ្លាក់ទៅក្នុងការបោសសម្អាតភូមិភាគដទៃទៀត (កលឧបាយនេះ គ្មានផលប្រយោជន៍អ្វីទាំងអស់) ។

នៅឆ្នាំ១៩៧៦ដដែលនោះ បក្សបានប្រកាសឲ្យដឹងអំពីការជំរុញបដិវត្តន៍សង្គមនិយមនិងបញ្ជាឲ្យលុបបំបាត់សម្ព័ន្ធភាពវណ្ណៈ -នេះជាការលុបបំបាត់វណ្ណៈផ្សេងៗរបស់ខ្លួនឯងផ្ទាល់ ។ ការបង្គាប់បញ្ជានេះបានក្លាយទៅជាកម្មវត្ថុនៃការបកស្រាយប្លែកៗពីគ្នា ។ កសិករមានទ្រព្យសម្បត្តិច្រើននិងដែលធ្លាប់រួមប្រយុទ្ធតស៊ូជាមួយខ្មែរក្រហមក្នុងរយៈពេលសង្គ្រាម ក៏ត្រូវបានសម្លាប់ចោលដែរពីព្រោះជាសត្រូវវណ្ណៈ ។ ខ្មែរក្រហមក៏បានសម្លាប់«ប្រជាជនចាស់» សមាជិកបក្សនិងកងទ័ពដោយសារតែមានជាប់ពាក់ព័ន្ធនឹងសមាជិកនៃវណ្ណៈមួយដែលផ្តល់គ្រោះថ្នាក់ដល់បដិវត្តន៍ ។ ក្រោយមក អៀង សារី បានរៀបរាប់ពីការតស៊ូវណ្ណៈឬ«ការផ្លាស់ប្តូរទ្រង់ទ្រាយសង្គម»នេះថាជាគ្រោះមហន្តរាយមួយដោយគូសបញ្ជាក់ថា នៅក្នុងតំបន់ខ្លះកម្មាភិបាលនិង«ប្រជាជនចាស់» បានប្រព្រឹត្តខុសគន្លងមាគ៌ា ដោយធ្វើទុក្ខទោសនិងសម្លាប់មនុស្សយ៉ាងច្រើន ។

ដោយតម្រូវទៅតាមស្ថានការណ៍នោះ បក្សបានបិទទ្វារលែងរើសមនុស្សចូលនិងបណ្តេញសមាជិករាប់ពាន់នាក់របស់ខ្លួនចេញ ។ កងទ័ពក៏ត្រូវបាន «បោសសម្អាត» ហើយយុទ្ធជនមួយចំនួនដែលមានវណ្ណៈដើមមិនល្អត្រូវបានសម្លាប់ ។

ក្នុងស្ថានភាពច្របូកច្របល់នេះ កងទ័ពរបស់ភូមិភាគបូព៌ាត្រូវបានបញ្ជូនទៅព្រំដែនដើម្បីទប់ទល់នឹងការទន្ទ្រានរបស់កងទ័ពវៀតណាម ។ បន្ទាប់ពីការប៉ះទង្គិចគ្នាស្រាលៗជាច្រើនលើកមជ្ឈិមបានស្ទីបន្ទោស សោ ភឹម លេខាបក្សភូមិភាគបូព៌ា ដោយចោទប្រកាន់ថា បានវាយវៀតណាមជ្រុលពេក ហើយបានបង្គាប់

គាត់ដោយដាច់ខាតថា ត្រូវលែងធ្វើឲ្យលូកកករដល់«ស្ថិរភាពផុយស្រួយ» ដែលសម្រេចហើយនៅតាមព្រំដែន ។

លទ្ធផលចុងឆ្នាំបាននាំមកនូវតួលេខស្តីពីការច្រូតកាត់នៅខែធ្នូ និងការប្រមូលផលមិនល្អរបស់ភូមិភាគពាយ័ព្យដែលធ្វើឲ្យបក្សខកចិត្តយ៉ាងខ្លាំង ។ នៅពេលដែលមជ្ឈិមសម្រេចថា កំហុសទាំងអស់ធ្លាក់ទៅលើកម្មាភិបាលរបស់ភូមិភាគពុំមែនមកពីនយោបាយលោភលន់ហួសហេតុរបស់ក្រុងភ្នំពេញ បក្សបានបញ្ជាឲ្យធ្វើការបោសសម្អាតថ្នាក់ភូមិភាគជាលើកទីពីរទៀត ។ មុនដំបូងសន្តិសុខបានទម្លាក់កំហុសទៅលើ កុយ ធួន ដើម្បីបញ្ចប់ការបោសសម្អាតលើកទីមួយ ។ កុយ ធួន ត្រូវចាប់ខ្លួនកាលពីមួយរយៈមុន ប៉ុន្តែត្រូវបានដោះលែងមកវិញ ។ នៅខែមករា ឆ្នាំ១៩៧៧ មជ្ឈិមបានយក កុយ ធួន ទៅដាក់គុកនៅទួលស្លែង ដែលមាន ឌុច ជាអ្នកត្រួតត្រាពិនិត្យពីលើការធ្វើទារុណកម្មនិងការសម្លាប់គាត់ដោយផ្ទាល់ ។ កុយ ធួន ត្រូវបានចោទប្រកាន់និងរកឃើញថា ជាភ្នាក់ងារសេ.អ៊ី.អាតាំងពីអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ខ្មែរក្រហមក៏យកចិត្តទុកដាក់ប្រឆាំងនឹងរូបគាត់ដោយលើកពីវណ្ណៈភាពដើមរបស់គាត់ដែលជាគហបតី ។

បក្សត្រូវការឲ្យពួកអ្នកមានស្មារតីភក្តិរបស់បក្សជឿលើភ័ស្តុតាងដាក់បន្ទុកដ៏ចម្លែកដែលផ្តោតប្រឆាំងនឹងមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំសំខាន់ៗរួចហើយ ក៏សម្លាប់អ្នកដែលនោះ ។ អំពើហិង្សាបានចាក់ឫសយ៉ាងជ្រៅក្នុងជួរបក្សរហូតទាល់តែលេខាបក្សភូមិភាគនានាមើលពុំឃើញអ្វីដែលជាភ័ស្តុតាងដាក់ស្តែងដូចរឿង កុយ ធួន ឡើយ គឺដឹងត្រឹមតែថា មជ្ឈិមអាចទម្លាក់ទោសកំហុសមកលើអ្នកណាម្នាក់ក៏បានដែរ ។

បន្ទាប់ពីបានរៀបចំការបោសសម្អាតអតីតភូមិភាគឧត្តរដោយការសម្លាប់ កុយ ធួន មជ្ឈិមបានចាប់ផ្តើមធ្វើការបោសសម្អាតភូមិភាគមួយទៀតគឺ ភូមិភាគពាយ័ព្យ ។ ម្តងនេះបក្សបានប្រើប្រាស់កម្មាភិបាលរបស់ភូមិភាគនិរតីដើម្បីកាប់បំបាក់កិច្ចសន្យាការពារគ្នាក្រៅផ្លូវការមួយដែលសម្រេចឡើងដោយមេដឹកនាំភូមិភាគបូព៌ានិងពាយ័ព្យ ។ មជ្ឈិមបានទុកលេខាបក្សភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម ឲ្យនៅកាន់មុខតំណែងមួយរយៈសិន ។

គណៈដឹកនាំបក្សបានចាត់ចែងឲ្យមានការស៊ើបអង្កេតមួយផ្សេងទៀត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាហូរហែអំពីទឹកចិត្តស្មោះត្រង់ទីទៃៗពីគ្នា ។ សញ្ញាដំបូងៗនៃការផ្លាស់ប្តូរនេះ ព្រមទាំងសញ្ញាផ្សេងៗទៀត មាននៅក្នុងសំណុំឯកសារជាច្រើនដែលមាននៅមន្ទីរឃុំឃាំងទួលស្លែង ។ នៅឆ្នាំ១៩៧៦ មនុស្សដែលត្រូវបានសម្លាប់ទាំងប៉ុន្មាន សុទ្ធតែជាមនុស្សនៅក្នុងរបបចាស់ៈ កម្មករ១៦៨នាក់ និស្សិត៦១នាក់ សាស្ត្រាចារ្យ៣៥នាក់ គ្រូពេទ្យនិងគិលានុបដ្ឋាក២០នាក់ វិស្វករ៤៩នាក់ អ្នករដ្ឋការ៥៥នាក់ ទាហាន២០៩នាក់ និង៤៧នាក់ជានិស្សិតនិងឥស្សរជនដែលធ្លាប់រស់នៅឯបរទេស ។ ក្នុងចំនួនអ្នកស្លាប់៧៥០នាក់ដែលមានចុះក្នុងបញ្ជីនៅទួលស្លែងនាឆ្នាំនោះ មានសមាជិកបក្សតែប្រមាណដប់ពីរនាក់ប៉ុណ្ណោះ ។ ឆ្នាំ១៩៧៦ ជាឆ្នាំដែលខ្សែបណ្តាញរបស់បុប្ផាណា ត្រូវគេធ្វើទារុណកម្មនិងសម្លាប់ចោល ។

ឆ្នាំ១៩៧៧ បានកំណត់នូវការផ្លាស់ប្តូរមួយបន្ទាប់ពីបក្សដាក់ចេញមតិណែនាំថ្មីៗទៀត ។ ចំនួននៃការប្រហារជីវិតមេដឹកនាំកុម្មុយនិស្តបានឡើងដល់៤៤នាក់ ហើយចំនួនអ្នកដែលត្រូវចាប់ដាក់គុកមាន៦១នាក់ ។ កម្មករចំនួន១៤២នាក់ ត្រូវបានសម្លាប់ចោល ។ តួលេខទាំងនេះបានបង្ហាញឲ្យឃើញពីការសម្រេចចិត្តរបស់បក្សដើម្បីជំរុញខស្សរាហូបនីយកម្មនិងពិនិត្យពិច័យប្រវត្តិដើមរបស់កម្មករដោយល្អិតល្អន់ដើម្បីស្វាបស្ទង់អំពី«ភក្តីភាព» ។ ការសម្រេចចិត្តនេះបាននាំទៅដល់ការសម្លាប់វណ្ណៈ អធនទៀត ដែលក្នុងនាមនៃវណ្ណៈនេះហើយដែលបដិវត្តន៍ត្រូវបានរៀបចំធ្វើឡើង ។

បន្ទាប់ពី កម្មករ ប្រភេទដែលរងការប៉ះពាល់ខ្លាំងបន្ទាប់គឺឥស្សរជននិងនិស្សិតដែលត្រឡប់មកពីបរទេសវិញចំនួន៨២នាក់ -ជាក្រុមចម្រុះដែលធ្លាប់មានសមានចិត្តនឹងបុព្វហេតុបដិវត្តន៍និងជាសមាជិកនៃរបបសង្គមចាស់ ។ នៅឆ្នាំ១៩៧៧ សាស្ត្រាចារ្យ៦៤នាក់ផ្សេងទៀតត្រូវបានសម្លាប់ចោល ។ តមកទៀត ជាវេនមេដឹកនាំកុម្មុយនិស្តចំនួន៦១នាក់ ។ ក្នុងចំនួនអ្នកដែលត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៧ មិនសូវមាននិស្សិត បុគ្គលិករដ្ឋការ វេជ្ជបណ្ឌិត វិស្វករ និងទាហានទេ ។ អ្នកដែលរួចផុតពីការកាប់សម្លាប់លើកដំបូងសុទ្ធតែចេះសម្របខ្លួនទៅតាមកាលៈទេសៈដោយលាក់បាំងប្រវត្តិដើមរបស់ខ្លួន ។

នៅឆ្នាំ១៩៧៨ មានការប្រែប្រួលថ្មីទៀតៈ លើកនេះប្រភេទមេដឹកនាំកុម្មុយនិស្ត និងអ្នករងគ្រោះ១០៧នាក់ ។

បញ្ជីឈ្មោះមនុស្សដែលត្រូវសម្លាប់នៅមន្ទីរឃុំឃាំងទួលស្លែងបានបង្ហាញឲ្យឃើញពីប្រសិទ្ធភាពនៃមតិណែនាំមជ្ឈិម ។ ពីរ-បីខែបន្ទាប់ពីបក្សទម្លាក់កំហុសទៅលើអ្នកណាម្នាក់ គេក៏ឃើញអ្នកនោះជាប់នៅក្នុងមន្ទីរឃុំឃាំង ។ រៀងរាល់លើកដែលបក្សសម្រេចរំលាយសម្ព័ន្ធភាពមួយឬបំភ្លេចពាក្យសន្យាមួយជនទាំងឡាយដែលខ្វាតចេញពីតំណែងនៅទីបំផុតបានមកជួបគ្នាជាថ្មីដោយដៃជើងជាប់ច្រវាក់នៅមន្ទីរឃុំឃាំងទួលស្លែង ។

សំណុំឯកសាររបស់ទួលស្លែង ក៏បង្ហាញឲ្យឃើញពីការស្អប់ខ្ពើមជនបរទេសដែលគ្មានប្រែប្រួលរបស់ខ្មែរក្រហមដោយការសម្លាប់ជនបរទេសអន្តការស្រាវជ្រាវឃើញនៅក្នុងប្រទេស ។ ឯកសារផ្សេងៗនៅមន្ទីរទួលស្លែងបង្ហាញឲ្យដឹងថា ជនជាតិថៃជាច្រើនដែលចាប់បាននៅកំពង់សោមត្រូវបានសម្លាប់ក្នុងមន្ទីរឃុំឃាំងនេះនៅខែឧសភា ឆ្នាំ១៩៧៦ ។ អ្នកជំនួញនិងនិស្សិតជាតិឥណ្ឌានិងប៉ាគីស្ថានក៏ត្រូវគេប្រហារជីវិតនៅទីនោះដែរ ។ នៅឆ្នាំ១៩៧៨ ទាហានម៉ារីនអាមេរិកាំង អូស្ត្រាលី អង់គ្លេសនិងនូវែលហ្សេឡង់ ដែលត្រូវចាប់ខ្លួនបាននៅក្នុងឈូងសមុទ្រថៃ ឬនៅតំបន់កោះនានាក្បែរឆ្នេរសមុទ្រ ក៏ត្រូវដឹកយកមកដាក់ឃុំនៅទួលស្លែងនិងត្រូវសម្លាប់ចោលទាំងអស់ ។

ចំនួនអ្នករងគ្រោះបង្ហាញឲ្យឃើញថា របបកម្ពុជាប្រជាធិបតេយ្យបានពឹងផ្អែកលើមន្ទីរឃុំឃាំងទួលស្លែងកាន់តែច្រើនឡើងៗ ថ្វីដ្បិតតែចំនួននេះនៅតែមិនទាន់ពេញលេញក៏ដោយ ។ បក្សត្រូវការឲ្យ ឌុច និងពេជ្ឈឃាតរបស់គាត់ បង្ហាញឲ្យឃើញអំពីមូលហេតុពិតនៃបរាជ័យរបស់បដិវត្តន៍ ។ នៅឆ្នាំ១៩៧៦ អ្នកទោសប្រហែលពីររយនាក់បានត្រូវនាំទៅដាក់គុកនៅមន្ទីរឃុំឃាំងទួលស្លែង ។ នៅឆ្នាំ១៩៧៧ មនុស្សជាងប្រាំមួយពាន់នាក់ក៏ត្រូវនាំទៅដាក់គុកនៅទីនោះដែរ ហើយមនុស្សដប់ពីរពាន់នាក់បានត្រូវចាប់ដាក់គុកនៅឆ្នាំ១៩៧៨ ។

ប្រសិនបើជាបញ្ជីសម្លាប់មនុស្សប្រាប់ឲ្យដឹងអំពីការកើនឡើងនៃចំនួនសមាជិកបក្សដែលជាប់នៅទួលស្លែង មានតែការអានចម្លើយសារភាពរបស់ជនរងគ្រោះមួយមុខប៉ុណ្ណោះដែលធ្វើឲ្យគេដឹងអំពីការគិតមមៃថ្មីៗរបស់បក្ស ។ បន្ទាប់ពីមន្ទីរបក្សចេញបញ្ជាឲ្យផ្លាស់ប្តូរទិសដៅរបស់ការបដិវត្តន៍ក្នុងសម័យប្រជុំផ្សេងៗនៅឆ្នាំ១៩៧៦ ពេជ្ឈឃាតនៅមន្ទីរឃុំឃាំងទួលស្លែងបានចាប់ផ្តើមសួរចម្លើយអ្នកទោសអំពីឥរិយាបថរបស់គេ ចំពោះប្រទេសវៀតណាម ។ មេដឹកនាំខ្ពស់បានជ្រើសរើសបញ្ហានេះដើម្បីវិនិច្ឆ័យពីភាពស្មោះត្រង់របស់សមាជិកបក្ស និងវែកមុខ «សត្រូវបង្កប់» ក្នុងជួរបក្សផង ។

បក្សបានផ្តើមជជែកអំពីបញ្ហាទាក់ទងនឹងវៀតណាមស្តីពីថ្ងៃខែនៃការបង្កើតបក្សកុម្មុយនិស្តកម្ពុជាឡើងវិញ ។ នេះពុំមែនជារឿងដែលមិនសូវសំខាន់នោះទេ ។ ក្នុងប្រវត្តិសាស្ត្រដូវការតែមួយគត់របស់បក្សដែលបោះពុម្ពផ្សាយក្នុងរយៈពេលសង្គ្រាមឆ្នាំ១៩៧៣ បក្សបានកំណត់យកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ ទុកជាថ្ងៃខែបង្កើតបក្ស ។ ថ្ងៃខែនេះជាការលាយឡុកឡំមួយរវាងនិន្នាការពីរ ជាផ្លែផ្កានៃការសម្រុះសម្រួលផ្នែកនយោបាយសំដៅបង្រួបបង្រួមកម្លាំងទាំងអស់របស់បក្សក្នុងកិច្ចប្រឹងប្រែងធ្វើសង្គ្រាម ។

នៅឆ្នាំ១៩៧៦ បក្សបានយកចិត្តទុកដាក់ប្រគល់ឲ្យអ្នកកុម្មុយនិស្តកម្ពុជានូវគុណបំណាច់ទាំងអស់នៃជោគជ័យនិងការធ្វើបដិវត្តន៍ដោយបានបញ្ចប់រឿងនេះជាមួយនឹងការស្រុះស្រួលគ្នាមួយអំពីថ្ងៃខែកំណើតបក្សដែលយល់ព្រមឲ្យប្រទេសវៀតណាមនូវតួនាទីដ៏សំខាន់មួយក្នុងការកសាងចលនាកុម្មុយនិស្តនៅកម្ពុជា ។ មជ្ឈិមមានបំណងបដិសេធចោលឧបការគុណទាំងអស់របស់វៀតណាមនិងចំណងទាក់ទងទាំងអស់ជាមួយអតីតបក្សកុម្មុយ-និស្តឥណ្ឌូចិន ហើយបានកាត់ចោលភាគខ្លះនៃប្រវត្តិសាស្ត្ររបស់ខ្លួន ដោយយកឆ្នាំ១៩៦០ជាឆ្នាំនៃការបង្កើតបក្ស ដោយធ្វើឲ្យក្រុងហាណូយជាអ្នកធ្វើអំពើល្អក្លាយទៅជាអ្នកគំរាមកំហែងវិញ ។

ការសម្របសម្រួលគ្នាអំពីថ្ងៃខែកំណើតបក្ស កិច្ចព្រមព្រៀងគ្នាដែលគ្មានចែងច្បាស់លាស់ស្តីពីប្រភពដើមរបស់បក្សបានត្រូវបំបាត់បានដោយងាយស្រួលដូចគ្នានឹងសម្ព័ន្ធភាពផ្សេងៗទៀតដែលបង្កើតឲ្យមានឡើងក្នុងសម័យសង្គ្រាមដែរ នៅពេលណាដែលបក្សត្រូវការកិច្ចគាំទ្រពីនិន្នាការទាំងអស់និងពីប្រទេសវៀតណាម ។ ដោយប្រទេសមានសន្តិភាព មជ្ឈិមចង់សាកល្បង

បង្កហេតុមួយ (ដោយមើលងាយគូប្រឆាំងថា គ្មានសមត្ថភាពធ្វើអ្វីកើត) ជាមួយពួកវៀតណាមដើម្បីបង្ហាញឲ្យឃើញពីឧត្តមភាពរបស់បដិវត្តកម្ពុជាជាថ្មីនិង «បន្សុទ្ធ» បក្សឲ្យផុតពីសមាសភាពទាំងអស់ដែលស្និទ្ធនឹងវៀតណាម ។

មេដឹកនាំកុម្មុយនិស្តផ្តោតការសង្ស័យទៅលើ«អ្នកថ្មី»ទៀតទេ ប៉ុន្តែបង្វែការសង្ស័យទៅលើប្រជាជនកម្ពុជាដែលធ្លាប់រួមចំណែកជួយកសាងបដិវត្តន៍ ។ ប្រវត្តិសាស្ត្រនៃបដិវត្តន៍របស់កម្ពុជាពីពេលនេះតទៅមានលក្ខណៈដូចប្រវត្តិសាស្ត្ររបស់បក្សមួយដែលប្រែត្រឡប់មកប្រឆាំងនឹងសមាជិកផ្ទាល់របស់ខ្លួនវិញ - និងប្រឆាំងនឹងមនុស្សរាប់ពាន់នាក់ផ្សេងទៀតដែលត្រូវបានសម្លាប់ក្នុងវិបត្តិដ៏ឆ្កួតលេលានេះ ។

ឌុច បានចាប់ផ្តើមស្វែងរកជនសង្ស័យពីរប្រភេទគឺបញ្ញវន្តជាសមាជិកបក្ស ឬសាច់សាលោហិតនិងប្រជាជនកម្ពុជាដែលត្រូវវិនិច្ឆ័យថា ជំពាក់ចិត្តនឹងវៀតណាមខ្លាំងពេក ។ តាមស្នាបក្សបានកំណត់កាលបរិច្ឆេទដ៏ជាក់លាក់មួយសម្រាប់ ឌុច ដើម្បីបង្កើនល្បឿនស្រាវជ្រាវរកកុម្មុយនិស្តដែលធ្លាប់ទាក់ទងជាមួយពួកវៀតណាម មុនប្រារព្ធបុណ្យខួបថ្ងៃកំណើតបក្ស ៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ។ សម្ព័ន្ធមិត្តដ៏ជិតស្និទ្ធបំផុតរបស់កម្ពុជាគឺប្រទេសចិនបានតៀនបន្តិច ប៉ុល ពត ទម្លាក់របាំងមុខចុះតាំងពីពេលកន្លងមកមិនជាយូរប៉ុន្មាន និងឲ្យទទួលស្គាល់ជាសាធារណៈថា ប្រទេសកម្ពុជាដឹកនាំគ្រប់គ្រងដោយបក្សកុម្មុយនិស្តមួយ ។

ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ម៉ៅ សេទុង បានទទួលមរណភាព ។ ក្នុងឋានៈខ្លួនជានាយករដ្ឋមន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត បានថ្លែងកោតសរសើរចំពោះមេដឹកនាំចិនរូបនេះ តាមវិទ្យុជាតិនៅថ្ងៃទី១៨ ខែដដែល ។ ការយឺតយូរប្រាំបួនថ្ងៃនេះពុំមានការពន្យល់បំភ្លឺឲ្យដឹងឡើយ ប៉ុន្តែអត្ថបទនៃសេចក្តីថ្លែងរបស់ ប៉ុល ពត បានបង្ហាញឲ្យឃើញភ័ស្តុតាងមួយ ជាលើកដំបូងបំផុត ប៉ុល ពត បានគូសបញ្ជាក់ថា មនោគមវិជ្ជារបស់អង្គការពឹងផ្អែកជាសំអាងលើលទ្ធិម៉ាក្ស-លេនីន ។ ខ្មែរក្រហមមិនដែលដាក់ខ្លួនទទួលស្គាល់ជាសាធារណៈអំពីឋានៈជាជនកុម្មុយនិស្តរបស់ខ្លួនទេ ប៉ុន្តែសេចក្តីប្រកាសនេះនៅតែពុំទាន់ជាក់លាក់និងច្បាស់លាស់ ដូចដែលបណ្តាមិត្តភក្តិបរទេសរបស់គាត់ចង់បានពីគាត់ទេ ។

សារសំខាន់នៃការទទួលសារភាពតែពាក់កណ្តាលនេះត្រូវបានធ្វើឲ្យលេចឡើងច្បាស់ក្រឡែត ពីរថ្ងៃក្រោយដោយព្រឹត្តិការណ៍ពីរ មួយជាព្រឹត្តិការណ៍ដែលគេដឹងឮគ្រប់គ្នា និងមួយទៀតសម្ងាត់ ។ ប៉ុល ពត បានសុំលាលែងពីមុខតំណែងជានាយករដ្ឋមន្ត្រីដោយសារមូលហេតុសុខភាព - តាមគាត់ប្រកាសឲ្យដឹង - ហើយបានចាត់តាំងឲ្យ នួន ជា ដែលជាមនុស្សគួរឲ្យជឿទុកចិត្តតែម្នាក់គត់ និងជាមនុស្សលំដាប់ទីពីររបស់បក្សឲ្យឡើងជំនួសជាបណ្តោះអាសន្ន ។ នៅពេលនោះអតីត សាឡុត ស មានសេរីភាពយ៉ាងពេញលេញដើម្បីគិតគូរពីព្រឹត្តិការណ៍សំខាន់មួយទៀតគឺការចាប់ខ្លួន កែវ មាស ជាមេដឹកនាំជាន់ខ្ពស់ម្នាក់ក្នុងចំណោមមេដឹកនាំកុម្មុយនិស្តជាន់ខ្ពស់ដែលកំពុងជាប់គុកនៅទួលស្លែង ។ នេះជាគោលដៅវាយប្រហារមួយក្នុងការតាមស្វែងរកនិងកម្ទេចបក្សពួកប្រឆាំងខាងនយោបាយ ដែលបក្សចាប់ដំណើរការដើម្បីប្រឆាំងនឹង «បណ្តាសមមិត្ត»របស់វៀតណាម ។

កែវ មាស ជាអតីតអ្នកប្រយុទ្ធតស៊ូដើងចាស់ម្នាក់ក្នុងសម័យសង្គ្រាមឥណ្ឌូចិនលើកទីមួយ នៅពេលដែលគាត់បានសុំចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិនដែលត្រួតត្រាដោយវៀតណាម ។ គឺរូបគាត់នេះដែរ ដែលជាអ្នករៀបចំចាត់ចែងបុគ្គលិកស្ថានីយ៍រថភ្លើងក្រុងភ្នំពេញឲ្យមានដំណើរការឡើងបន្ទាប់ពីសង្គ្រាមនោះផុតរលត់ទៅ ហើយគាត់បានដឹកនាំគណៈកម្មាធិការបក្សប្រចាំរាជធានីទៀត ។ នៅឆ្នាំ១៩៥៨ គាត់បានចាកចេញពីទីក្រុង ដើម្បីភៀសខ្លួនទៅទីកន្លែងដែលមានសន្តិសុខគ្រប់គ្រាន់ ហើយមុខតំណែងរបស់គាត់ត្រូវ ប៉ុល ពត កាន់ជំនួសវិញ ។ ក្នុងមហាសន្និបាតបក្សឆ្នាំ១៩៦០ កែវ មាស បានជាប់ឈ្មោះចូលក្នុងគណៈកម្មការមជ្ឈិមបក្ស ហើយបើទុកជាគាត់ពុំត្រូវបានជ្រើសរើសឡើងវិញ បន្ទាប់ពីមានការរើរុះនៅឆ្នាំ១៩៦៣ក៏ដោយ ក៏គាត់នៅតែជាឥស្សរជនសំខាន់ម្នាក់របស់បក្សដដែល ។

វាសំខាន់និងថ្លៃថ្នូរណាស់ ដែលបក្សជឿទុកចិត្តឲ្យគាត់រ៉ាប់រងបន្ទុកតាក់តែងប្រវត្តិសាស្ត្របក្សកុម្មុយនិស្តកម្ពុជាលើកដំបូងមួយដែលអាចល្មមទទួលយកបាន ។ ក្នុងមុខងារនេះ គាត់បានប្រមូលសក្ខីភាពទាំងអស់របស់មេដឹកនាំជាន់ខ្ពស់ រួមទាំង

ប៉ុល ពត ផង ហើយបានយល់ច្បាស់ពីផលដែលគេអាចឈានទៅដល់ការស្រុះស្រួលមួយអំពីថ្ងៃខែបង្កើតបក្សថែមទៀត ។ ដោយសារតែមូលហេតុនេះហើយ ទើបរយៈពេលជាងដប់ពីរឆ្នាំក្រោយមកគាត់ត្រូវបានចាប់ខ្លួននិងនាំទៅដាក់គុកនៅទួលស្លែង ដើម្បីបំភ្លឺពីការស្រុះស្រួលគ្នាក្នុងចម្លើយសារភាពជាបន្តបន្ទាប់មួយដើម្បីចោទប្រកាន់ខ្លួនឯងដែលបានចរចាពីរឿងនេះ និងអូសទាញបក្សឲ្យធ្លាក់ក្នុងការឃុបឃិតគ្នាជា សម្ងាត់មួយសំដៅបិទបាំងអត្តិភាពនៃបក្សសម្ងាត់ស្របគ្នាមួយដែលគ្រប់គ្រងដោយប្រទេសវៀតណាម ។


ហួត បុប្ផាណា: អ្នកទោសមន្ទីរស-២១
ចាប់ខ្លួននៅថ្ងៃទី ១៧/១០/៧៦
កម្ទេចនៅថ្ងៃ១៨/៣/៧៧

ការចោទប្រកាន់ទាំងនេះ ត្រូវបានរៀបចំយ៉ាងល្អិតល្អន់ ដោយការប្រឌិតហួសប្រមាណមួយ ប៉ុន្តែប្រកបដោយគោលដៅជាក់លាក់មួយដែលក្លាយទៅជាជាក់ស្តែងក្រោយពីនេះបន្តិច ។ ក្នុងចម្លើយសារភាពដំបូងៗដែលគាត់សរសេរមុនពេលត្រូវបង្ខំឲ្យទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួនក្រោមការធ្វើទារុណកម្ម កែ មាស នៅតែនិយាយកាន់ជើង ប៉ុល ពត និងក្រុមកុម្មុយនិស្តដែលស្ថិតនៅតែក្នុងប្រទេសកម្ពុជាក្រោយឆ្នាំ១៩៥៤ជានិច្ច ។ «មហាសន្និបាតឆ្នាំ១៩៦០ នៅក្នុងប្រទេសត្រូវបានសន្មតថាជាឆ្នាំនៃការបង្កើតបក្ស... ។ ពិនិត្យបញ្ហានេះឲ្យជិតដល់គេកត់សម្គាល់ថា ពីមុនមកពុំដែលមានបើកធ្វើមហាសន្និបាតទេ ហើយគេអាចចាត់ទុកមហាសន្និបាតឆ្នាំ១៩៦០ ថាជាមហាសន្និបាតបក្សលើកដំបូង ។

ក្នុងចម្លើយសារភាពរបស់គាត់ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ កែវ មាស បានបញ្ជាក់យ៉ាងច្បាស់អំពីប្រវត្តិនៃការស្រុះស្រួលគ្នាអំពីកាលបរិច្ឆេទនេះថា «បក្សបានសម្រេចប្រកាន់យកថ្ងៃទី៣០ ខែកញ្ញា (ជាថ្ងៃតែមួយដែលមហាសន្និបាតឆ្នាំ១៩៦០បើកប្រជុំ) ហើយឆ្នាំ១៩៥១ គឺជាឆ្នាំដែលមានចាត់តាំងបង្កើតគណៈកម្មាធិការកេណ្ឌប្រមូលកម្លាំងដើម្បីបង្កើតបក្ស» ។

កែវ មាស បានបញ្ជាក់ថា ការសម្របសម្រួលគ្នានេះពុំមានផ្តល់អត្ថប្រយោជន៍ដល់សមាជិកណាម្នាក់ឬចលនាណាមួយរបស់បក្សឡើយ ប៉ុន្តែដើម្បីបង្រួបបង្រួម«ក្រុមដែលប្រកាន់និន្នាការឆ្នាំ១៩៥១» និង«ក្រុមដែលប្រកាន់និន្នាការឆ្នាំ១៩៦០» តែប៉ុណ្ណោះ និយាយម្យ៉ាងទៀតគឺ អ្នកដែលចេញដំណើរទៅហាណូយ បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវនិងអ្នកស្ថិតនៅតែក្នុងប្រទេសកម្ពុជា ។ គាត់បានរៀបរាប់តាមលំដាប់លំដោយអំពីមូលហេតុផ្សេងៗដែលថា មហាសន្និបាតឆ្នាំ១៩៥១ពុំបានបង្កើតបក្សនៅឡើយទេ ប៉ុន្តែគ្រាន់តែបង្កើតគណៈកម្មាធិការមួយប៉ុណ្ណោះ ។ រឿងទាំងនេះប្រហែលជាអាចរកឃើញដោយការតាមដានយ៉ាងយកចិត្តទុកដាក់របស់ ប៉ុល ពត ប៉ុន្តែបក្សពុំមែនស្វែងរកការពិតជាប្រវត្តិសាស្ត្រទេ គឺបក្សចង់រកឲ្យឃើញការរួមគំនិតក្បត់មួយ ។

នៅទីបំផុត ដោយត្រូវធ្វើឲ្យឈឺចាប់ក្នុងចិត្ត កែវ មាស បាននិយាយឡើងវិញពីសេចក្តីថ្លែងមុនៗ ហើយបានអះអាងថា ការសម្របសម្រួលគ្នានេះពុំមែនជាការប្រឹងប្រែងដោយទៀងត្រង់ដើម្បីផ្សះផ្សានិន្នាការទាំងពីរនោះទេ ប៉ុន្តែគឺជាការរួមគំនិតក្បត់ដើម្បីបំផ្លាញភាពត្រឹមត្រូវតាមច្បាប់របស់បក្សកុម្មុយនិស្តកម្ពុជាទៅវិញ ។ ជាមួយនឹងចម្លើយសារភាពរបស់ កែវ មាស ក្នុងដៃស្រាប់ ប៉ុល ពត និងគណៈដឹកនាំបក្សអាចចាត់ចែងឲ្យធ្វើការផ្លាស់ប្តូរកាលបរិច្ឆេទថ្ងៃបង្កើតបក្សជាថ្មី ។ បន្ទាប់មក កែវ មាស ត្រូវយកទោសម្លាប់ចោល ។

ដើម្បីប្រកាសពីអត្តសញ្ញាណ កុម្មុយនិស្តរបស់បក្ស ដូចដែលប្រទេសចិនបានស្នើមេដឹកនាំបក្សត្រូវការវែកមុខនិងកម្ទេចបណ្តាសមាជិកដែលរួមគំនិតក្បត់ជាមួយ កែវ មាស ឲ្យអស់ជាមុនសិន ។

ឯកសារមួយរបស់បក្សបាននិយាយអំពីការគាបសង្កត់ជាច្រើន របស់បក្ស«ជាបងប្អូន»ដែរ នៅក្នុងពេលប្រកាសជាសាធារណៈពីអាទិភាពរបស់បក្ស ។ «*នៅខែកញ្ញានិងខែតុលា ឆ្នាំ១៩៧៦ យើងហៀបនឹងសម្រេចចិត្តបញ្ចេញឲ្យមហាជនពីអត្តសញ្ញាណរបស់យើងទៅហើយ ។ ប៉ុន្តែក្រោយមក ឯកសារផ្សេងៗបានបង្ហាញថា សត្រូវរបស់យើងបានប៉ុនប៉ងវាយប្រហារមកលើយើងដោយប្រើមធ្យោបាយគ្រប់បែបយ៉ាងទាំងអស់ ដែលគេរៀបបម្រុងជាស្រេច*» ។

ជាមនុស្សអាថ៌កំបាំងដោយសារចរិតពីកំណើត ប៉ុល ពត ប្រហែលជាប្រើប្រាស់ចម្លើយសារភាពទាំងអម្បាលម៉ានរបស់ កែវ មាស សម្រាប់ធ្វើជាមូលដ្ឋានបង្អែកក្នុងការសម្រេចចិត្តលាក់មុខពីក្រោយ«អង្គការ»តទៅទៀត ។ គេអាចសន្និដ្ឋានថា សាឡុត ស និងមេដឹកនាំឯទៀតៗនៃបក្សកុម្មុយនិស្តកម្ពុជាពុំចង់បញ្ចេញមុខឲ្យគេដឹងទេ ហើយចោទប្រកាន់ពីចំណងទាក់ទងរបស់ពួកគេជាមួយវៀតណាមឡើងវិញ មុនពេលដែលទុកចិត្តប្រាកដថា បន្ទាប់ពីមរណភាពរបស់ ម៉ៅ ប្រទេសចិននៅតែបន្តការគាំទ្រប្រទេសកម្ពុជាដដែល ។ ក្នុងអំឡុងរយៈកាលនេះ អ្នកតំណាងរបស់របបកម្ពុជាប្រជាធិបតេយ្យ បានយកចិត្តទុកដាក់ពង្រឹងជំហររបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងពិភពលោកទាំងមូល ។ ខៀវ សំផន ដែលក្លាយទៅជាប្រធានគណៈប្រធានរដ្ឋបានទៅចូលរួមសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ (ប្រទេសស្រីលង្កា) ជាទីដែលគាត់បានប្រកាន់បុកពាជាអ្នកការទូតរបស់ប្រទេសមួយដែលប្រឆាំងដាច់ខាតមិនចូលរួមក្នុងប្លុកណាមួយ ។ គាត់ពុំបានរួមដៃជាមួយប្រទេសឡាវនិងវៀតណាមក្នុងការថ្កោលទោសសំណើរបស់«អាស៊ាន» (កាលណោះមានប្រាំមួយប្រទេសគឺ ថៃ ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន ឥណ្ឌូនេស៊ី និងប្រុយណេ) ដើម្បីបង្កើតតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតមួយ នៅអាស៊ី-អាគ្នេយ៍ ។ គាត់បែរជាបញ្ជាក់ដោយប្រុងប្រយ័ត្នពីការគាំទ្ររបស់គាត់ចំពោះឯករាជ្យនៃកោះទីម័រខាងលិចដែលស្ថិតក្រោមការកាន់កាប់របស់ប្រទេសឥណ្ឌូនេស៊ីទៅវិញ ។

នៅឯមហាសន្និបាតអង្គការសហប្រជាជាតិ អៀង សារី បានថ្លែងចំណាប់អារម្មណ៍មួយរបៀបដូចគ្នា ដោយប្រកាសថា កម្ពុជាប្រជាធិបតេយ្យជាប្រទេសមួយដែលមិនចូលបក្សសម្ព័ន្ធដាច់ខាត ។ គាត់បានជំរុញដោយទទូចឲ្យបណ្តាប្រទេសក្រីក្រជាច្រើននៅអង្គការសហប្រជាជាតិបញ្ចប់នូវការត្រួតត្រាមួយរបស់ប្រទេសអ្នកមានដែលប្រព្រឹត្តមកលើអង្គការកំពូលនេះ ។ គណៈប្រតិភូមួយរបស់កម្ពុជាបានទៅធ្វើទស្សនកិច្ចនៅតាមប្រទេសកុម្មុយនិស្តជាច្រើន ដូចជា អាល់បានី កូរ៉េខាងជើងវៀតណាម និងឡាវ ។ ប្រទេសវៀតណាមនិងកម្ពុជាបានព្រមព្រៀងគ្នារៀបចំឲ្យមានការទាក់ទងតាមផ្លូវអាកាសជាប្រក្រតី ។ នៅក្នុងអំឡុងឆ្នាំដំបូងនៃការកាន់អំណាចពួកខ្មែរក្រហមហាក់ដូចជាចង់កំណត់ឲ្យច្បាស់លាស់នូវជំហរផ្អែកការទូតផ្ទាល់របស់ខ្លួន ដែលជាជំហរឯករាជ្យមិនចំណុះប្រទេសចិននិងវៀតណាម ប៉ុន្តែក៏មិនប្រឆាំងនឹងប្រទេសទាំងពីរនេះដែរ ។ ប្រហែលជាបក្សការពារខ្លួនជាមុនទល់នឹងអំពើក្បត់ដោយថាហេតុមួយរបស់ចិនបន្ទាប់ពីមរណភាពរបស់ ម៉ៅ ហើយមើលទៅ ។

គ្មានអ្នកណាម្នាក់នឹកឃើញថា ប៉ុល ពត បានជាប់ដៃប្រឡូកក្នុងការតស៊ូមួយដើម្បីដណ្តើមអំណាច ឬថាបក្សហៀបនឹងបែកបាក់គ្នាអំពីបញ្ហាទំនាក់ទំនងជាមួយនឹងប្រទេសវៀតណាមឡើយ ប៉ុន្តែគេរកស្មានមិនត្រូវតើអ្នកណាមួយហ៊ានជំទាស់នឹង ប៉ុល ពត នៅក្នុងកាលៈទេសៈនេះ ។ លេខាបក្សភូមិភាគបូព៌ាដ៏មានអំណាចបំផុតគឺ សោ ភឹម បានរួមសហការយ៉ាងពេញទំហឹងក្នុងការបោសសម្អាតអតីតភូមិភាគឧត្តរដែលសម្រេចដោយមជ្ឈិម ។ តាម៉ុក ដែលជាលេខាបក្សនៃភូមិភាគនិរតី ក៏មានអំណាចសំខាន់ណាស់ដែរបន្ទាប់ពី សោ ភឹម ក៏ធ្លាប់បានចូលរួមក្នុងការជម្លៀស «ប្រជាជនថ្មី» យ៉ាងច្រើនចេញពីតំបន់របស់គាត់ទៅកាន់ភូមិភាគពាយ័ព្យដែរ ។ តាមចម្លើយសាក្សីជាច្រើនដែលយកជាការបាន គណៈលេខាមជ្ឈិមបក្សបានអនុម័តយល់ព្រមតាមមតិណែនាំទាំងអស់របស់ ប៉ុល ពត រហូតមកដល់កាលបរិច្ឆេទនេះ ។ [*សមាជិកគណៈលេខានៃគណៈកម្មាធិការមជ្ឈិមបក្សមុនការបោសសម្អាតឆ្នាំ១៩៧៨ រួមមាន ប៉ុល ពត, នួន ជា, តាម៉ុក, សោ ភឹម, អៀង សារី, វ៉ន វេត, សុន សេន និងតាគី (នៃបញ្ជាការដ្ឋានកងទ័ពភូមិភាគពាយ័ព្យ) ។ នៅចុងឆ្នាំ១៩៧៨ តាគី, វ៉ន វេត និង សោ ភឹម ត្រូវបានសម្លាប់តាមបញ្ជារបស់ប៉ុលពត*] ។

បើពិនិត្យមើលតាមសភាពខាងក្រៅ ទំនាក់ទំនងផ្សេងៗជាមួយប្រទេសវៀតណាមមានសភាពល្អប្រសើរៈ ផ្លូវអាកាសមួយបានពីភ្នំពេញទៅទីក្រុងហូជីមិញ ហើយខបទ្ធវហេតុហេតុផ្សេងៗ នៅតាមព្រំដែនក៏មិនសូវមានញឹកញាប់ដែរ ។ ប្រទេសទាំងពីរបានចាត់ទុកសហរដ្ឋអាមេរិកជាសត្រូវសំខាន់បំផុតហើយ អៀង សារី បានធ្វើសេចក្ដីថ្លែងការណ៍មួយនៅអង្គការសហប្រជាជាតិចោទប្រកាន់សហរដ្ឋអាមេរិកថា នៅតែបន្តនាំមុខធ្វើ«សកម្មភាពឧក្រិដ្ឋ» ផ្សេងៗប្រឆាំងនឹងប្រជាជនកម្ពុជា ។ វៀត-ណាមទើបនឹងត្រូវបានទទួលការអនុញ្ញាតឲ្យចូលអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ថ្វីបើមានការប្រឆាំងពីអាមេរិកក៏ដោយ ។

ហេតុនេះ វាពុំមានមូលហេតុសមស្របណាមួយដើម្បីចាត់ចែងស្រាវជ្រាវនិងកម្ទេចបក្សពួកប្រឆាំងខាងនយោបាយជាសម្ងាត់នៅក្នុងផ្ទៃបក្សឡើយ ។ ប្រទេសវៀតណាមមិនសម្ដែងឲ្យឃើញលក្ខណៈគំរាមកំហែងខ្លាំងជាងគេទេ ហើយម្យ៉ាងទៀតក៏ពុំមានការខ្វែងគំនិតដោយចំហក្នុងផ្ទៃបក្សដែរ ។ ដំណាក់កាលនេះគឺជាឧទាហរណ៍មួយទៀតនៃការគិតអំពល់ពីរឿងអំណាចនិងលាក់ការណ៍ដែលធ្វើឲ្យមជ្ឈិមកើតទុក្ខដោយសារវា ។ បក្សបានសម្លាប់ភាគច្រើននៃ«ពួកកុម្មុយនិស្តឆ្នាំ១៩៥១» នៅពេលដែលពួកនេះវិលត្រឡប់ពីវៀតណាមខាងជើងមកវិញក្នុងរយៈពេលសង្គ្រាម ។ ហេតុនេះ ប៉ុល ពត និងមេដឹកនាំមួយក្ដាប់តូចគ្មានឃើញមូលហេតុណាមួយដើម្បីរក្សានូវការសម្របសម្រួលគ្នា (ដែលគេគ្រាន់តែសន្មត) ស្ដីពីកាលបរិច្ឆេទនៃការបង្កើតបក្សទៀតទេ ។ ដោយផ្លាស់ប្ដូរកាលបរិច្ឆេទនេះ បក្សបានប្រកាសឲ្យដឹងជាសាធារណៈថា មជ្ឈិមបានក្ដោបក្ដាប់អំណាចផ្ដាច់ការរបស់ខ្លួនលើការបដិវត្តន៍យ៉ាងពិតប្រាកដហើយ ។

ឌុច បានប្រើពេលអស់មួយឆ្នាំទៀតតាមរយៈការធ្វើទារុណកម្មដើម្បីទទួលបាន «ភស្តុតាង» អំពីបក្សសម្ងាត់របស់កម្ពុជាដែលគ្រប់គ្រងដោយវៀតណាម ។ ឌុច ប្រមូលបានភស្តុតាងក្នុងចំនួនមួយគ្រប់គ្រាន់សម្រាប់ការប្រារព្ធបុណ្យខួបកំណើតបក្សនៅឆ្នាំ១៩៧៧ ដែលក្នុងឱកាសនោះ ប៉ុល ពត បានប្រកាសជាផ្លូវការថា បក្សកុម្មុយនិស្តកម្ពុជាគឺជាអ្នកកាន់អំណាចនៅប្រទេសកម្ពុជា ។

ការដាក់ឲ្យអនុវត្តនូវគម្រោងការដ៏ធំមួយទៀតរបស់ ឌុច គឺការវែកមុខនិងកម្ទេចសមាសភាពគហបតីនិងបញ្ញវន្តក្នុងជួរបក្សបានទទួលជោគជ័យដូចគ្នា ។

ភាគច្រើននៃគំនិតនិងសកម្មភាពផ្សេងៗរបស់គណៈដឹកនាំបក្សច្រើនតែមិនសមហេតុផលនិងចម្លែកគួរឲ្យឆ្ងល់ ។ ប៉ុន្តែការប្រព្រឹត្តខុសគន្លងនេះមានរបៀបអនុវត្តម្យ៉ាងដោយឡែករបស់វាដែលគេរកឃើញក្នុងឯកសារផ្សេងៗនៅមន្ទីរឃុំឃាំងទួលស្លែងនិងឯកសារសម្ងាត់របស់បក្ស ។ ប៉ុន្តែ ក្នុងក្របខ័ណ្ឌនៃរបៀបអនុវត្តទៅម្យ៉ាងដោយឡែក ដែលសម្លាប់មនុស្សដោយចេតនានេះហាក់ដូចជាមិនទំនងទាល់តែសោះ ។

នៅឆ្នាំ១៩៧៥និង១៩៧៦ ឥស្សរជនជាច្រើនដូចជាជួន ប្រសិទ្ធិ ជាដើម បានសម្ដែងឲ្យឃើញការប្រឹងប្រែងជាច្រើនក្នុងគោលបំណងធ្វើអ្វីមួយដើម្បីបញ្ចុះបញ្ចូលឲ្យជនជាតិកម្ពុជាដែលកំពុងរស់នៅឯបរទេសត្រឡប់ចូលមកប្រទេសវិញដើម្បីចំណែកកសាងបដិវត្តន៍ ។ ពួកបញ្ញវន្តនិងអ្នកមានវិជ្ជាជីវៈសេរីដែលធ្លាប់គាំទ្រសម្ដេចព្រះ នរោត្តម សីហនុ និងខ្មែរក្រហមក្នុងសម័យសង្គ្រាម បានឆ្លើយតបនឹងការអំពាវនាវនេះ ។ អ្នកខ្លះក្នុងចំណោមនោះធ្លាប់បានឮការនិយាយពីការកាប់សម្លាប់មនុស្សនិងការអត់ឃ្លាន ការដំណាលរបស់ប្រជាជនជាច្រើនដែលរត់ភៀសខ្លួនទៅប្រទេសថៃដែរ ប៉ុន្តែអ្នកទាំងនោះមិនព្រមជឿទេ ដោយចាត់ទុកថាជាការឃោសនាបោកប្រាស់ ។ ភាគច្រើននៃជនជាតិកម្ពុជាទាំងនេះពុំមែនជាសមាជិកបក្សទេ ប៉ុន្តែជាអ្នកមានសមានចិត្តធម្មតា ដែលមានបំណងថា ការបដិវត្តសង្គមនិយមច្បាស់ជាធ្វើឲ្យប្រទេសគេផ្លាស់សភាពទ្រង់ទ្រាយនិងធ្វើឲ្យជោគវាសនារបស់ខ្លួនបានប្រសើរជាងមុន ។

បញ្ញវន្តបានលះបង់មុខរបរនិងគ្រួសាររបស់ខ្លួននៅសហរដ្ឋអាមេរិក ប្រទេសបារាំង កាណាដា ឬ បណ្ដាប្រទេសអឺរ៉ុបខាងកើត ។ ពួកគេសុខចិត្តបោះបង់មុខតំណែងទូតនៅមជ្ឈិមបូព៌ា ឬនៅអាស៊ីនិងបណ្ដាប្រទេសកុម្មុយនិស្ត និងមិនមែនកុម្មុយនិស្តដែលពួកគេធ្លាប់ធ្វើជាតំណាងបុព្វហេតុរណសិរ្សរួបរួមជាតិកម្ពុជាក្នុងសម័យសង្គ្រាម ហើយវិលត្រឡប់មកក្រុងភ្នំពេញវិញសម្រាប់តែឲ្យបក្សចាត់ទុកជាឥស្សរជនដែលគួរឲ្យសង្ស័យឬជាមនុស្សក្បត់

ប៉ុណ្ណោះ ។

អ្នកការទូតមួយក្រុមដែលហៅឲ្យត្រឡប់មកទីក្រុងភ្នំពេញវិញនៅឆ្នាំ១៩៧៦ ត្រូវបានដឹកពីអាកាសយានដ្ឋានពោចិនតុងទៅកាន់មន្ទីរឃុំឃាំងទួលស្លែងជាបន្ទាន់ ជាទីដែលអ្នកទាំងនោះត្រូវបានធ្វើទារុណកម្មនិងប្រហារជីវិត ។ ទោសរបស់អ្នកទាំងនោះគឺធ្លាប់រស់នៅឯបរទេស ដូច្នេះ «ដាច់ពីចលនាបដិវត្តន៍ហើយ» និងមានទម្លាប់ផ្តេសផ្តាសដោយការសេពគប់ជនបរទេស ។ ការស្អប់ជនបរទេសរបស់ខ្មែរក្រហមបានកើនរឹតតែខ្លាំងឡើងគ្មានឈប់ឈរ ។

បញ្ញវន្តនិងអ្នកមានវិជ្ជាជីវៈដែលត្រឡប់ពីបរទេសមកមាតុប្រទេសវិញ បានទទួលការធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅនៅពេលមកដល់ដំបូង ។ ក្នុងចំណោមនោះមាន ទ្រី ម៉េងហ៊ួត ដែលធ្លាប់បានរួមចំណែកធ្វើសកម្មភាពនយោបាយយ៉ាងសកម្មដើម្បីបុព្វហេតុ «សង្គមនិយម» នៅទីក្រុងប៉ារីសក្នុងពេលប្រទេសមានសង្គ្រាមដោយលះបង់ការសិក្សានិងសុខភាពរបស់គាត់ដើម្បីបដិវត្តន៍មួយដែលនឹងនាំមកនូវយុត្តិធម៌និងសេរីភាពសម្រាប់ប្រទេសរបស់គាត់ ។ គាត់បានវិលមកទីក្រុងភ្នំពេញវិញនៅចុងឆ្នាំ១៩៧៥ ព្រោះត្រូវធ្វើឲ្យស្រើបចិត្តខ្លាំងដោយទស្សនវិស័យមួយដើម្បីកសាងលទ្ធិសង្គមនិយមនៅប្រទេសកម្ពុជា ។ គាត់យល់ច្បាស់ពីការភាន់ច្រឡំរបស់គាត់តាំងពេលគាត់មកដល់អាកាសយានដ្ឋានពោចិនតុងម៉្លេះ ។

«យើងត្រឡប់មកប្រទេសវិញជុំគ្នាទាំងអស់ មានបញ្ញវន្តមកពីប្រទេសបារាំង រូម៉ានី អង់គ្លេស និងអាមេរិក...។ ខ្មែរក្រហមបានអនុញ្ញាតឲ្យគូស្វាមីភរិយាជាតិបរទេសតែម្នាក់គត់តាមមកជាមួយប្តីរបស់នាង ដោយសារការធ្វើអន្តរាគមន៍របស់សម្តេចព្រះ នរោត្តម សីហនុ ផង (ដែលនៅតែជាមេដឹកនាំរដ្ឋាភិបាលរណសិរ្សមានតែឈ្មោះប៉ុន្តែឥតអំណាច» ។

ទីក្រុងភ្នំពេញដែល ហ៊ួត បានឃើញឡើងវិញបន្ទាប់ពីការរស់នៅប្រាំបួនឆ្នាំនៅបរទេស លែងជាទីក្រុងដែលគាត់ធ្លាប់រក្សាអនុស្សាវរីយ៍ទៀតហើយ ។ «ទីក្រុងមានសភាពប្រែប្រួលខ្លាំងរហូតធ្វើឲ្យខ្ញុំស្រយុតចិត្ត ។ តាមខ្ញុំយល់ទីក្រុងដែលផ្លាស់ប្តូរច្រើនដូច្នេះប្រហែលពីព្រោះរបបថ្មីមិនចង់ឲ្យមានភាពខុសគ្នាខ្លាំងពេករវាងអ្នកមាននិងអ្នកក្រហើយមើលទៅ» ។

ហ៊ួត មានអាយុសាមសិបឆ្នាំ ។ តាមពាក្យសម្តីផ្ទាល់របស់គាត់ថាគាត់ជា«សកម្មជន»ម្នាក់នៃចលនាសង្គមនិយម ជានិស្សិតក្រីក្រម្នាក់ដែលតស៊ូយ៉ាងត្រដាបត្រដួសទប់ទល់នឹងជីវភាពដើម្បីបុព្វហេតុបដិវត្ត ។ ដូចជាគ្មានបានផលប្រយោជន៍អ្វីបន្តិចសោះក្នុងការសាកល្បងរបស់គាត់កន្លងមក ពេលដែលគាត់ចាប់ផ្តើមនឹកព្រួយបារម្ភតាំងពីការមកដល់ដំបូងម៉្លេះ ។

ខៀវ សំផន ត្រូវបានចាត់តាំងឲ្យមកអប់រំនយោបាយដល់បញ្ញវន្តដែលទើបនឹងចុះពីយន្តហោះនេះ ។ បញ្ញវន្តទាំងបីរយនាក់ ត្រូវអង្គការឲ្យស្នាក់នៅតាមបន្ទប់ផ្សេងៗនៃអតីតសាកលវិទ្យាល័យបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។ ខៀវ សំផន បាននិយាយថា «យើងសុទ្ធតែស្មើភាពគ្នា ។ មនុស្សទាំងអស់ត្រូវតែធ្វើការ ។ ក្នុងប្រទេសពុំមានស្រូវអង្ករច្រើនទេ ។ បដិវត្តន៍ជាកាតព្វកិច្ច រួមគ្នានឹងចិន» ។

ខៀវ សំផន ពុំមានលើកនិយាយពីប្រទេសវៀតណាមទេ ។ ការអប់រំនយោបាយបានចប់ត្រឹមនេះ ហើយការងារបានចាប់ផ្តើមភ្លាមដោយគ្មានបង្អែបង្អង់ ។ ហ៊ួត បានដំណាលថា «បញ្ញវន្តទាំងអស់ត្រូវអង្គការដាក់ឲ្យស្នាក់នៅក្នុងរោងបណ្តោះអាសន្នជាច្រើនដែលមានមនុស្សពេញណែនដូចជំរំអ្នកភៀសខ្លួន» ។ យើងធ្វើការដប់ពីរម៉ោងក្នុងមួយថ្ងៃ ដាំស្រូវនិងបន្លែបង្ការផ្សេងៗ ។ យើងទាំងអស់សុទ្ធតែមានបញ្ហាខាងសុខភាពនិងផ្លូវចិត្ត ។ ខ្ញុំមិនដែលនឹកគិតថារឿងនេះ អាចកើតមានចំពោះរូបខ្ញុំសោះ ។ ខ្ញុំគិតថានឹងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីប្រទេសរបស់ខ្ញុំ ប៉ុន្តែពុំមែនដាំស្រូវឬដាំស្ពៃពេញមួយឆ្នាំអីចឹងទេ» ។

ហ៊ួត បានសន្និដ្ឋានថា នៅចុងឆ្នាំ១៩៧៦ មានបញ្ញវន្តពីប្រាំរយទៅប្រាំមួយរយនាក់ធ្វើការនិងរស់នៅជាមួយគ្នាក្នុងតំបន់ជុំវិញទីក្រុងភ្នំពេញដាច់ឡែកពីប្រជាជនទាំងអស់ ។ ហ៊ួត នៅនឹកឃើញថា អ្នកដែលត្រឡប់ពីសហរដ្ឋអាមេរិកមកវិញត្រូវយកទៅដាក់ឲ្យរស់នៅឆ្ងាយពីអ្នកដទៃ ។ គឺនៅជិតនាន់នោះហើយដែល ហ៊ួត និងបញ្ញវន្តដទៃទៀត ត្រូវគេចាត់ឲ្យទៅធ្វើការនៅក្នុងផ្នែកមួយក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងឧស្សាហកម្ម បើតាមគាត់ស្មាន គឺដើម្បីជំនួសកម្មករប្រមាណ

ដប់នាក់ដែលត្រូវសន្តិបាលសម្លាប់នៅក្នុងមន្ទីរឃុំឃាំងទួលស្លែង នោះហើយ ។ ហ៊្វូត នៅធ្វើការក្នុងរោងចក្រស្មូដែកលេខ៧ តាម មាត់ទន្លេបាសាក់ ហើយបានមើលឃើញពីចម្ងាយនូវរបៀបរបប រស់នៅរបស់បណ្តាសមាជិកអ្នកមានឯកសិទ្ធិ ។

អ្នកត្រួតការនិងកម្មករសុទ្ធតែជាកម្មាភិបាលខ្មែរក្រហម ។ ហ៊្វូត រៀបរាប់ថា «នៅភ្នំពេញ អ្នកទាំងនោះស្នាក់នៅក្បែរ កន្លែងរបស់យើងដែរ ធ្វើការជាមួយយើង ប៉ុន្តែបរិភោគយ៉ាង គ្រប់គ្រាន់ នៅពេលដែលយើងហូបតែបបររាវប៉ុណ្ណោះ ។ នេះ ពុំមែនជាសមភាពទេ ។ រឿងនេះវាមិនសំខាន់ ប៉ុន្មានទេកាលបើ ខ្ញុំមិនដឹងស្លាប់ឬរស់នោះ ។ តើខ្ញុំអាចអួតខ្លួនបម្រើប្រទេសខ្ញុំដូច ម្តេចទៅ? »

ទ្រី ម៉េងហ៊្វូត និងបញ្ញវន្តដទៃទៀត បានចំណាយពេល វេលាដ៏សំខាន់បំផុតក្នុងជីវិតរបស់ខ្លួនដើម្បីសិក្សាអំពីបញ្ហា ដែល ឥឡូវនេះប្រទេសកម្ពុជាកំពុងតែប្រឈមមុខ -តើត្រូវប្រើប្រាស់ ឲ្យអស់លទ្ធភាពនូវប្រភពធនធានដ៏ស្តួចស្តើងរបស់ខ្លួន ត្រូវធ្វើ ទំនើបកម្មកសិកម្មនិងឧស្សាហកម្មដោយមិនពឹងផ្អែកសហគ្រាស ចម្រុះជាតិ ឬមហាអំណាចបរទេសដោយរបៀបណាទៅ? តើត្រូវ ប្រើមធ្យោបាយបែបណាដើម្បីញ៉ាំងឲ្យប្រជាជនជឿថា ការងារ និងការធ្វើពលិកម្មផ្សេងៗ ដែលផ្តល់ឲ្យក្នុងដំណាក់កាលដំបូងនៃ ការបដិវត្តន៍ពិតជាទទួលបានលទ្ធផលក្នុងការកែលម្អជីវភាពរស់ នៅប្រសើរជាងមុននិងធ្វើឲ្យមានឯករាជ្យពេញលេញ? ។ ប៉ុន្តែ បញ្ញវន្តត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់ចំណេះដឹងរបស់ខ្លួន ឡើយ ។ ការសិក្សាស្រាវជ្រាវរបស់បានក្លាយទៅជារបស់បញ្ញវន្ត ទាំងនោះដែលអន្តការសង្ស័យទៅវិញ ។ បញ្ញវន្តត្រូវតែលុប លាងទោសដោយធ្វើការងារបញ្ញវន្តជាច្រើនឆ្នាំដែលពួកគេត្រូវ បំពេញដើម្បីបម្រើខ្មែរក្រហម ។ ហ៊្វូត ដែលធ្លាប់តែជឿថា អាចក្លាយទៅជាសមាជិកបក្សកាន់អំណាចនោះ ពេលនេះទើប ដឹងខ្លួនថាជាទាសកររបស់បក្សទៅវិញសោះ ។ មានតែប្រជាជន កម្ពុជាដែលមានវណ្ណៈភាពដើមត្រឹមត្រូវមួយចំនួនប៉ុណ្ណោះ ដែល ចាត់ទុកជាមុខសញ្ញាល្អក្នុងការត្រៀមបញ្ចូលក្នុងជួរបក្ស ។ តាម បញ្ជីរបស់គណៈលេខាមជ្ឈិម សុន សេន និង ឌុច បានយកចិត្ត ទុកដាក់កម្ចាត់សមាសភាពគហបតីចេញពីក្នុងផ្ទៃបក្ស ពុំមែន បង្កើនចំនួនសមាជិកបក្សទេ ។

នៅឆ្នាំ១៩៧៧ បក្សកុម្មុយនិស្តបានចាប់ផ្តើមដាក់គុកនិង សម្លាប់បញ្ញវន្ត មន្ត្រី ដែលត្រឡប់មកពីបរទេសអស់មួយចំនួន (បញ្ញវន្ត១៤៨នាក់ដែលមានឈ្មោះក្នុងសំណុំឯកសារនៅ មន្ទីរឃុំឃាំងទួលស្លែងនិងអ្នកត្រូវសម្លាប់ភ្លាមៗតាំងពីដំបូង ឬ ត្រូវ«បាត់ខ្លួន»តែម្តង) ។

អ្នករងគ្រោះថ្មីៗទាំងនេះត្រូវសរសេររៀបរាប់ពី «ខ្សែ បណ្តាញ»របស់ខ្លួន ដែលជាអ្នកសមគំនិត ។ នេះជារបៀបចាត់ ចែងថ្មី ដើម្បីរកឲ្យឃើញ «សម្ព័ន្ធចារបុរស» ក្នុងប្រទេស ទាំងមូល ហើយតាម សារី ថា បញ្ហានេះត្រូវបានអនុម័តយល់ ព្រមតាំងពីឆ្នាំ១៩៧៦ម៉្លេះ ។ ទស្សនៈអំពី«ខ្សែបណ្តាញ»នេះគឺ ជារបៀបមួយដែលផ្សេងពីរបៀបចាត់ចែងរបស់ ស្តាលីន ដោយសារថា បណ្តាមិត្តភក្តិ ឪពុកម្តាយ និងសហការី ដែល មាននិន្នាការដូចគ្នាត្រូវបានវិនិច្ឆ័យជាអ្នកមានទោសពីបទសម គំនិតជាមួយនឹងអ្នកជាប់ចោទ ។

របៀបចាត់ចែងរកខ្សែបណ្តាញរួមគំនិតក្បត់បានក្លាយទៅ ជាបញ្ហាស្នូលរបស់មណ្ឌលសន្តិសុខដែលរៀបចំឡើងដោយ ឌុច និងបក្សដើម្បីបោសសម្អាត ។ មេដឹកនាំបក្សខិតខំស្រាវជ្រាវរក របៀបចាត់ចែងដ៏ល្អឥតខ្ចោះ ដែលពួកខ្មាំងសត្រូវបិទបាំងដើម្បី បំផ្លាញឲ្យដល់ឬសគល់នូវកិច្ចប្រឹងប្រែងរបស់ប្រជាជន ហើយ នៅទីបំផុតបំផ្លាញបដិវត្តន៍ថែមទៀត ។ តាមការឲ្យដឹងរបស់ អៀង សារី ថា ប្រសិនបើមនុស្សបីនាក់ចោទប្រកាន់មនុស្សម្នាក់ ថាបានរួមគំនិតប្រឆាំង និងជាសមាជិកនៃ«ខ្សែបណ្តាញ»មួយជន នេះនឹងត្រូវសន្មតថាជាអ្នកមានទោស ហើយអាចត្រូវចាប់ខ្លួន ទៀត ។ សារី បានបញ្ជាក់ថាៈ បើសិនមនុស្សបីនាក់អះអាងថា ម្នាក់ ក្នុងចំណោមបីនាក់ជាភ្នាក់ងារ សេ.អ៊ី.អា. ឬ កា.ហ្សេ.បេ. ម្នាក់ នោះក៏ត្រូវចាប់ខ្លួនដែរ» ។

ឌុច និងក្រុមសន្តិបាល បានគិតគូរអំពីការរួមគំនិតក្បត់និង ខ្សែបណ្តាញដ៏សាំញ៉ាំជាច្រើន ហើយបង្ហាញជាថ្មីលើបញ្ជីរាយ ឈ្មោះ ។ សន្តិបាលពុំហ៊ានបង្ហាញខ្លួនជាពេជ្ឈឃាតសាមញ្ញ ដែលកំពុងតែសម្លាប់គូប្រជែង ឬខ្មាំងសត្រូវដោយគ្មានអាណិត អាសូរនោះទេ ។ សន្តិបាលទាំងនោះបានចាត់ចែងការសម្លាប់

តែម៉្យាងគត់ គឺបន្ទាប់ពីពួកអ្នកទោសទទួល«សារភាព»ថាខ្លួនជាដើមហេតុនៃរាល់បញ្ហាដែលចោទឡើងចំពោះបដិវត្តន៍ ។ ការធ្វើទារុណកម្ម និងការសម្លាប់ត្រូវបានចាត់ទុកថាជាវិធីដែលចាំបាច់ខានមិនបាន ដើម្បីស្រាវរកខ្សែបណ្តាញក្បត់ ។ ភាគច្រើននៃមនុស្សដែលមានរៀបរាប់ក្នុងខ្សែបណ្តាញ បញ្ញវន្តទាំងនេះសុទ្ធតែជាបុគ្គលិកនៅក្រសួងការបរទេស ក្នុងនោះមានទាំង ជួន ប្រសិទ្ធិផង ។ ក្រសួងនេះ ជាមុខសញ្ញាធំមួយក្នុងចំណោមមុខសញ្ញាសំខាន់ៗនៃរលកបោសសម្អាតជាលើកដំបូងប្រឆាំងនឹងវណ្ណៈអនុធនពីព្រោះថាគ្មានក្រសួងណាផ្សេង មានអតីតបញ្ញវន្តច្រើនដូចក្រសួងនេះទេ ។ ភាគច្រើននៃនិស្សិតនិងសាស្ត្រាចារ្យ គ្រូបង្រៀនដែលត្រឡប់មកពីបរទេសក្រោយឆ្នាំ១៩៧៥ សុទ្ធតែស្គាល់រាប់អានមនុស្សដែលធ្វើការនៅក្រសួងការបរទេស ជាពិសេស ប្រសិទ្ធិ និង អៀង សារី ហើយអ្នកទាំងនោះបានរួមការងារជាមួយអ្នកទាំងពីរទៀតផង ។ ឥស្សរជនបក្សម្នាក់ក្នុងចំណោមឥស្សរជនដំបូងៗរបស់បក្ស ដែលត្រូវយកទៅដាក់គុកនៅទួលស្លែងនាខែកុម្ភៈ ឆ្នាំ១៩៧៦ គឺជាមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្រសួងនេះ ។

ម៉្យាងទៀត ក្រសួងការបរទេសត្រូវបានអង្គការចម្រាញ់យកអ្នកមិនល្អចេញជាប់ជាប្រចាំពេញមួយរយៈវេលានៃសម័យកាលខ្មែរក្រហម ថ្វីបើ អៀង សារី ជាមេដឹកនាំនៅក្រសួងនេះក៏ដោយ ។ ដោយពិតទៅ អៀង សារី បានលាក់បំពួនបញ្ញវន្តដែលមានចំណេះវិជ្ជាខ្ពស់ បុរសនិងស្ត្រីដែលធ្លាប់ចំណាយពេលវេលាជាច្រើនឆ្នាំនៅបរទេសក៏ដូចនៅក្នុងព្រៃភ្នំ ។ សារី បានសម្តែងឲ្យឃើញថាគាត់គ្មានសមត្ថភាពការពារពួកអ្នកទាំងនោះបានទេ ហើយក៏ពុំអាចបញ្ជូនអ្នកទាំងនោះទៅបរទេសវិញដែរ ។ នួន ជា បានបដិសេធផ្តល់ទិដ្ឋាការឲ្យកម្មាភិបាលមួយចំនួនដែល សារី បានស្នើសុំសម្រាប់មុខតំណែងការទូតមួយនៅបរទេស ។ ក្នុងរបាយការណ៍ដំណាច់ឆ្នាំ១៩៧៦ មេដឹកនាំម្នាក់បានត្អូញត្អែរអំពីការខ្វះខាតកម្មាភិបាលចេះដឹងសម្រាប់បញ្ជូនទៅបរទេសថា៖ «ការខ្វះខាតតែមួយគត់របស់យើងនៅបរទេស គឺគ្មានកម្មាភិបាលដែលអាចធ្វើការក្នុងវិស័យទំនាក់ទំនងក្រៅប្រទេស ។ អ្នកខ្លះដែលវិលពីបរទេសត្រូវយើងដកចេញពីជនបដិវត្តន៍ ។ អ្នកខ្លះទៀតមានប្រវត្តិដើមគួរទទួលយកបាន ប៉ុន្តែគ្មានគុណសម្បត្តិចាំបាច់ដែលបក្សត្រូវការសម្រាប់បម្រើចលនាបដិវត្តន៍ឡើយ ។ បច្ចុប្បន្ននេះយើងត្រូវការឯកអគ្គរដ្ឋទូតថ្មីពីបួនទៅដប់នាក់ ហើយយើងសូមឲ្យអ្នកដែលបានចូលរួមក្នុងសម័យប្រជុំនេះផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហានេះផង» ។

របបនេះត្រូវការឯកអគ្គរដ្ឋទូតថ្មីជាច្រើននាក់ ដោយសារតែក្រុមសន្តិសុខបានចាប់ខ្លួននិងសម្លាប់អ្នកការទូតចាស់ៗអស់ទៅហើយ ។

អ្នកបញ្ញវន្តនិយមឆ្វេងនិយម អ្នកមានសមានចិត្តនឹងលទ្ធិកុម្មុយនិស្តដែលត្រឡប់ពីបរទេសមកវិញ ត្រូវសម្លាប់នៅទួលស្លែង ឬដាក់ឲ្យរស់នៅក្នុង «ជំរំពិសេសសម្រាប់បញ្ញវន្ត» ដែលនៅតាមច្រកចេញពីទីក្រុងភ្នំពេញ ។ សារី បានបញ្ចប់ការតស៊ូដែលគ្មានសង្ឃឹមនេះមុនពេលកំណត់ដើម្បីឲ្យទទួលបានការអនុញ្ញាតបញ្ជូនអ្នកការទូតដែលមានបទពិសោធន៍ទៅបរទេស ដោយសារគាត់ពុំអាចបញ្ជូនកសិករបដិវត្តន៍ដែលមិនចេះអក្សរ ដែលពុំធ្លាប់ផ្តល់អត្ថប្រយោជន៍បន្តិចសោះឲ្យទៅជំនួសឡើយ ដូច្នេះមុខតំណែងទូតជាច្រើននៅបរទេសនៅតែទំនេរគ្មានអ្នកណាកាន់កាប់រហូត ។

ប៉ុន្តែ ដោយបណ្តាលេខាបក្សត្រូវប្រឈមមុខនឹងការបោសសម្អាតតាមភូមិភាគ សារី បានយល់ព្រមឲ្យអង្គការបោសសម្អាតក្រសួងរបស់គាត់និងសម្លាប់បញ្ញវន្តកម្ពុជាដែលគាត់ជាអ្នកបញ្ចុះបញ្ចូលឲ្យវិលត្រឡប់មកប្រទេសវិញ ។ ដូចមេដឹកនាំឯទៀតៗ សារី ក៏ជឿទៅលើរបៀបចាត់ចែងរបស់ក្រុមសន្តិសុខ និងអ្វីៗទាំងអស់ដែលមន្ទីរឃុំឃាំងទួលស្លែងជាតំណាងដែរ ។ គាត់ជឿថាមាន«ខ្មាំងសត្រូវ»បង្កប់ក្នុងជួរប្រជាជននិងបក្សដែលបំផ្លិចបំផ្លាញបដិវត្តន៍ និងរារាំងជោគជ័យរបស់បដិវត្តន៍ ។ សារី ក៏យល់ព្រមក្នុងការបោសសម្អាតជាច្រើនទៀត ដូច្នេះគាត់គ្មានការដោះ-ស្រាយណាផ្សេងក្រៅពីសុខចិត្តឲ្យសន្តិបាលបោសសម្អាតក្រសួងរបស់គាត់ឡើយ ។

ជោគវាសនារបស់បញ្ញវន្តកម្ពុជាត្រូវបញ្ចប់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ នៅពេលដែល ហ៊ូ នឹម ជាបិសាចម្នាក់ក្នុងចំណោម «បិសាចទាំងបី» ត្រូវចាប់ខ្លួនជាសម្ងាត់នាទីក្រុងភ្នំពេញ ។ ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ ហើយឈ្មោះរបស់គាត់ក៏ធ្លាប់ល្បីល្បាញមិនចាញ់ ខៀវ សំផន ដែលជាប្រធាន

គណៈប្រធានរដ្ឋឡើយ ។ ហ៊ូ នឹម ក៏ជាអ្នកធ្លាប់ធ្វើសកម្មភាព តំណាងឲ្យបុព្វហេតុរបស់ខ្មែរក្រហមក្នុងសម័យសង្គ្រាមដែរ ។ កាលពីដើម គាត់គឺជានិមិត្តរូបនៃការប្រឆាំងប្រកបដោយគុណធម៌ និងដែលបេះគិតគូរចំពោះសម្តេចព្រះ នរោត្តម សីហនុ និងអំពើពុករលួយផង ។ ប៉ុន្តែ ប្រការទាំងអស់នេះមានសារសំខាន់តិចតួចណាស់នៅឆ្នាំ១៩៧៧ ចំពេលដែលបក្សផ្តើមធ្វើសកម្មភាពកម្ចាត់បណ្តាសមាសភាពអនុធនចេញពីជួរ ។ ការភ័យខ្លាចជំងឺមិនទុកចិត្តលែងផ្តោតទៅរកជនបទទៀតហើយ ប៉ុន្តែគឺផ្តោតមកលើទីក្រុងភ្នំពេញវិញម្តង ហើយ ហ៊ូ នឹម មិនដែលសម្តែងឲ្យឃើញថា គាត់ជាមនុស្សមានប្រយោជន៍ដូច ខៀវ សំផន សោះឡើយ ។

ហ៊ូ នឹម ត្រូវបានអង្គការ «បូជាយញ្ញ» ដោយសារជំងឺមិនទុកចិត្តគេឯងនេះ ។ គាត់និងប្រពន្ធបានសារភាពក្រោមការធ្វើទារុណកម្មថា គាត់ជាសមាជិកម្នាក់នៃក្រុមក្បត់មួយដែលដឹកនាំដោយសេ.អ៊ី.អា. ។ នៅមន្ទីរឃុំឃាំងទួលស្លែង ហ៊ូ នឹម បានទទួលស្គាល់ថាខ្លួនជាជនក្បត់ម្នាក់និងជាចារបុរសម្នាក់ ។ គាត់ត្រូវអង្គការសម្លាប់នៅខែកក្កដាបន្ទាប់ពីការធ្វើទារុណកម្មអស់រយៈពេលបីខែ ។

ពុំមានការប្រកាសផ្សាយជាសាធារណៈអំពីមរណភាពរដ្ឋមន្ត្រីក្រសួងឃោសនាការនេះទេ ។ ជាច្រើនខែក្រោយមក ប្រពន្ធរបស់ សុន សេន ឈ្មោះ យុន យ៉ាត បានឡើងជំនួស ហ៊ូ នឹម ក្នុងអង្គការលេខនៃរដ្ឋាភិបាល ។ វង្វង់ប្រតិបត្តិការរបស់ក្រុមសន្តិបាលនៅពេលនេះមានទំហំយ៉ាងធំសម្បើម ។ នៅខែកក្កដា ឆ្នាំ១៩៧៧ មេដឹកនាំជាន់ខ្ពស់ៗទៀតៗរបស់បក្សបានដឹងខ្លួនអំពីសភាពធ្ងន់ធ្ងរនៃការបោសសម្អាត ។ ជនបរទេស ដែលយកចិត្តទុកដាក់តាមដានរឿងនេះក៏កត់សម្គាល់ឃើញដូចគ្នា ជាពិសេសអ្នកការទូតចិនម្នាក់ដែលធ្វើការនៅក្រុងភ្នំពេញ និងធ្លាប់ជាមិត្តរបស់ ហ៊ូ នឹម ។ អ្នកការទូតនេះពុំដែលស្គាល់ភាពរីករាយម្តងណាឡើយ នៅក្នុងកម្ពុជាប្រជាធិបតេយ្យហើយការបាត់ខ្លួនរដ្ឋមន្ត្រីឃោសនាការគឺជាតំណក់ទឹកចុងក្រោយដែលធ្វើឲ្យទឹកហៀរចេញពីកែវ ។

នៅប្រទេសកម្ពុជា គ្មានអ្នកណាម្នាក់មានជីវភាពរស់នៅប្រកបដោយផាសុកភាព ដូចអ្នកការទូតចិនម្នាក់នៅភ្នំពេញឡើយ ។ ស្ថានទូតរបស់ចិនមានសភាពត្រជាក់ល្ហឹមក្នុងពេលដែលនៅខាងក្រៅមានចំហាយក្តៅខ្លាំង ។ ក្នុងស្ថានទូតមានអាងហែលទឹកធំមួយនិងនិវេសនដ្ឋានធំទូលាយជាច្រើនសម្រាប់បុគ្គលិកស្នាក់នៅ ។ ចុងភៅចិនម្នាក់ជាមួយនឹងគ្រឿងបរិភោគ ដែលដឹកតាមយន្តហោះមកពីក្រុងប៉េកាំងជារៀងរាល់សប្តាហ៍ ។ ក្នុងឋានៈជាសម្ព័ន្ធមិត្តគួរឲ្យកត់សម្គាល់របស់កម្ពុជាប្រជាធិបតេយ្យ ជនជាតិចិនទាំងនេះអាចធ្វើការទាក់ទងជាមួយប្រជាជនបាន ហើយអាចធ្វើដំណើរទៅជនបទបានទៀត ។ ទីប្រឹក្សាចិនរាប់ពាន់នាក់បានចូលមកជួយប្រទេសកម្ពុជា ដោយស្នាក់អាស្រ័យនៅរយៈពេលខ្លីជាងការស្នាក់នៅរបស់ពួកទាហានអាមេរិកាំងនៅប្រទេសវៀតណាមទៅទៀត ប៉ុន្តែ ទីប្រឹក្សាចិនប្រហែលជាយល់តាំងពីដើមដំបូងថា រឿងរ៉ាវខ្លះនឹងពុំបានសម្រេចជោគជ័យឡើយនៅប្រទេសកម្ពុជា ។

អ្នកការទូតចិនជាន់ខ្ពស់រូបនេះ បាននិយាយថា «ប្រាកដណាស់ខ្ញុំផ្សើងឆ្ងល់យ៉ាងខ្លាំង នៅពេលមកដល់ក្រុងភ្នំពេញដំបូង ។ ខ្ញុំទើបនឹងមកពីរដ្ឋធានីមួយរបស់អឺរ៉ុប ប៉ុន្តែខ្ញុំសន្និដ្ឋានថា ខ្ញុំពិតជាទទួលរងការប៉ះទង្គិចផ្លូវចិត្តដូចគ្នា បើសិនជាខ្ញុំចេញមកពីទីក្រុងប៉េកាំង ។ ក្នុងទីក្រុងនេះគ្មានឃើញមនុស្សម្នាក់សោះ ។ គ្មានមនុស្សណាម្នាក់ដើរលើថ្នល់ឡើយ ។ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍បំផុតគឺ ស្ថានភាពស្ងាត់ជ្រងំរបស់ទីក្រុង ។ រៀងរាល់ព្រឹកមានក្រុមយុទ្ធជនដើរបោសសម្អាតផ្លូវមួយចំនួន ។ ក្នុងរយៈពេលមួយឆ្នាំកន្លះខ្ញុំមិនដែលឃើញប្រជាជនណាម្នាក់ដើរកម្សាន្តទាល់តែសោះ ។ កាលដែលខ្ញុំជួបមនុស្សម្នាគឺជួបតែនៅតាមផ្លូវ ឬការធ្វើដំណើរទៅកន្លែងធ្វើការ ឬនៅធ្វើការតាមផ្លូវ ឬយុទ្ធជនកំពុងឈរយាមតែប៉ុណ្ណោះ» ។

អ្នកការទូតរូបនេះ ធ្លាប់ឮសេចក្តីរាយការណ៍ផ្សេងៗស្តីពីបដិវត្តន៍របស់កម្ពុជាដែរ ហើយធ្លាប់តម្កើងផ្លូវចិត្តក្នុងសង្គមរីតត្បិតមួយ ប៉ុន្តែគាត់មិនដែលនឹកស្មានចំពោះប្រភេទនៃការដាក់ឲ្យអ្នកការទូតនៅតែក្នុងលំនៅឋាននៅទីក្រុងភ្នំពេញដោយមានការតាមឃ្លាំមើលរបៀបនេះទេ ។

ជាច្រើនថ្ងៃកន្លងផុតទៅ គាត់គ្មានមូលហេតុផ្លូវការណាមួយដើម្បីបានចេញពីស្ថានទូតទៅក្រៅ ហើយគាត់នៅតែរស់នៅ

ដូចមនុស្សជាប់ឃុំឃាំងក្នុងបរិវេណស្ថានទូតរបស់គាត់ដូចដែលគេធ្លាប់ព្រមានគាត់អ៊ីចឹងទៅ ។ ដោយពុំអាចទ្រាំទ្រនឹងបញ្ហានេះ គាត់បានចាប់ផ្តើមធ្វើដំណើរនៅតាមកម្សាន្តកន្លែងផ្សេងៗជាមួយអ្នកការទូតម្នាក់ក្នុងចំណោមអ្នកការទូតចិនប្រមាណដប់ពីរនាក់នៃស្ថានទូតនេះ ។ គាត់បាននិយាយថា «យើងទាំងអស់គ្នាសុទ្ធតែតប់ប្រមល់ក្នុងចិត្តនិងអផ្សុក... ។ រដ្ឋាភិបាលកម្ពុជាបានសុំកុំឲ្យយើងចេញដើរកម្សាន្តទៀត ប៉ុន្តែយើងនៅតែចេញដើរលេង ។ កងទ័ពម្នាក់ឬពីរនាក់ តែងដើរតាមពីក្រោយយើងជាប់ជានិច្ច ក្នុងចម្ងាយប្រមាណហាសិបម៉ែត្រ ។ យើងមិនដែលភ័យខ្លាចសោះឡើយនៅតាមផ្លូវ ពីព្រោះមានកងទ័ពប្រដាប់អាវុធដើរយាមល្បាតជាច្រើន» ។

កម្មាភិបាលម្នាក់នៅមន្ទីរបក្សបានមកកាន់ស្ថានទូតពីរឬបីដងក្នុងមួយសប្តាហ៍ ដើម្បីថែរក្សាទំនាក់ទំនងផ្លូវការផ្សេងៗឲ្យស្ថិតស្ថេរជាប្រក្រតី ។ អ្នកការទូតចិនបានទទួលសៀវភៅ ឬអត្ថបទផ្សេងៗដែលចេញពីរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិប-តេយ្យ គឺមានព្រឹត្តិប័ត្រព័ត៌មានប្រចាំថ្ងៃមួយ ទស្សនាវដ្តីនិងកាសែតខ្លះៗ ប៉ុន្តែមានចំនួនតិចណាស់ ។ មិនយូរប៉ុន្មានក្រោយមក អ្នកការទូតចិនបានចាប់ផ្តើមដើរកម្សាន្តដើម្បីសុខភាពនៅពេលព្រឹកនិងពេលល្ងាច បើទោះជាមានការស្តីបន្ទោសធ្ងន់ៗពីរបបនេះក៏ដោយ ។ នៅថ្ងៃគួរឲ្យចងចាំមួយ ពួកចិនបានលើកដៃជាសញ្ញាមិត្តភាពជាមួយអ្នកការទូតអេហ្ស៊ីបម្នាក់ដែលកំពុងហាត់រត់នៅតាមមហាវិថីដោយផ្អើននឹងការហាមឃាត់របស់ខ្មែរក្រហមយ៉ាងព្រងើយ ។ ប្រាកដហើយ ការដើរកម្សាន្តទាំងនេះក៏ជាមធ្យោបាយមួយស្រាវជ្រាវឲ្យដឹងថាតើប្រទេសនេះដើរទៅមុខដោយរបៀបណាទៅ ។ «ក្នុងឱកាសនៃដំណើរកម្សាន្តនៅពេលល្ងាចៗ យើងបានឃើញកន្លែងសិប្បកម្មតូចៗ មួយចំនួនដែលមានយុវនារីជាច្រើនកំពុងដេរខោអាវក្នុងទីនោះ ប៉ុន្តែយើងពុំអាចចូលទៅសួរសុខទុក្ខពួកគេបានទេ ។ យើងអាចចូលបានតែក្នុងរោងចក្រដែលផ្តល់ទុនដោយផ្ទាល់តាមរយៈកម្មវិធីជំនួយរបស់យើងប៉ុណ្ណោះ» ។

ការស្អប់ជនបរទេសរបស់កម្ពុជាបានរីករាលដាលដល់សម្ព័ន្ធមិត្តដែលជិតស្និទ្ធបំផុតរបស់ប្រទេសនេះថែមទៀត ។ តួនាទីរបស់អ្នកបច្ចេកទេសចិននៅប្រទេសកម្ពុជាគឺមានសារសំខាន់បំផុត ។ ក្រុមគ្រូពេទ្យចិន បានចូលមកជួយប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងដ៏សាហាវដែលលេចឡើងនៅឆ្នាំ១៩៧៦ ។ គ្រូពេទ្យចិនខ្លះទៀតបានបង្រៀនពីចំណុចគោលនៃវេជ្ជសាស្ត្របស្ចិមប្រទេសដល់ពេទ្យខ្មែរក្រហម រួមទាំងការវះកាត់ធម្មតានិងបច្ចេកទេសក្នុងការប្រើកាំរស្មីអ៊ិចផង ។ អ្នកបច្ចេកទេសចិនបានកសាងឡើងវិញ នូវរោងចក្រជាច្រើននៅភ្នំពេញនិងនៅតាមខេត្តមួយចំនួន ។ នៅឆ្នាំ១៩៧៧ កាលបើប្រជាជនកម្ពុជាត្រូវការទីប្រឹក្សាម្នាក់ខាងវិស័យកសិកម្ម ចិនបានបញ្ជូនអ្នកជំនាញការម្នាក់ក្នុងចំណោមអ្នកជំនាញដ៏ឆ្នើមបំផុតរបស់ខ្លួនមកឲ្យភ្លាម ។ ការផ្លាស់ប្តូរខាងពាណិជ្ជកម្មដែលមានព្រំដែនរបស់កម្ពុជាបានប្រព្រឹត្តទៅសំខាន់បំផុត តាមរយៈប្រទេសចិន ហើយនិស្សិតខ្មែរមួយចំនួនតូចដែលបញ្ជូនទៅបរទេសក៏បំពេញការសិក្សានៅទីក្រុងប៉េកាំងដែរ ។

ក៏ប៉ុន្តែ តាមការឲ្យដឹងរបស់អ្នកការទូតចិនថា ជំនួយដ៏មានតម្លៃនេះពុំបានផ្តល់សេរីភាពដ៏ទូលំទូលាយដល់គាត់ទេ ។ ការធ្វើដំណើរទាំងឡាយរបស់គាត់ទៅកាន់ខេត្ត ដើម្បីពិនិត្យមើលសមិទ្ធិផលនានាដែលផ្តល់ហិរញ្ញវត្ថុដោយប្រទេសចិនបានប្រែទៅជាការធ្វើដំណើរកម្សាន្តរបៀបទេសចរណ៍ទៅវិញ ហើយគាត់កម្របានទទួលការអនុញ្ញាតឲ្យធ្វើដំណើរទៅក្រៅរដ្ឋធានីលើសពីមួយយប់ណាស់ ។ គាត់បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយជាមួយនឹងឡានហ្ស៊ីបយ៉ាងហោចណាស់មួយគ្រឿងឬពីរគ្រឿងផ្ទុកទៅដោយកងការពារតាមឃ្លាំមើលគាត់ ដូចជាអ្នកទោស ។ គាត់បាននិយាយថា «មនុស្សគ្រប់គ្នាគិតថា យើងជាអ្នកដែលត្រូវគេលើកលែង ។ ការមួម៉ៅក្នុងចិត្តនិងការធុញទ្រាន់ គឺសម្រាប់ពួកខ្មែរក្រហម ពុំមែនសម្រាប់ពួកចិនទេ ។ ប៉ុន្តែយើងត្រូវខ្មែរក្រហមធ្វើឲ្យលំបាកដូចអ្នកការទូតដទៃទៀតដែរ ក្នុងការជជែករកខុសត្រូវជាមួយភាគច្រើននៃជនកម្ពុជា ។ យើងត្រូវដាក់ឲ្យរស់នៅដោយឡែកពីគេឯងដូចជនបរទេសឯទៀតៗដែរ» ។

អ្នកការទូតរូបនេះបានបញ្ជាក់ថា អ្នកការទូតចិនបានសម្រេចចិត្តមិនតវ៉ា និងមិនសម្តែងឲ្យឃើញការមិនយល់ស្របរបស់ខ្លួនចំពោះនយោបាយរបស់កម្ពុជាឡើយ ។ តាមគាត់ឲ្យដឹងថា ចាប់ពីឆ្នាំ១៩៧៦ អ្នកការទូចចិនដឹងថាមានការបោសសម្អាតយ៉ាង

ធំធេងនៅជនបទ ។ «យើងបានស្តាប់ពួកគេនិយាយពីការកាប់សម្លាប់ ។ ពុំមែនជាការនិយាយដោយជាក់លាក់ទេ ប៉ុន្តែគឺសុទ្ធតែពាក្យចចាមអារ៉ាម ។ យើងទាំងអស់គ្នាសង្ស័យថា ប្រជាជនកម្ពុជាមួយចំនួនធំបានត្រូវកម្មាភិបាលមូលដ្ឋានសម្លាប់នៅជនបទ» ។

ក៏ប៉ុន្តែ អ្នកការទូតចិនក៏មានជំនឿចំពោះជោគជ័យផ្នែកសេដ្ឋកិច្ច ដែលខ្មែរក្រហមបានអួតក្អេងក្អាងនិងចំពោះការឃោសនាដែលថា ប្រទេសជាតិបាន «លោតផ្លោះ» នៅឆ្នាំ១៩៧៧ និងប្រែក្លាយទៅជាប្រទេសដែលឧបត្ថម្ភខ្លួនដោយខ្លួនឯងបាន ។ អ្នកការទូតរូបនេះបានជួបនិយាយយ៉ាងយូរជាមួយ ប៉ុល អំពីបញ្ហាកសិកម្មដែលធ្វើឲ្យ ប៉ុល ពត ចាប់អារម្មណ៍អំពីរឿងនោះយ៉ាងខ្លាំង ។ «គាត់ប្រហែលធ្វើដំណើរច្រើនកន្លែងណាស់នៅក្នុងប្រទេស ហើយអាចពន្យល់យ៉ាងក្បោះក្បាយអំពីស្ថានភាពកសិកម្មនៅតាមខេត្តនានា...។ ប៉ុន្តែ ខ្ញុំគួរតែនិយាយដែរថា ខ្ញុំមិនដែលបានជួបសន្ទនាតែពីរនាក់ជាមួយគាត់ទេ ។ ជាទូទៅ គាត់មានអ្នកនៅអមជានិច្ច គឺ អៀង សារី និង ជួន ប្រសិទ្ធិ ។ ប៉ុន្តែរឿងនិទានអំពីការរីកលូតលាស់មានទំនងជារឿងពិតប្រាកដ ។ ឆ្នាំដំបូងគឺឆ្នាំ១៩៧៦ ប្រហែលជាឆ្នាំដែលលំបាកបំផុតសម្រាប់ប្រជាជនកម្ពុជាដែលសុទ្ធតែមានរាងកាយស្គាំងស្គម ។ នៅឆ្នាំ១៩៧៧ ស្ថានភាពមានលក្ខណៈប្រសើរជាងមុន កម្ពុជាប្រជាធិបតេយ្យអាចនាំស្រូវចេញទៅហុងកុងនិងធ្វើជាអំណោយទៅឲ្យប្រទេសឡាវទៀត» ។

ឆ្នាំ១៩៧៧ក៏ជាឆ្នាំដែលអ្នកការទូតនេះត្រូវប្រឈមមុខនឹងប្រភេទនៃការកាប់សម្លាប់នៅទូទាំងប្រទេស ។ មិត្តតែមួយគត់របស់គាត់ក្នុងរដ្ឋាភិបាលរបស់របបនេះគឺ ហ៊ូ នឹម បានបាត់ខ្លួនដោយគ្មានការបញ្ជាក់ច្បាស់លាស់ ។ «ហ៊ូ នឹម ជាមិត្តខ្ញុំតាំងពីទសវត្សរ៍ឆ្នាំ១៩៥០ ។ គាត់ជាមនុស្សរាក់ទាក់និងគួរឲ្យចូលចិត្ត ។ គាត់តែងតែប្រុងប្រយ័ត្នជានិច្ចនៅពេលដែលគាត់និយាយពីស្ថានការណ៍ផ្ទៃក្នុងរបស់កម្ពុជាជាមួយខ្ញុំម្តងៗ ហើយគាត់ចូលចិត្តជជែកពិភាក្សាអំពីខ្សែភាពយន្តនិងអត្ថបទផ្សេងៗ» ។

នៅពេល ហ៊ូ នឹម បាត់ខ្លួន អ្នកការទូតរូបនេះបានសុំឲ្យរដ្ឋាភិបាលគាត់ផ្លាស់គាត់ទៅកន្លែងថ្មីទៀតដោយមូលហេតុសុខភាព ។ «តាមធម្មតាអ្នកការទូតម្នាក់ត្រូវតំណែងនៅប្រទេសមួយក្នុងរយៈបីឆ្នាំ ។ ខ្ញុំចាកចេញពីក្រុងភ្នំពេញ ពីព្រោះខ្ញុំឈឺ ហើយខ្ញុំគ្មានការងារអ្វីសម្រាប់បំពេញផង...» ។

ជាបញ្ញវន្តពេញលក្ខណៈ គាត់អាចដឹងតទៅទៀតថា សម្តីនិយាយទាំងប៉ុន្មានរបស់គាត់ពិតជាធ្វើឲ្យ ប៉ុល ពត ត្រិះរិះពិចារណាជាមិនខាន ។ តាមសម្តីគាត់ថា រដ្ឋាភិបាលចិនបានទម្លាក់ទោសទៅលើ ប៉ុល ពត អំពី «ការប្រព្រឹត្តខុសចង់ឲ្យមានបដិវត្តន៍គ្រប់កន្លែង» ហើយក៏មិនចាត់ទុកជនកម្ពុជាជាជនម៉ៅនិយមសម័យទំនើបដែរ ។ ដូចជនកុម្មុយនិស្តដទៃៗទៀត គាត់កត់សម្គាល់ឃើញក្នុងចំណោមខ្មែរក្រហមនូវការចាប់កំណើតនៃគំនិតមួយដែលមានឈ្មោះជាអ្នកធ្វើបដិវត្តន៍ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ សមាជិកខ្មែរក្រហមសុទ្ធតែជាមនុស្សចេញមកពីចលនាមិនច្បាស់លាស់ដូចគ្នា ដែលហ្វ្រង់ហ្វាណុង *(Frantz Fanon)* បានវាយតម្លៃថាបដិវត្តន៍ខ្លាំងហួសពេកក្នុងនាមជាប្រជាជនមួយដែលធ្លាប់ត្រូវជិះជាន់ដោយអាណានិគមស្បែកស ។ ខ្មែរបានរងឥទ្ធិពលពីសម័យជាតិនិយមរើបកាន់តែខ្លាំងមួយដែលក្រុមទ័ពព្រៃទាំងឡាយទ្រាំមិនបាននឹងគ្រឿងទាក់ចិត្តមិនគួរជឿក្នុងការធ្វើបដិវត្តន៍ដោយប្រើអំពើហិង្សា ។

ភាពខុសគ្នារវាងខ្មែរក្រហមនិងអ្នកបដិវត្តន៍ដែលស្រើបចិត្តជំនាន់ស្រករគ្នាគឺថាក្រុងទីមួយ ពេលយកបានជ័យជម្នះហើយក៏ដាក់ឲ្យអនុវត្តនូវទស្សនះរបស់គេភ្លាមៗ ។ នៅឆ្នាំ១៩៧៧ វាបានស្តែងឡើងយ៉ាងច្បាស់សម្រាប់អ្នកការទូតគួរគោរពរបស់ចិន ដែលគាត់គោងតែចាកចេញពីការបដិវត្តន៍មួយ ពីព្រោះធាតុមួយក្នុងចំណោមធាតុដែលមានជាអចិន្ត្រៃយ៍ គឺអំពើភេរវកម្ម ។ អំពើភេរវកម្មនេះហើយ ដែលបានយកមិត្តរបស់គាត់ឈ្មោះ ហ៊ូ នឹម ធ្វើជាគោលដៅវាយប្រហារនិង ។

## ធនាគារិកនិងអ្នកស្រឡាញ់លទ្ធិកុម្មុយនិស្ត

គ្មានអ្នកណាម្នាក់បញ្ចេញឲ្យឃើញវិសុទ្ធកម្មអំពីការផ្លាស់ប្តូរទិសដៅសារសំខាន់នៃជំនឿស៊ប់របស់មជ្ឈិម ដែលគិតថា «ខ្មាំងសត្រូវ» ពុំមែនមានតែនៅក្នុងចំណោម«ពួកអ្នកថ្មី»ទេ ប៉ុន្តែមាននៅផ្ទៃក្នុងបក្សផ្ទាល់ដូចជាធនាគារិក ម៉ី កំផុត *(Mey Kamphot)* និងជនកុម្មុយនិស្តចំណូលថ្មីឈ្មោះ ដាត់ ជាក្មេងកំព្រាដែលសុំចូលជាសមាជិកចលនាកុម្មុយនិស្តនៅក្រុងភ្នំពេញបន្ទាប់ពីបានធ្វើការក្នុង

កាសែតរបស់ ខៀវ សំផន ។ ផាត់ បានឡើងបុណ្យស័ក្តិជាលំដាប់លំដោយនិងជាសហការីម្នាក់របស់ ប៉ុល ពត នៅពេលដែលមេដឹកនាំកុម្មុយនិស្តភៀសខ្លួនចេញពីភ្នំពេញនិងចាប់ផ្តើមបដិវត្តន៍នៅជនបទ ។

កុម្ពុត ជាធនាគារិកធ្លាប់គាំទ្រសាធារណរដ្ឋខ្មែរនៅគ្រាដំបូងៗ ប៉ុន្តែទៅជាខ្ពើមរអើមអំពើពុករលួយរបស់របបនេះ អសមត្ថភាព ការលោភលន់ទ្រព្យសម្បត្តិនិងជំនឿស៊ប់របស់ លន់ នល់ ទៅលើអ្វីៗដែលហួសពីធម្មជាតិពិត ។ គាត់បន់ឲ្យសង្គ្រាមឆាប់ចប់និងចង់ឲ្យពួកខ្មែរក្រហមរៀបចំរបបសង្គមនិយមមួយដែលនិយមផ្លូវកណ្តាលនិងច្បាស់លាស់ ។ គាត់ក៏ជឿងឆ្ងល់ដូចប្រជាជនទាំងអស់ដែរ នៅពេលដែលកងទ័ពកុម្មុយនិស្តបញ្ជាឲ្យចាកចេញពីរដ្ឋធានីនៅថ្ងៃដែលខ្លួនចូលមកដល់រដ្ឋធានី ។ គាត់ត្រូវអង្គការបញ្ជូនទៅដាក់នៅសហករណ៍ដូចអ្នកទីក្រុងឯទៀត ដោយបាត់បង់ឯកសិទ្ធិផ្សេងៗទាំងអស់របស់ខ្លួន ។ គាត់មានបំណងធ្វើអត្តឃាតក្រោយពីដឹងច្បាស់នូវអ្វីៗដែលបដិវត្តន៍ត្រៀមបម្រុងសម្រាប់រូបគាត់និងប្រទេសជាតិ ប៉ុន្តែគាត់បានផ្លាស់ប្តូរគំនិតនេះដោយការស្គាល់ករណីយកិច្ចចំពោះអ្នកដែលនៅជុំវិញគាត់ ។

វិធីរបស់ កុម្ពុត ដើម្បីឲ្យមានជីវិតរស់តទៅទៀត មានលក្ខណៈដូចគ្នានឹងវិធីរបស់ពួកអ្នកមានវិជ្ជាជីវៈសេរីជាច្រើនដទៃទៀតដែរ ។ ពួកខ្មែរក្រហមដឹងថា គាត់ធ្លាប់ធ្វើការក្នុងធនាគារមួយ ប៉ុន្តែពួកនោះយល់ឃើញថាគាត់គ្រាន់តែជាអ្នកធ្វើការក្រោមបង្គាប់គេប៉ុណ្ណោះ ។ កុម្ពុត បានញ៉ាំងឲ្យខ្មែរក្រហមលុះក្នុងការយល់ឃើញនេះ ដោយប្រកាន់ឥរិយាបថជាមនុស្សឡប់ៗ ។ គាត់បានបំព្រួញឈ្មោះរបស់គាត់ជា ផូត ហើយជម្រុះចោលរបៀបស្លៀកពាក់ជាអ្នកទីក្រុង មកទម្លាប់ខ្លួនស្លៀកខោខ្លីសាច់ក្រណាត់អំបោះវិញ ។ គាត់ចង់បង្ហាញឲ្យឃើញបុគ្គលជាមនុស្សល្ងីល្ងើម្នាក់ ។ ជាមួយបុគ្គលពិសេសផ្ទាល់ខ្លួននេះ កុម្ពុត ក៏ក្លាយទៅជាមនុស្ស«គ-ថ្លង់» ដើម្បីឲ្យបានរួចផុតពីមហន្តរាយដ៏គួរឲ្យព្រឺខ្លាចនេះ ។

ស្បែករបស់គាត់ដែលស្រអាប់ស្រាប់បានប្រែទៅជាខ្មៅ ។ គាត់បណ្តោយឲ្យសក់ដុះវែងដោយរវល់មិនថែទាំ ។ គាត់ទម្លាប់ខ្លួនមិនប្រកែកតវ៉ា ធ្វើគ-ថ្លង់ចំពោះការបាត់ខ្លួនសមាជិកសហករណ៍ ការខ្វះខាតម្ហូបអាហារថ្នាំពេទ្យនិងទុក្ខវេទនា ។ គាត់ខំធ្វើការយ៉ាងសកម្ម ។ ដើមឡើយសហករណ៍របស់គាត់មានទំហំតូចល្មម ។ ផូត ភរិយាមេម៉ាយនិងកូនៗរបស់បងប្អូនជីដូនមួយគាត់ អាចរស់នៅជុំគ្នាជាគ្រួសារមួយ ។ គាត់ត្រូវសរសេរជីវប្រវត្តិផ្ទាល់ខ្លួនជាថ្មីនៅពេលដែលគាត់មកតាំងទីលំនៅក្នុងភូមិ ប៉ុន្តែគាត់និងបងប្អូនជីដូនមួយទាំងអស់របស់គាត់បានរួចផុតពីគ្រោះថ្នាក់នេះគ្រប់គ្នា ។ នេះពុំមែនជាករណីសម្រាប់អ្នកផ្សេងៗទៀតនោះទេ ។ «មនុស្សជាច្រើនត្រូវសម្លាប់ម្តងមួយៗ-ពុំមានការសម្លាប់រង្គាលជាទ្រង់ទ្រាយទេ ។ មុនដំបូង «ប្រជាជនថ្មី» ប្រមាណដប់ពីរនាក់ដែលអង្គការសង្ស័យថាជាទាហាន លន់ នល់ ត្រូវអង្គការយកទៅសម្លាប់ចោល ។ ក្នុងរយៈពេលពីរឆ្នាំដំបូង «ពួកអ្នកថ្មី» ប្រហែលមួយភាគដប់ត្រូវបានយកទៅសម្លាប់ម្តងមួយៗជាមួយនឹងកូនចៅទាំងអស់ ។ ខ្ញុំពុំបានដឹងពីចំនួនអ្នកដែលស្លាប់មានប៉ុន្មានឡើយ» ។

កុម្ពុត បានមករស់នៅអតីតភូមិភាគឧត្តរដូច ផាត់ ដែរ ជាទីដែលគាត់មានមុខពេលមានព្រឹត្តិការណ៍ធ្វើវិស្សុទ្ធកម្មជាច្រើនសំដៅប្រឆាំងនឹងកម្មាភិបាលនៅទីនោះ ។ «កុយ ធួន ជាមេដឹកនាំភូមិភាគយើងត្រូវចាប់ខ្លួនយកទៅបាត់ ។ គាត់ជាមនុស្សរងគ្រោះពីការធ្វើវិស្សុទ្ធកម្មនេះ ។ គាត់ពិតជាត្រូវសម្លាប់ ប៉ុន្តែរឿងនេះ មិនដែលឮអ្នកណានិយាយសោះ ។ គាត់ត្រូវចោទប្រកាន់ថា ជាភ្នាក់ងារ សេ.អ៊ី.អា. ជាមនុស្សដែលនាំអន្តរាយដល់បដិវត្តន៍ គឺជាគហបតីម្នាក់ ។ កម្មាភិបាលថ្មីៗបានទៅដល់ ប៉ុន្តែអនុប្រធានរបស់ កុយ ធួន នៅតែកាន់អំណាចមួយរយៈពេលខ្លី ។ ក្រោយមកអង្គការបានចាប់អ្នកទាំងនោះដាក់គុកដោយចោទប្រកាន់ថាជាភ្នាក់ងាររបស់វៀតណាម» ។

វិទ្យុរបស់ភូមិដែលផ្សាយបន្តពីវិទ្យុរបស់រដ្ឋាភិបាល បានទៅជាប្រភពព័ត៌មានដ៏សំខាន់មួយដែលអាចឲ្យ កុម្ពុត បានយល់ដឹងច្រើនពីបដិវត្តន៍ ។ កុម្ពុត និយាយថា «យើងបានចូលរួមគ្រប់ការប្រជុំប៉ុន្តែគ្មានអ្វី«ប្រាកដប្រជា»ទេ ពុំមានការពិភាក្សាវាទនយោបាយទេ គឺមានតែការសន្ទនាគ្នាអំពីរបៀបកែលម្អឥរិយាបថធ្វើការងារនិងរបៀបប្រកាន់បុគ្គលឲ្យបានប្រសើរជាងមុនប៉ុណ្ណោះ ។ គេមិនដែលនិយាយពីលទ្ធិម៉ាក្ស-លេនីនទាល់តែសោះ ។ នៅពេលដំបូង គេក៏មិនដែលនិយាយពាក្យលទ្ធិកុម្មុយនិស្តដែរ គឺនិយាយតែពីការជឿនលឿនទៅមុខប៉ុណ្ណោះ ។ យើងគោរពតែធ្វើការរួមគ្នាកម្ទេចវណ្ណៈគហបតីទាំងអស់នេះពុំមែនជាគំនិត

ធ្វើឲ្យល្អជាងមុនទេ» ។

នៅឆ្នាំ១៩៧៦ កុម្ពុត ត្រូវតែសរសេរជីវប្រវត្តិរបស់ខ្លួនជាថ្មីទៀត ។ គាត់បាននិយាយថា «រៀងរាល់ពេលដែលគេសរសេរជីវប្រវត្តិរបស់ខ្លួន គេតែងព្រួយបារម្ភពីការបាត់ខ្លួនជានិច្ច» ។ ជាថ្មីម្តងទៀត អតីតធនាគារិកនិងគ្រួសាររបស់គាត់បានរស់រានមានជីវិត តមកទៀតដើម្បីចូលរួមក្នុងការធ្វើបដិវត្តន៍សង្គមនិយម ដែលប្រកាសឡើងដោយមជ្ឈិម ។ នោះគឺការបង្កើតឲ្យមានការហូបរួមនិងផ្ទះបាយរួម ។ ម្ហូបអាហារបានក្លាយទៅជាម្ហូបដែលមនុស្សស្ទើរតែបរិភោគមិនកើត ។ មនុស្សជាច្រើនកើតមានជំងឺរាកមួល ឬទល់លាមក ។ «យើងពុំមានដាំបន្លែបង្ការឲ្យសហករណ៍ទេ នៅប្រទេសកម្ពុជាមានបន្លែយ៉ាងច្រើនដែលដុះក្នុងព្រៃ ។ ប៉ុន្តែ ដោយយើងត្រូវហូបបាយរួមយើងត្រូវតែបង្ខំចិត្តហូបអ្វីដែលអង្គការផ្តល់ឲ្យយើង ។ មានតែក្រុមដែលត្រូវចាត់ឲ្យទៅរកបន្លែដែលដុះក្នុងព្រៃ ឬក្តាមខ្យងប៉ុណ្ណោះបានហូបគ្រាន់បើ ហើយកាលនោះម្ហូបអាហារមិនគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ទេ ។

ពុំមានថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺឡើយ ប៉ុន្តែ កុម្ពុត ក៏មិនដែលត្អូញត្អែរដែរ ។ តាំងពីដំបូងយើងតែងនឹកបារម្ភខ្លាចបាត់ខ្លួន ។ យើងមិនដែលហ៊ាននិយាយថា មនុស្សទាំងនោះស្លាប់ ឬត្រូវគេសម្លាប់ទេ ។ យើងនិយាយបានត្រឹមតែថារូបកាយរបស់អ្នកទាំងនោះបាត់លែងឃើញតែប៉ុណ្ណោះ» ។


កម្មាភិបាលខ្មែរក្រហម

កុម្ពុត បាននិយាយរៀបរាប់ថា ប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៦ «ប្រជាជនចាស់» ក៏ព្រមទទួលរបបអាហារកាន់តែថយតិចទៅៗពីមួយថ្ងៃដែរ ដែលនេះជាសញ្ញាមិនល្អមួយសម្រាប់ពួកគេ ។ ការប្រមូលផលស្រូវនៅឆ្នាំ១៩៧៥ ត្រូវបានបែងចែករវាងគ្រួសារទាំងអស់ ហើយការប្រមូលផលស្រូវឆ្នាំ១៩៧៦ ត្រូវដាក់ជាកម្មសិទ្ធិរួម ។ ការប្រមូលផលឆ្នាំ១៩៧៧ លែងជាកម្មសិទ្ធិរួមទៀតហើយៈ ស្រូវមួយភាគធំត្រូវដឹកជញ្ជូនទៅដាក់ក្នុងជង្រុករបស់រដ្ឋាភិបាល ។ សហករណ៍របស់ កុម្ពុត ដែលពេលឥឡូវមានសមាជិកចំនួនមួយពាន់ប្រាំរយនាក់ ចាប់ផ្តើមទទួលបានថ្នាំពេទ្យនិងសម្លៀកបំពាក់ជាច្រើន ប៉ុន្តែភាគច្រើនបានទៅ«ប្រជាជនមូលដ្ឋាន» ។ គឺនៅខែកក្កដា ឆ្នាំ១៩៧៧ ទើបកើតមានឡើងការសម្លាប់រង្គាលនៅក្នុងសហករណ៍របស់កុម្ពុត ។

«កាលពីមុនគេនាំយកមនុស្សដែលជាប់សង្ស័យពីរឿងអ្វីមួយ ទៅសម្លាប់តែម្នាក់ៗឯងប៉ុណ្ណោះ ពុំមែននាំយកទៅទាំងគ្រួសារទេ ។ នៅក្នុងអំឡុងការសម្លាប់រង្គាលនេះប្រជាជនថ្មីក៏ដូច «ប្រជាជនមូលដ្ឋានត្រូវនាំគ្រួសារទាំងមូល ។ គ្រួសារប្រាំពីរ ឬប្រាំបីត្រូវបានសម្លាប់ចោលរួមគ្នាតែមួយលើក ។ យើងមិនដឹងថាបណ្តាលមកពីមូលហេតុអ្វីទេ» ។

ស្ថានការណ៍បានផ្លាស់ប្តូរបក្សចាប់ផ្តើមមន្ទិលសង្ស័យទៅលើ «ប្រជាជនមូលដ្ឋាន» និងបក្ខជនកុម្មុយនិស្តមួយចំនួនដែលរួមគំនិតប្រឆាំងនឹងបដិវត្តន៍ ។ ការបោសសម្អាត «ប្រជាជនថ្មី» ត្រូវបានបញ្ចប់ការបោសសម្អាត «ប្រជាជនមូលដ្ឋាន» និងអ្នកស្មោះត្រង់នឹងបក្សទើបតែចាប់ផ្តើមប៉ុណ្ណោះ ។ ការសម្លាប់រង្គាល

ដំបូងដែលប្រព្រឹត្តក្នុងសហករណ៍របស់ កុម្មួត បានបង្ហាញឲ្យឃើញកាន់តែច្បាស់នូវការពិតមួយនៃការផ្លាស់ប្តូរដ៏គួរឲ្យរន្ធត់ ។ ចាប់ពីថ្ងៃនេះទៅ កុម្មួត លែងមានហេតុផលភ័យខ្លាចបាត់បង់ជីវិតរបស់គាត់ទៀតហើយ ។ ឥឡូវនេះមានតែបក្ខជនកុម្មុយនិស្តដូច ផាត់ ប៉ុណ្ណោះ ដែលត្រូវលំបាកចិត្ត ។

ក្នុងសម័យសង្គ្រាម ផាត់ បានឡើងឋានៈយ៉ាងឆាប់រហ័សរហូតដល់ក្លាយជាអនុប្រធានតំបន់១០៣ ក្នុងខេត្តព្រះវិហារ ដែលស្ថិតនៅភាគខាងជើងបំផុត ។ គាត់បានរៀបការនៅពេលគាត់ស្ថិតនៅក្នុងភាគខាងកើតប្រទេសនៅឡើយ ហើយ សោ ភឹម ដែលជាលេខាបក្សភូមិភាគបូព៌ាធ្លាប់ធ្វើជាមេបាក្នុងពិធីនេះ ។ ផាត់ ដែលត្រូវបានរាប់ចូលក្នុងចំណោមយុទ្ធជនវ័យក្មេងនិងពូកែរបស់កងទ័ព បានបែកចេញពីប្រពន្ធនិងកូនៗរបស់គាត់ ដើម្បីធ្វើដំណើរទៅកាន់តំបន់១០៣ ។ គាត់បានទទួលស្គាល់ថា ក្នុងពេលសង្គ្រាម គាត់បានក្លាយជាពេជ្ឈឃាតម្នាក់ ។ កុម្មុយនិស្តខ្មែរទាំងអស់ដែលវិលពីទីក្រុងហាណូយមកវិញក្រោយឆ្នាំ១៩៧០ ហើយដែលស្ថិតនៅក្នុងតំបន់របស់គាត់ត្រូវគេសម្លាប់ចោលដោយចេតនា ឬប្រើពាក្យថា«ជនគួរឲ្យមើលងាយទាំងអស់ដែលត្រឡប់ពីទីក្រុងហាណូយមកវិញបានបាត់ខ្លួននៅឆ្នាំ១៩៧៤» ។

ប៉ុន្តែ មានដំណើរសោហ្មងខ្លះជិតដាមលើរយៈពេលបម្រើការងាររបស់ ផាត់ ដែរ ។ នៅដើមឆ្នាំ១៩៧៤ ខ្មែរក្រហមបានផ្តើមធ្វើការវាយលុកជាទូទៅមួយប្រឆាំងនឹងក្រុងភ្នំពេញ ហើយយុទ្ធជនមួយចំនួនធំរបស់ភូមិភាគឧត្តរត្រូវបញ្ជូនមកភាគខាងត្បូងដើម្បីជួយហ៊ុមពទ្ធ័រដ្ឋធានី ។ ហេតុដូចនេះស្វាបចំហៀងរបស់កុម្មុយនិស្តនៅខេត្តកំពង់ធំត្រូវចំហ ហើយកងទ័ពរបស់សាធារណរដ្ឋខ្មែរបានឆ្លៀតឱកាសនេះធ្វើប្រតិបត្តិការមួយវាយទម្លុះ ហើយរំដោះយកប្រជាជនស៊ីវិលបានជិតបីម៉ឺននាក់ដែលកំពុងរស់នៅក្នុងតំបន់នេះ ។ កាលនោះប្រជាជនបានរៀបរាប់ប្រាប់អ្នកយកព័ត៌មានអន្តរជាតិនូវភ័ស្តុតាងដំបូងៗស្តីពីជីវភាពរស់នៅក្នុងតំបន់នានារបស់ខ្មែរក្រហម ហើយការរៀបរាប់ទាំងនោះពុំមែនជារឿងដែលគួរឲ្យរីករាយទាំងស្រុងទេ ។ តំបន់របស់ ផាត់ ត្រូវទទួលការខុសត្រូវមួយផ្នែកដែរក្នុងការវាយទម្លុះរបស់ទ័ពបច្ចាមិត្ត ។ មេបញ្ជាការវ័យក្មេងបានបាត់បង់យុទ្ធជនប្រហែលជាងហាសិបនាក់ ក្នុងនោះសែសិបបីនាក់ត្រូវចាប់បានជាឈ្លើយសឹក ។ មេកោយម្នាក់ក្នុងចំណោមមេកោយរបស់គាត់ បានព្រមានគាត់នៅពេលនោះថា «កំហុសមួយបែបនេះពុំអាចលុបលាងត្រឹមតែសម័យប្រជុំស៊ុយទិតៀនមួយបានទេ» ។

និយាយម្យ៉ាងទៀតថា វាមិនគ្រប់គ្រាន់ទេដែលត្រឹមតែទទួលស្គាល់កំហុសរបស់ខ្លួននិងស្តាប់ការប្រៀនប្រដៅមួយដ៏គួរឲ្យធុញទ្រាន់នោះ ។ ប៉ុន្តែ ផាត់ ពុំមែនជាមេដឹកនាំថ្នាក់លើបំផុតក្នុងតំបន់នោះឡើយ ហើយអង្គការមិនចាត់ទុកគាត់ជាអ្នកទទួលខុសត្រូវដោយផ្ទាល់ពីបញ្ហាទុកឲ្យចំហកន្លែងមួយក្នុងរយៈពេលខ្លីក្នុងកិច្ចការពាររបស់ខ្មែរក្រហមក្នុងពេលសង្គ្រាមដែរ ។ កំហុសត្រូវធ្លាក់ទៅលើមេកោយរបស់គាត់គឺសមមិត្ត ម៉ន ។ ២-៣ខែក្រោយមក គឺថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៤ ម៉ន បានស្លាប់ក្នុង«លក្ខណៈអាថ៌កំបាំងបំផុត»ដែលមានលំនាំដូចការសម្លាប់មួយដែលបញ្ជាដោយមជ្ឈិមដែរ ។ ផាត់ បានឡើងកាន់តំណែងជំនួស ម៉ន ហើយបានក្លាយទៅជាលេខាបក្សប្រចាំតំបន់ជាមុខតំណែងដែលគាត់កាន់ជាប់រហូតបន្ទាប់ពីការរៀបចំភូមិភាគជាច្រើនឡើងវិញនិងការកម្ចាត់ កុយ ធួន ។

ប៉ុន្តែ ការកម្ចាត់ កុយ ធួន បានធ្វើឲ្យសេចក្តីភ័យបារម្ភរបស់ជនកុម្មុយនិស្តវ័យក្មេងនេះចាប់មានឡើងដែរ ។ មជ្ឈិមបានចោទប្រកាន់ កុយ ធួន ជាភ្នាក់ងារសម្ងាត់ម្នាក់របស់សេ.អ៊ី.អា. អាមេរិកាំង ដោយបានបង្ខំឲ្យគាត់ឆ្លើយសារភាពថាធ្លាប់បានរួមគំនិតក្បត់យ៉ាងធំមួយ ហើយថាគាត់ជាសមាជិករបស់ក្រុម សេ.អ៊ី.អា. តាំងពីឆ្នាំ១៩៥៨ដែលបានជ្រៀតចូលបក្សនៅឆ្នាំ១៩៦០ ។ ពិតហើយ កុយ ធួន ជាអ្នកមានធាតុវណ្ណៈ «គហបតី» ជាងបណ្តាលេខាបក្សភូមិភាគឯទៀតៗ ហើយដែលអាចឲ្យគេជ្រើសរើសជា «ជនក្បត់» មុនគេដែរ ។ ប៉ុន្តែតាមការវាយតម្លៃម្យ៉ាងទៀតថា បើគេអាចធ្វើឃាតមនុស្សម្នាក់ដែលគេធ្លាប់ប្រគល់ភារកិច្ចឲ្យគាត់ការពារគណៈកម្មាធិការមជ្ឈិមក្នុងសម័យសង្គ្រាមនោះ តើមានអ្នកណាទៀតអាចគេចរួចពីគ្រោះថ្នាក់បាន?

ក្រោយពេលដែល នួន ជា បើកសាលានយោបាយបក្សនៅក្នុងទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៦បានបន្តិច ផាត់ ត្រូវបានថ្នាក់ដឹកនាំរបស់គាត់បញ្ជូនឲ្យទៅរៀននៅទីនោះ ។ មួយថ្ងៃមុនការ

ចាប់ផ្តើមបង្រៀនឯកសារ គាត់បានជួបសន្ទនាជាមួយអនុប្រធានសាលាម្នាក់ គឺសមមិត្ត ប៉ង់ ដែលគេចាត់ទុកថា ជាមនុស្សជិតស្និទ្ធបំផុតនឹង ប៉ុល ពត ។ «សមមិត្ត ប៉ង់ បានដើរមកជួបខ្ញុំសាកសួរពីសុខទុក្ខពួកយើងគ្រប់គ្នាពីគ្រួសារខ្ញុំនិងរូបខ្ញុំ» បន្ទាប់មកថា «មានជនក្បត់ជាច្រើនបានបញ្ចូលឈ្មោះឯងទៅក្នុងចម្លើយគេដែរ» ។ «តើអ្នកណាបញ្ចូលឈ្មោះខ្ញុំទៅក្នុងនោះ?» ខ្ញុំសួរទៅវិញយ៉ាងរហ័ស ។ គាត់និយាយថា «ឯងស្មានថាខ្ញុំជាអ្នកផ្តល់ឈ្មោះទៅឲ្យពួកអ្នកទាំងនោះឬ?» ។ បន្ទាប់មកគាត់បានបន្ថែមថា «ហេតុអ្វីបានជាឯងអាចទុកចិត្តថា ពួកអស់នោះមិនបានបញ្ចូលឈ្មោះឯង បើឯងធ្លាប់រួមរស់ជាមួយពួកគេដែរនោះ?» ។ ខ្ញុំបានឆ្លើយតបថា «ខ្ញុំគ្មានខ្លាចអ្វីទាំងអស់ព្រោះខ្ញុំពុំដែលបានប្រព្រឹត្តអំពើក្បត់» ។

របៀបស្រាវជ្រាវរក «ខ្សែបណ្តាញ» បានត្រូវបក្សបង្កើតឲ្យមានឡើងនៅពេលនេះ ហើយត្រូវបានប្រើប្រាស់ដោយក្រុមសន្តិបាលសម្រាប់ «បញ្ចូល» ឈ្មោះមនុស្សទាំងឡាយទៅក្នុងនោះ ដូចរូប ផាត់ ជាដើម ។ ផាត់ យល់ថា គាត់ត្រូវតែបង្ហាញឲ្យឃើញពីសេចក្តីស្មោះត្រង់របស់គាត់ចំពោះបក្សកុម្មុយនិស្តកម្ពុជាតែមួយប៉ុណ្ណោះ ហើយមិនយល់ថាសេចក្តីស្មោះត្រង់នេះ មានសារសំខាន់តិចតួចបែបនេះឡើយ ។ អង្គការបានចាត់ចែងឲ្យមានការបោសសម្អាតភូមិភាគឧត្តរ ហើយ ផាត់ ដែលធ្លាប់រស់នៅជាមួយមនុស្សដែលអង្គការកាត់ទោសជាអ្នកក្បត់រួចមកហើយនោះ ក៏ត្រូវចោទប្រកាន់ជាអ្នកក្បត់ដូចសមមិត្ត ប៉ង់ បានបញ្ជាក់ប្រាប់គាត់មែន ។ ម្យ៉ាងទៀត «សង្គ្រាមវណ្ណៈ» កំពុងមានភាពពុះកញ្ជ្រោលយ៉ាងខ្លាំង ហើយ ផាត់ ចាប់ផ្តើមចោទសួរខ្លួនឯងថា តើអង្គការមិនស៊ើបឆ្នោសឲ្យគាត់ពីរឿងសមាជិកគ្រួសារគាត់ខ្លះដែលប្រព្រឹត្តមិនល្អទេឬ? ។ ដោយឡែក គាត់បានត្រូវធ្វើព្រួយចិត្តយ៉ាងខ្លាំង ដោយសាររឿងបងប្រុសរបស់គាត់ម្នាក់ឈ្មោះ ទិត ដែលធ្លាប់គិតគូររកការងារឲ្យគាត់ធ្វើនៅពេលដែលគាត់ទៅដល់ក្រុងភ្នំពេញជាលើកដំបូង ។ ទិត ធ្លាប់ធ្វើជានាយទាហានម្នាក់ក្នុងកងទ័ពរបស់សម្តេចព្រះ នរោត្តម សីហនុ ។

សមាជិកគ្រួសាររបស់គាត់ផ្សេងទៀតពុំមានបង្កជាគ្រោះថ្នាក់ដោយការជាប់ពាក់ព័ន្ធពីរឿងវណ្ណៈឡើយ ។ ប៉ុន្តែមានស្ត្រីម្នាក់ទៀត គឺយុវនារីម្នាក់ដែលគាត់ធ្លាប់ស្គាល់កាលនៅខេត្តរតនគិរីក្នុងពេលដែលគាត់នៅធ្វើការជាមួយ ប៉ុល ពត និងគណៈកម្មាធិការមជ្ឈិម ។ ដោយធ្លាប់មានទំនាក់ទំនងយ៉ាងខ្លីជាមួយនាងដោយធ្លាប់ដឹកនាំឃោសនាប្រកាន់តាមគោលការណ៍តឹងរ៉ឹងបំផុតនោះ ឥឡូវនេះគាត់នឹកភ័យខ្លាចថា ច្បាស់ជារកឃើញថា គាត់ «ធ្លាប់បានប្រព្រឹត្តខុសសីលធម៌ជាមួយយុវនារីម្នាក់នោះ» មិនខានឡើយ ។

ផាត់ បានបញ្ចប់ការសិក្សានៅសាលានយោបាយបក្ស ហើយបានវិលត្រឡប់ទៅភូមិភាគឧត្តរវិញចំពេលដែល អៀង សារី ធ្វើដំណើរទៅបើកសម្ពោធភូមិភាគឧត្តរថ្មីដែរ ។ ដោយមានអារម្មណ៍មិនល្អស្រាប់ យុវបុរសនេះបានក្លាយទៅជាមនុស្សកើតជំងឺមិនទុកចិត្តគេឯងទាំងអស់នៅពេលដែលគេប្រុងតែទម្លាក់កំហុសមកលើរូបគាត់ ។ សារី បានត្រៀមរឿងមួយនេះនៅក្នុងសុន្ទរកថារបស់គាត់រួចជាស្រេច ។ «នៅពេលដែល បងទី២ (គឺ អៀង សារី) បានលើកយកមកនិយាយពី«រឿងបាត់ខ្សែអាត់ថតសំឡេង» ចំនួន១ម៉ឺនម៉ែត្រ ខ្ញុំនឹកភ័យថា គាត់ពិជាខឹងខ្ញុំមិនខាន» ។

តាមប្រហែល គេបានវង្វេងដៃដាក់ខ្សែអាត់ថតសំឡេងមួយដុំក្នុងមន្ទីររបស់ភូមិភាគដែលនៅដំណាក់កាលបដិវត្តនេះ គឺជារឿងដែលគេចាត់ទុកជាកំហុស ពុំមែនជាការភ័ន្តច្រឡំទេ ។ ប្រហែលជាមានអ្នកណាម្នាក់លួចយកទៅបាត់ ថ្វីបើវាពុំមែនជាផលិតផលដែលគេខំស្វះស្វែងរកដូចស្រូវអង្ករ ឬសាច់ក្រណាត់ក៏ដោយ ។ អង្គការបានចាប់ផ្តើមអនុវត្តទៅលើបណ្តាសមាជិកបក្ស និង«ប្រជាជនចាស់» នូវ«គោលការណ៍ផ្សេងៗ»ដែលធ្លាប់ប្រើសម្រាប់ដាក់ទោស «ប្រជាជនថ្មី» និងពួកមនុស្សដែលអង្គការសង្ស័យពីអំពើក្បត់ដែរ ។ តាំងពីថ្ងៃដំបូងៗនៃការបដិវត្តន៍ ខ្មែរក្រហមបានប្រៀនប្រដៅថា «គ្រោះថ្នាក់ទាំងឡាយ» អាចជាកំហុសដែលស្តែងឲ្យឃើញបំណងប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ។ ដូច្នេះ ផាត់ ពិតជាមានមូលហេតុព្រួយបារម្ភនូវអំពើសងសឹកមកវិញដែរ ព្រោះរូបគាត់ ផ្ទាល់ធ្លាប់បានដាក់ទោសមនុស្សជាច្រើន ព្រោះតែការប្រព្រឹត្តបទល្មើសកំប៉ិកកំប៉ុក ។ គាត់ពុំអាចចៀសវាងមិនកត់សម្គាល់ថា មជ្ឈិមបានបង្រួមបដិវត្តឲ្យទៅជាបញ្ហាផ្សេងៗ ដូចជាបាក់ផ្លៀងនង្គ័លមួយ ការផលិតស្រូវមិនបានតាមផែនការ បាត់ខ្សែអាត់មួយដុំរកមិនឃើញជាដើម ។

ការបាត់ខ្សែអាត់ថតសំឡេងនេះអាចត្រូវគេកាត់យល់ថា ជាការត្រួតពិនិត្យមិនដិតដល់របស់មន្ទីរមួយ ឬតំបន់មួយ ការប្រព្រឹត្តល្មើសចំពោះមជ្ឈិម ការធ្វើឲ្យអន្តរាយដល់សេដ្ឋកិច្ច និងបដិវត្តន៍ ។ អំពើក្បត់ពុំមែនស្ថិតនៅឯណាឆ្ងាយទេ ។ សមាជិកបក្សកាន់តែច្រើនឡើងៗត្រូវបាននាំទៅដាក់នៅមន្ទីរឃុំឃាំងទួលស្លែង ហើយនៅដំណាច់ឆ្នាំ១៩៧៧ គឺជាវេនរបស់ ផាត់ ។ មជ្ឈិមបានត្រៀមខ្លួនដាក់ចេញនូវការបោសសម្អាត ប្រឆាំងនឹងភូមិភាគបូព៌ា ដែលបណ្តាលឲ្យមានមនុស្សស្លាប់ច្រើនបំផុត ហើយ ផាត់ ធ្លាប់មានទំនាក់ទំនងនឹងភូមិភាគនេះរួមទាំងភូមិភាគឧត្តរផង ។ ឥឡូវនេះមន្ទីរឃុំឃាំងទួលស្លែងបានកម្ទេចបណ្តាមេដឹកនាំរបស់បដិវត្តន៍ច្រើនជាងអ្នកដឹកនាំនៃរបបចាស់ ។

នៅពេលចូលឆ្នាំសកលឆ្នាំ១៩៧៨ និរសារម្នាក់បាននាំយកលិខិតអញ្ជើញមួយមកមន្ទីររបស់ ផាត់ ដែលអញ្ជើញគាត់ឲ្យទៅចូលរួមសម័យប្រជុំគណៈដឹកនាំភូមិភាគដើម្បីរៀបចំផែនការប្រចាំឆ្នាំនិងមហាសន្និបាតមួយសំដៅថ្កោលទោសវៀតណាម ។ ស្អែកឡើង ផាត់ បានធ្វើដំណើរទៅដល់សៀមរាប នៅពេលរសៀលអមការពារអង្គរក្សពីរនាក់ ហើយការប្រជុំត្រូវចាប់ផ្តើមនៅព្រឹកថ្ងៃបន្ទាប់ ។ នៅពេលព្រលឹមស្រាងៗ រថយន្តមួយបានបើកមកទទួលយក ផាត់ និងមេដឹកនាំម្នាក់ទៀត ទៅជួបលេខាបក្សភូមិភាគ បន្ទាប់មកបានពិនិត្យមើលផែនការប្រចាំឆ្នាំពីស្រុកមួយទៅស្រុកមួយជាបន្តបន្ទាប់ ។ ប្រហែលម៉ោងប្រាំបួនព្រឹក ឡានហ្ស៊ីបមួយគ្រឿងបានបើកមកឈប់នៅពីមុខមន្ទីរលេខាបក្ស ក្រឡេកមើលទៅខាងក្រៅហើយប្រាប់ថា «សុទ្ធតែបងប្អូនខាងកងទ័ពអាកាសចរណ៍» ។ មនុស្សទាំងអស់នាំគ្នាក្រោកឈររួមទាំង ផាត់ ផង រួចដើរទៅមុខដៃហុចទៅរកអ្នកដែលដើរចូលមក ។

«ខ្ញុំគិតថា ពួកគេសុទ្ធតែជាបងប្អូនរួមជាតិឯង... ហើយយើងបានឱបរឹតគ្នាទៅវិញទៅមកជាសញ្ញាមិត្តភាព ។ ប៉ុន្តែពួកគេបានរឹតបន្តឹងការឱបនេះកាន់តែខ្លាំង ខ្ញុំរើបម្រះតែពួកគេបានបញ្ជាឲ្យខ្ញុំនៅឲ្យស្ងៀម កុំកម្រើក ។ បន្ទាប់មក គេបានដាក់ខ្នោះដៃខ្ញុំ និងយកក្រណាត់ចងភ្នែកខ្ញុំទៀត... ខ្ញុំគិតថា នៅទីនេះពិតជាមានសត្រូវមួយចំនួនធំដែលរួមបញ្ចូលឈ្មោះខ្ញុំទៅក្នុងចង្កោមពួកគេដែរ...» ។

«បងប្អូនរួមជាតិឯង»ទាំងនេះ ដែលធ្វើអ្វីៗទៅតាមការណែនាំរបស់ ឌុច ដោយមានការយល់ព្រមពីមេកោយផ្ទាល់របស់ ផាត់ ផង បានស្នើឲ្យអ្នកទោសប្រាប់ឈ្មោះរបស់ខ្លួនឲ្យបានច្បាស់លាស់ ។ ផាត់ បានធ្វើតាម ហើយបានប្រកាសថា «មុននឹងស្លាប់ឬរស់ខ្ញុំចង់ជួបអង្គការសិន» ។ ពួកនោះបានឆ្លើយថា «ត្រូវហើយ ឯងត្រូវតែទៅជួបអង្គការ» ។

ផាត់ បានឡើងជិះក្នុងរថយន្តហ្ស៊ីបដើម្បីនាំមកក្រុងភ្នំពេញ និងត្រូវឃុំឃាំងនៅទួលស្លែងនៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៨ ។ នៅថ្ងៃបន្ទាប់ គាត់បានសរសេរជីវប្រវត្តិដ៏ច្របូកច្របល់មួយពោរពេញទៅដោយវិប្បដិសារីចំពោះបទឧក្រិដ្ឋមួយដែលគាត់មិនដែលបានប្រព្រឹត្តទាល់តែសោះ ។ គាត់បានសរសេរថា «តាំងពីការចាប់ខ្ញុំដាក់គុក ខ្ញុំមើលឃើញតែផ្លូវមួយគត់ដែលចំហផ្លូវនៅចំពោះមុខខ្ញុំ ។ ខ្ញុំមុខជាស្លាប់ ពីព្រោះខ្ញុំដឹងពីប្រតិកម្មរបស់បក្សចំពោះរូបខ្ញុំ និងការប្រើ «វិធានការចុងក្រោយ»របស់បក្ស ។ ខ្ញុំនឹកក្នុងចិត្តថា ខ្ញុំត្រូវតែប្រុងប្រយ័ត្នមិនឲ្យមានអ្វីមកប៉ះពាល់ដល់សុខភាពខ្ញុំនៅតាមផ្លូវឡើយ ក្នុងគោលបំណងដើម្បីឲ្យខ្ញុំអាចរកឃើញមូលហេតុនៃការចាប់ខ្លួនខ្ញុំ» ។

*បក្សជាទីគោរព និងជាទីស្នេហា! បណ្តាមេដឹកនាំបក្សជាទីគោរពនិងជាទីស្នេហា! ខ្ញុំសូមស្នើឲ្យបក្ស បណ្តាសមមិត្តជាទីគោរពនិងជាទីស្នេហា អាណិតអាសូរចំពោះខ្ញុំផង ។ គ្មានពេលណាមួយដែលខ្ញុំមានបំណងក្បត់នឹងបក្សសោះឡើយ... ។ ដោយហេតុថា ឧត្តមគតិរបស់បក្សដែលខ្ញុំជឿទុកចិត្តនោះ ខ្ញុំអាចអះអាងចំពោះបក្សយ៉ាងស្មោះអស់ពីដួងចិត្តថា ខ្ញុំមានសេចក្តីភ័យខ្លាចនឹងប្រភេទនៃការស្លាប់បែបនោះណាស់ ។ ខ្ញុំបារម្ភខ្លាចក្រែងកូននិងចៅរបស់ខ្ញុំពុំបានក្លាយទៅជាអ្នកបន្តពូជរបស់បក្ស ... ។ ទោះជាអង្គការធ្វើទារុណកម្មខ្ញុំក៏ដោយ ក៏បក្សពុំអាចយកភ័ស្តុតាងណាមួយពីខ្ញុំដែលបង្ហាញឲ្យឃើញពីអំពើក្បត់ឡើយ ពីព្រោះខ្ញុំពុំដែលមានចិត្តក្បត់ទាល់តែសោះ ។ ខ្ញុំសូមអង្វរករបក្ស មេត្តាសម្តែងនូវការអាណិតអាសូរខ្លះ ចំពោះកូនៗរបស់ខ្ញុំ និងទុកជីវិតឲ្យពួកវាបានរស់នៅផង ពីព្រោះខ្ញុំជាសាច់ដាឈាមរបស់បក្សយ៉ាងពិតប្រាកដ ។*

*ផ្ញើនៅមន្ទីរឃុំឃាំងរបស់សន្តិបាល ព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨*

*ហត្ថលេខា ហង្ស [ឈ្មោះបដិវត្តរបស់ ដាត់]*

*បន្ទាប់ពីការធ្វើទារុណកម្មជាច្រើនសប្តាហ៍ ដាត់ បានប្រគល់ទៅឲ្យ ឌុច នូវចម្លើយសារភាពសរសេរដៃចំនួនប្រាំបីទំព័រស្តីអំពី«សកម្មភាពក្បត់របស់គាត់» ។ ក្រោយមក នៅខែកុម្ភៈ គាត់បានទទួលស្គាល់បទល្មើសផ្នែកសីលធម៌ ។ «កំហុសឆ្គងផ្នែកសីលធម៌ជាមួយនារី» នេះជាចំណងជើងចម្លើយសារភាពដែលក្នុងនោះគាត់បានរៀបរាប់ពីស្ត្រីទាំងអម្បាលម៉ានដែលគាត់ធ្លាប់មានទំនាក់ទំនងខាងផ្លូវភេទនៅមុននិងក្រោយការរៀបអាពាហ៍ពិពាហ៍របស់គាត់ ។ នៅខែមីនា គាត់បានសរសេរឯកសារមួយមាន៦៨ទំព័រអំពីខ្សែបណ្តាញឈ្លបយកការណ៍មួយដែលម្តងដឹកនាំដោយពួកសេ.អ៊ី.អា.ម្តងដឹកនាំដោយវៀតណាម ។*

*នៅទីបំផុត ដាត់ បានរកឃើញអាថ៌កំបាំងនៃការរួមគំនិតក្បត់ទាំងអស់ ។ គាត់បានរកឃើញថា នៅពីក្រោយរឿងទាំងនោះគឺមានតែពាក្យភូតកុហកដែលសន្តិបាលចម្រាញ់យកបានពីអ្នកទោសទាំងលំបាកក្រោមការវាយដំ ដើម្បីធ្វើឲ្យការព្រួយបារម្ភរបស់មជ្ឈិមបានស្រាកចុះប៉ុណ្ណោះ ។*

*នៅពេលដែល ដាត់ សរសេរចម្លើយសារភាពចំនួន៦៨ទំព័ររបស់គាត់ចប់ បេសកកម្មរបស់គាត់សម្រាប់បក្សក៏ចប់ត្រឹមនេះដែរ ។ អង្គការបានបិទសំណុំរឿងរបស់គាត់វិញ ហើយបានកម្ចាត់រូបគាត់ឲ្យបាត់ពីមុខមាត់ ។*

*តើមានអ្វីកើតឡើងក្នុងចិត្តគំនិតរបស់អ្នកដែលបានធ្វើទារុណកម្មនិងសម្លាប់ជនរងគ្រោះយ៉ាងច្រើននៅមន្ទីរឃុំឃាំងទួលស្លែង? ហេតុអ្វីបានជាជនបដិវត្តម្នាក់អាចធ្វើទារុណកម្មទៅលើជនបដិវត្តម្នាក់ទៀត? ហេតុអ្វីបានជាបក្សអាចញ៉ាំងឲ្យកម្មាភិបាលនៅទួលស្លែងជឿជាក់ថា ករណីយកិច្ចរបស់គេគឺវាយធ្វើបាបនិងធ្វើឲ្យមនុស្សជាច្រើនឈឺចាប់ក្នុងចិត្ត ដែលមុនចម្លើយអំពីរឿងនេះ គឺមាននៅក្នុងសៀវភៅជាច្រើនដែលថែរក្សាទុកមន្ទីរឃុំឃាំងកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលទាំងឡាយ នៅមណ្ឌលឃុំឃាំង ។ ជាយុវបុរសមានចំណេះដឹងនិងមានមនសិការម្នាក់ គាត់បានកត់ត្រាទុកអំពីពេលម៉ោងធ្វើការមគ្គុទេសក៍ណែនាំផ្សេងៗរបស់ខ្លួន សម្រាប់ការសួរចម្លើយនិងការធ្វើទារុណកម្ម ព្រមទាំងបណ្តាមូលហេតុផ្នែកនយោបាយដែលអ្នកទោសបកស្រាយបំភ្លឺផង ។ រឿងតែមួយគត់ដែលនៅខ្វះ គឺឈ្មោះរបស់គាត់ ដែលនេះប្រហែលជាសញ្ញានៃការខ្លាចរអែងផ្សេងៗ ឬការដឹងខ្លួនពីពិរុទ្ធភាពហើយមើលទៅ ។*

*កិច្ចការប្រចាំថ្ងៃចាប់ផ្តើមនៅម៉ោង៥និង៣០នាទីព្រឹក ដោយមានម៉ោងសួរចម្លើយដ៏ទៀងទាត់ចំនួនបីពេលទៀត គឺម៉ោង៦និង៤៥នាទី ម៉ោង១៣និង៤៥នាទី និងម៉ោង១៨និង៤៥នាទី ។ ចាប់ពីការចូលទៅដល់មន្ទីរឃុំឃាំងទួលស្លែង អ្នកទោសបានផ្លាស់ប្តូរស្ថានភាពផ្ទាល់ខ្លួនទាំងស្រុង ហើយបានទទួលឈ្មោះជា«ខ្មាំង» ឬ«ទណ្ឌិត»(អ្នកត្រូវទទួលទោស) ។ ក្នុងសៀវភៅរបស់គាត់មានសរសេរថា ជាទូទៅកម្មាភិបាលនៅទីនោះច្រើនតែចាត់ទុកអ្នកទោសបដិវត្តជា«សត្រូវ» ទាំងអស់ពីព្រោះគេចាត់ទុកអ្នកទាំងនោះជាមនុស្សដែលផ្តល់គ្រោះថ្នាក់ខ្លាំងបំផុតៈ «គេប្រើប្រាស់លទ្ធិកុម្មុយនិស្ត ដើម្បីបំផ្លាញលទ្ធិកុម្មុយនិស្ត» ។*

*សៀវភៅទាំងអស់នេះបានបង្ហាញអំពីដំណើរប្រព្រឹត្តទៅនៃការសួរចម្លើយនិងការធ្វើទារុណកម្មៈ«យើងចងអ្នកទោសនឹងប្រវាក់ យើងពិនិត្យបញ្ជាក់ថា មានអ្វីខ្លះជាប់នឹងខ្លួនអ្នកទោ ហើយនៅពេលដែលយើងសួរចម្លើយ យើងមិនទុកវត្ថុណាមួយនៅជិតដៃអ្នកទោសទេ ដោយអ្នកទោសនោះយកទៅប្រើជាអាវុធ» ។ ជាងនេះទៅទៀត កម្មាភិបាលនៅមន្ទីរឃុំឃាំងទួលស្លែងបានសរសេរថា «ជាការសំខាន់ដែលត្រូវធ្វើទារុណកម្មដោយដៃផ្ទាល់» ។ អ្វីដែលអ្នកសួរចម្លើយប្រព្រឹត្តដោយឡែកសម្រាប់អ្នកទោសភេទស្ត្រីគឺ «បក្សបានបញ្ជាឲ្យយើងវាយពួកស្ត្រីដែលមានទោសដោយខ្សែតីមិនឲ្យវាយនឹងដៃផ្ទាល់របស់យើងទេ» ។*

*បក្សបានហាមមិនឲ្យមានការវាយតប់ហួសកំណត់ដែរៈ «បើសិនគេវាយ«ខ្មាំង»យូរពេក ។ ខ្មាំងច្បាស់ជាធ្លាក់ខ្លួនឈឺ ហើយខ្លួនប្រាណនឹងចុះស្គមខ្លាំង ដែលយើងលែងវាយដំបាន ។ លទ្ធផលគឺ យើងគ្មានបានទទួលអ្វីជាដុំកំភួនពីពួកនោះឡើយ... ។ ធ្វើឲ្យខ្មាំងឈឺចាប់ខ្លាំងរហូតទាល់តែលែងហើបមាត់និយាយកើតនឹងធ្វើឲ្យបក្សទញ់ទាល់ក្នុងចិត្តជាខ្លាំង» ។*

*ប៉ុន្តែ ការធ្វើទារុណកម្មគឺជារឿងសំខាន់បំផុតនៅមន្ទីរឃុំឃាំងទួលស្លែង ហើយបច្ចេកទេសនៃការធ្វើទារុណកម្មគឺ*

មាននិយាយ នៅក្នុងកំណត់ហេតុខ្លីរបស់កម្មាភិបាល នោះដែរ ។ «គោលបំណងនៃការធ្វើទារុណកម្មគឺធ្វើយ៉ាងណាឲ្យបានទទួលចម្លើយ ។ យើងមិនមែនធ្វើទារុណកម្មសម្រាប់ការសប្បាយទេ... ជួនកាលការក្រេវក្រោធបានធ្វើឲ្យយើងលែងគិតឃើញខុសត្រូវ យើងក៏បាត់បង់ភាពម្ចាស់ការរបស់យើង ។ ជួនកាលការសួរចម្លើយតម្រូវឲ្យយើងស្រែកចំទាលដាក់ត្រចៀកខ្លាំង ហើយនៅពេលដែលវាឆ្លើយក្នុងន័យដែលយើងចង់បាន យើងទាំងអស់គ្នាមានសេចក្តីត្រេកអរយ៉ាងខ្លាំង យើងនាំគ្នាសើចសប្បាយ ហើយយើងក៏បានឈប់សម្រាកមួយស្របក់...» ។

បក្សបានក្រើនរំឭកកម្មាភិបាលនៅមន្ទីរឃុំឃាំងទួលស្លែងថា ហេតុអ្វីបានជាត្រូវវាយធ្វើទារុណកម្មអ្នកទោសគឺដើម្បីចម្រាញ់យកចម្លើយសារភាពនិង«ភស្តុតាងផ្សេងៗ» អំពីខ្សែបណ្តាញនិងការឃុបឃិតគ្នាជាសម្ងាត់បម្រុងក្បត់ដែលគំរាមកំហែងដល់ការបដិវត្តន៍ ។ អង្គការថ្នាក់លើបាននិយាយប្រាប់គាត់ថា «ការងាររបស់សន្តិសុខ គឺជាការងារតស៊ូវណ្ណៈមួយដើម្បីការពារបក្សវណ្ណៈអធន កម្ពុជាប្រជាធិបតេយ្យ មាគ៌ាឯករាជ្យ និងធ្វើម្ចាស់លើជោគវាសនារបស់ខ្លួន ។ ដោយហេតុនេះ យើងនឹងគាស់រំលើងអាថ៌កំបាំងរបស់ខ្មាំងយើងនឹងធ្វើឲ្យខូចគម្រោងការរបស់ពួកវាយើងនឹងកាត់ផ្តាច់ខ្សែបណ្តាញនិងផែនការក្បត់របស់ពួកវាប្រកបដោយប្រសិទ្ធភាពមួយដែលកាន់តែរឹងមាំឡើងៗ» ។

នីតិវិធីសួរចម្លើយគឺ ត្រូវយកឲ្យបានព័ត៌មានផ្សេងៗ ធ្វើទុក្ខបុកម្នេញអ្នកទោសជាមួយនឹងការឃោសនានយោបាយ «ដោយដេរប្រមាថជៀលត្និះអ្នកទោស» បន្ទាប់មក ធ្វើទារុណកម្ម ។ «ពិនិត្យមើលម្តងមួយៗនិងវិភាគចម្លើយរបស់អ្នកទោស» ដើម្បីដាក់សំណួរផ្សេងទៀត និងឲ្យសំអាងការចោទប្រកាន់ផ្សេងៗ ។ កុំធ្វើឲ្យអ្នកទោសស្លាប់ក្នុងពេលសួរចម្លើយនិងស្តាប់ចម្លើយអ្នកទោសផ្សេងទៀត ជាពិសេស ត្រូវរក្សាការសម្ងាត់ឲ្យបានអំពីសកម្មភាពទាំងឡាយនៅមន្ទីរឃុំឃាំងទួលស្លែង ។ ការធ្វើទារុណកម្មត្រូវតែស្ថិតនៅជាសម្ងាត់ គ្មានអ្នកណាម្នាក់ដឹងថា អ្នកទោសបានទទួលសារភាពក្រោមការវាយដំប្រំផាត់ឡើយ ។ នៅទីបំផុតរាល់ករណីរបស់អ្នកទោសតោងតែទៅពិភាក្សាជាមួយថ្នាក់លើជាបន្ទាន់ ។ «បើសិនគ្មានការសម្ងាត់ទេ សន្តិសុខក៏គ្មានន័យអ្វីដែរ» នេះគឺជាបទបញ្ញា ។

ចម្លើយសារភាពជាចំណុចសំខាន់បំផុតនៃប្រព័ន្ធសន្តិសុខ ។ អង្គការបានណែនាំឲ្យកម្មាភិបាលនៅទីនោះបណ្តោយឲ្យពួកអ្នកទោសសរសេរចម្លើយសារភាពដោយដៃផ្ទាល់ ហើយចុះហត្ថលេខានិងចុះថ្ងៃខែឲ្យបានច្បាស់លាស់ ។ កម្មាភិបាលម្នាក់បានណែនាំថា «ត្រូវតែឲ្យអ្នកទោសសរសេរប្រវត្តិនៃសកម្មភាពក្បត់របស់ខ្លួនធ្វើយ៉ាងណាឲ្យទាល់តែរឿងនោះចូលដល់ជម្រៅនៃអាថ៌កំបាំងចម្លើយសារភាពត្រូវតែច្បាស់លាស់ជាក់ស្តែង និងបង្ហាញឲ្យឃើញនូវមូលហេតុ»...ដោយបញ្ជាក់បំភ្លឺពីការធ្វើចារកម្មនិងការជ្រៀតចូលបែបណា ។ «អ្វីដែលប្រសើរជាងគេ គឺឲ្យអ្នកទោសសរសេរចម្លើយសារភាពផ្សេងៗដោយដៃ និងគំនិតផ្ទាល់របស់គេជាមួយពាក្យសម្តីត្រង់ៗ ។ យើងត្រូវចៀសវាងកុំនិយាយឲ្យសរសេរតាម ដូច្នេះនៅពេលដែលពួកគេនិយាយឬសរសេរចប់យើងចាំតែដកស្រង់ចំណុចខ្សោយប៉ុណ្ណោះបានហើយ» ។

ចម្លើយសារភាពដំបូងៗ ដែលសរសេរជាមួយនឹងពាក្យសម្តីផ្ទាល់របស់អ្នកទោសបានរួមបង្កជាឯកសារប្រវត្តិសាស្ត្រដែលមានលក្ខណៈប្លែកពីធម្មតានិងគួរឲ្យរន្ធត់ក្រៃលែង ។

បទបញ្ញាចុងក្រោយមួយគឺថា «ការសរសេរនិងក្រដាសសរសេរត្រូវតែស្អាតល្អ កុំឲ្យមានស្នាមប្រឡាក់» ។

មតិណែនាំចំពោះពួកកម្មាភិបាលនៅទីនោះ ពុំទុកឲ្យមានសេចក្តីសង្ស័យណាមួយឡើយៈ អ្នកទោសទាំងអស់សុទ្ធតែត្រូវសន្មតថា ជាពិរុទ្ធជននិងត្រូវមានទោសប្រហារជីវិតដោយមិនគិតអំពីចម្លើយសារភាពដែលអ្នកទាំងនោះបានសរសេរទេ ។ ថ្នាក់លើបានទូន្មានកម្មាភិបាលទាំងនោះថា «ចូរសមមិត្តទាំងអស់យកចិត្តទុកដាក់ចំពោះមធ្យោបាយដោះកុននិងល្បិចកលបោកប្រាស់របស់អ្នកទោសជាប់គុក ក្នុងគោលបំណងបោកបញ្ឆោតយើងអង្វរករយើងនិងអះអាងថា ខ្លួនសុទ្ធតែជាមនុស្សស្លូតត្រង់ ពុំដែលបានក្បត់នឹងបដិវត្តន៍ម្តងណាឡើយ... ហើយបន្ទោសថា យើងបានវាយធ្វើបាបពួកគេទាំងអយុត្តិធម៌ ហើយថាពួកគេពុំមែនជាពួកក្បត់ទេ...ឬថា ពួកគេបង្ខំចិត្តឆ្លើយសារភាពដោយសារការឈឺចាប់តែប៉ុណ្ណោះ» ។ កម្មាភិបាលថ្នាក់ខ្ពស់ម្នាក់ទៀតបានបន្ថែមថា មិនត្រូវបណ្តោយឲ្យអ្នកទោសធ្វើអត្តឃាតទេ ការធ្វើអត្តឃាត

ក៏ជាល្បិចកលមួយដែរ ។

កម្មាភិបាលថ្នាក់ខ្ពស់បានប្រាប់អ្នកសួរចម្លើយដែលទើបនឹងចូលធ្វើការឲ្យចេះប្រើពាក្យភូតកុហកដើម្បីជំរុញឲ្យអ្នកទោសទទួលសារភាព ឧទាហរណ៍ សន្យានឹងអ្នកទោសថា បើទទួលសារភាពអាចនឹងត្រូវលើកលែងទោសឲ្យរួចជីវិត ព្រមទាំងសមាជិកគ្រួសារផង ។ បក្សបានណែនាំឲ្យពន្យល់ប្រាប់អ្នកទោសថា ពួកគេនឹងត្រូវយកទៅផ្ញើនៅអង្គភាពពិសេសមួយរបស់បក្ស ហើយថាបក្ស «មិនបន្ទាតពេលវេលារបស់ខ្លួនដើម្បីចាប់និងសម្លាប់មនុស្សទាំងនោះទេ បក្សចង់ស្វែងរកតែការពិតប៉ុណ្ណោះ» ។

ប៉ុន្តែ របៀបនិយាយឬសរសេរដែលប្រើពាក្យសម្តីមិនសមទំនងក្នុងសៀវភៅទាំងនោះបានធ្វើឲ្យគេសន្និដ្ឋានថា កម្មាភិបាលដែលធ្វើការនៅមន្ទីរឃុំឃាំងទួលស្លែងទាំងប៉ុន្មានប្រហែលសុទ្ធតែត្រូវធ្វើឲ្យអំពល់ដោយ«មនុស្សខុសគេ» ដែលសន្តិបាលកំពុងតែបង្កើតនោះហើយ ។ ជាមួយនឹងរបៀបគ្រប់គ្រងមួយដោយសន្ទូតជាពិរុទ្ធជននូវអ្នកទោស អ្នករួមគំនិត ឪពុកម្តាយរបស់អ្នកទោសនិងទំនាក់ទំនងទាំងអស់ នៅទីបំផុតម៉ាស៊ីនសម្លាប់មនុស្សនៅមន្ទីរឃុំឃាំងទួលស្លែងអាចបញ្ចូលបក្ខជនទាំងមូលរបស់បក្សទៅក្នុងនោះដែរ ។ ភាពជាមនុស្សគ្មានកំហុសពុំមានសារសំខាន់ទេ កម្មាភិបាលទាំងអស់ត្រូវតែមានសេចក្តីស្មោះត្រង់ដាច់ខាតមួយនៅក្នុងបក្ស ។ ក៏ប៉ុន្តែ មានតែមេដឹកនាំជាន់ខ្ពស់ប្រមាណជាសាមសិបនាក់ ក្នុងគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះដែលដឹងពីលក្ខណៈពិតប្រាកដនៃសកម្មភាពទាំងឡាយរបស់ក្រុមសន្តិសុខនៅមន្ទីរឃុំឃាំងទួលស្លែងនិងនៅតាមបណ្តាខេត្ត ។ កម្មាភិបាលថ្នាក់ខ្ពស់បានប្រាប់ពួកកម្មាភិបាលនៅមជ្ឈមណ្ឌលឃុំឃាំងថា ការប្រែប្រួលប្របល់មួយអាចស្តែងឲ្យឃើញឡើងៈ «បក្សផ្លាស់ប្តូរចិត្តឆាប់រហ័សនិងជារឿយៗ ។ បក្សបានប្តូរផ្លាស់អ្នកទោសដែលយើងត្រូវសួរចម្លើយដោយគ្មានកំណត់ពេលវេលាជាក់លាក់...បក្សបានកែប្រែនីតិវិធីចងក្រងឯកសារផ្សេងៗ វិធីសាស្ត្រក្នុងការសួរចម្លើយ ការឃោសនានយោបាយ ការធ្វើទារុណកម្ម ការចាប់ដាក់គុកនិងការផ្ទេរពួកអ្នកទោសដែលមានជាញឹកញាប់និងយ៉ាងរហ័សបំផុត» ។

មន្ទីរឃុំឃាំងទួលស្លែងគ្រាន់តែជាកន្លែងកំពូលនៃរឿងអាថ៌កំបាំង ជាទីសេនាធិការរបស់សន្តិបាល និងជាមជ្ឈមណ្ឌលឃុំឃាំងរបស់មន្ទីរបក្សប៉ុណ្ណោះ ។ កម្មាភិបាលនៅទីនោះមាននាទីត្រឹមតែទទួលខុសត្រូវមួយចំណែកតូចប៉ុណ្ណោះក្នុងការសម្លាប់មនុស្សគឺ ការសម្លាប់អ្នករងគ្រោះដែលកំពុងរស់នៅក្នុងភូមិភាគក្រុងភ្នំពេញ ឬអ្នករងគ្រោះដែលត្រូវវិនិច្ឆ័យថាជាមនុស្សមានអំណាចគ្រាន់បើស័ក្តិសមនឹងឲ្យ ខុច ធ្វើទារុណកម្មនិងសួរចម្លើយ ។

មានកន្លែងឃុំឃាំងរបៀប «ទួលស្លែង» ច្រើនរាប់មិនអស់ផ្សេងទៀត ដែលធ្វើឲ្យប្រទេសជាតិប្រឡាក់ទៅដោយឈាមគឺគុក កន្លែងប្រហារជីវិត និងរណ្តៅកប់សាកសព ។ ការផ្សារនិងការសម្លាប់មនុស្សជាសភាពពិតជាក់ស្តែងពីររបស់កម្ពុជាប្រជាធិប-តេយ្យ ។ អំពើកំណាចឃោរឃៅរបស់ប្រធានភូមិនិងស្រុក មុនដំបូងមានសភាពជាការប្រព្រឹត្តខុសគន្លងសុទ្ធសាធ ប៉ុន្តែជាអំពើដែលប្រជាជនអាចស្មានដឹងមុន ។ ប្រជាជនទាំងអស់ចេះការពារខ្លួនបែបណាៗជាមុនប្រឆាំងនឹងការធ្វើទោសដែលជាក់ស្តែងបំផុត ។ ប្រជាជនចេះលាក់ដើមកំណើតរបស់ខ្លួន ចេះធ្វើតាមបទបញ្ជាដោយគ្មានតវ៉ាត្អូញត្អែរ ។ ប៉ុន្តែប្រជាជននៅមិនដឹងពីមធ្យោបាយដើម្បីគេចឲ្យផុតពីកំហឹងក្រេវក្រោធ នៅពេលដែលមជ្ឈិមចេញបញ្ជាឲ្យបោសសម្អាតនិងការកាប់សម្លាប់ថ្មីៗទៀត ។ គេមិនដែលធ្វើអ្វីៗដោយចេញមុខទេ លើកលែងតែការឆ្លើយដោះសាពីរឿងផ្សេងៗ ដែលកើតឡើងដោយសារជំងឺមិនទុកចិត្តរបស់មជ្ឈិមប៉ុណ្ណោះ ។ បញ្ហាទាំងនេះបក្សបានធ្វើឡើងបន្ទាប់ពីបានពិចារណាមុនរួចជាស្រេច ។ ទោះបីជាកម្មាភិបាលរបស់បក្សក៏មិនត្រូវគេផ្តល់ព័ត៌មានឲ្យដឹងពីរឿងនេះដែរ ។ ការបំភិតបំភ័យជាមធ្យោបាយដំបូងរបស់មជ្ឈិមដើម្បីក្តោបក្តាប់ប្រជាជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ប៉ុន្តែ បក្សអាចបញ្ចេញឲ្យឃើញមាគ៌ាទូទៅមួយក្នុងការសម្លាប់រង្គាល ។ ផ្នែកសន្តិសុខរបស់បក្ស ដែលរៀបចំឲ្យមាននៅមន្ទីរឃុំឃាំងទួលស្លែងបានរួមបង្កជារបៀបគ្រប់គ្រងដ៏រឹងមាំបំផុតមួយក្នុងចំណោមរបៀបគ្រប់គ្រងដ៏រឹងមាំបំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅថ្នាក់ភូមិ កន្លែងសម្រាប់សម្លាប់មនុស្សគ្រាន់តែជាចម្ការសាមញ្ញមួយប៉ុណ្ណោះ ។ បណ្តាកម្មាភិបាលដែលគ្រប់គ្រងដឹកនាំសហករណ៍គោងតែផ្តល់ដំណឹងអំពីការសម្លាប់មនុស្សទៅឲ្យ

អ្នកកាន់អំណាចថ្នាក់លើភ្លាមៗ គឺទៅបណ្តាប្រធានឃុំ ។ ភាគច្រើននៃមនុស្សដែលត្រូវសម្លាប់ក្នុងភូមិ«ទាក់ទងទៅនឹងវិន័យ» ។ អ្នកស្លាប់ទាំងនោះសុទ្ធតែជាមនុស្សដែលហ៊ានចោទសួរពីបញ្ហាអំណាចរបស់អង្គការ ជាមនុស្សដែលពុំអាចដើរតាមបដិវត្តន៍ដែលប្រព្រឹត្តកំហុសឆ្គងជាច្រើន ហើយធ្លាក់ទៅក្នុងប្រភេទជាពលករគ្មានប្រយោជន៍ ជាមនុស្សដែលគេច្រើនអះអាងថាៈ «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។

ប៉ុន្តែ ថ្នាក់ក្រោមពុំដែលរាយការណ៍រសម្លាប់ទាំងអស់ឲ្យថ្នាក់លើដឹងទេ ហើយមជ្ឈិមក៏ប្រហែលជាមិនដែលដឹងអំពីទំហំនៃការប្រហារជីវិតឥតអាសូរនេះដែរ ។ ឃុំខ្លះ ស្រុកភាគច្រើន តំបន់និងភូមិភាគទាំងអស់សុទ្ធតែមានគុកដាក់មនុស្ស ។ ជាទូទៅ ខ្មែរក្រហមច្រើនយកសាលារៀន វត្ត ឬផ្ទះ ធ្វើជាគុក ដោយមានទីធ្លាមួយសម្រាប់ធ្វើទារុណកម្មនិងរណ្តៅមួយក្បែរនោះសម្រាប់ដាក់ខ្មោច ។ នៅមានជំរំជាច្រើនទៀតសម្រាប់បង្ខាំងទុកមនុស្សឲ្យនៅតែមួយកន្លែង ហើយអ្នកទោសក្នុងនោះត្រូវធ្វើការដូចអ្នកស្រែចម្ការដែរ គឺមានសភាពដូចគ្នានឹងជំរំកែប្រែ ។ យើងអាចសន្និដ្ឋានដោយគ្មានខ្លាចភ័ន្តច្រឡំថា ជាទូទៅ គុកទាំងនោះបានយកមន្ទីរឃុំឃាំងទួលស្លែងធ្វើជាគំរូ ហើយជំរំមរណៈនានានៅតាមជនបទបានធ្វើទារុណកម្មនិងសម្លាប់ជនទាំងឡាយណាដែលអង្គការចាត់ទុកជាខ្មាំងសត្រូវនៅពេលនេះ ហើយថា អ្នកស្លាប់ទាំងនោះក៏មានទុកឯកសារផ្សេងៗដូចនៅមន្ទីរឃុំឃាំងទួលស្លែងដែរ ។

ប៉ុន្តែ កាលបើពេលណាមួយត្រូវធូរស្រាល ការធ្វេសប្រហែសបានបណ្តាលឲ្យកើតវង្វង់ពិរុទ្ធភាព គឺការសប្បាយនឹងធ្វើឲ្យអ្នកដទៃឈឺចាប់ ។ ចំណង់សងសឹក ឬសម្លាប់តាមធម្មតាត្រូវបានបង្កើនរហូតទាល់តែកម្មាភិបាលសម្លាប់មនុស្សក្នុងមួយលើកៗដោយគ្មានញញើតដៃបន្តិចឡើយ ។ គ្មានអ្វីមួយអាចបង្អន់ការខ្នះខ្នែងរបស់ពួកឃាតកទាំងនោះ ដែលនៅទីបំផុតសុទ្ធតែយល់ផ្ទុយថា អ្នកណាក៏ដោយក៏អាចបែរក្បាលមកប្រឆាំងនឹងអង្គការវិញដែរ ជាពិសេសមេដឹកនាំបក្ស ហើយខំប្រឹងកម្ចាត់សត្រូវផ្ទាល់របស់ខ្លួនចោលទាំងអស់ ។ កម្មាភិបាលថ្នាក់ក្រោមបានលាក់ចំនួនមនុស្សដែលខ្លួនសម្លាប់ចំពោះថ្នាក់លើ ។

ប៉ុន្តែ យើងអាចរាប់ឃើញចំនួនប្រជាជនកម្ពុជាដែលត្រូវសម្លាប់យ៉ាងវង្វេងតាមរយៈបណ្តឹងរបស់សាក្សីម្នាក់ដែលធ្លាប់រស់នៅភូមិភាគនិរតី ។ គាត់រស់នៅតំបន់១៣ ជាតំបន់មួយក្នុងចំណោមតំបន់ទាំងសាមសិបបីរបស់ភូមិភាគ ។ ដូចក្នុងទូទាំងភូមិភាគនិរតីដែរ តំបន់នេះត្រូវបានសម្រាំងទុកដោយមជ្ឈិមសម្រាប់ប្រើប្រាស់កម្មាភិបាលនៅទីនោះក្នុងការបោសសម្អាតភូមិភាគដទៃៗទៀត ។ សាក្សីរូបនោះបាននិយាយថា ប្រជាជនកម្ពុជាប្រហែល៣៨.៤០០នាក់ត្រូវបានសម្លាប់ជាផ្លូវការក្នុងតំបន់របស់គាត់ចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ។ ចំនួននេះប្រហែលជាផ្អែកតាមចិត្តរបស់អ្នកណាម្នាក់ ដូចគ្នានឹងតួលេខនៃការប្រមូលផលទាំងឡាយដែលកម្មាភិបាលបានក្លែងបន្លំឯកសារសម្រាប់អង្គការកណ្តាលដែរ ប៉ុន្តែក្នុងន័យផ្ទុយគ្នាស្រឡះ ។ ជាទូទៅ កម្មាភិបាលទាំងនោះច្រើនបន្ថយចំនួនពិតនៃអ្នកស្លាប់ឲ្យតិចបំផុតនៅក្នុងរបាយការណ៍ផ្សេងៗ ពីព្រោះរបបនេះបានប្រកាសថាចំនួនប្រជាជនគោងតែបង្កើនឲ្យច្រើនថែមទៀត ។ ទង្វើនេះហើយដែលធ្វើឲ្យឃើញច្បាស់លាស់ពីភាពឆ្គួតលេលារបស់របបនេះ: មជ្ឈិមបានបង្គាប់បញ្ជាឲ្យថ្នាក់ក្រោមបោសសម្អាតពោលគឺសម្លាប់មនុស្សនិងការធ្វើឲ្យប្រជាជនកម្ពុជាស្លាប់ក្នុងពេលធ្វើការងារ ប៉ុន្តែមជ្ឈិមបែរជាសង្ឃឹមចង់ឲ្យប្រជាជនកើនមួយទ្វេជាពីរក្នុងរយៈពេលពីរទសវត្សរ៍ខាងមុខទៅវិញ ។

បើគិតឲ្យសព្វៗទៅ បញ្ជីឈ្មោះជនរងគ្រោះដ៏វែងនៅមន្ទីរឃុំឃាំងទួលស្លែងធ្វើឲ្យគេដឹងចំនួនអ្នកស្លាប់តិចជាងចំនួនប្រជា-ជនដែលគេបានសម្លាប់រៀងរាល់ឆ្នាំក្នុងទូទាំងប្រទេសទៅទៀត ។ មានតែឯកសារដែលកម្រកបានដូចជាចម្លើយសារភាពប៉ុណ្ណោះដែលបង្ហាញឲ្យគេដឹងពីប្រវត្តិរបស់បណ្តាសមាជិកបក្សកុម្មុយនិស្តនិងប្រវត្តិមនុស្សធម្មតាមុននិងក្រោយបដិវត្តន៍ ។ ឯកសារទាំងនោះបានរៀបរាប់ពីប្រវត្តិនៃការពិភាក្សាផ្អែកនយោបាយកលល្បិចសម្ងាត់បម្រុងបំផ្លាញគ្នាឯង និងការតស៊ូដើម្បីអំណាចផ្ទៃក្នុងបក្ស ។ ក្នុងរដ្ឋមួយដែលពឹងផ្អែកលើសន្តិសុខជាធំដែលបិទទ្វារប្រទេសជាតិឯងទាំងស្រុងនោះ មន្ទីរឃុំឃាំងទួលស្លែងបានក្លាយទៅជាស្ថាប័នតែមួយគត់ដែលអាចឲ្យដឹងពីបច្ច័យដែលជាដើមហេតុផ្សេងៗ និងគំនិតគួរឲ្យព្រឺខ្លាចបំផុតរបស់បដិវត្តន៍ ។ ◆◆◆

# ដីកាចាប់ខ្លួនដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ដីកាចាប់ខ្លួនដំបូងបំផុតដែលនឹងត្រូវចេញដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ត្រូវបានចេញដោយអង្គបុរេជំនុំជម្រះទីពីរ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ។ ដីការចាប់ខ្លួននេះគឺដើម្បីចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ប្រាំនាក់របស់កងទ័ពតស៊ូរបស់ព្រះ *(Lord's Resistance Army ឬ LRA)* ទាក់ទងនឹងបទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ដែលបានប្រព្រឹត្តនៅក្នុងប្រទេសអ៊ុយហ្កាន់ដា កាលពីខែកក្កដា ឆ្នាំ២០០២ ។ អង្គបុរេជំនុំជម្រះនេះបានធ្វើសេចក្តីសន្និដ្ឋានថា «មានហេតុផលសមរម្យក្នុងការជឿជាក់ថា ចូសេហ្វ កូនី, វិនសិន អូទី, អូកុត អូឌីអាមបូ, ដូមីនីក អុងវែន, និង រ៉ាស្កា លូកវីយ៉ា បានចេញបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់តុលាការ [ព្រហ្មទណ្ឌអន្តរជាតិ]» ។

ដោយមានការយល់ព្រមពីអង្គបុរេជំនុំជម្រះទីពីរ ដីកាចាប់ខ្លួនទាំងនេះត្រូវបានដាក់ទៅក្នុងស្រោមសំបុត្រនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៥ ដើម្បី «ធានាសុវត្ថិភាពនិងសុខុមាលភាពផ្នែករាងកាយនិងស្មារតី» និងដើម្បី «ការពារការលាតត្រដាងអត្តសញ្ញាណ ឬទីកន្លែងរបស់ជនរងគ្រោះសាក្សីនិងក្រុមគ្រួសារ» ។ អង្គបុរេជំនុំជម្រះនេះក៏បានចេញលិខិតចាប់ខ្លួននិងនាំខ្លួនមេបញ្ជាការកងទ័ពតស៊ូរបស់ព្រះទាំងប្រាំនាក់ដែលមានឈ្មោះនៅក្នុងដីកាចាប់ខ្លួន និងព្រមទាំងបានសម្រេចថាក្រឡាបញ្ជីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងបញ្ជូនដីកាចាប់ខ្លួនទាំងនេះទៅឲ្យរដ្ឋាភិបាលរបស់ប្រទេសអ៊ុយហ្កាន់ដា ។

អង្គបុរេជំនុំជម្រះទីពីរបានសម្រេចកាលពីថ្ងៃទី១៣ ខែតុលា ក្នុងការចេញដីកាចាប់ខ្លួនអ្នកទាំងនេះ ដោយកត់សម្គាល់ថា «ទាក់ទងនឹងស្ថានភាពនៅក្នុងប្រទេសអ៊ុយហ្កាន់ដា ផែនការទូទៅសម្រាប់បញ្ហាសន្តិសុខរបស់សាក្សីនិងជនរងគ្រោះត្រូវបានរៀបចំនិងអនុវត្តរួចហើយ និងថាតាមរយៈការវាយតម្លៃនិងយោបល់របស់ព្រះរាជអាជ្ញា និងអង្គភាពសាក្សីនិងជនរងគ្រោះ ផែនការទូទៅបានផ្តល់នូវវិធានការការពារគ្រប់គ្រាន់និងចាំបាច់ចំពោះការព្រួយបារម្ភទាំងឡាយ នៅក្នុងដំណាក់កាលនេះ» ។

## ដើមហេតុនៃការចោទប្រកាន់

ដោយយោងទៅតាមបទចោទប្រកាន់ដែលមានសរសេរនៅក្នុងដីកាចាប់ខ្លួន LRA គឺជាក្រុមប្រដាប់អាវុធមួយដែល«បានបន្តការរីករាលដាលនៃអំពើហិង្សាទៅលើជនស៊ីវិលដោយប្រើសកម្មភាពផ្សេងៗរួមមានៈ មនុស្សឃាត ការចាប់ពង្រត់ទាសភាពផ្លូវភេទ កាត់អវយវៈ (ធ្វើឲ្យមនុស្សពិការ) ក៏ដូចជាការដុតបំផ្លិចបំផ្លាញផ្ទះសម្បែង និងលួចទ្រព្យសម្បត្តិ ហើយជនស៊ីវិលដែលត្រូវចាប់ពង្រត់នេះ ដែលរួមទាំងកុមារៗ ត្រូវបង្ខំឲ្យធ្វើជាអ្នកប្រយុទ្ធកម្មករ និងជាទាសករផ្លូវភេទនិងចូលរួមប្រយុទ្ធប្រឆាំងនឹងទាហានរដ្ឋាភិបាលអ៊ុយហ្កាន់ដានិងសហគមន៍ជនស៊ីវិល ។

បទចោទប្រកាន់ទាំងនេះគឺថា កាលពីពាក់កណ្តាលឆ្នាំ២០០២ ចូសេហ្វ កូនី បានបញ្ជាឲ្យកងកម្លាំងរបស់ LRAចាប់ផ្តើមប្រតិបត្តិការមួយវាយប្រហារលើជនស៊ីវិល ។ នៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០០៣ កូនី បានចេញបញ្ជាឲ្យសម្លាប់លួចនិងចាប់ពង្រត់ប្រជាជនស៊ីវិល ដែលក្នុងនោះមានទាំងជនភៀសសឹកដែលរស់នៅក្នុងជំរំផង ។ តាមរយៈនេះមេបញ្ជាការជាន់ខ្ពស់កងទ័ពតស៊ូរបស់ព្រះនិងមេបញ្ជាការកងពលតូចទាំងអស់ រួមមានអ្នកទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាចាប់ខ្លួនទាំងអស់បានចាប់ផ្តើមវាយប្រហារតំបន់មួយចំនួននៅក្នុងប្រទេសអ៊ុយហ្កាន់ដា ។ ព្រះរាជអាជ្ញាបានដាក់ជូនតុលាការនូវភស្តុតាងផ្សេងៗដែលបង្ហាញអំពីការចូលរួមដោយផ្ទាល់របស់អ្នកដែលតុលាការកំពុងស្វែងរកចាប់ខ្លួនទាំងនេះពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រនិងប្រតិបត្តិការវាយប្រហារនេះ ។

## បទចោទប្រកាន់

១) ដីកាចាប់ខ្លួនរបស់ ចូសេហ្វ កូនី មានរាយបទចោទ-ប្រកាន់ចំនួន៣៣ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវ

ជាលក្ខណៈបុគ្គលដោយយោងតាមមាត្រា២៥(៣)(ក) និង មាត្រា២៥ (៣)(ខ) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម(ជាច្បាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ) រួមមានៈ

បទចោទប្រកាន់ចំនួនដប់ពីរអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាត[មាត្រា៧(១)(ក)] ទាសភាព [មាត្រា៧(១)(គ)] ទាសភាពផ្លូវភេទ [មាត្រា៧(១)(ឆ)] រំលោភ[មាត្រា៧(១)(ឆ)] សកម្មភាពអមនុស្សធម៌ក្នុងការបង្ករបួសស្នាមធ្ងន់ធ្ងរនិងការឈឺចាប់[មាត្រា៧(១)(ដ)] ។

បទចោទប្រកាន់ចំនួនម្ភៃមួយទៀតអំពីឧក្រិដ្ឋកម្មសង្គ្រាម មនុស្សឃាត[មាត្រា៨(២)(គ)(i)] ការប្រព្រឹត្តឃោរឃៅចំពោះជនស៊ីវិល [មាត្រា៨(២)(គ)(i)] វាយប្រហារដោយចេតនាទៅលើប្រជាជនស៊ីវិល[មាត្រា(៨២)(ង)(i)] ការឆក់ប្លន់ [មាត្រា(៨២)(ង)(v)] រំលោភ [មាត្រា៨(២)(ង)(vi)] ការបង្ខំកុមារឲ្យធ្វើទាហាន [មាត្រា៨(២)(ង)(vii)] ។

២)ដីកាចាប់ខ្លួន វិនសិន អូទី មានរាយបទចោទប្រកាន់ចំនួនសាមសិបពីរ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវជាលក្ខណៈបុគ្គល(មាត្រា២៥(៣)ខ) នៃច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តជាតិរួមមានៈ

បទចោទប្រកាន់ចំនួនដប់មួយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាដ [មាត្រា៧(១)(ក)] ទាសភាពផ្លូវភេទ [មាត្រា៧(១)(ឆ)] សកម្មភាពអមនុស្សធម៌ក្នុងបង្ករបួសស្នាមធ្ងន់ធ្ងរនិងការឈឺចាប់ [មាត្រា៧(១)(ដ)] ។

បទចោទប្រកាន់ចំនួនម្ភៃមួយអំពីឧក្រិដ្ឋកម្មសង្គ្រាមរួមមានៈ បទរំលោភ [មាត្រា៨(២)(ង)(vi)] វាយប្រហារដោយចេតនាទៅលើជនស៊ីវិល [មាត្រា៨(២)(ង)(i)] ការបង្ខំកុមារឲ្យធ្វើទាហាន [មាត្រា៨(២)(ង)(vii)] ប្រព្រឹត្តអំពើឃោរឃៅចំពោះជនស៊ីវិល [មាត្រា៨(២)(គ)(i)] ការឆក់ប្លន់-មាត្រា៨(២)(ង)(v) , មនុស្សឃាដ [មាត្រា៨(២)(គ)(i)] ។

៣) ដីកាចាប់ខ្លួន អូកុត អូឌីអាំបូ មានរាយបទចោទប្រកាន់ចំនួនដប់ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលមាត្រា២៥(៣)(ខ) នៃច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តជាតិរួមមានៈ

បទចោទប្រកាន់ចំនួនពីរអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាដ [មាត្រា៧(១)(ក)] ទាសភាព [មាត្រា៧(១)(គ)] ។ បទចោទប្រកាន់ចំនួនប្រាំបីពីបទឧក្រិដ្ឋកម្មសង្គ្រាមមនុស្សឃាដ [មាត្រា៨(២)(គ)(i)] ប្រព្រឹត្តអំពើឃោរឃៅចំពោះជនស៊ីវិល [មាត្រា៨(២)(ង)(i)] ការឆក់ប្លន់ [មាត្រា៨(២)(ង)(v)] ការបង្ខំកុមារៗឲ្យធ្វើទាហាន [មាត្រា៨(២)(ង)(vii)] ។

៤)ដីកាចាប់ខ្លួន ដូមីនីក អុងវ៉ែន មានរាយបទចោទប្រកាន់ចំនួនប្រាំពីរ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាមមាត្រា២៥(៣)(ខ) នៃច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តជាតរួមមានៈ

បទចោទប្រកាន់ចំនួនបីពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាដ [មាត្រា៧(១)ក)] ទាសភាព [មាត្រា(៧)(១)(គ)] សកម្មភាពអមនុស្សធម៌ក្នុងការបង្ករបួសស្នាមធ្ងន់ធ្ងរ និងការឈឺចាប់ [មាត្រា៧(១)(ដ)] ។

បទចោទប្រកាន់ចំនួនបួនពីបទឧក្រិដ្ឋកម្មសង្គ្រាមមនុស្សឃាដ [មាត្រា៨(២)(គ)(i)] ការធ្វើបាបឃោរឃៅចំពោះជនស៊ីវិល[មាត្រា៨(២)(គ)(i)] វាយប្រហារដោយចេតនាទៅលើប្រជាជនស៊ីវិល[មាត្រា៨(២)(ង)(i)] ការឆក់ប្លន់ [មាត្រា៨(២)(ង)(v)] ។

៥) ដីកាចាប់ខ្លួន រ៉ាស្កា លូកវីយ៉ា មានរាយបទចោទប្រកាន់ចំនួនបួន ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈមាត្រា២៥(៣)(ខ) នៃច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តជាតិរួមមានៈ

បទចោទប្រកាន់ចំនួនមួយពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាសភាព [មាត្រា(៧)(១)(គ)] ។

បទចោទប្រកាន់ចំនួនបីពីបទឧក្រិដ្ឋកម្មសង្គ្រាមប្រព្រឹត្តអំពើឃោរឃៅចំពោះជនស៊ីវិល[មាត្រា៨(២)(គ)(i)] វាយប្រហារដោយចេតនាទៅលើប្រជាជនស៊ីវិល [មាត្រា៨(២)(ង)(i)] ការឆក់ប្លន់ [មាត្រា៨(២)(ង)(v)] ។

## **អង្គបុរេជំនុំជម្រះទីពីរ**

កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៤ ប្រធានតុលាការនេះបានប្រគល់ស្ថានការណ៍នៅក្នុងប្រទេសអ៊ុយហ្កាន់ដា ទៅឲ្យអង្គ

បុរេជំនុំជម្រះទីពីរដែលមានសមាសភាពចៅក្រមៈ ទូអ៊ីឡូម៉ា ណេរ៉ូនី ស្វែដ (មកពីសាម៉ូអា), ម៉ូរ៉ូ ប៉ូលីទី (អ៊ីតាលី), និង ចៅក្រម ហ្វាទូម៉ាតា ដេមបេឡេ ឌីយ៉ារ៉ា (ប្រទេសម៉ាលី) ។

### ពត៌មានខ្លះៗអំពីស្ថានការណ៍នៅក្នុងប្រទេសអ៊ុយហ្គាន់ដា (ផ្ញើនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤)

ជម្លោះបច្ចុប្បន្ននេះបានកើតឡើងតាំងពីដប់ប្រាំពីរឆ្នាំមុនម៉្លេះ ដែលនៅក្នុងរយៈពេលនេះជនស៊ីវិលអ៊ុយហ្កាន់ដានៅភាគខាងជើងរបស់ប្រទេសត្រូវប្រឈមមុខទៅនឹងការវាយប្រហារយ៉ាងធ្ងន់ធ្ងរ ។ ភាពតានតឹងនេះចាប់ផ្តើមឡើងភ្លាមៗបន្ទាប់ពីលោកប្រធានាធិបតី យ៉ូវេរី មូសេវេនី ឡើងកាន់អំណាចនៅឆ្នាំ១៩៨៦ ។ បន្ទាប់ពីនេះមិនយូរប៉ុន្មាន ក្រុមឧទ្ទាមមួយក្រុមដែលមានឈ្មោះថា កងទ័ពតស៊ូរបស់ព្រះ (ឬហៅកាត់ថាLRA) ត្រូវបានបង្កើតឡើងពីក្រុមតូចៗដែលមានប្រភពពីអតីតកងទ័ពប្រជាធិបតេយ្យប្រជាជនអ៊ុយហ្កាន់ដា (Ugandan People's Democratic Army) ។

យោងតាមរបាយការណ៍ផ្សេងៗដែលផ្តល់ទៅឲ្យការិយាល័យរដ្ឋអាជ្ញា ស្ថានការណ៍នេះបានបង្កជាការរំលោភសិទ្ធមនុស្សធ្ងន់ធ្ងរទៅលើជនស៊ីវិលនៅក្នុងតំបន់ ដែលរួមមានការសម្លាប់ភ្លាមៗ ទារុណកម្ម និងការបង្កពិការភាព ការយកកុមារធ្វើទាហាន ការបំពារបំពានផ្លូវភេទលើកុមារ រំលោភ ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ លួច និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជាជន ។

ភាគច្រើននៃ «កងទ័ពតស៊ូរបស់ព្រះ» អ្នកភូមិដែលត្រូវចាប់ពង្រត់ ជាពិសេសកុមារដែលភាគច្រើនមានអាយុចន្លោះពី១១ និង១៥ឆ្នាំ និងអាយុក្មេងជាងនេះដែរ ។ បើយោងតាមរបាយ-ការណ៍ ជាង៨៥ភាគរយនៃកងកម្លាំងរបស់ «កងទ័ពតស៊ូរបស់ព្រះ» ជាកុមារដែលត្រូវប្រើប្រាស់ ជាទាហានប្រយុទ្ធអ្នកលីសែងកម្មករ និងទាសករបម្រើផ្លូវភេទ ។ នៅពេលចាប់ផ្តើមបង្កើតជាចលនាឧទ្ទាមដំបូងកុមារដែលត្រូវចាប់ពង្រត់ ត្រូវបង្ខំឲ្យប្រព្រឹត្តអំពើអមនុស្សធម៌ រួមទាំងការសម្លាប់ដើម្បីពិធីផ្សេងៗនិងការកាត់ អវយវៈផង ។ ចំនួនកុមារសរុបដែលត្រូវចាប់ពង្រត់ត្រូវបានរាយការណ៍ថា មានច្រើនជាង២ម៉ឺននាក់ ។ បើតាមរបាយ-ការណ៍ទាំងនោះ កុមារត្រូវវាយដំជាញឹកញាប់ និងត្រូវបង្ខំឲ្យលីសែងសម្ភារធ្ងន់ធ្ងរក្នុងចម្ងាយផ្លូវដ៏ឆ្ងាយ លួចទ្រព្យសម្បត្តិ និងដុតផ្ទះ វាយដំសម្លាប់ជនស៊ីវិលនិងសម្លាប់កុមារដែលត្រូវចាប់ពង្រត់ ជាមួយគ្នា និងចាប់ពង្រត់កុមារផ្សេងទៀត ។

របាយការណ៍ទាំងនោះបានរំឭកថា ដើម្បីគេចពីការចាប់ខ្លួន កុមាររាប់ពាន់នាក់បានក្លាយទៅជា «អ្នកភៀសខ្លួនពេលយប់» រត់ទៅតំបន់ឆ្ងាយៗក្នុងចម្ងាយផ្លូវរាប់សិបគីឡូម៉ែត្រទៅមជ្ឈមណ្ឌលដែលបង្កើតដោយអង្គការក្រៅរដ្ឋាភិបាល ដេកនៅតាមផ្លូវនៅតាមសំយាបហាងទំនិញ នៅក្នុងព្រះវិហារសាសនា នៅក្នុងរោងចក្រ ហើយត្រឡប់ទៅភូមិរបស់ខ្លួនវិញនៅពេលព្រលឹមស្រាងៗ ។

របាយការណ៍បានបង្ហាញទៀតថា បន្ទាប់ពីការចាប់ពង្រត់កុមារីក្មេងៗជាច្រើនបានក្លាយជាអ្នកបម្រើរបស់មេបញ្ជាធ្វើកិច្ចការផ្ទះគ្មានពេលសម្រាក និងត្រូវវាយដំរាងកាយបន្ថែមទៀត ។ នារីដែលមានអាយុច្រើនបន្តិចត្រូវបង្ខំឲ្យធ្វើជាប្រពន្ធរបស់ទាហានជាន់ខ្ពស់ ឬត្រូវឲ្យជារង្វាន់ផ្លូវភេទដល់ទាហានដែលស្តាប់បង្គាប់ ដូច្នេះនារីទាំងនេះត្រូវប្រឈមមុខនឹងអំពើរំលោភ ហើយមានផ្ទៃពោះដែលខ្លួនមិនចង់បាន និងមានជំងឺកាមរោគ ។

របាយការណ៍មួយទៀតបានបញ្ជាក់ថា ការវាយប្រហាររបស់«កងទ័ពតស៊ូរបស់ព្រះ»នៅពាក់កណ្តាលទសវត្សរ៍១៩៩០ បានបង្ខំឲ្យប្រជាជនអាខូលីនៅភាគខាងជើងប្រមាណ៧៥ភាគរយចាកចេញពីផ្ទះរបស់ខ្លួននៅក្នុងស្រុកហ្គូលូ គីហ្គូម និង ភេដឺរ ។ នៅក្នុងឆ្នាំកន្លងទៅ សកម្មភាពវាយប្រហារឃោរឃៅរបស់ «កងទ័ពតស៊ូរបស់ព្រះ» បានបណ្តាលឲ្យចំនួនប្រជាជនរស់នៅតាមជំរំកើនឡើងពីរដងពីប្រមាណ៤ម៉ឺនទៅ៨ម៉ឺននាក់ ។

មានការរាយការណ៍ថា អ្នកភូមិដែលសង្ស័យថាគាំទ្ររដ្ឋាភិបាល ត្រូវចាប់យកទៅកាត់អវយវៈ កាត់ស្លឹកត្រចៀកឬបបូរមាត់ ។ ជាងនេះទៅទៀត នៅអំឡុងពេលមានវិបត្តិនេះ «កងទ័ពតស៊ូរបស់ព្រះ» យ៉ាងហោចណាស់ បានដុតផ្ទះអស់ចំនួន១៩៨៦ ឃ្លាំងសម្ភារចំនួន១៦០០ ។យ៉ាងហោចណាស់ក្រុមនេះបានលួចអីវ៉ាន់ក្នុងផ្ទះអស់ចំនួន១៣២៧ខ្នងនៅក្នុងភូមិចំនួន១១៦និងក្នុងហាងលក់ទំនិញចំនួន៣០៧ ។

បទចោទប្រកាន់ថាការប្រព្រឹត្តនៅក្នុងតំបន់នេះ (ដូចជាកេណ្ឌទាហាន ឬបញ្ចូលកុមារក្រោមអាយុ១៥ឆ្នាំឲ្យធ្វើទាហាន

សម្លាប់ដោយចេតនា រំលោភ ទាសភាពផ្លូវភេទ មានផ្ទៃពោះដោយបង្ខំ និងការផ្លាស់ប្តូរទីលំនៅជនស៊ីវិលដោយបង្ខំ) អាចជាឧក្រិដ្ឋកម្មប្រឆាំមនុស្សជាតិនៅក្រោមលក្ខន្តិកៈទីក្រុងរ៉ូម ។

តុលាការព្រហ្មទណ្ឌអន្តរជាតិមានយុត្តាធិការលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត និងដែលប្រព្រឹត្តនៅក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០០២ ។ ឧក្រិដ្ឋកម្មទាំងនេះមានៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ឧក្រិដ្ឋកម្មទាំងអស់នេះមានចែងនៅក្នុងលក្ខន្តិកៈក្រុងរ៉ូម ។ រដ្ឋដែលជាសមាជិករបស់លក្ខន្តិកៈនេះអាចស្នើសុំឲ្យរដ្ឋអាជ្ញាផ្តើការស៊ើបអង្កេត ។ រដ្ឋអាជ្ញាមានអំណាចក្នុងការចាប់ផ្តើមស៊ើបអង្កេតទៅតាមពត៌មានដែលបានពីប្រភពគួរឲ្យទុកចិត្តបាននិងដោយមានការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ ។

**បកប្រែពី** **(www.icc-cpi.int/newsletter)**

**ដោយ ឌី ឆេរិទ្ធ**

# ភាសាខ្មែរក្រហមនិងការលំបាករបស់អ្នកបកប្រែ

ចាប់តាំងពីការចាប់បដិសន្ធិនៅឆ្នាំ១៩៩៥មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងតែប្រមូលចងក្រងឯកសារទាក់ទងនឹងប្រវត្តិនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ មកទល់នឹងពេលបច្ចុប្បន្ននេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងឯកសារជាង៦សែនទំព័រដែលបន្សល់ទុកដោយរបបនេះ ក្នុងនោះរួមមានសៀវភៅសិក្សា លិខិតឆ្លងឆ្លើយ កំណត់ហេតុកម្មាភិបាល កំណត់ហេតុប្រចាំថ្ងៃ ទូរលេខ កំណត់ហេតុគណៈកម្មាធិការមជ្ឈិមបក្ស របាយការណ៍នានា ព្រមទាំងរូបថតនិងខ្សែភាពយន្ត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ប្រមូលចងក្រងញត្តិនិងអត្ថបទសម្ភាសន៍នៃអ្នកដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យព្រមទាំងឯកសារនិងសម្ភារជាច្រើនទៀត ។

ភាសាដែលខ្មែរក្រហមប្រើប្រាស់ដើម្បីប្រាស្រ័យទាក់ទងគ្នាក្នុងវិស័យផ្សេងៗដូចជា យោធា អប់រំឃោសនា និងរដ្ឋបាលសាធារណៈ នឹងក្លាយជាឧបសគ្គសម្រាប់អ្នកបកប្រែផ្ទាល់មាត់និងអ្នកបកប្រែឯកសារ ពីព្រោះថាភាសានេះមានលក្ខណៈខុសប្លែកពីភាសាខ្មែរទូទៅ ។ ភាសាខ្មែរក្រហមមានបែបផែនដូចខាងក្រោមនេះ÷

ក) សំនួនវោហារៈ ឯកសារបក្សកុម្មុយនិស្តផ្ទុកទៅដោយពាក្យពេចន៍និងឃ្លោងឃ្លាបង្កប់ន័យមិនច្បាស់លាស់ជាច្រើនដែលប្រជាជនភាគច្រើន(រួមទាំងអ្នកបកប្រែនិងអ្នកច្បាប់ផង) អាចពិបាកក្នុងការយល់ប្រសិនបើគ្មានចំណេះដឹងអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឧទាហរណ៍ «វាយសម្រុក» «កម្ទេច» «ជំហរបដិវត្តរឹងប៉ឹងខាងសីលធម៌រស់នៅស្អាតស្អំ និងស្អាតស្អំខាងនយោបាយ» និង«ជំងឺសតិអារម្មណ៍» ។

ខ) ខ្វះសេចក្តីបញ្ជាក់ឲ្យច្បាស់លាស់ៈ ឯកសារបក្សកុម្មុយនិស្តកម្ពុជាក៏ប្រើន័យប្រៀបធៀបខាងនយោបាយដែលពុំអាចដឹងច្បាស់បានដោយអត្ថន័យញាណឡើយ ។ ឧទាហរណ៍ដូចជា «ដុតឲ្យខ្លោចរោចឲ្យឆៅ» និង «តូចស៊ីដោយតូច ធំស៊ីដោយធំ» ។ មានពាក្យពេចន៍ខ្លះទៀតបង្កប់នូវន័យធៀបដូចជា «អង្គការភ្នែកម្នាស់» (មានន័យថាអង្គការអាចដឹងគ្រប់សកម្មភាពទាំងអស់របស់ប្រជាជនគ្រប់ទីកន្លែងទាំងអស់ ទោះជាទៅទីណាឬធ្វើអ្វីក៏ដោយ) ។

គ) ម៉ៅនិយមៈ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យប្រកាន់យកទ្រឹស្តីម៉ៅនិយមជ្រុល ។ ខ្មែរក្រហមបានប្រើឃ្លាបែបលទ្ធិកុម្មុយនិស្ត ដូចជា «បដិច្ចសមុប្បាទ» ប៉ុន្តែថែមទាំងច្នៃន័យទៅតាមរបៀបរបស់ខ្លួនផង ។ ឧទាហរណ៍ «ក្តាប់សំណូមពរនៃការបោសសម្អាតជាបន្តបន្ទាប់» «តម្រង់ទស្សនៈសតិអារម្មណ៍ចាត់តាំង» «ផ្តាច់ការវណ្ណៈអធនរបស់បក្ស» និង «ត្រូវពង្រឹងគោលជំហរតស៊ូវណ្ណៈដាច់ខាតនិងក្តៅជាប់ជានិច្ច» ។

ឃ) គុណនាមនិងកិរិយាវិសេសៈ ខ្មែរក្រហមចូលចិត្តប្រើគុណនាម និងកិរិយាវិសេសដែលមានទម្ងន់ស្មើគ្នា ។ ឧទាហរណ៍ «ទទួលអំណរខួបឆ្នាំទី២នៃឯករាជ្យជាតិថ្ងៃទី១៧មេសាដ៏អស្ចារ្យ» «កម្ចាត់សតិអារម្មណ៍កម្មសិទ្ធិបុគ្គលសួនតួឲ្យជ្រះស្រឡះដាច់ខាត»

«បោសសម្អាតឲ្យអស់» និង «សូមប្រសិទ្ធិពរជ័យមហាប្រសើរជូនចំពោះបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿងក្នុងឱកាសបុណ្យខួបបង្កើតបក្សទី២៤នាថ្ងៃ៣០កញ្ញា ឆ្នាំ១៩៧៥» ។

ង) វិស័យរដ្ឋបាលៈ បក្សកុម្មុយនិស្តកម្ពុជារៀបចំប្រព័ន្ធរដ្ឋបាលដែលមានទម្រង់ខុសគ្នាឆ្ងាយពីប្រព័ន្ធដែលប្រើក្នុងរបបមុនៗ ។ ឯភាសាដែលប្រើបញ្ជាក់អំពីភាពខុសគ្នានេះ ដូចជាពាក្យរដ្ឋបាល «កង» «កងហា» «កងចល័ត» «កងសេដ្ឋកិច្ច» «ក្រុមក្តៅ» «ក្រុមត្រជាក់» និង «ក្រុមអង្កៀម» ។ ក្រុមទាំងបីក្រោយនេះតាមការយល់ឃើញ គឺសំដៅទៅលើអង្គភាពនានារបស់បក្សកុម្មុយនិស្តកម្ពុជាដែលទទួលខុសត្រូវខាងធ្វើទារុណកម្មនិងស្រង់យកចម្លើយ ។

ភាសាចម្លែកបែបនេះត្រូវបានបកស្រាយនិងយល់ឃើញខុសគ្នាដោយអ្នកសិក្សាស្រាវជ្រាវខ្មែរនិងអន្តរជាតិ ។ ប្រការនេះអាចបង្កជាបញ្ហាចំពោះអ្នកបកប្រែទាក់ទងនឹងភាពត្រឹមត្រូវនិងពេលវេលាដើម្បីផលិតចេញនូវការបកប្រែមួយដែលមានលក្ខណៈត្រឹមត្រូវនិងខុសន័យដើមតែបន្តិចបន្តួច ។ វិធីសំខាន់ក្នុងការស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការគ្រប់គ្រងរដ្ឋបាល និងសព្ទបច្ចេកទេស (ចំណេះដឹងច្បាស់លាស់អំពីវប្បធម៌ខ្មែរក៏មានសារសំខាន់ដែរ) ។

ដើម្បីប្រឈមជាមួយបញ្ហានេះ ជាពិសេសនៅពេលដែលតុលាការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមកាន់តែខិតជិតមកដល់ហើយនោះ «ក្រុមឆ្លើយតបភ្លាមៗ» នៅនឹងតុលាការខ្មែរក្រហមដែលបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតជាសទ្ទានុក្រមជាភាសាអង់គ្លេស-ខ្មែរ និង ខ្មែរ-អង់គ្លេសមួយ ។ សទ្ទានុក្រមនេះឲ្យនិយមន័យពាក្យដែលខ្មែរក្រហមធ្លាប់ប្រើ ។ មិនតែប៉ុណ្ណោះ យើងក៏បានច្នៃចេញនូវប្រព័ន្ធសរសេរអក្សរឈ្មោះដោយប្រើអក្សរភាសាឡាតាំងប្រយោជន៍ដើម្បីឲ្យមានភាពដូចៗគ្នាក្នុងការប្រែឈ្មោះមនុស្សនិងទីកន្លែង ។

សទ្ទានុក្រមនិងប្រព័ន្ធសរសេរឈ្មោះមនុស្សនិងទីកន្លែងជាភាសាឡាតាំងនេះត្រូវបានបង្កើតឡើយក្រោយពីមានការអានយ៉ាងយកចិត្តទុកដាក់និងការសិក្សាស្រាវជ្រាវយ៉ាងច្រើននៅលើកំណត់ហេតុប្រចាំថ្ងៃរបស់កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាជាសៀវភៅសរសេរដៃទាក់ទងនឹងវគ្គរៀនសូត្រនយោបាយព្រមទាំងអត្ថបទឃោសនា ដែលធ្វើឲ្យយើងយល់កាន់តែច្បាស់និងស៊ីជម្រៅទៅលើខ្លឹមសារនៃភាសាដែលខ្មែរក្រហមប្រើប្រាស់ ។ ចំណុចចុងក្រោយមួយទៀតគឺបទពិសោធន៍របស់យើងក្នុងការចុះធ្វើសម្ភាសន៍ជាមួយអតីតកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាថ្នាក់ក្រោម ។ បទពិសោធន៍នេះកាន់តែសម្រួចការយល់ដឹងរបស់យើងមួយកម្រិតបន្ថែមទៀតទាក់ទងនឹងពាក្យពេចន៍ដែលយើងពើបប្រទះនៅក្នុងឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជា ។

មុនពេលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចាប់ផ្តើមដំណើរការ វាជាការសំខាន់ដែលអ្នកបកប្រែនិងក្រុមស៊ើបអង្កេតឲ្យតុលាការនេះស្វែងយល់អំពីន័យខ្លឹមសាររបស់ស័ព្ទទាំងឡាយដែលមាននៅក្នុងឯកសារបក្សកុម្មុយនិស្តកម្ពុជា ។ ដើម្បីអនុវត្តចំណុចនេះ ដំបូងគឺតម្រូវឲ្យអ្នកទាំងនោះសិក្សាអំពីបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលនឹងផ្តល់នូវមូលដ្ឋានដ៏ប្រសើរក្នុងការស្វែងយល់អំពីរបៀបដែលខ្មែរក្រហមប្រើភាសាដ៏ចម្លែករបស់ខ្លួន ។ បើមិនដូច្នេះទេ ចំណុចសំខាន់មួយចំនួននៃភ័ស្តុតាងនឹងត្រូវបាត់បង់មិនខាន ។

**សួ ប៊ុនស៊ួ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# សមាជិកាសភាអាមេរិករំឭកដល់ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍នៅកម្ពុជា

វ៉ាស៊ីនតោនឌីស៊ីៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ សមាជិកាសភាសហរដ្ឋអាមេរិក លោកស្រី មិកខូលូម បានដាក់ជូននូវសេចក្ដីថ្លែងការណ៍ខាងក្រោមទៅក្នុងរបាយការណ៍របស់សភានៅក្នុងអំឡុងពេលពិភាក្សាលើសេចក្ដីសម្រេចចិត្តចងចាំជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា (H.Con.Res. ២៣៨) ។

«ខ្ញុំមានកិត្តិយសជាខ្លាំងក្នុងការតំណាងឲ្យជនភៀសខ្លួនរាប់ពាន់នាក់នៅក្នុងសភាសហរដ្ឋអាមេរិក ដែលក្នុងចំណោមអ្នកទាំងនេះ មានជនភៀសខ្លួនជាច្រើននាក់មកពីប្រទេសកម្ពុជា ហើយដែលឥឡូវនេះបានហៅរដ្ឋមីនីសូតាថាជាផ្ទះរបស់ខ្លួន ។ រឿងរ៉ាវជនភៀសខ្លួនកម្ពុជាគឺជាសោកនាដកម្មនិងអំពើហិង្សាដ៏សង្វេគមួយ ប៉ុន្តែវាក៏ជារឿងមួយនៃសេចក្ដីក្លាហាននិងភាពអត់ធន់នឹងការប៉ះទង្គិចដែរ ។ កាលពីជាងសាមសិបឆ្នាំមុន ប៉ុល ពត បានដឹកនាំក្រុមឧទ្ទាមកុម្មុយនិស្តក្នុងទម្រង់ធំមួយដែលគ្រប់គ្នាស្គាល់ថា ខ្មែរក្រហម ក្នុងគោលបំណងដើម្បីកសាងសង្គមខ្មែរឡើងវិញ ។ នៅក្នុងរយៈពេលតែបួនឆ្នាំប៉ុណ្ណោះ ប្រជាជនកម្ពុជាជិតពីរលាននាក់ ឬជាងមួយភាគបួននៃប្រជាជនសរុប បានបាត់បង់ជីវិតនៅក្នុងអំពើឃោរឃៅបំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រទំនើបនេះ ។

«ជាការឆ្លើយតបទៅនឹងសោកនាដកម្មរន្ធត់ចិត្តនេះ នៅក្នុងឆ្នាំ១៩៨០ សភាបានអនុម័តច្បាប់ជនភៀសខ្លួនមួយដែលជាច្បាប់គួរឲ្យកត់សម្គាល់ដោយបានបញ្ចូលជាផ្លូវការទៅក្នុងច្បាប់របស់សហរដ្ឋអាមេរិកនូវនិយមន័យរបស់«ជនភៀសខ្លួន»និងដោយធ្វើឲ្យទៅជាផ្លូវការនូវដំណើរការនៃការតាំងលំនៅថ្មីរបស់ជនភៀសខ្លួន ។ ឆ្នាំនេះជាខួបគម្រប់លើកទី២៥ នៃច្បាប់ជនភៀសខ្លួនដែលបានត្រួសត្រាយផ្លូវឲ្យប្រជាជនកម្ពុជាចំនួន១៥ម៉ឺននាក់តាំងទីលំនៅក្នុងសហរដ្ឋអាមេរិក» ។

«រដ្ឋមីនីសូតាមានប្រពៃណីដ៏មានមោទកភាពនិងយូរមកហើយថាជាឋានសួគ៌របស់ជនភៀសខ្លួន ។ គណៈកម្មាធិការជនភៀសខ្លួនអាមេរិកាំងដែលមានមូលដ្ឋាននៅ មីនីសូតា ត្រូវបានបង្កើតឡើងដើម្បីជាជំនួយដល់ជនរងគ្រោះនៃវិបត្តិកម្ពុជា ។ ដោយមានជំនួយនេះ គ្រួសារកម្ពុជាជាច្រើនបានកសាងជីវិតថ្មីនៅក្នុងរដ្ឋនេះ ហើយដែលឥឡូវនេះកំពុងតែជួយធ្វើឲ្យសហគមន៍របស់យើងកាន់តែរីកចម្រើនឡើង ដោយបានក្លាយជាម្ចាស់ពាណិជ្ជកម្ម អ្នកដឹកនាំសហគមន៍ អ្នកវិជ្ជាជីវៈ និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ ។

«ឧទាហរណ៍គួរឲ្យកត់សម្គាល់មួយគឺរឿងរ៉ាវរបស់អ្នកតំណាងមណ្ឌលសភារបស់ខ្ញុំ ឃុនរ៉ាត់ ឡាំ និង ខេវិន ឡាំ ដែលអ្នកទាំងពីរនេះបានរួចរស់ជីវិតពីរបបវាលពិឃាត និងជាម្ចាស់ភោជនីយដ្ឋាន ចេង ហេង នៅក្នុងទីក្រុង សេនថ៍ ផូល ។ ខ្មែរក្រហមបានប៉ុនប៉ងសម្លាប់ ឃុនរ៉ាត់ ដោយសារតែគាត់ជាបញ្ញវន្តទីក្រុង ។ បើទោះបីជាឪពុករបស់ ឃុនរ៉ាត់ អាចគេចផុតពីការសម្លាប់នេះក៏ដោយ ក៏សមាជិកក្រុមគ្រួសាររបស់ ឃុនរ៉ាត់ ចំនួន២០០នាក់រួមទាំងបងប្អូនប្រុសរបស់គាត់ដែលនៅជាទារកផង បាត់បង់ជីវិតនៅក្នុងអំពើប្រល័យពូជសាសន៍នេះ ។

«បើទោះបីជាមានការបាត់បង់ច្រើនយ៉ាងនេះក៏ដោយ ក៏ ឃុនរ៉ាត់ ឡាំ បានមកដល់មីនីសូតាប្រកបដោយសុទិដ្ឋិនិយមនិងក្ដីសង្ឃឹម ។ គាត់និងប្ដីរបស់គាត់កំពុងតែប្រកបរបរពាណិជ្ជកម្មដ៏ជោគជ័យមួយនិងនៅតែមានសកម្មភាពយ៉ាងសកម្មនៅក្នុងសហគមន៍របស់ខ្លួន ។ កាលពីបួនឆ្នាំមុន អ្នកទាំងពីរបានចាប់ផ្ដើមប្រមូលវិភាគទានពីអតិថិជនស្មោះត្រង់របស់ខ្លួន ហើយឥឡូវនេះសាលារៀនថ្មីមួយត្រូវបានសាងសង់ឡើងនៅក្នុងភូមិកំណើតឪពុករបស់ ឃុនរ៉ាត់ នៅភាគពាយ័ព្យប្រទេសកម្ពុជាដែលធ្លាប់ជាប្រទេសហាមប្រាមមិនឲ្យមានសាលារៀន ។ សិស្សានុសិស្សជាង៨០០នាក់បានចូលរៀននៅសាលាបឋមសិក្សាសារ៉ា ដែលដាក់ឈ្មោះតាមកូនស្រីរបស់ ឃុនរ៉ាត់ ហើយឥឡូវនេះ គ្រួសារ ឡាំ កំពុងតែបន្តរៃអង្គាសថវិកាសម្រាប់សាងសង់សាលារៀនមួយទៀតនៅភូមិក្បែរគ្នានោះ ។

«រឿងរ៉ាវរបស់គ្រួសារ ឡាំ គឺជារឿងមួយនៅក្នុងចំណោមជនភៀសខ្លួនជាច្រើនទៀតដែលពោរពេញទៅដោយសុទិដ្ឋិនិយមនិងក្ដីសង្ឃឹម ។ ខ្ញុំមានមោទកភាពដែលបានរួមចំណែកគាំទ្រសេចក្ដីសម្រេចចិត្តចងចាំជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍កម្ពុជា និងស្វាគមន៍ចំពោះការបង្កើតសាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិមួយដើម្បីនាំយកឧក្រិដ្ឋជនប្រល័យពូជសាសន៍ទៅប្រឈមមុខនឹងយុត្តិធម៌ ។ **បកប្រែពី(www.mccollum.house.gov) ដោយ ជី ទេវិទ្ធ**

# ស្ពានឆ្ពោះទៅរកយុត្តិធម៌

*នៅពេលនិយាយអំពីឧក្រិដ្ឋកម្មសាហាវយោរឃៅនៅក្នុងសតវត្សរ៍ទី២០ យើងប្រាកដជានឹកឃើញដល់អំពើឃោរឃៅដែលប្រព្រឹត្តដោយរបបខ្មែរក្រហមនៅលើទឹកដីកម្ពុជាកាលពី៣០ឆ្នាំមុន ។ ខ្មែរក្រហមបានផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរបស់ប្រទេសទាំងមូលដើម្បីធ្វើឲ្យប្រទេសនេះក្លាយជាប្រទេសកុម្មុយនិស្តឈានមុខតែក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ ។ ដើម្បីសម្រេចគោល-បំណងនេះ ខ្មែរក្រហមបានអនុវត្តបដិវត្តន៍កសិកម្មដាច់ខាតដោយការជម្លៀសប្រជាជនពីទីក្រុងទាំងអស់ឲ្យទៅធ្វើស្រែចម្ការនៅតាមទីជនបទ ។ ប្រជាជនទាំងអស់ត្រូវបានប្រែក្លាយឲ្យទៅជាកសិករ ធ្វើការងាររហូតសម្ងាំង ប្រឈមមុខនឹងការលំបាកគ្រប់បែបយ៉ាង អាហារបរិភោគមិនគ្រប់គ្រាន់ បាក់បែកក្រុមគ្រួសាររស់នៅក្នុងភាពភ័យខ្លាចរាល់ថ្ងៃ និងភ័យខ្លាចខ្មែរក្រហមយកទៅសម្លាប់ ។*

*នៅសម័យនោះ ប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជាគ្មាននរណាម្នាក់អាចគេចរួចពីឥទ្ធិពលនៃការកែប្រែសង្គមរបស់ខ្មែរក្រហមទេ សូម្បីតែព្រះមហាក្សត្ររបស់ប្រទេស កុំថាឡើយត្រឹមតែប្រជាជនធម្មតាដូចជាលោក សេង ស៊ីវត្ថា ដែលសព្វថ្ងៃនេះជាចៅក្រមសាលាឧទ្ធរណ៍ ។*

## ***ជីវិតនៅក្រោមរបបខ្មែរក្រហម***

*នៅពេលដែលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥ លោក ស៊ីវត្ថា មានអាយុទើបតែ១៣ឆ្នាំប៉ុណ្ណោះ ។*

*មិនដល់មួយថ្ងៃផងបន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមបណ្តេញប្រជាជនចេញពីទីក្រុង ឲ្យទៅធ្វើកសិកម្មនៅតាមបណ្តាខេត្តផ្សេងៗ ។ នៅក្នុងចំណោមអ្នកទីក្រុងទាំងនេះក៏មានលោក ស៊ីវត្ថា និងក្រុមគ្រួសាររបស់គាត់ដែរ ។ បន្ទាប់ពីការជម្លៀសក្រុមគ្រួសាររបស់គាត់បានទៅរស់នៅក្នុងភូមិថ្មី ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។*

*លោក ស៊ីវត្ថា ក៏មិនខុសពីប្រជាជនឯទៀតទេ គាត់បានប្រឈមមុខទៅនឹងការលំបាកដោយការធ្វើការងាររហូតសម្ងាំង ខ្វះអាហារបរិភោគនិងរស់នៅដោយគ្មានសិទ្ធិសេរីភាព ។ លោក ស៊ីវត្ថា និយាយថា «ខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យឃ្វាលគោ ដាំដំឡូង និងធ្វើជីពីស្លឹកឈើ» ។ គាត់បានបន្ថែមថា នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ គាត់បានជួបមុខឪពុកម្តាយនិងប្អូនស្រីតែមួយគត់របស់គាត់បានញឹកញាប់ ។*

*ចាប់ពីឆ្នាំ១៩៧៦ដល់១៩៧៨ លោក ស៊ីវត្ថា ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការឆ្ងាយពីផ្ទះនៅក្នុងកងចល័ត ។ ក្នុងរយៈពេលកន្លះឆ្នាំ គាត់ទទួលបានការអនុញ្ញាតឲ្យមកលេងឪពុកម្តាយបងប្អូនតែមួយឬពីរលើកប៉ុណ្ណោះ ។ អ្វីដែលអាក្រក់បំផុតនោះគឺនៅក្នុងអំឡុងពេលពីរឆ្នាំនេះ គាត់បានជួបមុខឪពុករបស់គាត់តែពីរដងគត់មុនពេលឪពុករបស់គាត់បាត់បង់ជីវិត ។*

*បដិវត្តន៍របស់ខ្មែរក្រហមគឺគ្មានអ្វីល្អទាល់តែសោះ ហើយលទ្ធផលនៃការកែប្រែសង្គមនេះគឺអាក្រក់បំផុត ។ លទ្ធផលនៃការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលខ្មែរក្រហមក្នុងការកែប្រែកម្ពុជាឲ្យទៅជាប្រទេសកុម្មុយនិស្តនាំមុខគេដោយឈរលើមូលដ្ឋាននៃការអភិវឌ្ឍវិស័យកសិកម្ម គឺសម្រេចបានផ្ទុយពីនេះទាំងស្រុង ។ ផែនការក្នុងការកែប្រែកម្ពុជាឲ្យទៅជាវាលស្រែពណ៌ខៀវដែលទទួលបានទិន្នផលលើសលប់ដោយមិនប្រើប្រាស់គ្រឿងម៉ាស៊ីន បែរជាប្រែក្លាយកម្ពុជាឲ្យទៅជា«វាលពិឃាត»ជំនួសវិញ ហើយផែនការអភិវឌ្ឍប្រទេសកម្ពុជាឲ្យទៅជាប្រទេសឧស្សាហកម្មដែលសម្បូរទៅដោយរោងចក្រ បែរជាបង្កើតជា «មន្ទីរឃុំឃាំងនិងរណ្តៅសាកសព»នៅពាសពេញផ្ទៃប្រទេសទៅវិញ ។ ជាលទ្ធផល គោល-នយោបាយកំណែទម្រង់នេះ បានក្លាយទៅជាសោកនាដកម្មមួយដែលមិននឹកស្មានដល់ បណ្តាលឲ្យប្រជាជនកម្ពុជាស្ទើតត្រង់ជិតពីរលាននាក់ស្លាប់បាត់បង់ជីវិតតែក្នុងរយៈពេលមិនដល់៤ឆ្នាំ ។ នៅក្នុងចំណោមជនរងគ្រោះទាំងនោះ មាន២១នាក់គឺជាសាច់*

ញាតិរបស់លោក វត្ថា ដែលរួមមាន ឪពុកបង្កើត មាមីង និង បងប្អូនជីដូនមួយ ។

## ការសិក្សា

ភ្លាមៗ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាបានខិតខំកសាងជីវិតឡើងវិញយ៉ាងត្រដាបត្រដួស ដោយគ្មានទិសដៅច្បាស់លាស់ និងដោយគ្មានអ្វីទាំងអស់ក្រៅពីសម្លៀកបំពាក់ខ្មៅមួយកំប្លេជាប់នឹងខ្លួន ដែលបន្សល់ទុកពីអតីតអ្នកគ្រប់គ្រងនៃរបបមុនៗ ប្រជាជនស្ទើរតែទាំងអស់បានវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ហើយអ្នកទីក្រុងក៏បានវិលត្រឡប់ចូលទីក្រុងវិញដែរ ។

នៅពេលមកដល់ទីក្រុងភ្នំពេញជាលើកដំបូង លោក វត្ថា បានមើលឃើញថា ការអប់រំគឺមានសារសំខាន់ណាស់សម្រាប់អនាគតផ្ទាល់ខ្លួនរបស់លោក ក៏ដូចជាសម្រាប់ការកសាងប្រទេសឡើងវិញ បន្ទាប់ពីទទួលរងនូវការបំផ្លិចបំផ្លាញស្ទើរតែខ្ទេចខ្ទាំអស់ដោយសារសង្គ្រាម និងជាពិសេសដោយសាររបបខ្មែរក្រហមបានបំផ្លិចបំផ្លាញប្រព័ន្ធអប់រំទាំងមូល ។ បើទោះបីជាត្រូវប្រឈមមុខនឹងជីវភាពលំបាកលំបិននិងខ្វះខាតសម្ភារសម្រាប់ការសិក្សា គ្រូបង្រៀន សាលារៀន និងសម្ភារសិក្សាផ្សេងៗទៀតនៅដើមទសវត្សរ៍១៩៨០ លោក វត្ថា បានតស៊ូរៀនសូត្ររហូតបានចប់វិទ្យាល័យនៅឆ្នាំ១៩៨៧ ។

លោក វត្ថា អាចសម្រេចនូវបំណងរបស់គាត់នៅពេលដែលគាត់ទទួលបានអាហារូបករណ៍ពីក្រសួងអប់រំទៅសិក្សាច្បាប់នៅប្រទេសអ៊ុយក្រែននៅក្នុងឆ្នាំ១៩៨៨ ហើយគាត់បានទទួលសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកច្បាប់នៅក្នុងឆ្នាំ១៩៩៤ ។ ក្រៅពីនេះ គាត់ក៏បានចូលរួមវគ្គសិក្សាមួយចំនួនដូចជា ច្បាប់អន្តរជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ច្បាប់មនុស្សធម៌អន្តរជាតិ និងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ។

## អាជីពនិងឧបសគ្គ

ដោយមានចំណេះដឹងខាងច្បាប់និងបទពិសោធន៍ខាងច្បាប់ជាតិនិងអន្តរជាតិ លោក វត្ថា បានប្រឡូកការងារក្នុងវិស័យច្បាប់អស់រយៈពេលជាង១០ឆ្នាំហើយ សព្វថ្ងៃ គាត់ជាចៅក្រមនៅសាលាឧទ្ធរណ៍ ។

លោកបានថ្លែងថា «ដោយសារខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងក្នុងវិស័យច្បាប់ និងតាមរយៈការសិក្សានិងស្រាវជ្រាវវិស័យនេះ ខ្ញុំស្រឡាញ់យុត្តិធម៌ហើយចង់ធ្វើអ្វីៗដើម្បីយុត្តិធម៌សង្គម» ។

ការស្ថិតនៅក្នុងតំណែងមួយដែលអាចសម្រេចឲ្យនរណាម្នាក់ចាញ់ឬឈ្នះបាន គឺមានការលំបាកនិងមានឧបសគ្គច្រើនណាស់ ។ ការយល់ដឹងតិចតួចរបស់សាធារណជនអំពីច្បាប់គឺជាឧបសគ្គមួយនៅក្នុងការបំពេញការងាររបស់លោក វត្ថា ក៏ដូចជាសម្រាប់វិស័យយុត្តិធម៌របស់ប្រទេសទាំងមូលដែរ ប៉ុន្តែឧបសគ្គគឺតែងតែមានជាធម្មតាក្នុងគ្រប់ការងារទាំងអស់ ហើយឧបសគ្គនេះក៏ជាការលើកទឹកចិត្តសម្រាប់បន្តធ្វើការងារនេះទៀតដែរ ។

ឧបសគ្គអ្វីដែលជាការលើកទឹកចិត្តឲ្យគាត់បន្តការងារដែលមានការទទួលខុសត្រូវខ្ពស់បែបនេះ? ចៅក្រមបានឆ្លើយថា «ដោយសារខ្ញុំស្រឡាញ់ប្រជាពលរដ្ឋរបស់ខ្ញុំ ។ ខ្ញុំនឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋរបស់ខ្ញុំ ។ ការផ្តល់យុត្តិធម៌ទៅឲ្យមនុស្សគ្រប់គ្នាដូចដែលមានចែងនៅក្នុងច្បាប់គឺជាការលើកទឹកចិត្តធំបំផុតសម្រាប់ខ្ញុំ» ។

## យោបល់ផ្ទាល់ខ្លួនចំពោះបញ្ហាដែលទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ

អំពើហិង្សាឃោរឃៅគ្រប់ប្រភេទទាំងអស់បានកើតឡើងនៅប្រទេសផ្សេងៗក្នុងពិភពលោក ។ ប៉ុន្តែ យ៉ាងហោចណាស់ជនដៃដល់នៃអំពើទាំងនេះត្រូវបានជំនុំជម្រះនិងផ្តន្ទាទោសតាមច្បាប់ដូចជា នៅក្នុងទ្វីបអឺរ៉ុបនិងប្រទេសជប៉ុនបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ប្រទេសរ៉្វាន់ដា ប្រទេសអតីតយូហ្គោស្លាវី ប្រទេសសៀរ៉ាឡេអូន ទីម័រខាងកើត និងថ្មីៗនេះនៅប្រទេសអ៊ីរ៉ាក់ ។ ដោយឡែកតែប្រទេសកម្ពុជាប៉ុណ្ណោះ ដែលជនដៃដល់នៃឧក្រិដ្ឋកម្មដែលបានបណ្តាលឲ្យបាត់បង់ជីវិតមនុស្សអស់ជិតពីរលាននាក់ឥឡូវនេះនៅតែរស់នៅយ៉ាងមានសេរីភាពនៅចំពោះមុខជនរងគ្រោះអស់រយៈពេលជិតបីទសវត្សរ៍មកហើយ ។

វាច្បាស់ណាស់ថា ការចរចាបានអូសបន្លាយពេលអស់

រយៈពេល៨ឆ្នាំមកហើយរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិជុំវិញបញ្ហានៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប-តេយ្យ ។ នៅក្នុងរយៈពេលនេះ ទាំងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានឆ្លងកាត់នូវឧបសគ្គជាច្រើន ហើយឥឡូវនេះយើងស្ទើរតែជំនះនូវឧបសគ្គទាំងអស់ហើយ ។ ឥឡូវនេះយើងឈានដល់ដំណាក់កាលដែលអង្គការសហប្រជាជាតិកំពុងតែជ្រើសរើសបុគ្គលិកផ្នែកអន្តរជាតិដើម្បីធ្វើជាចៅក្រម ចៅក្រមស៊ើបអង្កេតព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយរាជរដ្ឋាភិបាលកម្ពុជាក៏កំពុងតែបំពេញការងារដូចគ្នានេះដែរ ។ នៅពេលដែលកិច្ចការនេះបំពេញរួចរាល់ អង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្ដើមដំណើរការរបស់ខ្លួនបានហើយ ។

បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតរួចហើយក្ដី យើងក៏មិនរំពឹងទុកថាដំណើរការជំនុំជម្រះអាចធ្វើដំណើរទៅបានដោយស្រួលដែរ ។ បញ្ហាច្បាប់ជាច្រើនដែលគេរំពឹងថានឹងប្រាកដជាលេចឡើង ដែលនេះអាចជាការអូសបន្លាយពេលនៃសាលាជំនុំជម្រះក្ដីនេះថែមទៀតនៅក្នុងពាក់កណ្ដាលផ្លូវទៀតនៃការស្វែងរកយុត្តិធម៌នៃអំពើឃោរឃៅនៅកម្ពុជា ដោយសារតែយើងបានមើលឃើញថា បញ្ហាទាំងអស់នេះបានកើតឡើងរួចមកហើយនៅក្នុងសាលាជំនុំជម្រះក្ដីផ្សេងទៀត ។ ជាក់ស្ដែងសាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដែលត្រូវបានបង្កើតតាំងពីឆ្នាំ១៩៩៥ដើម្បីជំនុំជម្រះជនដៃដល់នៃអំពើប្រល័យពូជសាសន៍ដែលបានបណ្ដាលឲ្យបាត់បង់ជីវិតប្រជាជនរ៉្វាន់ដាជិតមួយលាននាក់តែក្នុងរយៈពេល១០០ថ្ងៃនោះរហូតមកដល់សព្វថ្ងៃនេះមានរយៈពេល១០ឆ្នាំហើយ ។ សវនាការជំនុំជម្រះសំណុំរឿងរបស់ ស្លូបូដាន មីឡូសេវិក របស់ប្រទេសអតីតយូហ្គោស្លាវីដែលចាប់ផ្ដើមតាំងពីឆ្នាំ១៩៩៩មិនទាន់បញ្ចប់នៅឡើយដែរ ។ តើនរណាដឹងថាមានរឿងអ្វីកើតឡើងនៅក្នុងសវនាការជំនុំជម្រះសំណុំរឿងរបស់មេដឹកនាំនៃរបបខ្មែរក្រហម ។

*អំពីបញ្ហាពេលវេលាៈ* លោក វិត្ត បានបញ្ចេញទស្សនៈផ្ទាល់ខ្លួនថា «វាមិនមែនជារឿងងាយស្រួលនោះទេ ក្នុងការប្រមូលភ័ស្តុតាងនិងស៊ើបអង្កេតឧក្រិដ្ឋកម្មដែលបានកើតឡើងកាលពី៣០កន្លងមកហើយនោះ» ។

*ការសន្មតទុកជាមុនថាគ្មានទោសៈ* ក្នុងនាមជាចៅក្រមម្នាក់ៗត្រូវតែមិនលម្អៀង បើមិនដូច្នោះទេ គេប្រាកដជារំលោភគោលការណ៍នៃការសន្មតទុកជាមុនថាគ្មានទោសមិនខាន ហើយជាលទ្ធផលសវនាការជំនុំជម្រះនោះពិតជាមិនយុត្តិធម៌ទេ ។ ករណីដូចគ្នានេះក៏នឹងអនុវត្តនៅក្នុងករណីនៃការជំនុំជម្រះក្ដីរបស់មេដឹកនាំខ្មែរក្រហមដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាពលរដ្ឋខ្លួនឯងដែរ ។ ប្រសិនបើចៅក្រមឬមន្ត្រីរបស់អង្គជំនុំជម្រះវិសាមញ្ញណាម្នាក់និយាយជាសាធារណៈថាអតីតមេដឹកនាំខ្មែរក្រហមណាម្នាក់មានទោសនៅមុនពេលដែលអង្គជំនុំជម្រះនេះចាប់ផ្ដើមដំណើរការ ។ ពាក្យសម្ដីនេះនឹងត្រូវចាត់ទុកថាជាពាក្យសម្ដីលម្អៀង ។ សម្រាប់លោក ស៊ីវិត្តៈ ដរាបណាអតីតមេដឹកនាំខ្មែរក្រហមទាំងនោះមិនទាន់ទទួលបានសាលក្រមស្ដាពរពីអង្គជំនុំជម្រះវិសាមញ្ញទេ គាត់មិននិយាយអ្វីទាំងអស់ទាក់ទងនឹងកំហុសរបស់អ្នកទាំងនេះ បើទោះបីជាមានភ័ស្តុតាងច្បាស់ថា ប្រជាជនជិតពីរលាននាក់បានបាត់បង់ជីវិតនៅក្រោមរបបនោះក៏ដោយ ។ «ខ្ញុំមិននិយាយថាតើអ្នកទាំងនេះមានកំហុសឬអត់ទេ ដរាបណាចៅក្រមមិនទាន់ចេញសាលក្រមស្ដាពរ» ។

*សិទ្ធិទទួលបានមេធាវីៈ* គួរឲ្យកត់សម្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញឬសាលាជំនុំជម្រះក្ដីខ្មែរក្រហមគឺជាសាលាជំនុំជម្រះក្ដីក្នុងស្រុកដោយមានជំនួយនិងការចូលរួមពីអង្គការសហប្រជាជាតិ ។ ចៅក្រមនិងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិនឹងចូលរួមនៅក្នុងសាលាជំនុំជម្រះក្ដីនេះ ហើយនឹងប្រើទាំងច្បាប់ក្នុងស្រុកនិងអន្តរជាតិ ។

វាជាចម្ងល់នៅក្នុងចំណោមមេធាវីនិងអ្នកជំនាញច្បាប់ជាច្រើនអំពីថាតើមេធាវីអន្តរជាតិអាចធ្វើជាអ្នកតំណាងពេញលេញរបស់កូនក្ដីខ្លួននៅក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញបានដែរឬអត់? មាត្រា១៣នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្ដីពីការបង្កើតអង្គជំនុំជម្រះ

វិសាមញ្ញនិងមាត្រាមាត្រា៣៥ថ្មីនៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងយ៉ាងច្បាស់ថា «ជនជាប់ចោទមានសិទ្ធិមានពេលវេលានិងសម្ភារគ្រប់គ្រាន់សម្រាប់រៀបចំការការពាររបស់ខ្លួននិងមានសិទ្ធិទំនាក់ទំនងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង» ។ ប៉ុន្តែ មាត្រា៥នៃច្បាប់បង្កើតគណៈមេធាវីបានចែងមិនសូវជាច្បាស់លាស់ប៉ុន្មានថា មេធាវីបរទេសអាចត្រឹមតែជួយមេធាវីកម្ពុជាប៉ុណ្ណោះ នេះមិនគិតដល់លក្ខខណ្ឌមួយចំនួនទៀតមុនពេលដែលមេធាវីបរទេសអាចអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជាផង ។

លោក វត្តា យល់ថា នេះមិនមែនជាឧបសគ្គរារាំងដល់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញទេ ។ គាត់បាននិយាយថា «ដោយយោងតាមមាត្រា៣១នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញជនជាប់ចោទមានសិទ្ធិជ្រើសរើសសេវាច្បាប់ណាមួយក៏បានដើម្បីការពារខ្លួន» ។ គាត់បានបន្ថែមទៀតថា ករណីដែលជនជាប់ចោទជ្រើសរើសយកមេធាវីបរទេសមកការពារខ្លួនមិនមែនជាឧបសគ្គប្លែកអ្វីនៅក្នុងដំណើរការផ្លូវច្បាប់នេះទេ ដោយសារថានៅក្នុងអង្គជំនុំជម្រះនេះក៏មានចៅក្រមនិងព្រះរាជអាជ្ញាបរទេសដែរ ។

លោក ស៊ីវត្ថា បាននិយាយជាចុងក្រោយថា «ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញជាផ្លូវមួយទៅរកយុត្តិធម៌ ហើយយើងបានរង់ចាំច្បាប់នេះអស់រយៈពេលរាប់ឆ្នាំមកហើយ» ។

បើទោះបីជាឧក្រិដ្ឋកម្មនោះបានកើតឡើងកាលពី៣០ឆ្នាំមុនក៏ដោយ ការនាំយកអ្នកទទួលខុសត្រូវចំពោះទង្វើនេះទៅប្រឈមមុខនឹងយុត្តិធម៌គឺជាអ្វីដែលត្រូវតែធ្វើដើម្បីបញ្ចប់វប្បធម៌និទណ្ឌភាពនិងពង្រឹងនីតិរដ្ឋរបស់កម្ពុជា ។ **ជី ធេរិទ្ធិ**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។ សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យព័ត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ព័ត៌មានសាធារណៈ

# គ្មានថ្ងៃបំភ្លេច

ខ្ញុំបាទឈ្មោះ ឈុន ឡៃហេង កើតនៅឆ្នាំ១៩៤៥ ក្នុងភូមិព្រៃកគារអាំ ឃុំបុស្សលាវ ស្រុកក្រចេះ ខេត្តក្រចេះ ជាកូនកសិករថ្នាក់ក្រោម ។ បច្ចុប្បន្នជាគ្រូបង្រៀននៅសាលាអនុវិទ្យាល័យហ៊ុនសែនស្នួល ស្រុកស្នួល ខេត្តក្រចេះ ។

ខ្ញុំបានសិក្សានៅវិទ្យាល័យព្រះកុសមៈខេត្តក្រចេះ ។ ក្រោយពេលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ខ្ញុំបានមកស្នាក់នៅផ្ទះឪពុកមានៅឯក្រុងភ្នំពេញដើម្បីរកការងារធ្វើ ។ នៅឆ្នាំ១៩៦៥ ខ្ញុំបានប្រឡងជាប់ចូលជានាយទាហានយន្តការីវេងអាកាសចរណ៍ ។ ឆ្នាំនោះខ្ញុំបានចូលហ្វឹកហាត់ផ្នែកយោធារយៈពេល៦ខែ ។ ក្រោយពីនោះខ្ញុំបានទៅសិក្សាផ្នែកចំណេះទូទៅប្រមាណ៣ខែ និងបានទៅហ្វឹកហាត់ការងារផ្ទាល់ខាងផ្នែកអគ្គិសនីនិងបរិក្ខារយន្តហោះអស់រយៈពេល៦ខែ ទើបប្រឡងចេញទទួលបានប្រកាសនីយបត្របច្ចេកទេស ។ នៅឆ្នាំ១៩៦៦ ខ្ញុំទទួលឋានន្តរស័ក្តិជាពលបាលត្រី ។ នៅឆ្នាំ១៩៦៨ ខ្ញុំបានឡើងឋានន្តរស័ក្តិជាពលបាលឯក ហើយនៅឆ្នាំ១៩៧០ បានឡើងឋានន្តរស័ក្តិជាព្រឹន្ទបាលទោ ។

នៅឆ្នាំ១៩៧១ ខ្ញុំឡើងឋានន្តរស័ក្តិជាព្រឹន្ទបាលឯក ។ ឆ្នាំ១៩៧២ ខ្ញុំត្រូវទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ឯក ។ ខ្ញុំបានទៅហ្វឹកហាត់ជួសជុលយន្តហោះផ្នែកអគ្គិសនីនៅប្រទេសថៃជាច្រើនដង ដើម្បីបំប៉នចំណេះដឹងបន្ថែមនិងជួសជុលយន្តហោះថ្មីម៉ាក C១២៣ ។ នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ទោ ។

ថ្ងៃដែលកងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញ ពេលនោះខ្ញុំកំពុងតែស្ថិតនៅក្នុងបន្ទាយ ចំណែកប្រពន្ធនិងកូនរបស់ខ្ញុំនៅផ្ទះនៅសង្កាត់អូរបែកក្អម ។ ខ្ញុំមានកូនប្រាំនាក់ កូនស្រីច្បងអាយុ១១ឆ្នាំកូនពៅអាយុបាន៣ខែ ។ ខ្ញុំទុកទោចក្រយានយន្តសម្ភារនិងការងារទាំងអស់ចោលហើយប្រញាប់ប្រញាល់ទៅផ្ទះដើម្បីទៅជួបជុំប្រពន្ធកូន ។ ពេលខ្ញុំទៅដល់ផ្ទះប្រពន្ធរបស់ខ្ញុំមិននៅផ្ទះទេព្រោះរវល់តែទៅលេងបងប្រុសរបស់នាង ។ នៅពេលល្ងាចកងទ័ពខ្មែរក្រហមបានចូលមកក្នុងទីក្រុងភ្នំពេញឈរយាមគ្រប់ប្រកផ្លូវ ។ ខ្ញុំនិងប្អូនប្រុសបានទៅទទួលប្រពន្ធត្រឡប់មកផ្ទះវិញ ។ កងទ័ពទាំងនោះសួរខ្ញុំថា «ទៅណា?» ។ ខ្ញុំឆ្លើយថាទៅផ្ទះខ្ញុំ ។ វាក៏អនុញ្ញាតឲ្យទៅ ។ ខ្ញុំបានទៅដល់ផ្ទះមួយសន្ទុះកងទ័ពខ្មែរក្រហមមកគោះទ្វារផ្ទះខ្ញុំហើយប្រាប់ថា ត្រូវនាំគ្នាចាកចេញពីផ្ទះចម្ងាយមួយគីឡូម៉ែត្រសិន ព្រោះខ្លាចយន្តហោះអាមេរិកាំងទម្លាក់គ្រាប់បែក ។ យើងទាំងអស់គ្នារៀបចំសម្លៀកបំពាក់និងម្ហូបអាហារខ្លះៗដាក់លើរថយន្តហ្ស៊ីប ហើយចេញដំណើរទាំងយប់ទៅទិសខាងលិច ។ យើងនាំគ្នាចូលទៅសម្រាកនៅក្នុងវត្តស្ទឹងមានជ័យមួយយប់ ។ នៅទីនោះមានមនុស្សម្នាច្រើនសន្ធឹកសន្ធាប់ ដេកលាយឡំជាមួយសាកសពដែលនៅកណ្តាលវាល ។ ព្រឹកឡើង កងទ័ពខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនវិលត្រឡប់មកផ្ទះវិញទេ ប៉ុន្តែខ្ញុំឆ្លៀតឱកាសទៅមើលផ្ទះរបស់ខ្ញុំដែលស្ថិតនៅអូរបែកក្អមទាំងភ័យខ្លាច ។ នៅក្នុងផ្ទះខ្ញុំគ្មានបាត់របស់របរអ្វីទេ ប៉ុន្តែបរិស្ថានជុំវិញមានសភាពស្ងាត់ជ្រងំ ។ ខ្ញុំចាក់សោផ្ទះវិញ ហើយក៏ប្រញាប់ប្រញាល់ទៅជួបប្រពន្ធនិងបងខ្ញុំដែលកំពុងរង់ចាំនៅឯវត្តវិញ ។ តាមផ្លូវខ្ញុំឃើញរថយន្តយោធាដែលមានសម្លៀកបំពាក់ពណ៌ខ្មៅប្រដាប់ដោយអាវុធអាកា៤៧គ្រប់ដៃ ជួតក្បាលនិងបង់កក្រមាបើកចុះឡើងជាមួយនឹងសំឡេងហ៊ោកញ្ជ្រៀវអឹងអាប់ ។ ខ្ញុំបានឮប្រជាជននិយាយតគ្នាថា ថ្ងៃនោះក្រុមរដ្ឋសភាដែលនៅរង់ចាំទទួល ប៉ុល ពត ត្រូវកងទ័ពរំដោះសម្លាប់ចោលអស់ ហើយអ្នកជំងឺនៅក្នុងមន្ទីរពេទ្យក៏ត្រូវកងទ័ពសម្លាប់ចោលអស់ដែរ ។

នៅរសៀលថ្ងៃនោះ កងទ័ពខ្មែរក្រហមបានបណ្តេញយើងឲ្យធ្វើដំណើរទៅមុខទៀត ដោយប្រាប់ថា «អង្គការឲ្យទៅមុខទៀត» ។ យើងរុញកូនឡានដែលមានផ្ទុកអីវ៉ាន់បន្តិចបន្តួចដើម្បីសន្សំសំចៃសាំង ។ ប្រជាពលរដ្ឋជាច្រើនកុះករ ខ្លះរែក ខ្លះពុន ទូលអីវ៉ាន់

*បេះតែធ្វើដំណើរទៅមុខរហូតមិនដឹងទៅទីណា ។ ខ្ញុំឃើញកងទ័ពអាវខ្មៅបណ្តើរអតីតទាហានលន់នល់ដែលមានតែខោខ្លីទាំងខ្សែៗ*

*ដោយការធ្វើដំណើរតាមផ្លូវដ៏វែងឆ្ងាយ កូនតូចៗរបស់ខ្ញុំវាយំទារឈប់សម្រាកនិងទារបាយហូប ។ ខ្ញុំអាណិតកូនខ្លោចចិត្ត បានត្រឹមតែលួងកូនថា «ទ្រាំទៅជិតដល់ហើយកូន» ។ ម៉ោងប្រមាណ ៧យប់ យើងបានមកឈប់សម្រាកនៅក្បែរអូរមួយ ដើម្បីដងទឹកមកដាំបាយហូប ។ ក្រោយពីហូបបាយឆ្អែតដោយអស់កម្លាំងខ្លាំងពេកយើងក៏លង់លក់ទាំងអស់គ្នា ។ លុះពេលព្រឹកឡើងខ្ញុំអើតមើលទឹកអូរនោះ ព្រះអើយ! ទឹកនោះល្អក់មើលមិនយល់និងគួរឲ្យខ្លាច ព្រោះមានឈាមនិងមានសាកសពអណ្តែតនៅលើផ្ទៃទឹក ។*

*យើងចេញដំណើរទៅមុខទៀតមកដល់ផ្លូវលំថ្មីមួយ ។ ការធ្វើដំណើររបស់យើងឆ្លងកាត់តាមផ្លូវលំ ផ្លូវធំ ឆ្លងបឹង ឆ្លងស្ទឹង ឆ្លងអូរ កាត់វាល កាត់ព្រៃ កាត់ពីភូមិមួយទៅភូមិមួយ ហាក់បីដូចមនុស្សវង្វេងផ្លូវ ។ តាមភូមិខ្លះមានកងទ័ពអាវខ្មៅព្រាងព្រាត ភូមិខ្លះមានតែផ្ទះអត់មនុស្សនៅ ។ ពេលធ្វើដំណើរចូលដល់ព្រៃកងទ័ពខ្មែរក្រហមបានដកយកឡានរបស់យើង ដូច្នេះ យើងទាំងអស់គ្នាត្រូវចែកអីវ៉ាន់គ្នាកាន់និងដឹកដៃកូនតូចៗធ្វើដំណើរទាំងត្រដាបត្រដួស ។*

*អស់រយៈពេលជាច្រើនថ្ងៃយើងក៏មកដល់ផ្លូវថ្នល់ជាតិ អ្នកដំណើរទាំងអស់បាននាំគ្នាឈប់សម្រាកតាមចិញ្ចើមថ្នល់មួយយប់ទៀត ។ ខ្ញុំបានឮអ្នកសម្រាកក្បែរខ្ញុំនិយាយថា អង្គការត្រូវការរាជការចាស់យកទៅធ្វើការងារវិញ អ្នកណាធ្វើការងារអីគេឲ្យធ្វើការនោះវិញ ។ អ្នកណាពាក់ស័ក្តិប៉ុន្មានគេឲ្យពាក់ស័ក្តិប៉ុណ្ណឹងវិញ ។ នៅពេលនោះខ្ញុំពិចារណាថា សភាពការណ៍មិនស្រួលទេ ព្រោះប្រសិនបើអ៊ីចឹងមែនហេតុអ្វីចាំបាច់ដេញប្រជាជនចេញពីទីក្រុង? ខ្ញុំមិនចាប់អារម្មណ៍នឹងពាក្យសម្តីទាំងអស់នោះឡើយ ខ្ញុំនឹកព្រួយនិងអាណិតកូនៗប៉ុណ្ណោះ ។ យើងធ្វើដំណើរទៅមុខដោយគ្មានពេលកំណត់ យប់ត្រង់ណាសម្រាកត្រង់នោះ ។ នៅកន្លែងខ្លះយើងត្រូវដាំបាយហូបនិងដងទឹកថ្លុកក្របីក៏មាន ។*

*ថ្ងៃមួយ កងទ័ពបានហៅក្រុមគ្រួសារខ្ញុំឡើងជិះកាណូតពីដីឥដ្ឋឆ្ពោះទៅកាន់ព្រែកពោធិ៍ ហើយឲ្យសម្រាកនៅទីនោះមួយយប់ ។ បងថ្លៃប្រុសរបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមប្រាប់ថាឲ្យទៅរៀនសូត្រ ។ កងទ័ពខ្មែរក្រហមនិយាយថា វាតាមតាំងពីភ្នំពេញមកម៉្លេះ ។ បងថ្លៃខ្ញុំជាវរសេនីយ៍ឯកជើងគោកនៅខេត្តកំពង់ស្ពឺ ។ យោធាខ្មែរក្រហមបាននាំយើងឡើងជិះកាណូតឆ្ពោះទៅកាន់ទន្លេបិទ ពេលនោះខ្ញុំសង្ស័យនិងភិតភ័យណាស់ ។ ចំពោះរឿងបងថ្លៃខ្ញុំអស់សង្ឃឹមហើយ ។ ខ្ញុំស្នាក់នៅទន្លេបិទមួយយប់ទៀត ទើបព្រឹកឡើងកងទ័ពយករទេះសេះមកដឹកយើងខ្ញុំទៅស្ងួងឆ្លងកាត់ចម្ការកៅស៊ូឆ្ពោះទៅកាន់ភូមិចាមមួយឈ្មោះថាភូមិរការពប្រាំ ។*

*នៅទីនោះប្រពន្ធនិងប្អូនរបស់ខ្ញុំទៅធ្វើការងារផ្សេងពីគ្នា ។ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅឃ្វាលគោក្របីជាច្រើនក្បាលតាំងពីព្រឹកទល់ល្ងាច ។ ខ្ញុំដើរតាមហ្វូងក្របីជាប់រហូតគ្មានបានសម្រាក ។ ក្រោយមកខ្ញុំមានជំងឺគ្រុនចាញ់ គ្មានថ្នាំព្យាបាលជំងឺ មានតែដើរបេះស្លឹកឈើឫសឈើយកមកស្ងោរផឹករហូតបានសះស្បើយ ។ ប្រធានសហករណ៍បានចែករបបស្រូវឲ្យប្រជាជនយកមកកិនហូបនៅឯផ្ទះ ប៉ុន្តែបើខ្វះខាតត្រូវដោះស្រាយខ្លួនឯង ។ ពេលខ្លះប្រពន្ធខ្ញុំបានយកសារុង ខោអាវ ទៅដូរយកអង្ករហូប ។ មិនថាពេលថ្ងៃពេលល្ងាចឬយប់ទេ ខ្ញុំត្រូវឈ្លបតាមដានជាប់ជានិច្ច ។*

*ប្រធានភូមិបានចុះស្រង់ប្រវត្តិរូបជាញឹកញាប់ដើម្បីបញ្ជាក់អំពីអតីតភាពនិងការងាររបស់ខ្ញុំ ។ ខ្ញុំកុហកថា ខ្ញុំជាកម្មករ ហើយប្រពន្ធខ្ញុំនៅផ្ទះមើលកូននៅឯក្រុងភ្នំពេញ ។ ដោយឡែកឪពុកម្តាយនិងបងប្អូនខ្ញុំបែរជាប្រាប់ប្រវត្តិរូបពិតទៅវិញ ។ រាល់ថ្ងៃរាល់យប់ ខ្ញុំព្រួយបារម្ភខ្លាចក្រែងមនុស្សរបស់អង្គការមកសួរឪពុកម្តាយខ្ញុំនៅភូមិកំណើត ព្រោះថាភូមិរការប្រាំនិងភូមិព្រែកតាអាំនៅមិនឆ្ងាយពីគ្នាទេ ។ នៅទីនោះប្រជាជនជម្លៀសត្រូវអង្គការហៅទៅរៀនសូត្រសឹងតែរាល់ថ្ងៃ ទៅបាត់ៗមិនឃើញត្រឡប់មកវិញឡើយ ។ ថ្ងៃមួយប្រជាជនជម្លៀសដែលនៅក្នុងភូមិត្រូវបានជម្លៀសចេញទៅកាន់កន្លែងផ្សេង គ្រួសាររបស់ខ្ញុំគ្មានឈ្មោះទៅទេ ប៉ុន្តែខ្ញុំបានសុំទៅដែរ ។ ការធ្វើដំណើរដោយរទេះក្របីតាំងពីព្រឹកទល់ល្ងាចទើបមកដល់ទន្លេបិទ រួចបន្តតាមកាណូតឆ្ពោះទៅខេត្តកំពង់ចាមទាំងយប់អធ្រាត្រដោយគ្មានបាយចូលពោះមួយគ្រាប់សោះ ។ បន្ទាប់មក មានរថយន្តមកទទួលយើងទាំងយប់ដើម្បីធ្វើដំណើរបន្តទៀត ។ នៅលើឡានមួយៗចង្អៀតណែនគ្មានកន្លែងអង្គុយទេ យើងត្រូវឈរទាំងអស់គ្នា ។ លុះជិតភ្លឺទើប*

យើងទៅដល់ភូមិមួយឈ្មោះថា ភូមិចើងដើង ក្នុងឃុំកំពង់ថ្ម ខេត្តកំពង់ធំ ។ យើងចុះពីឡានអង្គុយរង់ចាំដល់មេឃភ្លឺ ។ ពេលព្រះអាទិត្យរះទើបឃើញមេក្រុមមកបែងចែកប្រជាជនយកទៅកន្លែងរៀងៗខ្លួន ។ គ្រួសារខ្ញុំបានទទួលកូនខ្ទមតូចមួយដែលសង់មិនទាន់រួច ។ ខ្ញុំចូលព្រៃកាប់កូនឈើដើម្បីធ្វើរនាបនិងជួសជុលកូនខ្ទមដែលគ្មានដំបូល ។ ប្រពន្ធខ្ញុំឆៀតដើរច្រូតស្បូវយកមកក្រៀបប្រក់ដំបូលនិងធ្វើជាជញ្ជាំង ។ អង្គការប្រើយើងធ្វើពលកម្មសង្គមរួមទាំងយប់ទាំងថ្ងៃគ្មានពេលទំនេរ ។ ប្អូនប្រុសរបស់ខ្ញុំនិងកូនស្រីច្បងត្រូវបញ្ជូនទៅកងចល័ត ។ ប្រពន្ធខ្ញុំនៅក្នុងកងនារីឯខ្ញុំត្រូវចាត់ឲ្យទៅធ្វើការឆ្ងាយៗ ។ នៅទីនោះអង្គការចាប់ផ្ដើមស្រង់ប្រវត្តិរូបថ្មីជាទៀត ។ ចំពោះជនដែលអង្គការសង្ស័យត្រូវយកទៅសម្លាប់ចោល ។ គ្រួសារខ្ញុំក៏ផ្លាស់ប្រវត្តិរូបថ្មីដែរ ខ្ញុំកុហកថាកើតនៅភ្នំពេញ ឪពុកម្ដាយនិងបងប្អូនខ្ញុំស្លាប់អស់ហើយ ។

ការងារនិងការហូបចុកនៅទីនោះពិបាកខ្លាំងណាស់ ។ ពេលថ្ងៃខ្ញុំត្រូវធ្វើស្រែ នៅពេលយប់ជីកស្រះនិងរែកដី ។ យើងគ្មានសិទ្ធិនិយាយរកគ្នាទេ ។ ប្រុសនិងស្រីនិយាយគ្នាក៏មិនបានដែរ ត្រូវចោទថា ខុសសីលធម៌ ហើយប្រសិនបើស៊ើបដឹងថា អ្នកណាមួយមាននិន្នាការជាទាហានប្ការជការត្រូវសម្លាប់ចោលដោយវាយនឹងត្បូងចប ។

នៅឆ្នាំ១៩៧៧-៧៨ អង្គការមានផែនការថ្មី ចាប់ផ្ដើមដឹកជញ្ជូនប្រជាជនជម្លៀសទាំងរទេះៗយកទៅសម្លាប់ចោល មេក្រុមមេភូមិបានប្រកាសថា អង្គការខ្វះស្បៀង ដូច្នេះត្រូវបញ្ជូនប្រជាជនថ្មីឲ្យទៅស្រុកកំណើតដើមវិញខ្លះ និងបន្ថយរបបបាយដើម្បីសន្សំសំចៃស្បៀងអាហារ ។ ម្នាក់ៗសប្បាយណាស់ព្រោះថាបានទៅស្រុកកំណើតវិញ ។ ម្នាក់ៗមានទឹកមុខញញឹមរីករាយដោយមិនបានដឹងថាអង្គការកំពុងបញ្ឆោតយកទៅសម្លាប់ចោលឡើយ ។ តាំងពីពេលនោះមកខ្ញុំឃើញរថយន្តដឹកមនុស្សចេញពីភូមិស្ទើររាល់ថ្ងៃរាល់យប់ ។ រាល់យប់យោធាខ្មែរក្រហមតែងតែយកប្រជាជនថ្មីទៅដោយស្ងាត់ៗ សូម្បីតែផ្ទះនៅជិតគ្នាក៏មិនដឹងដែរ ។ ចំពោះខ្ញុំគិតតែខិតខំធ្វើការតាមផែនការ មិនហ៊ាននិយាយស្តីអ្វីទេ ។ នៅពេលយប់ដេកព្រួយមិនដឹងជាយប់ណាអង្គការឲ្យទៅស្រុកកំណើតដូចប្រជាជនទាំងនោះដែរ ។

មានពេលមួយប្រពន្ធខ្ញុំត្រូវបានចាត់តាំងឲ្យដាំបន្លែនៅឆ្ងាយពីភូមិប្រហែល១០គីឡូម៉ែត្រ ។ ខ្ញុំត្រូវបានចាត់តាំងឲ្យលើកទំនប់ឆ្ងាយពីភូមិប្រហែលជាង២០គីឡូម៉ែត្រ ។ នៅទីនោះខ្ញុំរែកដីតាំងពីព្រឹកព្រលឹមទល់ព្រលប់ ហើយបានរបបបបរមួយ



ពេលមួយកូនចាន ។ ខ្ញុំធ្វើការគ្មានពេលសម្រាកទេ ហូបក៏មិនឆ្អែតដែរ ពេលយប់ដេកមិនលក់ដោយសារមូសខាំ មិនយូរប៉ុន្មានខ្ញុំធ្លាក់ខ្លួនឈឺ ប៉ុន្តែខ្ញុំនៅតែទ្រាំធ្វើការព្រោះខ្លាចអង្គការចោទថាខ្ញុំឈឺពុត ។ រាងកាយខ្ញុំស្គម ក្បាលជង្គង់ខ្ញុំឡើងគ្រមោងៗ ។ ចំណែកប្រពន្ធរបស់ខ្ញុំនៅភូមិរែកទឹកស្រោចបន្លែរាល់ថ្ងៃរហូតដល់ថ្ងៃសម្រាលកូន ។

ជាច្រើនខែកន្លងទៅ ការសាងសង់ទំនប់បានរួចរាល់ជាស្ថាពរ ខ្ញុំបានត្រឡប់មកផ្ទះជួបប្រពន្ធនិងកូនវិញ ។ ពេលនោះខ្ញុំត្រូវចាត់តាំងឲ្យឃ្វាលគោនិងដឹកខសដាក់រោងបាយ ។ ប្រពន្ធខ្ញុំទៅក្រងស្បូវ ។ កូនតូចៗរបស់ខ្ញុំអង្គការឲ្យសែងអាចម៍គោដាក់ស្រែ ។ ប៉ុន្តែប្អូនប្រុសនិងកូនស្រីច្បងរបស់ខ្ញុំដែលទៅធ្វើនៅកងចល័តបាត់ដំណឹងឈឹងមិនដឹងជាសុខទុក្ខយ៉ាងណា ។ ពេលខ្ញុំទៅឃ្វាលគោខ្ញុំឃើញកងឈ្លបបណ្តើរមនុស្សចូលព្រៃរាល់ថ្ងៃ ។ ចូលមកដល់ភូមិវិញ ខ្ញុំឮមេក្រុម មេភូមិនិយាយគ្នាថា សាច់អ្នកនេះឆ្ងាញ់ ថ្លើមអ្នកនោះឆ្ងាញ់ ។

ប្រជាជនថ្មីត្រូវធ្វើការដូចជាសត្វពាហនៈ ខោអាវរហែករយ៉ៃ ។ ចំណែកកម្មាភិបាលខ្មែរក្រហមវិញ ស៊ីឆ្ងាញ់ ដេកស្រួល មានខោអាវនិងប្រដាប់ប្រដាប្រើប្រាស់មិនអស់ មួយថ្ងៃៗអង្គុយចាំតែចាប់កំហុសប្រជាជន ហើយបើត្រូវការនារីណាម្នាក់ កម្មាភិបាលនឹងយកនារីនោះរហូតដល់មានផ្ទៃពោះ រួចបញ្ជាឲ្យរៀបការជាមួយបុរសថ្មីទៀត បើមិនព្រមទេ គេយកទៅសម្លាប់ចោល ។

នៅថ្ងៃ៧មករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានរំដោះប្រទេសកម្ពុជាទាំងមូល ។ របបកម្ពុជាប្រជាធិបតេយ្យដែលជារបបមួយគ្មានច្បាប់ទម្លាប់ ធ្វើបាបមនុស្សដូចគ្នា បំបែកបំបាក់មនោសញ្ចេតនាគ្រួសារ បង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ហូបមិនគ្រប់គ្រាន់និងកាប់សម្លាប់មនុស្សបានផុតរលត់ទៅ ។ ពេលនោះគ្រួសារខ្ញុំត្រូវដើររកគ្នា ប្អូនប្រុសនិងកូនស្រីខ្ញុំបានវិលត្រឡប់មកផ្ទះជួបជុំគ្នាអស់ហើយ ។ យើងនាំគ្នាចេញពីខេត្តកំពង់ធំឆ្ពោះទៅស្រុកកំណើតនៅខេត្តក្រចេះវិញ ។

នេះជាប្រវត្តិរឿងរ៉ាវដែលខ្ញុំជួបប្រទះនៅក្នុងជីវិតរបស់ខ្ញុំ និងមិនអាចបំភ្លេចបាននៅក្នុងមួយជីវិតរបស់ខ្ញុំ ។ ចាប់ពីពេលនេះតទៅមុខទៀត ខ្ញុំសូមអង្វរអ្នកមានអំណាច មេត្តាធ្វើយ៉ាងណាកុំឲ្យមានរឿងដ៏អាក្រក់បែបនេះកើតឡើងជាថ្មីម្តងទៀត ។ ត្រូវមានចិត្តមេត្តា ករុណា អធ្យាស្រ័យគ្នា សន្តោសគ្នាទៅវិញទៅមកចេះស្រឡាញ់ពូជសាសន៍ ការពារគ្នា ការពារបូរណភាពទឹកដីខ្មែរឲ្យគង់វង្សជារៀងរហូត ដូចពាក្យស្លោកពោលថា «សាមគ្គីជាកម្លាំង បែកបាក់នាំមកនូវក្តីអន្តរាយ» ។

ជាទីបញ្ចប់ ខ្ញុំសូមសំណូមពរមួយគឺសុំឲ្យចងក្រងរឿងរ៉ាវដែលកើតមាននៅជំនាន់ប្រល័យពូជសាសន៍ទាំងអស់ជាឯកសារទុកសម្រាប់កូនចៅខ្មែរមើលឲ្យដឹងរឿងផង ព្រោះក្មេងជំនាន់នេះពេលខ្ញុំនិយាយពីរឿងឈឺចាប់នៅសម័យនោះពួកគេមិនជឿទាំងអស់ទេ ។ **ឈុន ឡៃហេង**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ផាត រចនា**

# សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះ ឡាំ សំអ៊ីន


ឡាំ យឿន
មុនឆ្នាំ១៩៧៥

នាងខ្ញុំឈ្មោះ ឡាំ យឺន អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិឡូទឹកត្រី ឃុំកំពង់ឆ្នាំង ស្រុក កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុនរបបកម្ពុជាប្រជាធិបតេយ្យរស់នៅភូមិក្រងផ្តិល ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ នាងខ្ញុំសូមសួររកប្អូនប្រុសឈ្មោះ ឡាំ សំអ៊ិន ដែលបានបែកគ្នាក្នុងពេលខ្មែរក្រហមជម្លៀស ពីប្រឡាយមាសទៅស្រុកកំពង់លែង ។ មុនរបបកម្ពុជាប្រជាធិបតេយ្យ ប្អូនបួសជាសង្ឃនៅវត្តប្រឡាយ មាសក្នុងស្រុកកំណើតបានបីវស្សា បន្ទាប់មកលាចាកសិក្ខាបទនៅឆ្នាំ១៩៧៥ក្នុងអាយុ២១ឆ្នាំ ។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ខ្ញុំបានទទួលដំណឹងពីឈ្មោះ ឆឹង កូន និង លោកពូស៊ុន នៅក្នុងភូមិ ជាមួយគ្នាថាគាត់បានជួប សំអ៊ិន នៅសំឡូតខេត្តបាត់ដំបង ហើយបានបបួល សំអ៊ិន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ សំអ៊ិន ប្រកែកថាមិនហ៊ាន មកទេខ្លាចខ្មែរក្រហមឃើញតាមផ្លូវសម្លាប់ចោល ។ ខ្ញុំថែមទាំងដឹងទៀតថា ប្អូនបានប្តូរឈ្មោះពី ឡាំ សំអ៊ិន ទៅជា អ៊ិន កំសត់ ។ បើប្អូន ឡាំ សំអ៊ិន បានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ឡាំ សំអ៊ិន ឬ (អ៊ិន កំសត់) សូមមេត្តាផ្តល់ដំណឹងមក នាងខ្ញុំនៅភូមិឃុំខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនស្រី ឈឹម ធត

ខ្ញុំបាទឈ្មោះ ឈឹម សុខុម ឪពុកឈ្មោះ ឈឹម គ្រីប និងម្តាយឈ្មោះ ពៅ (ស្លាប់ឆ្នាំ១៩៧៧ដោយសារជំងឺ) ។ សព្វថ្ងៃរស់ នៅភូមិស្រែចិន្តា ឃុំព្រះស្រែ ស្រុកខត្តុគ្គ ខេត្តកំពង់ស្ពឺ សូមប្រកាសសួររកប្អូនស្រីឈ្មោះ ឈឹម ទត ហៅ សុផល ដែលបាត់ខ្លួន ក្នុងរបបកម្ពុជាប្រធិបតេយ្យ ។ សុផល បានចូលបម្រើខ្មែរក្រហមតាំងពីឆ្នាំ១៩៧៤នៅឯមន្ទីរឃុំ តាមរយៈបងប្រុសឈ្មោះ ឈឹម សុង ជាគណៈឃុំ ។ ក្រោយមកឆ្នាំ១៩៧៦ សុផល ត្រូវបានបញ្ជូនទៅធ្វើការនៅមន្ទីរពេទ្យ១៧មេសានៅឯភ្នំពេញ ។ ក្នុងឆ្នាំដដែល សុផល បានមកលេងម្តាយដែលឈឺរយៈពេល៥ថ្ងៃនៅឯភូមិនេះ រួចក៏បានត្រឡប់ទៅវិញ ហើយក៏បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ប្រសិនបើប្អូនស្រីបានឃើញនូវការប្រកាសនេះ ឬក៏បងប្អូនណាបានស្គាល់ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើឬ មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១៨៧៥ ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ម៉ាន ម៉ុន

យស ផេង អាយុ៧២ឆ្នាំ ត្រូវជាម្តាយ ព្រមទាំងកូនស្រី ម៉ាន ម៉ន អាយុ៤៥ឆ្នាំ សូមប្រកាសសួររកូនប្រុសឈ្មោះ ម៉ាន ម៉ុន ដែលបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៦ បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ដើមឆ្នាំ១៩៧៦ ម៉ាន ម៉ុន ត្រូវខ្មែរក្រហមបង្ខំឲ្យសឹក បន្ទាប់មក ត្រូវបានបញ្ជូនទៅធ្វើការក្នុងកងដំឡូងនៅម្តុំភ្នំពាមជាំង ស្រុកព្រះស្តេច ។ តាំងពីពេលនោះមក ម៉ាន់ ម៉ុន មិនបានត្រឡប់មកផ្ទះវិញទេ ។

ប្រសិនបើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ ពត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សៀវភៅដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ព




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

DC-Cam Main Office: #66, Preah Sihanouk Blvd, Tonle Basac, Chamkar Morn, Phnom Penh, Cambodia. Tel: (855) 23 211 875, Fax: (855) 23 210 358, Email:dccam@online.com.kh, Homepage: www.dccam.org.